សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច

**Université Royale de Droit et des Sciences Economiques**

**Royal University of Law and Economics**

## សារណាបញ្ចប់ការសិក្សា

# ក្របខណ្ឌគតិយុត្តនៃការវិនិយោគ រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណៈរដ្ឋប្រជាមានិតចិន

ស្រាវជ្រាវពីថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០១៥ ដល់ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១៥

ស្រាវជ្រាវដោយ

និស្សិតឈ្មោះ **ភ. លី ហ្គេចហ៊ុយ**

សាស្ត្រាចារ្យណែនាំ

លោកស្រី **ម៉ូលី បញ្ញា**

ថ្នាក់បរិញ្ញាបត្រ នីតិសាស្ត្រ

ជំនាន់ទី ២០

ឆ្នាំចូលសិក្សា ២០១១

ឆ្នាំសរសេរសារណា ២០១៥

# សេចក្តីថ្លែងអំណរគុណ

នាងខ្ញុំឈ្មោះ **លី ហ្គេចហ៊ុយ** ជានិស្សិតផ្នែកនីតិសាស្ត្រ ជំនាន់ទី១៥ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច សូមសម្តែងនូវកត្តញ្ញូតាធម៌ ការដឹងគុណ និងសេចក្តីគោរពយ៉ាងជ្រាលជ្រៅបំផុតចំពោះ៖

**លោកឪពុក និងអ្នកម្តាយ** ដែលលោកទាំងពីរបានផ្តល់កំណើតដល់កូន ផ្តល់នូវការទំនុកបម្រុង ចិញ្ចឹមបីបាច់ថែរក្សា អប់រំប្រៀនប្រដៅ និងផ្តល់នូវភាពកក់ក្តៅសម្រាប់កូនរហូតមក។ លទ្ធផលដែលកូនទទួលបាននាថ្ងៃនេះ កើតចេញពីការលះបង់ធនធានសម្ភារៈនិងស្មារតី និងការតស៊ូប្រឹងប្រែងទាំងកម្លាំងកាយនិងកម្លាំងចិត្ត របស់លោកទាំងពីរ។ លោកទាំងពីរបានព្យាយាមធ្វើអ្វីៗគ្រប់បែបយ៉ាងដោយពុំខ្លាចនឿយហត់ ក្នុងការរៀបចំផ្លូវអនាគតដ៏ល្អមួយសម្រាប់កូន និងណែនាំធ្វើយ៉ាងណាអោយកូនបានក្លាយជាធនធានមនុស្សសម្រាប់សង្គមជាតិ។ មហាគុណរបស់លោកទាំងពីរ គឺជារបស់ដែលមានតម្លៃបំផុតដែលពុំអាចកាត់ថ្លៃបាន។

**ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង សាស្ត្រាចារ្យ** នៃសាកលវិទ្យាល័យ ភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ទាំងអស់ ដែលបានខិតខំព្យាយាម ក្នុងការបង្ហាត់បង្ហាញ ផ្តល់ចំណេះដឹង និងបទពិសោធន៍ជាច្រើនសម្រាប់ខ្ញុំក្នុងរយៈពេល៤ឆ្នាំកន្លងមកនេះ។

**លោកស្រីសាស្ត្រាចារ្យ ប៉ូលី បញ្ញា** ដែលបានផ្តល់ការណែនាំ និងអនុសាសន៍ល្អៗយ៉ាងច្រើនអំឡុងពេលនៃការសិក្សាស្រាវជ្រាវលើប្រធានបទមួយនេះ។ មិនត្រឹមតែប៉ុណ្ណោះ លោកស្រីសាស្ត្រាចារ្យ ក៏បានចំណាយពេលវេលាដ៏មានតម្លៃក្នុងការកែលម្អសារណាមួយនេះ រហូតបានបញ្ចប់ដោយជោគជ័យ។

**មិត្តភក្តិ** ដែលតែងតែជួយយកអាសានិងតែងតែជួយលើកទឹកចិត្តគ្រប់ពេលវេលា។

ជាចុងបញ្ចប់ នាងខ្ញុំសូមគោរពជូនពរលោកអ្នកមានគុណ លោកស្រីសាស្ត្រាចារ្យ សាកលវិទ្យាធិការ សាកលវិទ្យាធិការរង សាស្ត្រាចារ្យ និងមិត្តភក្តិទាំងអស់អោយជួបប្រទះតែពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

ប្រទេសកម្ពុជា ដែលធ្លាប់ជាប្រទេសមានអរិយធម៌រុងរឿងរីកចម្រើន បានក្លាយជាប្រទេសកំពុងអភិវឌ្ឍន៍ ក្នុងចំណោមប្រទេសនានាក្នុងពិភពលោក ដោយសារតែការឃោឃៅពីសង្គ្រាមដែលបានអូសបន្លាយអស់រយៈពេលជាច្រើនទសវត្សរ៍។ សង្គ្រាមបានកើតឡើងពីការខ្វែងគំនិតគ្នាខាងផ្នែកនយោបាយ ដែលជាបុព្វហេតុនាំអោយមានរដ្ឋប្រហារកើតឡើងនាឆ្នាំ ១៩៧០ ហើយបានធ្វើអោយប្រទេសជាតិទាំងមូលស្ថិតក្នុងភាពចលាចល។ រហូតមកដល់ ឆ្នាំ១៩៧៥ ជារបបដ៏ខ្មៅងងឹតបានកាប់សម្លាប់ប្រជាជនអស់រាប់លាននាក់ ហើយប្រទេសជាតិបានធ្លាក់ដល់ចំណុចសូន្យ។ ទោះបីជាយ៉ាងណា ដោយមានការរួបរួមសាមគ្គីគ្នា ទីបំផុតប្រទេសកម្ពុជាបានទទួលសុខសន្តិភាពពេញលេញ ហើយរដ្ឋាភិបាលកម្ពុជាបានបន្តស្តារ និងកសាងឡើងវិញនូវស្ថានភាពសេដ្ឋកិច្ច និងសង្គមកិច្ច ដើម្បីអោយប្រទេសជាតិទាំងមូលសម្រេចបាននូវការអភិវឌ្ឍន៍។ ដើម្បីសម្រេចអោយបាននូវគោលដៅមួយនេះ ប្រទេសកម្ពុជាត្រូវពឹងផ្អែកលើការអភិវឌ្ឍសេដ្ឋកិច្ចជាតិ ពោលគឺត្រូវផ្តោតសំខាន់លើការវិនិយោគ។ ប៉ុន្តែដោយសារការវិនិយោគក្នុងស្រុកនៅមានកម្រិតនៅឡើយ ការវិនិយោគពីសំណាក់អ្នកវិនិយោគបរទេសគឺជាតម្រូវការចាំបាច់មួយផងដែរ ដើម្បីជាស្នូលក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិអោយបានឆាប់រហ័ស ដោយហេតុថា ការវិនិយោគបរទេសបាននាំមកនូវអត្ថប្រយោជន៍ ជាច្រើនដូចជាមូលធន បច្ចេកវិទ្យា ការងារ ជាដើម។ លើសពីនេះទៅទៀត យើងក៏អាចយកគម្រូពីប្រទេសជិតខាងដែលមានការរីកចម្រើនក្នុងការវិនិយោគ សម្រាប់ជាមេរៀនក្នុងការអភិវឌ្ឍន៍វិស័យវិនិយោគអោយបានជោគជ័យផងដែរ។

ដោយមើលឃើញពីសក្តានុពលវិនិយោគរបស់បរទេសក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ នាងខ្ញុំសម្រេចជ្រើសរើសការស្រាវជ្រាវស្តីពី "ការប្រៀបធៀបក្របខណ្ឌគតិយុត្តវិនិយោគរវាងសាធារណរដ្ឋប្រជាមានិតចិន និងព្រះរាជាណាចក្រកម្ពុជា" ដើម្បីឆ្លុះបញ្ចាំងពីលក្ខណៈដូចគ្នានិងខុសគ្នាក្នុងការអនុវត្តក្របខណ្ឌគតិយុត្ត រវាងប្រទេសទាំងពីរ ថាតើធ្វើយ៉ាងណាអោយមានការទាក់ទាញការវិនិយោគ ដើម្បីជាប្រយោជន៍ដល់ការអភិវឌ្ឍន៍សេដ្ឋកិច្ច និងធ្វើអោយប្រទេសជាតិទាំងមូលឆ្ពោះទៅរកភាពរុងរឿងរីកចម្រើនឡើងវិញ។

# មាតិកា

**សេចក្តីថ្លែងអំណរគុណ**

**អារម្ភកថា**

**សេចក្តីផ្តើម** ........ ១

**ជំពូកទី១: សញ្ញាណទូទៅនៃបទបញ្ញត្តិច្បាប់វិនិយោគនៃប្រទេសកម្ពុជានិងប្រទេសចិន** ........ ៥

**ផ្នែកទី១: អត្ថន័យនៃបទបញ្ញត្តិច្បាប់វិនិយោគនៃប្រទេសកម្ពុជា និង ប្រទេសចិន** ........ ៥

**កថាខណ្ឌទី១: អត្ថន័យនៃបទបញ្ញត្តិច្បាប់វិនិយោគនៅប្រទេសកម្ពុជា** ........ ៥

**១. អត្ថន័យទូទៅ** ........ ៥

១.១. គោលការណ៍ទូទៅ ........ ៥

**កថាខណ្ឌទី២: អត្ថន័យនៃបទបញ្ញត្តិច្បាប់វិនិយោគនៅប្រទេសចិន** ........ ៦

**១. អត្ថន័យទូទៅ** ........ ៦

១.១ គោលការណ៍ទូទៅ ........ ៦

**កថាខណ្ឌទី៣: ការប្រៀបធៀបបទបញ្ញត្តិវិនិយោគរវាងប្រទេសកម្ពុជា និង ប្រទេសចិន** ........ ៨

**១. បទបញ្ញត្តិទូទៅចំពោះការគ្រប់គ្រងសកម្មភាពវិនិយោគ** ........ ៨

១.១. ផលប្រយោជន៍ និង ភាពទាក់ទាញចំពោះការវិនិយោគ ........ ៨

**២. បទបញ្ញត្តិពិសេសចំពោះសកម្មភាពវិនិយោគ** ........ ១០

២.១. ករណីប្រទេសកម្ពុជា ........ ១០

២.២. ករណីប្រទេសចិន ........ ១០

**ផ្នែកទី២: អាជ្ញាប័ណ្ណវិនិយោគនៅប្រទេសកម្ពុជា និងប្រទេសចិន** ........ ១២

**កថាខណ្ឌទី១: អាជ្ញាប័ណ្ណវិនិយោគនៅប្រទេសកម្ពុជា** ........ ១២

**១. នីតិវិធីក្នុងការដាក់ពាក្យស្នើសុំអាជ្ញាប័ណ្ណវិនិយោគ** ........ **១២**

១.១. លក្ខខណ្ឌនៃពាក្យសុំវិនិយោគ ........ **១៣**

១.២. ការអនុញ្ញាត និង ការដកហូតសិទ្ធិ ........ **១៤**

១.៣. ការចេញវិញ្ញាបនបត្រចុះបញ្ជីជាស្ថាពរ ........ **១៥**

**២. ស្ថាប័នទទួលបន្ទុកកិច្ចការវិនិយោគ** ........ **១៧**

២.១. ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ........ **១៧**

២.២. អនុគណៈកម្មាធិការវិនិយោគខេត្ត-ក្រុង ........ **២៣**

**៣. នីតិវិធីដោះស្រាយវិវាទវិនិយោគ** ........ **២៦**

៣.១. ការសម្របសម្រួលរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ........ **២៦**

៣.២. ការដោះស្រាយដោយមជ្ឈត្តកម្ម ........ **២៧**

៣.៣. ការដោះស្រាយតាមផ្លូវតុលាការកម្ពុជា ........ **២៨**

**កថាខណ្ឌទី២: អាជ្ញាប័ណ្ណវិនិយោគនៅប្រទេសចិន** ........ **៣០**

**១. នីតិវិធីក្នុងការដាក់ពាក្យស្នើសុំអាជ្ញាប័ណ្ណវិនិយោគ** ........ **៣០**

**២. ស្ថាប័នទទួលបន្ទុកកិច្ចការវិនិយោគ** ........ **៣១**

**៣. នីតិវិធីដោះស្រាយវិវាទវិនិយោគ** ........ **៣១**

៣.១. ការចចារ ........ **៣១**

៣.២. សន្ធានកម្ម ........ **៣២**

៣.៣. មជ្ឈត្តកម្ម ឬ អាជ្ញាកណ្ដាលចិន ........ **៣២**

៣.៤. ការដោះស្រាយតាមផ្លូវតុលាការ ........ **៣៣**

**កថាខណ្ឌទី៣: ការប្រៀបធៀបអាជ្ញាប័ណ្ណវិនិយោគរវាងប្រទេសកម្ពុជា និងប្រទេសចិន** ........ **៣៤**

**១. ប្រសិទ្ធភាពនៃការគ្រប់គ្រង** ........ ៣៤

**ផ្នែកទី៣: រូបភាពនៃការវិនិយោគនៃប្រទេសកម្ពុជា និងប្រទេសចិន** ........ ៣៥

**កថាខណ្ឌទី១: របបគតិយុត្តនៃក្រុមហ៊ុនវិនិយោគនៅប្រទេសកម្ពុជា** ........ ៣៥

**១. ទម្រង់ក្រុមហ៊ុនវិនិយោគ** ........ ៣៥

១.១. ក្រុមហ៊ុនភាគទុន ១០០%ជាខ្មែរ ឬ បរទេស ........ ៣៥

១.២. ក្រុមហ៊ុនចម្រុះ ........ ៣៦

១.៣. កិច្ចសន្យាសហប្រតិបត្តិការ ........ ៣៧

**កថាខណ្ឌទី២ : របបគតិយុត្តនៃក្រុមហ៊ុនវិនិយោគនៅប្រទេសចិន** ........ ៣៨

**១. ទម្រង់ក្រុមហ៊ុនវិនិយោគ** ........ ៣៨

១.១. ក្រុមហ៊ុនបណ្ដាក់ទុនរួមគ្នា/ ក្រុមហ៊ុនរួមសម្ព័ន្ធអាជីវកម្ម ........ ៣៨

១.២. ក្រុមហ៊ុនសហប្រតិបត្តិការ ........ ៣៩

១.៣. ក្រុមហ៊ុនវិនិយោគបរទេសតែមួយគត់ ........ ៤១

១.៤. ក្រុមហ៊ុនវិនិយោគបរទេសទទួលខុសត្រូវតាមកម្រិតភាគហ៊ុន ........ ៤២

១.៥. ក្រុមហ៊ុនវិនិយោគទុនបរទេស ........ ៤២

១.៦. កិច្ចសន្យាសាងសង់-អាជីវកម្ម-ផ្ទេរ ........ ៤២

**ជំពូកទី២: ឱកាសចំពោះការវិនិយោគនៃប្រទេសកម្ពុជា និង ប្រទេសចិន** ........ ៤៣

**ផ្នែកទី១: គោលនយោបាយជំរុញអោយមានការវិនិយោគនៅប្រទេសកម្ពុជា និងប្រទេសចិន** ........ ៤៣

**កថាខណ្ឌទី១: គោលនយោបាយជំរុញអោយមានការវិនិយោគនៅប្រទេសកម្ពុជា** ........ ៤៣

**១. អត្ថន័យនៃគោលនយោបាយ** ........ ៤៣

១.១. អភិបាលកិច្ចល្អ ........ ៤៣

១.២. តំបន់សេដ្ឋកិច្ចពិសេស ........ ៤៤

១.៣. ការប្រើប្រាស់ដីធ្លី ........ ៤៧

**កថាខណ្ឌទី២: គោលនយោបាយជំរុញអោយមានការវិនិយោគនៅប្រទេសចិន ...... ៤៨**

**១. អត្ថន័យនៃគោលនយោបាយ ........ ៤៨**

១.១. Going Global ........ ៤៨

**កថាខណ្ឌទី៣: ការប្រៀបធៀបគោលនយោបាយនៃការជំរុញអោយមានការវិនិយោគរវាង ប្រទេសកម្ពុជា និងប្រទេសចិន ........ ៥០**

**១. អត្ថន័យនៃគោលនយោបាយ ........ ៥០**

**២. ប្រសិទ្ធិភាពនៃការអនុវត្ត ........ ៥២**

**ផ្នែកទី២ : យុទ្ធសាស្រ្តនៃការជំរុញអោយមានការវិនិយោគនៅប្រទេសកម្ពុជា និងប្រទេសចិន ........ ៥២**

**កថាខណ្ឌទី១: យុទ្ធសាស្រ្តនៃការជំរុញអោយមានការវិនិយោគនៅប្រទេសកម្ពុជា.. ៥២**

**១. អត្ថន័យនៃយុទ្ធសាស្រ្ត ........ ៥២**

១.១. ការធានា ........ ៥៣

១.២. ការលើកទឹកចិត្ត ........ ៥៤

**កថាខណ្ឌទី២: យុទ្ធសាស្រ្តនៃការជំរុញអោយមានការវិនិយោគនៅប្រទេសចិន...... ៥៨**

**១. អត្ថន័យនៃយុទ្ធសាស្រ្ត ........ ៥៨**

១.១ . វិធានការទាំងប្រាំដែលបានប្រកាសដោយរដ្ឋាភិបាលចិន ........ ៥៩

១.២. គោលការណ៍ទាំង៩ក្នុងការលើកទឹកចិត្តការវិនិយោគ ........ ៥៩

**កថាខណ្ឌទី៣: ការប្រៀបធៀបយុទ្ធសាស្រ្តនៃការជំរុញអោយមានការវិនិយោគរវាង ប្រទេសកម្ពុជា និងប្រទេសចិន ........ ៦១**

**១. អត្ថន័យនៃយុទ្ធសាស្រ្ត ........ ៦១**

២. ប្រសិទ្ធិភាពនៃការអនុវត្ត........................................................................ ៦១
សេចក្តីសន្និដ្ឋាន........................................................................................ ៦៤
អនុសាសន៍..............................................................................................៦៧
ឧបសម្ព័ន្ធ
ឯកសារយោង

# សេចក្តីផ្តើម

ក្រោយឆ្លងកាត់ប្រវត្តិសង្គ្រាមដ៏ជូរចត់អស់រយៈពេលជាច្រើនទសវត្សរ៍រួចមក ប្រទេសកម្ពុជាបានជួបប្រទះនូវការលំបាកជាច្រើន ក្នុងការស្តារមុខមាត់ប្រទេសជាតិឡើងវិញ។ ប៉ុន្តែដោយសារការតស៊ូ រួបរួមសាមគ្គី ផ្សះផ្សាគ្នារវាងថ្នាក់ដឹកនាំប្រទេស និងប្រជាជនរួចមក ប្រទេសកម្ពុជាបានវិវត្តន៍ និង អភិវឌ្ឍន៍ខ្លួនបន្តិចម្តងៗ។ ផ្តើមចេញពីចំណុចសូន្យ ក្រោយពីការផុតរលត់សង្គ្រាម ថ្នាក់ដឹកនាំប្រទេសកម្ពុជា បានខិតខំអភិវឌ្ឍន៍ប្រទេសជាតិ រហូតមានការរីកចម្រើនឡើង។ ក្រោយការមកដល់របស់ UNTAC នាឆ្នាំ១៩៩៣ ប្រទេសកម្ពុជាបានកែប្រែមុខមាត់របស់ខ្លួនដោយប្រទេសកម្ពុជា បានក្លាយជាប្រទេសប្រកាន់លទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស និងជាប្រទេសទីផ្សារសេរី ស្របពេលនោះដែរ ប្រទេសកម្ពុជាក៏បានចូលរួមក្នុងអង្គការអន្តរជាតិនានាជាច្រើនផងដែរ ដោយធ្វើអោយសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជាបានកើនឡើងបន្តិចម្តងៗ គួរអោយកត់សម្គាល់ចាប់តាំងពីពេលនោះមក។

ក្រោយមកប្រទេសកម្ពុជាបានវិវត្តន៍ខ្លួន តាមរយៈការធ្វើសមាហរណកម្មចូលទៅក្នុងសេដ្ឋកិច្ចទីផ្សារពិភពលោក។ ការបោះជំហានចូលទៅក្នុងសេដ្ឋកិច្ចទីផ្សារពិភពលោកបែបនេះ បានធ្វើអោយសន្ទុះសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជាមានការកើនឡើងគួរអោយកត់សម្គាល់។ ស្របពេលនោះដែរ រដ្ឋាភិបាលប្រទេសកម្ពុជា ក៏បានចាប់ផ្តើមអនុវត្តនូវវិធានការជាច្រើនតាមរយៈការបង្កើតនូវវិធានគតិយុត្តមួយដែលមានលក្ខណៈទូលំទូលាយ ពោលគឺច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីជាការធានាដល់ការវិនិយោគនៅប្រទេសកម្ពុជា និងទាក់ទាញការវិនិយោគពីបរទេស។ ជាងនេះទៅទៀត ប្រទេសកម្ពុជាក៏បានបង្កើតនូវគោលនយោបាយផ្សេងៗជាច្រើនទៀតដើម្បីជាការលើកកម្ពស់ដល់វិស័យវិនិយោគនៅប្រទេសកម្ពុជា និងធ្វើអោយប្រទេសកម្ពុជាសម្រេចបាននូវគោលដៅនៃការវិនិយោគដែលទាក់ទាញបំផុតទាំងវិនិយោគជាតិ និង វិនិយោគបរទេស។

លទ្ធផលជាវិជ្ជមានក្រោយការបង្កើតអោយមានក្របខណ្ឌគតិយុត្តវិនិយោគរួចមកគេសង្កេតឃើញថាប្រទេសកម្ពុជា ជាប្រទេសគោលដៅសម្រាប់ការវិនិយោគនៃប្រទេសជាច្រើន។ ជាក់ស្តែងសហរដ្ឋអាមេរិក បានដាក់គម្រោងវិនិយោគមកប្រទេសកម្ពុជាដែលមានទឹកប្រាក់រាប់លានដុល្លារ ស្របពេលដែលសាធារណៈរដ្ឋប្រជាមានិតចិន ក៏បានសម្លឹងមើលពីគោលដៅសម្រាប់វិនិយោគនៅក្នុងប្រទេសកម្ពុជាផងដែរ។ ទាំងនេះសុទ្ធតែជាការជួយលើកតម្កើងដល់សេដ្ឋកិច្ចប្រទេសកម្ពុជា ក៏ដូចជាប្រជាពលរដ្ឋនៅក្នុងប្រទេសផងដែរ។ ក្រោយៗមកទៀត បទដ្ឋានគតិយុត្តនានាស្តីពីការ

វិនិយោគដូចជា អនុក្រឹត្យស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ច្បាប់ស្តីពីការវិនិយោគនៃព្រះរាជាណាចក្រកម្ពុជាជាដើម ត្រូវបានធ្វើវិសោធនកម្មជាបន្តបន្ទាប់ ដើម្បីអោយស្របតាមតម្រូវការវិនិយោគ។

បច្ចុប្បន្ននេះ ប្រទេសកម្ពុជា បានទាក់ទាញវិនិយោគិនបរទេសជាច្រើនអោយមកបណ្តាក់ទុនក្នុងទឹកដីប្រទេសកម្ពុជាដូចជា ចិន កូរ៉េ សហរដ្ឋអាមេរិក វៀតណាម ជាដើម។ ជាក់ស្តែង ទំនាក់ទំនងរវាងប្រទេសកម្ពុជា និងសាធារណៈរដ្ឋប្រជាមានិតចិន ក៏ដូចជាការវិនិយោគរបស់ចិនមកក្នុងប្រទេសកម្ពុជាមានការកើនឡើងគួរអោយកត់សម្គាល់។ ដោយមើលឃើញពីទំនាក់ទំនងល្អរវាងប្រទេសទាំងពីរ និង ទស្សនៈវិស័យសម្រាប់ការវិនិយោគនាពេលអនាគតសម្រាប់ប្រទេសទាំងពីរដែលជាសក្តានុពលនៃការវិនិយោគសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិ ការសិក្សាស្រាវជ្រាវមួយនេះត្រូវបានធ្វើឡើងដើម្បីសិក្សាប្រៀបធៀប ក្របខណ្ឌគតិយុត្តវិនិយោគរវាងប្រទេសកម្ពុជា និង សាធារណៈរដ្ឋប្រជាមានិតចិន ។ ការសិក្សាទៅលើក្របខណ្ឌគតិយុត្តវិនិយោគរបស់ប្រទេសកម្ពុជាគឺបានបង្កើនចំណេះដឹងក៏ដូចជាការទាក់ទាញចំពោះវិនិយោគិនបរទេសដែលចង់មកវិនិយោគនៅក្នុងប្រទេសកម្ពុជា។ ការសិក្សាស្រាវជ្រាវនេះ នឹងផ្តោតសំខាន់ទៅលើអត្ថន័យនៃបទបញ្ញត្តិច្បាប់វិនិយោគ ស្ថាប័នទទួលបន្ទុកការវិនិយោគ ក៏ដូចជាគោលនយោបាយ និងយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលទៅលើវិស័យវិនិយោគ ដែលអាចអោយវិនិយោគិនដែលចង់មកបណ្តាក់ទុននៅក្នុងព្រះរាជាណាចក្រកម្ពុជា អាចស្វែងយល់ពីលក្ខខណ្ឌ ដែលត្រូវបំពេញមុននឹងទទួលបានការវិនិយោគ និង ការការពារដោយស្របច្បាប់នៅលើទឹកដីព្រះរាជាណាចក្រកម្ពុជា។ ដោយឡែក ការសិក្សាទៅលើក្របខណ្ឌគតិយុត្តវិនិយោគនៅសាធារណៈរដ្ឋប្រជាមានិតចិន ដោយសារតែទំនាក់ទំនងរវាងប្រទេសទាំងពីរមានភាពល្អគួរអោយកត់សម្គាល់ ហើយសាធារណៈរដ្ឋប្រជាមានិតចិន ក៏មានចំនួនប្រជាជនច្រើន ដែលជាហេតុនាំអោយមានតម្រូវការច្រើននៅក្នុងស្រុកផងដែរ ដែល វិនិយោគិននានា ជាពិសេសវិនិយោគិនខ្មែរអាចពិចារណាលើការវិនិយោគនៅក្នុងប្រទេសមួយនេះ។ បន្ថែមពីនេះទៀត ដោយសារតែសាធារណៈរដ្ឋប្រជាមានិតចិន ជាប្រទេសដែលប្រកាន់របបកុំម្មុយនីស និង មានរបបសេដ្ឋកិច្ចទីផ្សារសេរី ការសិក្សាស្រាវជ្រាវនេះក៏ផ្តោតសំខាន់ទៅលើអត្ថន័យនៃបទបញ្ញត្តិច្បាប់វិនិយោគនៃសាធារណៈរដ្ឋប្រជាមានិតចិន ស្ថាប័នទទួលបន្ទុកវិនិយោគ ក៏ដូចជាការដាក់ចេញនូវគោលនយោបាយ និងយុទ្ធសាស្ត្ររបស់រដ្ឋាភិបាលចិនសម្រាប់វិនិយោគ។ វិនិយោគិនអាចសិក្សាពីលក្ខខណ្ឌមួយចំនួនដែលតម្រូវអោយបំពេញ មុននឹងអាចបណ្តាក់ទុននៅក្នុងប្រទេសចិនបានដោយស្របច្បាប់ ក៏ដូចជាបានទទួលនូវអាជ្ញាប័ណ្ណវិនិយោគសម្រាប់ការវិនិយោគរបស់ខ្លួន។ ការ

សិក្សានេះក៏ចង់ប្រៀបធៀបពីភាពខុសគ្នា និង ដូចគ្នាពីការអនុវត្តរបស់ប្រទេសទាំងពីរទាក់ទងនឹងវិស័យវិនិយោគផងដែរដែលអាចអោយអ្នកអានបានដឹង ស្វែងយល់ និង វិភាគទៅលើវិស័យមួយនេះ។

**ចំណោទបញ្ហានៃការស្រាវជ្រាវ៖** ដោយហេតុថា ប្រទេសកម្ពុជា ជាប្រទេសដែលប្រកាន់របបប្រជាធិបតេយ្យសេរីពហុបក្ស និងមានសេដ្ឋកិច្ចទីផ្សារសេរី ចំណែកឯសាធារណៈរដ្ឋប្រជាមានិតចិនវិញ ជាប្រទេសកុំម្មុយនីស តែមានសេដ្ឋកិច្ចបែបទីផ្សារសេរី ដូច្នេះការសិក្សាមួយនេះចង់ធ្វើការប្រៀបធៀបពីក្របខណ្ឌគតិយុត្តវិនិយោគរវាងទាំងពីរនោះ ថាតើមានលក្ខណៈដូចគ្នា និងខុសគ្នាដូចម្តេចខ្លះ?

**គោលបំណងនៃការស្រាវជ្រាវ៖** ដោយឃើញពីសន្ទុះនៃការវិនិយោគនៅក្នុងប្រទេសកម្ពុជាមានការកើនឡើង ការស្រាវជ្រាវមួយនេះចង់បង្ហាញអោយឃើញពីខ្លឹមសារ ក្របខណ្ឌគតិយុត្តវិនិយោគសំខាន់ដែលតម្រូវអោយវិនិយោគិនគ្រប់រូបត្រូវបំពេញលក្ខខណ្ឌ មុននឹងអាចទទួលបានការវិនិយោគមួយដ៏ស្របច្បាប់នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ បន្ថែមពីនេះទៀត ការសិក្សាស្រាវជ្រាវមួយនេះក៏បានផ្តោតទៅលើការប្រៀបធៀបក្របខណ្ឌគតិយុត្តវិនិយោគ រវាងប្រទេសកម្ពុជា និងសាធារណៈរដ្ឋប្រជាមានិតចិន ដើម្បីឆ្លុះបញ្ចាំងអោយឃើញពីភាពដូចគ្នា និងភាពខុសគ្នារវាងក្របខណ្ឌគតិយុត្តប្រទេសទាំងពីរ។

**ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ៖** ដោយហេតុថា ការសិក្សាលើក្របខណ្ឌគតិយុត្តមានលក្ខណៈស៊ីជម្រៅ និងស្មុគស្មាញខ្លាំង កិច្ចការស្រាវជ្រាវមួយនេះ សូមធ្វើការលើកបង្ហាញតែអំពីអត្ថន័យនៃបទបញ្ញត្តិច្បាប់វិនិយោគនៃព្រះរាជាណាចក្រកម្ពុជា និងសាធារណៈរដ្ឋប្រជាមានិតចិនសកម្មភាពវិនិយោគ ស្ថាប័នទទួលបន្ទុកវិនិយោគ ក៏ដូចជាការដាក់ចេញនូវគោលនយោបាយ និងយុទ្ធសាស្ត្ររបស់រដ្ឋាភិបាលរបស់ប្រទេសទាំងពីរ សម្រាប់ការវិនិយោគដើម្បីធានាដល់និរន្តរភាពវិនិយោគសម្រាប់ប្រទេសទាំងពីរ។

**វិធីសាស្ត្រស្រាវជ្រាវ៖** ដោយសារតែប្រធានបទមួយនេះ ជាប្រធានបទមួយថ្មីដែលពុំធ្លាប់មានអ្នកធ្វើការស្រាវជ្រាវពីមុនមក ក៏ដូចជាកង្វះខាតនូវឯកសារជាភាសាខ្មែរ ទើបកិច្ចការស្រាវជ្រាវមួយនេះត្រូវចំណាយពេលយូរក្នុងការស្វែងរកឯកសារដែលពាក់ព័ន្ធ។ តែទោះបីជាយ៉ាងណា ក្របខណ្ឌគតិយុត្តវិនិយោគរបស់ព្រះរាជាណាចក្រកម្ពុជា អាចរកបាននៅក្នុងគេហទំព័រក្រសួងផ្សេងៗឯកសារចងក្រងមួយចំនួនជាដើម។ ដោយឡែក ក្របខណ្ឌគតិយុត្តវិនិយោគរបស់សាធារណៈរដ្ឋប្រជាមានិតចិន ត្រូវពឹងផ្អែកស្ទើរតែទាំងស្រុងទៅលើឯកសារបរទេស ដែលអាចរកបាននៅតាម

ប្រព័ន្ធអ៊ីនធើណេត ក្នុងគេហទំព័ររបស់ក្រសួងនានាដែលពាក់ព័ន្ធ ហើយខ្លឹមសារទាំងមូលត្រូវពឹងលើការបកប្រែពីភាសាបរទេសមកជាភាសាខ្មែរ រួមទាំងការស្វែងរកបន្ថែមជាច្រើនទៀត។

**រចនាសម្ព័ន្ធនៃការស្រាវជ្រាវះ** នៅក្នុងកិច្ចការស្រាវជ្រាវមួយនេះ នឹងធ្វើការបែងចែកជាពីរជំពូកធំៗ ហើយនៅក្នុងជំពូកនីមួយៗនឹងធ្វើការបែងចែកជា ផ្នែក និងកថាខណ្ឌ។ ក្នុងនោះជំពូកទី១ ស្តីអំពី **សញ្ញាណទូទៅនៃបទបញ្ញត្តិច្បាប់វិនិយោគនៃប្រទេសកម្ពុជា និងប្រទេសចិន** និងជំពូកទី២ ស្តីពី **ឱកាសចំពោះការវិនិយោគនៃប្រទេសកម្ពុជា និងប្រទេសចិន**។

# ជំពូកទី១

# សញ្ញាណទូទៅនៃបទបញ្ញត្តិ ច្បាប់វិនិយោគនៃប្រទេសកម្ពុជា និងប្រទេសចិន

# ជំពូកទី១

# សញ្ញាណទូទៅនៃបទបញ្ញត្តិច្បាប់វិនិយោគនៃប្រទេសកម្ពុជានិងប្រទេសចិន

ការសិក្សាទៅលើសញ្ញាណទូទៅនៃបទបញ្ញាត្តិច្បាប់វិនិយោគនេះ យើងចង់រំលេចអោយឃើញពីអត្ថន័យជាទូទៅនៃបទបញ្ញាត្តិច្បាប់វិនិយោគនៃប្រទេសទាំងពីរ ក៏ដូចជាចង់ដឹងថាតើ រវាងបទបញ្ញាត្តិវិនិយោគនៃប្រទេសកម្ពុជា និង សាធារណៈរដ្ឋប្រជាមានិតចិន មួយណាមានលក្ខណៈល្អប្រសើរជាង ឬក៏មានលក្ខណៈខុសប្លែកគ្នាត្រង់ចំណុចណាខ្លះ ដែលយើងនឹងធ្វើការសិក្សានៅក្នុង **ផ្នែកទី១ : អត្ថន័យនៃបទបញ្ញាត្តិច្បាប់វិនិយោគនៃប្រទេសកម្ពុជា និង ប្រទេសចិន**។ ទន្ទឹមនឹងនេះផងដែរ យើងក៏នឹងធ្វើការសិក្សាអំពីអាជ្ញាប័ណ្ណវិនិយោគដែលផ្តល់អោយវិនិយោគិននៅក្នុងប្រទេសទាំងពីរ ដែលនឹងធ្វើការបកស្រាយលម្អិតនៅក្នុង **ផ្នែកទី២: អាជ្ញាប័ណ្ណវិនិយោគនៅប្រទេសកម្ពុជា និង ប្រទេសចិន**។ ស្របពេលជាមួយគ្នានេះ យើងក៏សិក្សាអំពី ប្រភេទផ្សេងៗនៃក្រុមហ៊ុនវិនិយោគដែលអាចចូលមកធ្វើការវិនិយោគដោយស្របច្បាប់ និងទទួលបាននូវអាជ្ញាប័ណ្ណវិនិយោគដែលចេញដោយស្ថាប័នទទួលបន្ទុកកិច្ចការវិនិយោគនៃប្រទេសទាំងពីរ នៅក្នុង **ផ្នែកទី៣: រូបភាពនៃការវិនិយោគនៃប្រទេសកម្ពុជា និងប្រទេសចិន ។**

## ផ្នែកទី១: អត្ថន័យនៃបទបញ្ញាត្តិច្បាប់វិនិយោគនៃប្រទេសកម្ពុជា និង ប្រទេសចិន

### កថាខណ្ឌទី១: អត្ថន័យនៃបទបញ្ញាត្តិច្បាប់វិនិយោគនៅប្រទេសកម្ពុជា

#### ១. អត្ថន័យទូទៅ

##### ១.១. គោលការណ៍ទូទៅ

ច្បាប់ស្តីពីវិនិយោគដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ០៣/នស/រកម/០២៩៧/០៣ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៩៤ មាន៩ជំពូក និង ២៦មាត្រា ដែលបានធ្វើវិសោធនកម្មដោយច្បាប់ស្តីពីវិសោធនកម្មច្បាប់វិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ដែលបានប្រកាសអោយដោយព្រះរាជក្រមលេខ នស/រកម/០៣០៣/០០៩ ចុះថ្ងៃទី ២៤ ខែ មិនា ឆ្នាំ ២០០៣ ដែលក្នុងនោះមាត្រាដែលត្រូវកែប្រែមានដូចជា មាត្រា ១, មាត្រា២, មាត្រា៦, មាត្រា៧, មាត្រា៨, មាត្រា១០, មាត្រា១២, មាត្រា១៤, មាត្រា១៥, មាត្រា១៦, មាត្រា១៨, មាត្រា២០, មាត្រា២១, មាត្រា២២, មាត្រា២៣, ជំពូកទី៩ មាត្រា២៤, និងជំពូកទី១០ មាត្រា២៥, មាត្រា២៦, និងមាត្រា២៧។ ច្បាប់ស្តីពីវិនិយោគនេះ មានគោលបំណងបង្កើតនូវនីតិវិធីផ្លូវការសម្រាប់ការធ្វើវិនិយោគ និងការធានាចំពោះការវិនិយោគ ព្រមទាំងផ្តល់ការលើកទឹកចិត្តដល់វិនិយោគគិនក្នុងប្រទេស និងក្រៅប្រទេសដើម្បីចូលរួមនៅក្នុង

គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ហៅកាត់ថា គ.ល.គ[1] នៅក្នុងប្រទេសកម្ពុជា។ ជាមួយគ្នានេះ អនុក្រឹត្យលេខ១១១ អនក្រ.បក ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០០៥ ស្តីពីការអនុវត្តច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា បានបំពេញបន្ថែម និងចាត់ចែងគ្រប់គ្រងការអនុវត្តច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា និងមានគោលដៅជំរុញការលើកទឹកចិត្ត និងធ្វើនិយ័តកម្មលើការវិនិយោគទាំងឡាយរបស់នីតិបុគ្គលសញ្ជាតិខ្មែរ និងបរទេសនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ យោងតាមច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីវិនិយោគឆ្នាំ២០០៣ បានកំណត់វិសាលភាពទៅលើគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ទាំងអស់ នៅក្នុងព្រះរាជាណាចក្រកម្ពុជា និងកំណត់នីតិវិធីនៃគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដែលធ្វើឡើងដោយបុគ្គលណាមួយ ដែលអាចជារូបវន្តបុគ្គល ឬនីតិបុគ្គល[2]។ ម្យ៉ាងវិញទៀត មានតែអ្នកវិនិយោគដែលទទួលបានគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ទេ ទើបមានសិទ្ធិទទួលបានផលប្រយោជន៍ដែលស្ថិតនៅក្នុងក្របខណ្ឌនៃច្បាប់នេះ[3]។

## **កថាខណ្ឌទី២: អត្ថន័យនៃបទបញ្ញត្តិច្បាប់វិនិយោគនៅប្រទេសចិន**

### **១. អត្ថន័យទូទៅ**

#### **១.១ គោលការណ៍ទូទៅ**

ច្បាប់ស្តីពីការវិនិយោគនៃសាធារណៈរដ្ឋប្រជាមានិតចិន ត្រូវបានបង្កើតឡើងក្នុងគោលបំណងក្នុងការជំរុញឲ្យមានការបើកចំហនូវការវិនិយោគផ្សេងៗនៅក្នុងប្រទេស ក៏ដូចជាដើម្បីការការពារនូវសិទ្ធិ និងផលប្រយោជន៍របស់វិនិយោគិនស្របច្បាប់ ការពារសន្តិសុខនិងបម្រើផលប្រយោជន៍សាធារណៈ លើកកម្ពស់ការអភិវឌ្ឍដែលនាំមកនូវសេដ្ឋកិច្ចទីផ្សារនៅក្នុងប្រទេស[4]។ ច្បាប់ដែលត្រូវបានបង្កើតឡើងនេះ ត្រូវអនុវត្តទៅលើគ្រប់វិនិយោគិនដែលធ្វើការវិនិយោគនៅក្នុងសាធារណៈរដ្ឋប្រជាមានិតចិន[5] ។ ដើម្បីធ្វើការទាក់ទាញវិនិយោគិន និងផ្តល់សេចក្តីទុកចិត្តទៅដល់វិនិយោគិនអោយមកវិនិយោគនៅក្នុងប្រទេស រដ្ឋត្រូវធ្វើការធានា ការពារសិទ្ធិ និងផលប្រយោជន៍ស្របច្បាប់របស់វិនិយោគិន[6]។ យ៉ាងណាមិញ វិនិយោគិន និងសហគ្រាសវិនិយោគទាំងអស់ដែល

[1] គ.ល.គ (គំពោងវិនិយោគដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់) សំដៅដល់គំពោងវិនិយោគដែលទទួលបានវិញ្ញាបនបត្រចុះបញ្ជីជាស្ថាពរ។

[2] មាត្រា១ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីវិនិយោគ ឆ្នាំ២០០៣។

[3] មាត្រា២ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីវិនិយោគ ឆ្នាំ២០០៣។

[4] មាត្រា ១ នៃច្បាប់ស្តីពីការវិនិយោគ។

[5] មាត្រា ២ នៃច្បាប់ស្តីពីការវិនិយោគ។

[6] មាត្រា ៣ នៃច្បាប់ស្តីពីការវិនិយោគ។

បានវិនិយោគនៅក្នុងប្រទេសចិន ក៏ត្រូវតែគោរពតាមច្បាប់ប្រទេសចិន ដែលរាល់សកម្មភាពវិនិយោគ គឺមិនត្រូវធ្វើអោយប៉ះពាល់ទៅដល់សន្តិសុខជាតិ និងប្រយោជន៍សាធារណៈរបស់ប្រទេសចិនឡើយ។ វិនិយោគិននិងសហគ្រាសវិនិយោគដែលចូលរួមក្នុងសកម្មភាពវិនិយោគក្នុងសកម្មភាពអាជីវកម្មនៅក្នុងប្រទេស ត្រូវតែអនុវត្តអោយបាននូវក្រមសីលធម៌សង្គម ក្រមសីលធម៌អាជីវកម្ម ភាពស្មោះត្រង់ ការយកចិត្តទុកដាក់ ការត្រួតពិនិត្យសង្គម ការប្តេជ្ញាចិត្ត និងការទទួលខុសត្រូវនៅក្នុងសង្គម[7]។ ដើម្បីធានាអោយបាននូវការអនុវត្តការគ្រប់គ្រងការវិនិយោគប្រកបទៅដោយជោគជ័យ និងប្រសិទ្ធិភាពការគ្រប់គ្រង គឺត្រូវតែធ្វើឡើងដើម្បីអោយស្របតាមគោលការណ៍បើកចំហ និងគោលការណ៍តម្លាភាព[8]។ បន្ថែមពីនេះទៀត ដើម្បីបង្កើតអោយមាននូវទិដ្ឋភាពវិនិយោគដែលមានលក្ខណៈដ៏សមរម្យមួយនៅក្នុងប្រទេស សាធារណៈរដ្ឋប្រជាមានិតចិនបានរៀបចំនូវប្រព័ន្ធគតិយុត្តមួយចំនួនបន្ថែមទៀតផងដែរ។ ជាក់ស្តែងនៅក្នុងឆ្នាំ១៩៧៩ សភាប្រជាជនជាតិ (National People's Congress) នៃសាធារណៈរដ្ឋប្រជាមានិតចិន បានដាក់ចេញនូវច្បាប់ស្តីពីការបណ្តាក់ទុនរួមគ្នាដោយសមធម៌ (Chinese-Foreign Equity Joint Ventures)។ រយៈពេល២០(ម្ភៃ)ឆ្នាំបន្ទាប់រដ្ឋាភិបាលរបស់ប្រទេសចិន បានប្រកាសអោយប្រើ និងដាក់ចេញជាបន្តបន្ទាប់នូវច្បាប់ និងលក្ខន្តិកៈដែលផ្តោតទៅលើការបង្កើត ការប្រព្រឹត្តិទៅ ការបញ្ចប់ ក៏ដូចជាការទូទាត់នៃសហគ្រាសវិនិយោគបរទេស។ បទបញ្ញត្តិទាំងនេះមានចំនួន៣សំខាន់ៗ៖ ច្បាប់ស្តីពីការបណ្តាក់ទុនរួមគ្នាដោយសមធម៌នៃសាធារណៈរដ្ឋប្រជាមានិតចិន(The Law of the People's Republic of China on Chinese-Foreign Equity Joint Ventures) ច្បាប់ស្តីពីកិច្ចសន្យាបណ្តាក់ទុនរួមគ្នានៃសាធារណៈរដ្ឋប្រជាមានិតចិន (The Law of the People's Republic of China on Chinese-Foreign Contractual Joint Ventures) និងច្បាប់ស្តីពីសហគ្រាសគ្រប់គ្រងដោយបរទេសទាំងស្រុង (The Law of the People's Republic of China on Wholly Foreign-Owned Enterprises) ហើយរួមទាំងបទបញ្ញត្តិលម្អិតសម្រាប់ការអនុវត្តច្បាប់គ្រឹះទាំងនេះ ច្បាប់ស្តីពីក្រុមហ៊ុននៃសាធារណៈរដ្ឋប្រជាមានិតចិន ច្បាប់ស្តីពីពន្ធលើប្រាក់ចំណូលនៃសាធារណៈរដ្ឋប្រជាមានិតចិន សម្រាប់សហគ្រាស វិនិយោគបរទេស និងសហគ្រាសបរទេស ខលក្ខខណ្ឌសម្រាប់ណែនាំការវិនិយោគបរទេស បញ្ជីឧស្សាហកម្មសម្រាប់ការវិនិយោគបរទេស, ខលក្ខខណ្ឌដែលផ្តោតសំខាន់ទៅលើការវិនិយោគ នៃសហគ្រាសវិនិយោគបរទេសនៅក្នុងប្រទេសចិន ខលក្ខខណ្ឌដែលទាក់ទងនឹងសហគ្រាសវិនិយោគបរទេសរួមគ្នា និង

[7] មាត្រា ៩ នៃច្បាប់ស្តីពីការវិនិយោគ។

[8] មាត្រា ៨ នៃច្បាប់ស្តីពីការវិនិយោគ។

ដាច់ដោយឡែក និងវិធានការទូទាត់សម្រាប់សហគ្រាសវិនិយោគបរទេស។ បទបញ្ញត្តិទាំងនេះបានផ្តល់នូវមូលដ្ឋានគតិយុត្ត ក្នុងការធានានូវសិទ្ធិនៃការប្រព្រឹត្តិទៅដោយឯករាជ្យនៃសហគ្រាសបរទេស និងផ្តល់នូវការការពារនូវសិទ្ធិស្របច្បាប់ និងផលប្រយោជន៍ទាំងអ្នកវិនិយោគជាតិ និងបរទេស។ នាពេលថ្មីៗនេះ រដ្ឋាភិបាលចិនក៏កំពុងធ្វើការត្រួតពិនិត្យឡើងវិញនូវបទបញ្ញត្តិ និងលក្ខន្តិកៈដែលមាន ដើម្បីអោយស្របតាមគម្រោងអង្គការពាណិជ្ជកម្មពិភពលោក។ វាបានលុបចោលនូវច្បាប់ ក៏ដូចជាបទបញ្ញាដែលនិរាករណ៍ ហើយបានកែប្រែឡើងវិញនូវច្បាប់ និងបទបញ្ញាដែលមិនត្រូវគ្នានឹងបទបញ្ញាត្តិច្បាប់អង្គការពាណិជ្ជកម្មពិភពលោក។ នៅក្នុងឆ្នាំ២០០០ ប្រទេសចិនបានកែសម្រួលឡើងវិញនូវច្បាប់ស្តីពីកិច្ចសន្យាបណ្តាក់ទុនរួមគ្នា (Chinese Foreign Contractual Joint Ventures)នៃសាធារណៈរដ្ឋប្រជាមានិតចិន និងច្បាប់ស្តីពីសហគ្រាសគ្រប់គ្រងដោយបរទេសទាំងស្រុង (Wholly Foreign Owned Enterprises)នៃសាធារណៈរដ្ឋប្រជា មានិតចិន និងលុបចោលនូវលក្ខខណ្ឌដែលទាក់ទងនឹងតុល្យភាពនៃគណនេយ្យរូបិយប័ណ្ណ និងការរីករាលដាលនៃការផ្គត់ផ្គង់។ ហើយនៅក្នុងឆ្នាំ២០០១ ច្បាប់ស្តីពីការបណ្តាក់ទុនរួមគ្នាដោយសមធម៌(Chinese Foreign Equity Joint Ventures)នៃសាធារណៈរដ្ឋប្រជាមានិតចិនក៏ត្រូវបានកែប្រែឡើងវិញដែរ។

## កថាខណ្ឌទី៣: ការប្រៀបធៀបបទបញ្ញត្តិវិនិយោគរវាងប្រទេសកម្ពុជា និង ប្រទេសចិន

### ១. បទបញ្ញត្តិទូទៅចំពោះការគ្រប់គ្រងសកម្មភាពវិនិយោគ

#### ១.១. ផលប្រយោជន៍ និង ភាពទាក់ទាញចំពោះការវិនិយោគ

ច្បាប់វិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ក៏ដូចជាច្បាប់វិនិយោគនៃសាធារណៈប្រជាមានិតចិន គឺបង្កើតឡើងក្នុងគោលបំណងជំរុញអោយមានបរិយាកាសវិនិយោគនៅក្នុងប្រទេសកាន់តែមានលក្ខណៈល្អប្រសើរឡើង និងដើម្បីលើកកម្ពស់ការអភិវឌ្ឍសេដ្ឋកិច្ចប្រទេសតាមរយៈការបើកចំហនូវសេដ្ឋកិច្ចទីផ្សារសេរី។ ជាមួយគ្នានេះ ដើម្បីទាក់ទាញអោយអ្នកវិនិយោគមានចំណាប់អារម្មណ៍បោះទុនមកវិនិយោគនោះ តាមរយៈច្បាប់ស្តីពីវិនិយោគនៃប្រទេសទាំងពីរ ក៏បានធ្វើការធានា និងការពារផលប្រយោជន៍ស្របច្បាប់របស់អ្នកវិនិយោគិន ព្រមទាំងបានលើកទឹកចិត្តដល់អ្នកវិនិយោគ ដែលបានមកវិនិយោគនៅក្នុងប្រទេសទាំងពីរផងដែរ។ ជាក់ស្តែងដូចជានៅក្នុងប្រទេសកម្ពុជា ដើម្បីទាក់ទាញវិនិយោគិនអោយមកវិនិយោគនៅកម្ពុជានោះ រាជរដ្ឋាភិបាលកម្ពុជាបានខិតខំពង្រឹង និងបង្កើតបទដ្ឋានគតិយុត្តជាច្រើនដែលពាក់ព័ន្ធនឹងការវិនិយោគ ហើយតាមរយៈបទដ្ឋានគតិយុត្តទាំងនោះ បានផ្តល់នូវទំនុកចិត្តដល់វិនិយោគិនជាតិ និងបរទេសឲ្យមកវិនិយោគនៅក្នុង

ប្រទេសកម្ពុជា។ ដូចជាការបង្កើតឲ្យមានការលើកទឹកចិត្ត និងការធានាទៅលើគម្រោងវិនិយោគ ដែលធ្វើឡើងស្របតាមច្បាប់វិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ដែលមានដូចជាការធានាលើការមិនរើសអើងសញ្ជាតិនៃវិនិយោគិន ទោះបីជាអ្នកវិនិយោគនោះមានសញ្ជាតិខ្មែរ ឬបរទេសក៏ដោយក៏អ្នកវិនិយោគទាំងនោះ មានសិទ្ធិទទួលបានការធានាពីរាជរដ្ឋាភិបាលកម្ពុជាដោយស្មើភាពគ្នាអោយតែការវិនិយោគនោះធ្វើឡើងស្របតាមច្បាប់ ការធានាមិនធ្វើជាតូបនីយកម្មនូវទ្រព្យសម្បត្តិឯកជនរបស់វិនិយោគិន ការធានាទៅលើការមិនកំណត់តម្លៃ និងសេវារបស់ក្រុមហ៊ុនវិនិយោគ។ ហើយការលើកទឹកចិត្តដល់អ្នកវិនិយោគ មានដូចជាការលើកលែងពន្ធលើប្រាក់ចំណេញដែលអ្នកវិនិយោគទទួលបាន ការលើកលែងពន្ធនាំចូលនៅគ្រឿងសម្ភារៈបរិក្ខារផ្សេងៗ ដែលបម្រើដល់សកម្មភាពវិនិយោគ ការលើកលែងពន្ធលើផលិតផលដែលអ្នកវិនិយោគនាំចេញទៅក្រៅប្រទេសកម្ពុជាជាដើម។ ទន្ទឹមនឹងនេះ នៅក្នុងសាធារណៈប្រជាមានិតចិន ក៏មិនមានលក្ខណៈខុសប្លែកគ្នាពីប្រទេសកម្ពុជាប៉ុន្មានដែរ ពោលគឺដើម្បីបង្កើនការវិនិយោគនៅប្រទេសរបស់គេនោះ សាធារណៈប្រជាមានិតចិនក៏មានវិធីសាស្ត្រធ្វើយ៉ាងណាក្នុងការទាក់ទាញអ្នកវិនិយោគឲ្យមកធ្វើការវិនិយោគនៅក្នុងប្រទេសផងដែរ។ ដូចជារដ្ឋាភិបាលចិនបានធ្វើការធានា និងការពារទៅលើផលប្រយោជន៍ស្របច្បាប់របស់វិនិយោគិន ព្រមទាំងខិតខំប្រឹងប្រែងពង្រឹងនូវប្រព័ន្ធគតិយុត្តដែលទាក់ទងនឹងវិនិយោគរបស់ខ្លួនឲ្យរឹងមាំ ដែលបទបញ្ញត្តិទាំងនេះបានផ្តល់នូវមូលដ្ឋានគតិយុត្តក្នុងការធានានូវសិទ្ធិនៃការប្រព្រឹត្តិទៅដោយឯករាជ្យនៃសហគ្រាសបរទេស និងផ្តល់នូវការការពារនូវសិទ្ធិស្របច្បាប់និងផលប្រយោជន៍ទាំងអ្នកវិនិយោគជាតិ និងបរទេស។

ជារួមយើងសង្កេតឃើញថា បទបញ្ញត្តិវិនិយោគនៃប្រទេសទាំងពីរ គឺបង្កើតឡើងក្នុងគោលដៅធ្វើយ៉ាងណាឲ្យការវិនិយោគនៅក្នុងប្រទេសមានលក្ខណៈល្អប្រសើរ និងជំរុញការអភិវឌ្ឍសេដ្ឋកិច្ចជាតិតាមរយៈការបើកផ្លូវស្វាគមន៍យ៉ាងកក់ក្តៅ ឲ្យបុគ្គលដែលមានបំណងចង់មកវិនិយោគ មកធ្វើការវិនិយោគនៅក្នុងប្រទេសរបស់ពួកគេ។ មិនត្រឹមតែប៉ុណ្ណោះ បើយើងក្រឡេកទៅមើលកត្តាដែលទាក់ទាញឲ្យមានការវិនិយោគនៅក្នុងប្រទេសទាំងពីរវិញ គឺមានលក្ខណៈល្អប្រសើរ និងមានភាពខុសប្លែកគ្នាបន្តិចបន្តួចតែប៉ុណ្ណោះ ប៉ុន្តែសុទ្ធតែមានគោលបំណងទាក់ទាញធ្វើយ៉ាងណាអោយមានការវិនិយោគនៅក្នុងប្រទេសមានការកើនឡើង ដែលជាកត្តាដ៏សំខាន់ក្នុងការរុញច្រានសេដ្ឋកិច្ចជាតិឲ្យមានការរីកចម្រើនទៅមុខផងដែរ។ ដោយឡែកយើងក៏បានសម្គាល់ឃើញថា កត្តាមួយដ៏សំខាន់ក្នុងចំណោមកត្តាផ្សេងៗទៀតជាច្រើន ដែលអាចទាក់ទាញចំណាប់អារម្មណ៍ពីវិនិយោគិនបានខ្លាំងជាងគេនៅក្នុងប្រទេសកម្ពុជា និងសាធារណៈរដ្ឋប្រជាមានិតចិននោះ គឺការបង្កើតឲ្យមាន

បទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងវិនិយោគដ៏រឹងមាំមួយ ដែលនេះជាចំណុចមួយដែលអ្នកវិនិយោគ មិនដែលមើលរំលងម្តងណានោះទេ ព្រោះថានៅពេលដែលពួកគេមានបំណងចង់ទៅបណ្តាក់ទុនវិនិយោគនៅក្នុងប្រទេសណាមួយនោះ ពួកគេតែងតែពិនិត្យជាមុនទៅលើបណ្តាប្រព័ន្ធច្បាប់នៅក្នុងប្រទេសនោះ ថាតើច្បាប់នៅក្នុងប្រទេសដែលគេចង់ទៅវិនិយោគ អាចធានា និងការពារទៅលើគម្រោងវិនិយោគរបស់ពួកគេបានដល់កម្រិតណា? ហើយវាបានផ្តល់ផលប្រយោជន៍អ្វីខ្លះចំពោះពួកគេដែលជាវិនិយោគិន។

## ២. បទបញ្ញត្តិពិសេសចំពោះសកម្មភាពវិនិយោគ

### ២.១. ករណីប្រទេសកម្ពុជា

តាមរយៈអនុក្រឹត្យលេខ ១៤៨ អនក្រ.បក បានបង្កើតឲ្យមានតំបន់សេដ្ឋកិច្ចពិសេសនៅក្នុងប្រទេសកម្ពុជា ដែលជាមជ្ឈមណ្ឌលពិសេសសម្រាប់អភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ និងជាតំបន់គ្រប់គ្រងសកម្មភាពវិនិយោគពិសេស ដែលប្រមូលផ្តុំទៅដោយសកម្មភាពឧស្សាហកម្ម និងសកម្មពាក់ព័ន្ធដទៃទៀត ព្រមទាំងអាចមានតំបន់ឧស្សាហកម្មទូទៅ ឬតំបន់ផលិតកែច្នៃនាំចេញ។ តំបន់សេដ្ឋកិច្ចពិសេសនីមួយៗ ត្រូវមានមណ្ឌលផលិតកម្ម និងអាចមានមណ្ឌលផលិតកម្មសេរី មណ្ឌលសេវាកម្ម មណ្ឌលលំនៅដ្ឋាន និងមណ្ឌលទេសចរណ៍។

តំបន់សេដ្ឋកិច្ចពិសេសនេះបង្កើតឡើងក្នុងគោលដៅ បង្កើនបរិយាកាសវិនិយោគដែលអំណោយផលដល់ការធ្វើអោយកាន់តែប្រសើរនូវផលិតភាពក្នុងការផលិតទំនិញ ការប្រជែងឈ្នះកំណើនសេដ្ឋកិច្ចជាតិ ជំរុញការនាំចេញ ដោះស្រាយការងារជូនប្រជាជន កាត់បន្ថយភាពក្រីក្រព្រមទាំងសម្របសម្រួលសកម្មភាពវិនិយោគ និងជំរុញលើកទឹកចិត្តដល់ការវិនិយោគរបស់អ្នកអភិវឌ្ឍន៍តំបន់ និងអ្នកវិនិយោគក្នុងតំបន់សេដ្ឋកិច្ចពិសេសជាដើម។ សព្វថ្ងៃនេះតំបន់សេដ្ឋកិច្ចពិសេសកម្ពុជាបានអនុម័ត ២៥(ម្ភៃប្រាំ)តំបន់សេដ្ឋកិច្ចពិសេស ដែលមាន៩(ប្រាំបួន)តំបន់កំពុងដំណើរការ។ តំបន់សេដ្ឋកិច្ចពិសេសទាំងនេះមានទីតាំងស្ថិតនៅក្បែរព្រំដែនប្រទេសថៃ និងវៀតណាម និងនៅក្នុងរាជធានីភ្នំពេញ ខេត្តកំពត និងក្រុងព្រះសីហនុ ចំណែកឯតំបន់ផ្សេងទៀតកំពុងស្ថិតនៅក្នុងដំណាក់កាលផ្សេងគ្នានៃការអភិវឌ្ឍ និងមួយចំនួននៅតែកំពុងអភិវឌ្ឍន៍ ។

### ២.២. ករណីប្រទេសចិន

រដ្ឋាភិបាលប្រទេសចិន ធ្វើការដកហូតពន្ធចំពោះសហគ្រាសវិនិយោគបរទេស ហើយគោលនយោបាយលើពន្ធបុរិមា គឺត្រូវបានផ្តល់អោយចំពោះវិស័យ និងតំបន់ទាំងឡាយណាដែលការវិនិយោគត្រូវបានលើកទឹកចិត្តដោយរដ្ឋាភិបាល។

ក. ពន្ធលើប្រាក់ចំណូល

-អត្រាពន្ធលើប្រាក់ចំណូលៈ ពន្ធលើប្រាក់ចំណូលរបស់សហគ្រាសវិនិយោគបរទេសគឺត្រូវបានដកហូតពន្ធក្នុងកម្រិត៣៣%។ ពន្ធលើប្រាក់ចំណូលរបស់សហគ្រាសវិនិយោគបរទេសដែលមានទីតាំងនៅក្នុងតំបន់សេដ្ឋកិច្ចពិសេស តំបន់ឧស្សាហកម្មថ្មី (state new-and hi-tech industrial zone) ឬក៏តំបន់អភិវឌ្ឍសេដ្ឋកិច្ចនិងបច្ចេកវិទ្យា (Economic and Technological development Zones) ត្រូវបានដកហូតពន្ធនៅក្នុងអត្រា១៥%។ ពន្ធលើប្រាក់ចំណូលផលិតផលនៃសហគ្រាសវិនិយោគបរទេស ដែលមានទីតាំងនៅក្នុងតំបន់ច្រាំងសេដ្ឋកិច្ចចំហ (Coastal economic open zones) តំបន់សេដ្ឋកិច្ចពិសេស (Special economic zone) ឬតំបន់ទីក្រុងចំណាស់ដែលតំបន់អភិវឌ្ឍសេដ្ឋកិច្ច និងបច្ចេកវិទ្យាតាំងនៅ គឺត្រូវដកហូតពន្ធក្នុងអត្រា២៤%។ ហើយពន្ធលើប្រាក់ចំណូលរបស់សហគ្រាសវិនិយោគបរទេសដែលបានផ្សាភ្ជាប់ជាមួយគម្រោងមួយចំនួនដូចជា ថាមពល គមនាគមន៍ កំពង់ផែ គឺត្រូវបានដកហូតក្នុងអត្រាបន្ថយពន្ធ១៥%។

-ការកាត់បន្ថយពន្ធ និងការលើកលែងពន្ធៈ ចំពោះសហគ្រាសវិនិយោគផលិតផលដែលរយៈពេលនៃការធ្វើប្រតិបត្តិការលើសពី១០(ដប់)ឆ្នាំគិតចាប់ពីពេលបង្កើតប្រាក់ចំណេញ ត្រូវបានលើកលែងពន្ធលើប្រាក់ចំណូលសម្រាប់២(ពីរ)ឆ្នាំដំបូង និងអនុញ្ញាតអោយមានការកាត់បន្ថយពន្ធ ៥០%នៅក្នុងរយៈពេល៣(បី)ឆ្នាំបន្ទាប់។ សហគ្រាសវិនិយោគបរទេសដែលផ្សាភ្ជាប់នឹងវិស័យកសិកម្ម ព្រៃឈើ ការចិញ្ចឹមសត្វ និងសហគ្រាសវិនិយោគបរទេសដែលត្រូវបានបង្កើតឡើងនៅក្នុងតំបន់ដាច់ស្រយាល ដែលបានទទួលការយល់ព្រមពីការិយាល័យពន្ធដារ ត្រូវបានអនុញ្ញាតអោយមានការកាត់បន្ថយពន្ធលើប្រាក់ចំណូលពី ១៥ទៅ៣០ភាគរយ សម្រាប់១០(ដប់)ឆ្នាំបន្តទៀត បន្ទាប់ពីមានការលើកលែងពន្ធ និងកាត់បន្ថយពន្ធដូចដែលបានបញ្ជាក់ពីខាងដើម។ ចំពោះពន្ធលើប្រាក់ចំណូលរបស់សហគ្រាសវិនិយោគបរទេស ដែលមានទីតាំងនៅប៉ែកកណ្ដាល ភាគខាងលិចប្រទេសចិន ដែលផ្សាភ្ជាប់ទៅនឹងការលើកទឹកចិត្តដោយរដ្ឋាភិបាល ត្រូវបានដកហូតពន្ធក្នុងអត្រាបន្ថយពន្ធ១៥%សម្រាប់រយៈពេល៣(បី)ឆ្នាំ បន្ទាប់ពីការផុតកំណត់នៃកំឡុងពេលប្រាំឆ្នាំចំពោះការលើកលែង និងកាត់បន្ថយពន្ធ។ សម្រាប់សហគ្រាសវិនិយោគបរទេស ដែលទទួលយកបច្ចេកវិទ្យាទំនើបត្រូវលើកលែងពន្ធសម្រាប់២(ពីរ)ឆ្នាំដំបូង និងអនុញ្ញាតអោយកាត់បន្ថយពន្ធចំនួន៥០សម្រាប់ ៦(ប្រាំមួយ)ឆ្នាំបន្ទាប់។ បន្ថែមពីលើការលើកលែងពន្ធចំនួន២(ពីរ)ឆ្នាំ និងការកាត់បន្ថយពន្ធចំនួន៣(បី)ឆ្នាំ សហគ្រាសវិនិយោគបរទេសដែលផលិតសម្រាប់នាំចេញ ត្រូវបានកាត់បន្ថយពន្ធក្នុងអត្រា ៥០%ស្របពេលដែលការនាំចេញជាប្រចាំមានចំនួន៧០%នៃការលក់។ វិនិយោគិនបរទេសដែល

ចង់បណ្តាក់ទុនវិនិយោគសារជាថ្មីនូវភាគហ៊ុនចំណេញដែលបានមកពីសហគ្រាស នៅក្នុងគម្រោងដែលកំពុងតែដំណើរការក្នុងរយៈពេលតិចជាង៥(ប្រាំ)ឆ្នាំ វិនិយោគិនត្រូវទទួលការយល់ព្រមពីការិយាល័យពន្ធដារសម្រាប់ពាក្យស្នើសុំ ក្នុងការទទួលបានប្រាក់មកវិញចំនួន៤០%នៃពន្ធលើប្រាក់ចំណូលដែលបានបង់ទៅលើការបណ្តាក់វិនិយោគសារជាថ្មី។

២. ពន្ធលើដំណាក់កាលចរាចរណ៍ (Circulation-stage tax)

ចាប់តាំងពីថ្ងៃទី១ ខែមករា ឆ្នាំ១៩៩៤មក រដ្ឋាភិបាលចិនបានដកហូតពន្ធបង្រួបបង្រួមបន្ថែម (Unified value-added) ពន្ធលើការប្រើប្រាស់ និងពន្ធលើជំនួញរបស់សហគ្រាសវិនិយោគបរទេស និងសហគ្រាសក្នុងស្រុក។ ការផ្លាស់ប្តូរបច្ចេកវិទ្យា និងការអភិវឌ្ឍបច្ចេកទេសដោយសហគ្រាសបរទេស និងសហគ្រាសវិនិយោគបរទេសត្រូវបានលើកលែងពន្ធពីពន្ធលើតម្លៃបន្ថែម (value-added tax) ដើម្បីជាការពង្រីកនូវតម្រូវការក្នុងស្រុក និងលើកទឹកចិត្តចំពោះការផ្លាស់ប្តូរបច្ចេកទេសនៅក្នុងសហគ្រាសវិនិយោគបរទេស។ សម្រាប់សហគ្រាសវិនិយោគដែលផ្សាភ្ជាប់ជាមួយនឹងគម្រោងលើកទឹកចិត្ត ឬបញ្ជីមានកំណត់( Restricted-B categories), ពន្ធលើតម្លៃបន្ថែមសម្រាប់របស់របរប្រើប្រាស់ចិន ដែលត្រូវបានជាវដោយសហគ្រាសនោះក្នុងចំនួនសរុបនៃការវិនិយោគ ត្រូវបានប្រគល់អោយវិញប្រសិនបើរបស់របរទាំងនោះបានចុះបញ្ជីដែលបានផ្តល់អោយសម្រាប់ការលើកលែងពន្ធលើការនាំចូលនិងការនាំចេញ។

៣. ពន្ធលើតម្លៃបន្ថែមក្នុងការនាំចូល (Import-stage Value-added tax)

-អត្រាពន្ធនាំចេញនិងនាំចូល តាំងពីឆ្នាំ ១៩៩២ រដ្ឋាភិបាលចិនបានកាត់បន្ថយអត្រាពន្ធនាំចេញ និងនាំចូលចំនួន៩(ប្រាំបួន)ដង សម្រាប់ការនាំចូលទំនិញ។ អត្រាពន្ធនាំចេញ និងនាំចូលជាមធ្យមនាពេលបច្ចុប្បន្នគឺស្មើនឹង ១២%។

-ការលើកលែងពន្ធសម្រាប់បើការនាំចូលសម្ភារៈប្រើប្រាស់៖ សម្ភារៈប្រើប្រាស់ដែលបាននាំចូលសម្រាប់គម្រោងវិនិយោគបរទេស ឬក្នុងស្រុក ដែលត្រូវបានលើកទឹកចិត្ត និងគាំទ្រដោយរដ្ឋត្រូវទទួលបាននូវការលើកលែងពន្ធនាំចូល និងពន្ធនាំចូលលើតម្លៃបន្ថែមក្នុងពេលនាំចូល(import-stage value-added tax)។

## ផ្នែកទី២: អាជ្ញាប័ណ្ណវិនិយោគនៅប្រទេសកម្ពុជា និងប្រទេសចិន

### កថាខណ្ឌទី១: អាជ្ញាប័ណ្ណវិនិយោគនៅប្រទេសកម្ពុជា

#### ១. នីតិវិធីក្នុងការដាក់ពាក្យស្នើសុំអាជ្ញាប័ណ្ណវិនិយោគ

រាល់បុគ្គលដែលមានបំណងបង្កើតគម្រោងវិនិយោគ ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់

តាមច្បាប់ស្តីពីវិសោធនកម្មច្បាប់វិនិយោគនៃព្រះរាជាណាចក្រកម្ពុជា បុគ្គលទាំងនោះត្រូវដាក់សំណើវិនិយោគទៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ឬអនុគណៈកម្មាធិការវិនិយោគខេត្ត-ក្រុង ទៅតាមទម្រង់បែបបទនៃការដាក់ពាក្យសុំដែលបានបំពេញសព្វគ្រប់ ហើយត្រូវចុះហត្ថលេខាត្រឹមត្រូវដោយម្ចាស់គម្រោងដែលមានសិទ្ធិ ឬអ្នកតំណាងអោយអ្នកដាក់ពាក្យសុំដែលមានការប្រគល់សិទ្ធិត្រឹមត្រូវ និងត្រូវបង់ថ្លៃចុះបញ្ជីចំនួន៧.០០០.០០០(ប្រាំពីរលាន)រៀលនៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ឬអនុគណៈកម្មាធិការវិនិយោគខេត្ត-ក្រុង ដែលជាថ្លៃសេវារដ្ឋបាលដើម្បីទទួលបាននូវរាល់ការយល់ព្រម ការអនុញ្ញាត អាជ្ញាប័ណ្ណ ឬបញ្ជីការនានាពីគ្រប់ក្រសួង ស្ថាប័ន មន្ទីរមានសមត្ថកិច្ចពាក់ព័ន្ធទាំងអស់ទាំងពន្ធប្រថាប់ត្រាផងដែរ[៩]។

តើទម្រង់បែបបទនៃការដាក់ពាក្យសុំវិនិយោគដែលមានលក្ខណៈសព្វគ្រប់ ដូចបានរៀបរាប់ខាងលើនេះ ត្រូវបំពេញលក្ខខណ្ឌយ៉ាងដូចម្តេចខ្លះ?

**១.១. លក្ខខណ្ឌនៃពាក្យសុំវិនិយោគ**

បុគ្គលដែលមានបំណងស្នើសុំការលើកទឹកចិត្ត និងការធានាលើការវិនិយោគ ត្រូវដាក់ជូនក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ឬអនុគណៈកម្មការធិការវិនិយោគខេត្ត-ក្រុង នូវសំណើវិនិយោគតាមទម្រង់បែបបទនៃការដាក់ពាក្យសុំដែលបានបំពេញសព្វគ្រប់ ដែលត្រូវធ្វើការកំណត់របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដែលមានកំណត់នៅក្នុងឧបសម្ព័ន្ធទី២នៃអនុក្រឹត្យលេខ១១១ អនក្រ.បក ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ ២០០៥ ស្តីពីការអនុវត្តច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា[10]។

-ភស្តុតាងស្តីពីសិទ្ធិអំណាចក្នុងការចុះហត្ថលេខា: ប្រសិនបើសំណើវិនិយោគនោះចុះហត្ថលេខាដោយតំណាងអ្នកដាក់ពាក្យសុំ ឯកសារស្តីពីការទទួលបានសិទ្ធិឲ្យចុះហត្ថលេខានោះ ត្រូវដាក់ជូនទៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ឬអនុគណៈកម្មាធិការវិនិយោគខេត្ត-ក្រុងដោយភ្ជាប់មកជាមួយនូវសំណើវិនិយោគនោះ។

-គម្រោងពហុសកម្មភាព: ប្រសិនបើបុគ្គលមានបំណងធ្វើសកម្មភាពវិនិយោគ និងដំណើរការលើសពីសកម្មភាពវិនិយោគមួយឡើងទៅ ហើយប្រសិនបើគម្រោងត្រូវបានចុះបញ្ជីដើម្បីដំណើរការជាគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ បុគ្គលនោះត្រូវដាក់សំណើដាច់ដោយឡែកពីគ្នាសម្រាប់សកម្មភាពវិនិយោគនីមួយៗ។

---

[9] មាត្រា៥ ចំណុច ៥.១ នៃអនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីវិសោធនកម្មច្បាប់វិនិយោគនៃព្រះរាជាណាចក្រកម្ពុជា។

[10] សូមមើលឧបសម្ព័ន្ធ។

-ជ្រើសរើសការលើកលែងពន្ធលើប្រាក់ចំណេញៈ អ្នកដាក់ពាក្យសុំដែលមានបំណងលើកលែងពន្ធលើប្រាក់ចំណេញតាមមាត្រា១៤ ចំណុច ១៤.១នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់វិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ដោយអនុលោមតាមមាត្រា១៥នៃអនុក្រឹត្យលេខ១១១ អនក្រ.បក ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០០៥ ស្តីពីការអនុវត្តច្បាប់ស្តីពីវិសោធនកម្មច្បាប់វិនិយោគនៃព្រះរាជាណាចក្រកម្ពុជា នៅពេលទទួលបានវិញ្ញាបនបត្រចុះបញ្ជីជាស្ថាពរ ត្រូវធ្វើការជ្រើសរើសជាលាយលក្ខណ៍អក្សរនូវការលើកទឹកចិត្តដែលខ្លួនចង់បាននៅក្នុងសំណើវិនិយោគ។

-ការជ្រើសរើសដោយបដិសេធនូវរំលោះពិសេសផ្នែកសារពើពន្ធផ្សេងៗៈ ក្នុងការជ្រើសរើសតាមកថាខណ្ឌទី៣ខាងលើ (ជ្រើសរើសការលើកលែងពន្ធលើប្រាក់ចំណេញ) អ្នកដាក់ពាក្យសុំទទួលស្គាល់ថាការជ្រើសរើសដើម្បីប្រើប្រាស់រយៈពេលលើកលែងពន្ធលើប្រាក់ចំណេញដែលមានចែងក្នុងមាត្រា១៤.២នៃច្បាប់វិនិយោគ នឹងធ្វើអោយអ្នកវិនិយោគគ្មានសិទ្ធិក្នុងការទាមទាររំលោះពិសេសផ្នែកវិនិយោគដែលអនុវត្តសម្រាប់អ្នកវិនិយោគ តាមច្បាប់ស្តីពីសារពើពន្ធដែលទាក់ទងទៅនឹងគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់នោះឡើយ។

-ការជ្រើសរើសតែការធានាលើការវិនិយោគៈ អ្នកដាក់ពាក្យសុំដែលមានបំណងទទួលបាននូវផលប្រយោជន៍តែការធានាលើការវិនិយោគ អាចធ្វើការជ្រើសរើសជាលាយលក្ខណ៍អក្សរនៅក្នុងទម្រង់បែបបទនៃការដាក់ពាក្យស្នើសុំ ដោយអ្នកដាក់ពាក្យសុំនោះមិនមែនជាគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ទេ តែស្ថិតនៅក្រោមការធានាលើការវិនិយោគនៃច្បាប់វិនិយោគ។ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ឬអនុគណៈកម្មាធិការវិនិយោគខេត្ត-ក្រុង ត្រូវចេញនូវអាជ្ញាប័ណ្ណមួយដោយឡែកដើម្បីបញ្ជាក់ជូនអ្នកដាក់ពាក្យសុំសម្រាប់ករណីនេះ។

### ១.២. ការអនុញ្ញាត និង ការដកហូតសិទ្ធិ

ក្រុមហ៊ុនវិនិយោគទាំងអស់ ក្រោយពីទទួលបានការអនុញ្ញាតពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ឬអនុគណៈកម្មាធិការវិនិយោគខេត្ត-ក្រុង ត្រូវធ្វើសកម្មភាពអាជីវកម្មរបស់ខ្លួនទៅតាមការដែលខ្លួនបានស្នើសុំទៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ឬអនុគណៈកម្មាធិការវិនិយោគខេត្ត-ក្រុង។ ក្រុមហ៊ុនវិនិយោគទាំងអស់មិនអាចធ្វើសកម្មភាពណាមួយក្រៅពីអ្វីដែលបានស្នើសុំទៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ឬអនុគណៈកម្មាធិការវិនិយោគខេត្ត-ក្រុងនោះឡើយ។ ប្រសិនបើក្រុមហ៊ុននោះធ្វើនូវសកម្មភាពណាមួយដែលផ្សេងពីអ្វីដែលបានស្នើសុំទៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជានោះនឹងអាចទទួលរងនូវការផាកពិន័យ ឬបញ្ឈប់នូវសកម្មភាពអាជីវកម្មរបស់ក្រុមហ៊ុនវិនិយោគនោះស្របតាមនីតិវិធីនៃច្បាប់វិនិយោគ ឬច្បាប់ផ្សេងៗទៀតដែលពាក់ព័ន្ធ។ ការដកហូត ឬការលុបចោល វិញ្ញាបនបត្រចុះ

បញ្ជីជាស្ថាពរនោះត្រូវកំណត់ដោយអនុក្រឹត្យ ស្តីពីការអនុវត្តច្បាប់វិសោធនកម្មច្បាប់វិនិយោគនៃព្រះរាជាណាចក្រកម្ពុជាដូចតទៅ៖វិញ្ញាបនបត្រចុះបញ្ជីជាស្ថាពរត្រូវដកហូតវិញ ប្រសិនបើអ្នកវិនិយោគទទួលបាននូវវិញ្ញាបនបត្រចុះបញ្ជីជាស្ថាពរ ឬវិញ្ញាបនបត្របញ្ជាក់ពីការបាននូវកាតព្វកិច្ចតាមរយៈឯកសារក្លែងបន្លំ ឬមិនត្រឹមត្រូវនោះ ចាប់ពីថ្ងៃចេញជូនដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ឬអនុគណៈកម្មាធិការ វិនិយោគខេត្ត-ក្រុង និងមិនបានធ្វើសកម្មភាពក្នុងរយៈពេល០៦(ប្រាំមួយ)ខែក្រោយពីបានទទួលបានវិញ្ញាបនបត្រចុះបញ្ជីជាស្ថាពរ លើកលែងតែករណីកិច្ចសន្យាសម្បទានដែលរយៈពេលទាំងអស់នឹងកំណត់ជាក់ស្តែងតាមការព្រមព្រៀងគ្នាក្នុងកិច្ចសន្យា។

ប្រសិនបើក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ឬអនុគណៈកម្មាធិការវិនិយោគខេត្ត-ក្រុង ដកហូតវិញនូវវិញ្ញាបនបត្រចុះបញ្ជីជាស្ថាពរ ដោយអនុលោមតាមអនុក្រឹត្យលេខ១១១ ខាងលើនេះ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ឬអនុគណៈកម្មាធិការវិនិយោគខេត្ត-ក្រុង ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរស្តីពីការដកហូតនេះជូនទៅអ្នកវិនិយោគទុន។ អ្នកវិនិយោគដែលវិញ្ញាបនបត្រចុះបញ្ជីជាស្ថាពររបស់ខ្លួនត្រូវបានដកហូតដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ឬអនុគណៈកម្មាធិការវិនិយោគខេត្ត-ក្រុងនោះ អាចធ្វើការតវ៉ាជាលាយលក្ខណ៍អក្សរទៅសហប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាក្នុងរយៈពេល២០(ម្ភៃ)ថ្ងៃ នៃថ្ងៃធ្វើការ ចាប់ពីទទួលបានការជូនដំណឹងជាលាយលក្ខណ៍អក្សរពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ឬអនុគណៈកម្មាធិការវិនិយោគខេត្ត-ក្រុង តាមកថាខណ្ឌទី២ខាងលើ។ គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដែលវិញ្ញាបនបត្រចុះបញ្ជីជាស្ថាពររបស់ខ្លួនត្រូវបានដកហូត ឬលុបចោល មិនមានសិទ្ធិទាមទារការលើកទឹកចិត្តពីការវិនិយោគណាមួយដែលមានចែងក្នុងវិញ្ញាបនបត្រចុះបញ្ជីជាស្ថាពរនោះទេ គិតចាប់ពីថ្ងៃបរិច្ឆេទដកហូត ឬលុបចោលនោះមក។

**១.៣. ការចេញវិញ្ញាបនបត្រចុះបញ្ជីជាស្ថាពរ**

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ឬអនុគណៈកម្មាធិការវិនិយោគខេត្ត-ក្រុង ត្រូវសុំការយល់ព្រមការអនុញ្ញាតផ្សេងៗដូចជា៖ នៅពេលដែលក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ឬអនុគណៈកម្មាធិការវិនិយោគខេត្ត-ក្រុង ចេញវិញ្ញាបនបត្រចុះបញ្ជីមានលក្ខខណ្ឌដោយអនុលោមតាមចំណុច៦.៣ នៃអនុក្រឹត្យស្តីពីការអនុវត្តច្បាប់វិសោធនកម្មច្បាប់វិនិយោគនៃព្រះរាជាណាចក្រកម្ពុជារួចហើយ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ឬអនុគណៈកម្មាធិការវិនិយោគខេត្ត-ក្រុង ត្រូវទទួលយកជំនួសមុខឲ្យអ្នកដាក់ពាក្យសុំនូវការយល់ព្រម ការអនុញ្ញាត អាជ្ញាប័ណ្ណ លិខិតអនុញ្ញាត ឬបញ្ជីការនានា ដែលមានចែងនៅក្នុងចំណុច៦.១ (ក) នៃអនុក្រឹត្យខាងលើ ពីក្រសួង នាយកដ្ឋាន មន្ទីរនានាចំណុះខេត្ត-ក្រុង ឬភ្នាក់ងារដែលមានការពាក់ព័ន្ធផ្សេងៗរបស់រាជរដ្ឋាភិបាល។ អ្នកវិនិយោគមិនត្រូវបានកំណត់

អោយបង់ប្រាក់កក់ សម្រាប់ធានាការវិនិយោគឡើយ លើកលែងតែក្នុងករណីសម្បទានលើវិស័យហេដ្ឋារចនាសម្ព័ន្ធដែលកិច្ចសន្យាសម្បទាននោះបានតម្រូវឲ្យបង់ប្រាក់កក់ ប្រសិនបើអ្នកវិនិយោគមានវិញ្ញាបនបត្រចុះបញ្ជីមានលក្ខខណ្ឌទទួលបាននូវរាល់ការយល់ព្រម ការអនុញ្ញាត អាជ្ញាប័ណ្ណ លិខិតអនុញ្ញាត ឬបញ្ជីការនានាដែលមានចែងក្នុងចំណុច៦.៣ (ក) នៃអនុក្រឹត្យខាងលើ រួចហើយនោះ។ ប៉ុន្តែប្រសិនបើក្នុងករណីដែលអ្នកវិនិយោគទុន មានវិញ្ញាបនបត្រចុះបញ្ជីមានលក្ខខណ្ឌតែមិនបានទទួលនូវរាល់ការយល់ព្រម ការអនុញ្ញាត អាជ្ញាប័ណ្ណ លិខិតអនុញ្ញាត ឬបញ្ជីការនានាដែលមានចែងនៅក្នុងចំណុច៦.៣ ក្នុងរយៈពេល២៨(ម្ភៃប្រាំបី)ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីចេញវិញ្ញាបនបត្រចុះបញ្ជីមានលក្ខខណ្ឌនោះមក ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ឬអនុគណៈកម្មាធិការវិនិយោគខេត្ត-ក្រុង ត្រូវចេញវិញ្ញាបនបត្រចុះបញ្ជីជាស្ថាពរឲ្យអ្នកវិនិយោគទុននោះ។ ការចេញវិញ្ញាបនបត្រចុះបញ្ជីជាស្ថាពរ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ឬអនុគណៈកម្មាធិការវិនិយោគខេត្ត-ក្រុង ដែលអនុលោមតាមចំណុច ៧.៥ នៃអនុក្រឹត្យខាងលើនោះ មិនមែនជាការលើកលែងអោយអ្នកដាក់ពាក្យសុំរួចផុតពីកាតព្វកិច្ច ដែលត្រូវទទួលបាននូវការយល់ព្រម ការអនុញ្ញាត អាជ្ញាប័ណ្ណ លិខិតអនុញ្ញាត ឬបញ្ជីការនានានោះទេ គឺដើម្បីអោយគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដំណើរការបានងាយស្រួលតែប៉ុណ្ណោះ។ គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ចាប់ផ្តើមនៅថ្ងៃចេញវិញ្ញាបនបត្រចុះបញ្ជីជាស្ថាពរសម្រាប់គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់នោះ ហើយចាប់ផ្តើមរយៈពេលគន្លឹះសម្រាប់ការគណនារយៈពេលលើកលែងពន្ធលើប្រាក់ចំណេញ តាមមាត្រា១៤ ចំណុច១៤.១ នៃច្បាប់វិនិយោគ និងកថាខណ្ឌទី១៥.១ នៃអនុក្រឹត្យលេខ១១១តែម្តង។ គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ត្រូវដាក់ពាក្យស្នើសុំសម្រេចជាលាយលក្ខណ៍អក្សរជូនក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ឬអនុគណៈកម្មាធិការវិនិយោគខេត្ត-ក្រុង តាមនីតិវិធីដើម្បីទទួលបាននូវការយល់ព្រមលើការប្តូរប្រាក់ អាសយដ្ឋាន ទីស្នាក់ការ ការប្តូរទីតាំងអាជីវកម្ម ការប្តូរនាមករណ៍ ការប្តូរភាគហ៊ុន ឬការផ្លាស់ប្តូរលម្អិតផ្សេងៗទៀត ដែលមានចែងនៅក្នុងសំណើវិនិយោគ និងក្នុងលក្ខន្តិកៈរបស់អ្នកវិនិយោគក្នុងរយៈពេលមុនធ្វើការប្តូរ១០(ដប់) ថ្ងៃនៃថ្ងៃធ្វើការដើម្បីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ឬអនុគណៈកម្មាធិការវិនិយោគខេត្ត-ក្រុង សម្រេចជូនយ៉ាងយូរក្នុងរយៈពេល ១០(ដប់)ថ្ងៃនៃថ្ងៃធ្វើការ[11]។

[11] មាត្រា៧ នៃអនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីវិសោធនកម្មច្បាប់វិនិយោគនៃព្រះរាជាណាចក្រកម្ពុជា។

## ២. ស្ថាប័នទទួលបន្ទុកកិច្ចការវិនិយោគ

ស្ថាប័នដែលមានសមត្ថកិច្ចទទួលបន្ទុកកិច្ចការវិនិយោគទាំងឡាយ នៅក្នុងព្រះរាជាណាចក្រកម្ពុជា មានពីរស្ថាប័នគឺ៖ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC) និង អនុគណៈកម្មាធិការវិនិយោគកម្ពុជា ។

### ២.១. ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ត្រូវបានបង្កើតឡើងនៅខែសីហា ឆ្នាំ១៩៩៤ ។ វាជាអង្គការមានសមត្ថកិច្ច និងជាច្រកចេញចូលតែមួយគត់ក្នុងការទទួលបន្ទុកការងារនីតិសម្បទា អភិវឌ្ឍន៍ និងការវិនិយោគ។ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាជាសេនាធិការរបស់រាជរដ្ឋាភិបាលក្នុងការពិនិត្យ និងសម្រេចការងារនីតិសម្បទា និងអភិវឌ្ឍន៍ ការវិនិយោគនានា[12]។

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា មានគណៈកម្មាធិការ ២ សំរាប់ជំនួយការគឺ:

-គណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍ (DRDB)

-គណៈកម្មធិការវិនិយោគកម្ពុជា (CIB)[13]។

#### ២.១.១. សមាសភាពនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាហៅកាត់ថា ក.អ.ក មានសមាសភាពដូចតទៅ:

| | |
|---|---|
| ១-សម្តេចហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា | ប្រធាន |
| ២-ឯកឧត្តម អូន ព័នមុនីរ័ត្ន រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | អនុប្រធានទី១ |
| ៣-ឯកឧត្តម សុន ចាន់ថុល រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម | អនុប្រធាន |
| ៤-ឯកឧត្តម គង់ វិបុល រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | អនុប្រធាន |
| ៥-រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ឬតំណាង | សមាជិក |
| ៦-រដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង ឬតំណាង | សមាជិក |
| ៧-សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ឬតំណាង | សមាជិក |
| ៨-រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ឬតំណាង | សមាជិក |
| ៩-សហរដ្ឋមន្ត្រីក្រសួងការពារជាតិ ឬតំណាង | សមាជិក |

[12] មាត្រា ៣ នៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៤។

[13] មាត្រា ៤ នៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៤។

១០-រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ឬតំណាង សមាជិក
១១-រដ្ឋមន្ត្រីក្រសួងពត៌មាន ឬតំណាង សមាជិក
១២-រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ ឬតំណាង សមាជិក
១៣-រដ្ឋមន្ត្រីក្រសួងសុខាភិបាល ឬតំណាង សមាជិក
១៤-រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ឬតំណាង សមាជិក
១៥-រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ឬតំណាង សមាជិក
១៦-រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧត្តុនិយម ឬតំណាង សមាជិក
១៧-រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ឬតំណាង សមាជិក
១៨-រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ
និងយុវនីតិសម្បទា ឬតំណាង សមាជិក
១៩-រដ្ឋមន្ត្រីក្រសួងកិច្ចការនារី និងអតីតយុទ្ធជន ឬតំណាង សមាជិក
២០-រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ឬតំណាង សមាជិក
២១-រដ្ឋមន្ត្រីក្រសួងផែនការ ឬតំណាង សមាជិក
២២-រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឬតំណាង សមាជិក
២៣-រដ្ឋមន្ត្រីក្រសួងបរិស្ថាន ឬតំណាង សមាជិក
២៤-រដ្ឋមន្ត្រីក្រសួងសាធារណៈការ និងដឹកជញ្ជូន ឬតំណាង សមាជិក
២៥-រដ្ឋមន្ត្រីក្រសួងទេសចរណ៍ ឬតំណាង សមាជិក
២៦-រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ឬតំណាង សមាជិក
២៧-រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច
ឬតំណាង សមាជិក
២៨-រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា ឬតំណាង សមាជិក
២៩-អគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា ឬតំណាង សមាជិក
៣០-រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ឬតំណាង សមាជិក
៣១-រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល ឬតំណាង សមាជិក
៣២-អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ ឬតំណាង សមាជិក
៣៣-អគ្គនាយកនគរបាលជាតិ ឬតំណាង សមាជិក
៣៤-មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស ឬតំណាង សមាជិក

៣៥-អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា សមាជិក

៣៦-អគ្គលេខាធិការគណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍ សមាជិក

៣៧-អគ្គលេខាធិការគណៈកម្មាធិការវិនិយោគកម្ពុជា សមាជិក

៣៨-អភិបាលខេត្ត-រាជធានី ឬតំណាង សមាជិក

៣៩-ប្រធានសភាពាណិជ្ជកម្មរាជធានីភ្នំពេញ ឬតំណាង សមាជិក

**២.១.២. រចនាសម្ព័ន្ធរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា**

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាមានរចនាសម្ព័ន្ធដូចតទៅ:

-គណៈកម្មាធិការ នីតិសម្បទា និងអភិវឌ្ឍន៍ ហៅកាត់ថា "គ.ជ.នា" ដែលស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់របស់អគ្គលេខាធិការមួយរូប។

-គណៈកម្មាធិការវិនិយោគកម្ពុជា ហៅកាត់ "គ.វ.ក" ដែលស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់របស់អគ្គលេខាមួយរូប។

-អគ្គលេខាធិការដ្ឋាននៃ "ក.អ.ក" ដែលស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់របស់អគ្គលេខាធិការ"ក.អ.ក"។ អគ្គលេខាធិការដ្ឋាននេះរួមមាន"ផ្នែកគាំទ្រ"ចំនួន៤ ៖

- ផ្នែកនីតិកម្ម និងដោះស្រាយវិវាទ
- ផ្នែកហិរញ្ញវត្ថុ និងរដ្ឋបាល
- ផ្នែកគ្រប់គ្រងមន្ត្រី និងបុគ្គលិក
- ផ្នែកផែនការនីយកម្មយុទ្ធសាស្ត្រ[14]។

អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា អគ្គលេខាធិការគណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍ និងអគ្គលេខាធិការគណៈកម្មាធិការវិនិយោគកម្ពុជាមានអគ្គលេខាធិការរងមួយរូបរៀងខ្លួនសំរាប់ជាជំនួយការក្នុងការងារ។ អគ្គលេខាធិការរងនីមួយៗបំពេញកិច្ចការតាមភារកិច្ច ដែលអគ្គលេខាធិការប្រគល់អោយ ក្រោយពីបានពិភាក្សាឯកភាពជាមួយគណៈកម្មាធិការប្រតិបត្តិនៃ"ក.អ.ក"។ អគ្គលេខាធិការមួយរូបៗត្រូវបំពេញការងារដោយផ្លាស់ប្តូរយោបល់ជាប្រចាំជាមួយអគ្គលេខាធិការរងរបស់ខ្លួន[15]។

ដោយឡែកគណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា(CRDB) មិនទាក់ទិនច្រើនទៅនឹង

[14] មាត្រា ២ នៃអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ឆ្នាំ២០០១។

[15] មាត្រា ៣ នៃអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ឆ្នាំ២០០១។

វិនិយោគឯកជន ខ្ញុំនឹងមិនលើកយកមកនិយាយអោយបានច្រើនទេ។

### ២.១.៣. សមត្ថកិច្ចនិង តួនាទីរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

#### ២.១.៣.១. សមត្ថកិច្ច និងភារកិច្ច

**ក. សមត្ថកិច្ច:**

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា គឺជាស្ថាប័នប្រតិបត្តិរបស់រាជរដ្ឋាភិបាល ហើយមានសមត្ថកិច្ចដូចតទៅ៖

-ជាសេនាធិការ និងជា "ច្រកចេញចូលតែមួយ" របស់រាជរដ្ឋាភិបាលក្នុងការទទួលបន្ទុកកិច្ចការ នីតិសម្បទា និងអភិវឌ្ឍន៍ និងវិនិយោគនានា។

-ធ្វើការដឹកនាំការងាររៀបចំទស្សនទាន និងយុទ្ធសាស្ត្រអភិវឌ្ឍន៍សម្រាប់ប្រទេសកម្ពុជា ដោយសហការជាមួយបណ្តាស្ថាប័នពាក់ព័ន្ធ។

-ធ្វើការទាក់ទងជាមួយប្រទេស ក៏ដូចជាអង្គការអន្តរជាតិពហុជាតិ/ទ្វេភាគី និងអង្គការក្រៅរដ្ឋាភិបាលទាំងអស់ ដើម្បីធ្វើអោយគេមានការយល់ដឹង និងមានការជ្រួតជ្រាបអំពីទស្សនទានយុទ្ធសាស្ត្រសេដ្ឋកិច្ច និងបណ្តាអាទិភាពនៃកម្មវិធីជាតិសំរាប់នីតិសម្បទា និងអភិវឌ្ឍន៍ប្រទេស ដើម្បីជាការសម្របសម្រួលដល់ការទទួល និងការប្រើប្រាស់ជំនួយអន្តរជាតិអោយមានប្រសិទ្ធិភាពស្របតាមសេចក្តីត្រូវការ និងអាទិភាពរបស់ប្រទេសជាតិ។

-សម្របសម្រួលការងាររវាងបណ្តាក្រសួង និងស្ថាប័ននានាដែលមានការពាក់ព័ន្ធជាមួយនឹងប្រទេស និងអង្គការអន្តរជាតិអ្នកផ្តល់ជំនួយព្រមទាំងជាមួយអ្នកវិនិយោគ។

-តម្រង់ទិសក្នុងការបែងចែក និងការប្រើប្រាស់ធនធានសាធារណៈ និងធនធានឯកជនក្នុងកិច្ចការអភិវឌ្ឍប្រទេសកម្ពុជា។

-បង្កនូវលក្ខណៈងាយស្រួល និងសម្រួលកិច្ចការដល់អ្នកផ្តល់ជំនួយ និងដល់វិនិយោគិន

-ធ្វើការត្រួតពិនិត្យ និងធ្វើការសម្រេចរាល់កិច្ចការនីតិសម្បទា និងអភិវឌ្ឍន៍ និងការវិនិយោគនានា តាមរយៈយន្តការ "ច្រកចេញចូលតែមួយ" នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC)[16] ។

*ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ត្រូវសុំយោបល់សម្រេចពីគណៈរដ្ឋមន្ត្រីលើគម្រោងវិនិយោគទាំងឡាយដែលមានលក្ខណៈសម្បត្តិណាមួយដូចតទៅ:

[16] មាត្រា ៨ នៃអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ឆ្នាំ២០០១។

-ទំហំទុនវិនិយោគសរុបចាប់ពី ៥០លានដុល្លារអាមេរិកឡើងទៅ

-មានវេទយិតភាពខាងនយោបាយ

-ការរុករក និងការធ្វើអាជីវកម្មរ៉ែ និងធនធានធម្មជាតិ

-អាចបង្កគ្រោះថ្នាក់ដល់បរិស្ថាន

-គម្រោងយុទ្ធសាស្ត្ររយៈពេលវែង

-គម្រោង "សង់-អាជីវកម្ម-ផ្ទេរ" ហៅកាត់ "ស.អ.ផ" ឬ គម្រោង "សង់-កាន់កាប់-អាជីវកម្ម-ផ្ទេរ" ហៅកាត់ថា "ស.ក.អ.ផ" ឬគម្រោង"សង់-កាន់កាប់-អាជីវកម្ម" ហៅកាត់ថា "ស.ក.អ" ឬគម្រោង "សង់-ជួល- ផ្ទេរ" ហៅកាត់ថា "ស.ជ.ផ" [17]។

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា(CDC) ត្រូវតែទទួលខុសត្រូវចំពោះមុខគណៈរដ្ឋមន្ត្រីអំពីសកម្មភាពរបស់ខ្លួន។

**ខ. ភារកិច្ចៈ**

**ខ.១. ក្នុងកិច្ចការនីតិសម្បទា និងអភិវឌ្ឍន៍ CDC មានភារកិច្ចដូចតទៅៈ**

-រួមគ្នាជាមួយក្រសួង និងស្ថាប័នដែលពាក់ព័ន្ធក្នុងការរៀបចំទស្សនទានជាយុទ្ធសាស្ត្រសម្រាប់ នីតិសម្បទា និងអភិវឌ្ឍន៍ប្រទេស និងធ្វើការលើកឡើងនូវលំដាប់អាទិភាពនៃតម្រូវការរបស់ប្រទេសជាតិក្នុងពេលបច្ចុប្បន្នជាបន្ទាន់ និងសម្រាប់រយៈពេលខ្លី រយៈពេលមធ្យម និងរយៈពេលវែង ដើម្បីបង្កើតឡើងនូវកម្មវិធីការងាររំកិលតាមឆ្នាំ។ ការអនុវត្តនូវកម្មវិធីខាងលើត្រូវតែមានលក្ខណៈជាប្រព័ន្ធរលូន ប្រទាក់ក្រឡា និងស៊ីចង្វាក់គ្នា។

-រួមគ្នាជាមួយក្រសួងនិងស្ថាប័នដែលពាក់ព័ន្ធ ក្នុងការរៀបចំផែនការសេដ្ឋកិច្ច សង្គមកិច្ច និងផែនការតាមផ្នែកសម្រាប់អភិវឌ្ឍន៍កម្ពុជា។

-ធ្វើការគ្រប់គ្រងកិច្ចការវិនិយោគសាធារណៈ ដោយមានការសហការជាមួយនឹងក្រសួង និងស្ថាប័ពាក់ព័ន្ធអោយបានជិតស្និត។ ការងារនេះពាក់ព័ន្ធសំខាន់ទៅនឹងការសម្របសម្រួល និងការតម្រង់ទិសក្នុងការបែងចែក និងការប្រើប្រាស់ធនធាននៅក្នុងប្រទេស ក៏ដូចជាធនធានដែលបានមកពី ក្រៅប្រទេសដើម្បីកិច្ចការស្តារ និងអភិវឌ្ឍន៍ប្រទេសកម្ពុជា។

-ជា"ច្រកចេញចូលតែមួយ" ក្នុងការទាក់ទងរវាងរដ្ឋាភិបាល ជាមួយនឹងប្រទេស អង្គការអន្តរជាតិ អង្គការក្រៅរដ្ឋាភិបាល នានាដែលជាអ្នកផ្តល់ជំនួយដល់កម្ពុជា ហើយធ្វើជាចំណុចប្រមូលផ្តុំ និងជា "ច្រកចេញចូលតែមួយ" ក្នុងការទំនាក់ទំនងរវាងក្រសួង និងស្ថាប័ននានានៃរាជរដ្ឋាភិបាល

[17] មាត្រា ៩ នៃអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ឆ្នាំ២០០១។

ដើម្បីសម្របសម្រួលការទទួលជំនួយ និង/ឬការបែងចែកជំនួយ។

-តាមការប្រគល់សិទ្ធិពីនាយករដ្ឋមន្ត្រី ចុះហត្ថលេខាក្នុងនាមរាជរដ្ឋាភិបាលជាមួយនឹងអ្នកផ្តល់ជំនួយទ្វេភាគី ពហុភាគី និង/ឬអង្គការអន្តរជាតិនានាដើម្បីទទួលជំនួយ និង/ឬបែងចែកជំនួយ។

-សហការជាមួយក្រសួង និងស្ថាប័នដែលពាក់ព័ន្ធ ដឹកនាំការងារក្នុងការរៀបចំឯកសារចាំបាច់នានាសម្រាប់កិច្ចប្រជុំអន្តរជាតិ សម្រាប់ការកសាងប្រទេសកម្ពុជាឡើងវិញ ដូចជា"ក្រុមពិគ្រោះយោបល់សម្រាប់កម្ពុជា"ជាដើម។

-ធ្វើការរៀបចំ និងចងក្រងឯកសារ ក៏ដូចជាលិខិតបទដ្ឋាននានា ដែលទាក់ទងទៅនឹងកិច្ចការវិនិយោគសាធារណៈសម្រាប់ជាការផ្សព្វផ្សាយនៅក្នុងប្រទេស និងនៅក្រៅប្រទេស។

-ធ្វើរបាយការណ៍ប្រចាំឆមាស និងប្រចាំឆ្នាំសម្រាប់ដាក់ជូនរាជរដ្ឋាភិបាលដើម្បីអោយរាជរដ្ឋាភិបាល បានត្រួតពិនិត្យ និងលើកឡើងនូវវិធានការចាំបាច់សម្រាប់ជាការកែលម្អ និងតម្រង់ទិសការងារនីតិសម្បទា និងអភិវឌ្ឍន៍។

**ខ.២. ក្នុងកិច្ចការវិនិយោគឯកជន CDC មានភារកិច្ចដូចតទៅ:**

-បំពេញតួនាទីជាយន្តការ"*ច្រកចេញចូលតែមួយ*" និងជាសេនាធិការរបស់រាជរដ្ឋាភិបាលក្នុងការពិនិត្យ និងសម្រេចលើការវិនិយោគនានា ដូចបានកំណត់ក្នុងមាត្រា៣នៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា។ យោងតាមមាត្រា៣ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា(CDC) ជាអង្គការមានសមត្ថកិច្ច និងជាច្រកចេញចូលតែមួយគត់ក្នុងការទទួលបន្ទុកការងារនីតិសម្បទា អភិវឌ្ឍន៍និងការវិនិយោគ។ CDC ជាសេនាធិការរបស់រាជរដ្ឋាភិបាលក្នុងការពិនិត្យ និងសម្រេចការងារនីតិសម្បទា និងអភិវឌ្ឍន៍ និងការវិនិយោគនានា ។

-ធ្វើការវិភាគ "*ការប្រណាំងប្រជែងដណ្តើមឈ្នះ*" លើទីផ្សារអន្តរជាតិសំរាប់ប្រទេសកម្ពុជាលើកឡើងនូវទស្សនៈអនាគត អំពីកិច្ចការវិនិយោគឯកជនសម្រាប់ប្រទេសកម្ពុជា និងសម្រេចអោយបាននូវទស្សនៈនេះដោយធ្វើអោយប្រទេសកម្ពុជាក្លាយជា "**សាជីវកម្មកម្ពុជា**" ។ បន្ថែមពីនេះទៀតត្រូវមានការសហការជាមួយក្រសួង និងស្ថាប័នដែលពាក់ព័ន្ធក្នុងការរៀបចំយុទ្ធសាស្ត្រនៃការវិនិយោគឯកជន និងដើម្បីលើកគម្រោងនានាសម្រាប់ការវិនិយោគឯកជន។

-ធ្វើការផ្សព្វផ្សាយអំពីគម្រោងនានា សម្រាប់ការវិនិយោគឯកជនដែលរាជរដ្ឋាភិបាលបានលើកឡើង និងផ្តល់គម្រោងទាំងនោះទៅអោយអ្នកវិនិយោគតាមនីតិវិធីដែលមានចែងនៅក្នុងបទបញ្ញត្តិផ្ទៃក្នុងរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។

-សម្របសម្រួលការគ្រប់គ្រងគម្រោង"សង់-អាជីវកម្ម-ផ្ទេរ" ហៅកាត់ថា"ស.ក.អ.ផ" គម្រោង "សង់- កាន់កាប់-អាជីវកម្ម-ផ្ទេរ"ហៅកាត់ថា "ស.ក.អ.ផ" គម្រោង"សង់-កាន់កាប់-អាជីវកម្ម"ហៅកាត់ថា "ស.ក.អ" និងគម្រោង"សង់-ជួល-ផ្ទេរ" ហៅកាត់ថា "ស.ជ.ផ" ។

-ផ្តួចផ្តើម និងសម្របសម្រួលការគ្រប់គ្រងតំបន់អភិវឌ្ឍន៍ពិសេស ដែលជាអាទិភាពរបស់រាជរដ្ឋាភិបាល។

-លើកគម្រោង និងផ្តល់យោបល់ជូនរាជរដ្ឋាភិបាលស្តីពីការរៀបចំ និងកែលម្អច្បាប់ បទបញ្ញាត្តិ និងលិខិតបទដ្ឋានផ្សេងៗ ដែលទាក់ទិនទៅនឹងការវិនិយោគឯកជនក្នុងគោលបំណងបង្កើតលក្ខខណ្ឌដែលអនុគ្រោះ និងដែលលើកទឹកចិត្តដល់អ្នកវិនិយោគដើម្បីបង្កើនប្រសិទ្ធិភាពការងារក្នុងវិស័យឯកជន ។

-ធ្វើការចងក្រងឯកសារ និងលិខិតបទដ្ឋាននានា ដែលទាក់ទងទៅនឹងភារកិច្ចវិនិយោគឯកជនសម្រាប់ជាការផ្សព្វផ្សាយនៅក្នុងប្រទេស និងក្រៅប្រទេស។

-ធ្វើរបាយការណ៍ប្រចាំឆមាស និងប្រចាំឆ្នាំ ជូនរាជរដ្ឋាភិបាលដើម្បីពិនិត្យ និងលើកឡើងនូវវិធានការចាំបាច់សំរាប់កែលម្អ និងតម្រង់ទិសការងារវិនិយោគឯកជន។

**២.២. អនុគណៈកម្មាធិការវិនិយោគខេត្ត-ក្រុង**

អនុគណៈកម្មាធិការវិនិយោគខេត្ត-ក្រុង ត្រូវបានបង្កើតឡើងដោយអនុក្រឹត្យលេខ៣៣ អនក្រ.បក ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០០៥ ដែលត្រូវដំណើរការការងារទៅតាមនីតិវិធីនៃច្បាប់ និងបទបញ្ញាត្តិស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ក្នុងការចុះបញ្ជីសំណើវិនិយោគរបស់ក្រុមហ៊ុនថ្មីជាគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ចំពោះគម្រោងវិនិយោគដែលមានទុនវិនិយោគទាបជាង០២(ពីរ)លានដុល្លារអាមេរិក[18]។ ប៉ុន្តែចំពោះគម្រោងវិនិយោគដែលមានទុនវិនិយោគលើសពី០២(ពីរ)លានដុល្លារអាមេរិក ឬ គម្រោងវិនិយោគដែលមានទីតាំងស្ថិតនៅក្នុងសមត្ថកិច្ចគ្រប់គ្រងរបស់រាជធានី-ខេត្ត ចាប់ពីពីរឡើងទៅ ឬគម្រោងវិនិយោគដែលស្ថិតនៅក្នុងតំបន់សេដ្ឋកិច្ចពិសេសត្រូវស្ថិតនៅក្រោមសមត្ថកិច្ចរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាវិញ[19]។

**២.២.១. សមាសភាពនៃអនុគណៈកម្មាធិការរាជធានី-ខេត្ត**

អនុគណៈកម្មាធិការវិនិយោគរាជធានី-ខេត្ត ដែលមានសមត្ថកិច្ចទៅលើគម្រោងវិនិយោគ

[18] មាត្រា៣ នៃអនុក្រឹត្យស្តីពីការបង្កើតអនុគណៈកម្មាធិការវិនិយោគខេត្ត-ក្រុង ឆ្នាំ២០០៥។
[19] មាត្រា៦ នៃអនុក្រឹត្យស្តីពីការបង្កើតអនុគណៈកម្មាធិការវិនិយោគខេត្ត-ក្រុង ឆ្នាំ២០០៥។

ទាំងឡាយណា ដែលមានទុនវិនិយោគទាបជាង០២(ពីរ)លានដុល្លារអាមេរិកនេះ មានសមាសភាពដូចតទៅ៖

| | |
|---|---|
| ១-អភិបាលខេត្ត-ក្រុង | ប្រធាន |
| ២-តំណាងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា/គណៈកម្មាធិការវិនិយោគកម្ពុជា | អនុប្រធានអចិន្ត្រៃយ៍ |
| ៣-អភិបាលរងទី១រាជធានី-ខេត្ត | អនុប្រធាន |
| ៤-អភិបាលរងទី២រាជធានី-ខេត្ត | អនុប្រធាន |
| ៥-ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៦-ប្រធានមន្ទីរពាណិជ្ជកម្ម | សមាជិក |
| ៧-ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល | សមាជិក |
| ៨-ប្រធានមន្ទីរសាធារណៈការ និងដឹកជញ្ជូន | សមាជិក |
| ៩-ប្រធានមន្ទីរបរិស្ថាន | សមាជិក |
| ១០-ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ១១-ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| ១២-ប្រធានមន្ទីរផែនការ | សមាជិក |
| ១៣-ប្រធានមន្ទីរធនធានទឹក និងឧតុនិយម | សមាជិក |
| ១៤-ប្រធានមន្ទីរទេសចរណ៍ | សមាជិក |
| ១៥-ប្រធានមន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ | សមាជិក |
| ១៦-តំណាងសភាពាណិជ្ជកម្មខេត្ត-ក្រុង | សមាជិកសង្កេតការណ៍ |
| ១៧-តំណាងលេខាធិការដ្ឋាន | លេខាធិការ |

សមាសភាពដូចមានចែងខាងលើ ត្រូវអញ្ជើញចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន និង អនុប្រធានក្នុងករណីប្រធានអវត្តមាន។ ចំពោះគ្រប់មន្ទីរ-អង្គភាពពាក់ព័ន្ធ-អភិបាលស្រុកក្នុងខេត្ត-ក្រុង[20]។

[20] មាត្រា ១ នៃអនុក្រឹត្យស្តីពីការបង្កើតអនុគណៈកម្មាធិការវិនិយោគខេត្ត-ក្រុង។

**២.២.២. ភារកិច្ច**

អនុគណៈកម្មាធិការវិនិយោគខេត្ត-ក្រុង ត្រូវដំណើរការងារទៅតាមនីតិនៃច្បាប់ និងបទបញ្ញាត្តិនៃស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ក្នុងការចុះបញ្ជីសំណើវិនិយោគរបស់ក្រុមហ៊ុនថ្មីជាគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ចំពោះគម្រោងវិនិយោគដែលមានទុនវិនិយោគទាបជាង ០២(ពីរ)លានដុល្លារអាមេរិក[21]។

អនុគណៈកម្មាធិការវិនិយោគខេត្ត-ក្រុង ត្រូវមានលេខាធិការដ្ឋានមួយ សម្រាប់ដោះស្រាយការងារប្រចាំថ្ងៃរបស់ខ្លួន ដឹកនាំដោយអនុប្រធានអចិន្ត្រៃយ៍អនុគណៈកម្មាធិការវិនិយោគខេត្ត-ក្រុង។

អនុគណៈកម្មាធិការវិនិយោគខេត្ត-ក្រុង មានសិទ្ធិប្រើប្រាស់ជាផ្លូវការនូវត្រាដោយឡែកសម្រាប់កិច្ចដំណើរការរបស់ខ្លួន។

អនុគណៈកម្មាធិការវិនិយោគខេត្ត-ក្រុង ត្រូវផ្តល់ឯកសារពាក់ព័ន្ធនឹងគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ មកក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា/គណៈកម្មាធិការវិនិយោគកម្ពុជា បន្ទាប់ពីបានចុះបញ្ជីវិនិយោគរួចហើយ ដើម្បីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា/គណៈកម្មាធិការវិនិយោគកម្ពុជាមានមូលដ្ឋានក្នុងការពិនិត្យ និងការផ្តល់ការលើកទឹកចិត្តលើសំណើនាំចូលរបស់អ្នកវិនិយោគ។

នីតិវិធីនៃការចុះបញ្ជីសំណើវិនិយោគ និងផ្តល់ការលើកទឹកចិត្តសំណើវិនិយោគរបស់អនុគណៈកម្មាធិការវិនិយោគខេត្ត-ក្រុង គឺ៖

-ដើរតួជាយន្តការច្រកចេញ-ចូលតែមួយលើការវិនិយោគខេត្ត-ក្រុង

-ត្រូវអនុវត្តតាមនីតិវិធី ដោយផ្អែកលើច្បាប់-បទប្បញ្ញាត្តិស្តីពីវិនិយោគជាធរមាន ដូចដែលអនុវត្តនៅក្នុងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា/គណៈកម្មាធិការវិនិយោគកម្ពុជាដែរ។

អនុគណៈកម្មាធិការវិនិយោគខេត្ត-ក្រុង ត្រូវទទួលការបណ្តុះបណ្តាលមុខជំនាញ ពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា/គណកម្មាធិការវិនិយោគកម្ពុជា ដើម្បីធានាឲ្យដំណើរការនៃយន្តការនេះប្រព្រឹត្តទៅមានភាពរលូន និងមានប្រសិទ្ធិភាពខ្ពស់។ ជាមួយគ្នានេះអនុគណៈកម្មាធិការវិនិយោគខេត្ត-ក្រុង ត្រូវធ្វើរបាយការណ៍ជាប្រចាំខែ មកក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា/គណៈកម្មាធិការវិនិយោគកម្ពុជា ដើម្បីអោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា/គណៈកម្មាធិការវិនិយោគកម្ពុជា មានមូលដ្ឋានគ្រប់គ្រាន់សម្រាប់ធ្វើរបាយការណ៍ជូនរាជរដ្ឋាភិបាល។

[21] មាត្រា ៣ នៃអនុក្រឹត្យស្តីពីការបង្កើតអនុគណៈកម្មាធិការវិនិយោគខេត្ត-ក្រុង។

## ៣. នីតិវិធីដោះស្រាយវិវាទវិនិយោគ

ប្រសិនបើការដោះស្រាយវិវាទដែលបានកើតឡើងក្នុងការវិនិយោគពុំទទួលបានលទ្ធផលល្អ ក្រុមហ៊ុនវិនិយោគដែលមានវិវាទកើតឡើងអាចឈានទៅដល់ការរំលាយក្រុមហ៊ុនវិនិយោគ។ ប្រសិនបើវិនិយោគិន មានបំណងបញ្ចប់សកម្មភាពវិនិយោគរបស់ខ្លួននៅព្រះរាជាណាចក្រកម្ពុជា អ្នកវិនិយោគត្រូវជូនពតិមានទៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា តាមរយៈលិខិតអនុសិដ្ឋ ឬលិខិតប្រគល់ផ្ទាល់ដៃ ដោយមានបញ្ជាក់អំពីមូលហេតុនៃការបញ្ចប់សកម្មភាពនោះ និងចុះហត្ថលេខាដោយអ្នកវិនិយោគ ឬមេធាវីតំណាងផ្ទាល់របស់ខ្លួន[22]។ វិវាទដែលទាក់ទងទៅនឹងគម្រោងមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ពាក់ព័ន្ធទៅនឹងសិទ្ធិ និងកាតព្វកិច្ចដែលមានចែងនៅក្នុងច្បាប់ស្តីវិសោធនកម្មនៃច្បាប់វិនិយោគនៃព្រះរាជាណាចក្រ កម្ពុជា លើកលែងតែករណីដែលទាក់ទងនឹងវិវាទដីធ្លី។ ភាគីនៃវិវាទមានសិទ្ធិស្នើសុំធ្វើការផ្សះផ្សា សម្របសម្រួលនៅចំពោះមុខក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា **(៣.១)** ស្នើសុំធ្វើការដោះស្រាយមជ្ឈត្តកម្ម **(៣.២)** និងស្នើសុំធ្វើការដោះស្រាយតាមផ្លូវតុលាការ កម្ពុជា **(៣.៣)** ។

### ៣.១. ការសម្របសម្រួលរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

វិនិយោគិន ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ នៅពេលដែលមានវិវាទកើតឡើងទាក់ទងនឹងសិទ្ធិ និងកាតព្វកិច្ច មានសិទ្ធិស្នើសុំទៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដើម្បីធ្វើការផ្សះផ្សាសម្របសម្រួលនៅចំពោះមុខក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។ យ៉ាងណាមិញ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាធ្វើការផ្សះផ្សាតែទៅលើវិវាទទាំងឡាយ ដែលទាក់ទងទៅនឹងការវិនិយោគ ដែលបានធ្វើឡើងដោយអ្នកវិនិយោគទុន តាមនីតិវិធីនៃច្បាប់ស្តីវិសោធនកម្មនៃច្បាប់វិនិយោគព្រះរាជាណាចក្រកម្ពុជា។ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាធ្វើការដោះស្រាយ ដោយសម្រុះសម្រួលដែលអាចធ្វើទៅបានតាមរយៈការពិគ្រោះយោបល់គ្នារវាងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា អ្នកវិនិយោគ និងភាគីណាមួយផ្សេងទៀតដែលពាក់ព័ន្ធក្នុងវិវាទ។ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងក្រសួងការងារ រួមគ្នាបង្កើតជាគណៈកម្មាធិការមួយសម្រាប់ធ្វើការដោះស្រាយ ផ្សះផ្សា សម្រុះសម្រួលទៅលើវិវាទដែលបានស្នើឡើងដោយអ្នកវិនិយោគ ប៉ុន្តែមុននឹងធ្វើការដោះស្រាយទៅលើវិវាទទាំងនោះចាំបាច់ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាត្រូវតែធ្វើការសិក្សាស៊ើបអង្កេតទៅលើបញ្ហានៃវិវាទដែលកើតមានឡើងនោះ ដើម្បីរកអោយឃើញពីមូលហេតុដែលបង្កើតអោយមានជម្លោះជាគោលសម្រាប់ធ្វើការផ្សះផ្សា សម្រុះសម្រួលទៅលើវិវាទ និងដើម្បីរកអោយឃើញពីកំហុសដែលកើតមានឡើង ហើយភាគីណាមួយជាអ្នកមានកំហុស

[22] មាត្រា ២១ថ្មី នៃច្បាប់ស្តីពីវិសោធនកម្ម ច្បាប់វិនិយោគ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី២៤ ខែមិនា ឆ្នាំ២០០៣។

នៅក្នុងវិវាទនេះ។ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា មានសិទ្ធិត្រឹមតែធ្វើការផ្សះផ្សាទៅលើវិវាទតែប៉ុណ្ណោះ គ្មានសិទ្ធិសម្រេច អោយភាគីមួយឈ្នះលើភាគីមួយទៀតឡើយ ជារួមគ្រាន់តែធ្វើអោយភាគីជម្លោះត្រូវរ៉ូវគ្នាវិញ ហើយធ្វើការវិនិយោគជាមួយគ្នាបន្តទៅមុខទៀត។ ក្នុងរយៈពេល ០២(ពីរ) ខែបន្ទាប់ពីការបរិច្ឆេទនៃសំណើជាលាយលក្ខណ៍អក្សរ ដំបូងដែលស្នើសុំការពិគ្រោះគ្នានេះ ប្រសិនបើភាគីមានវិវាទពុំអាចដោះស្រាយតាមការសម្រុះសម្រួលគ្នាទេ ភាគីណាមួយអាចលើកយកវិវាទនោះទៅសុំធ្វើការដោះស្រាយដោយមជ្ឈត្តកម្មបាន[23]។

**៣.២. ការដោះស្រាយដោយមជ្ឈត្តកម្ម**

មជ្ឈត្តករជាអ្នកអនុវត្តច្បាប់ អ្នកអព្យាក្រឹត្យ ហើយរាល់សេចក្តីសម្រេចត្រូវតែគោរពតាម។ ការដោះស្រាយដោយមជ្ឈត្តកម្មគឺមានភាពល្អប្រសើរសម្រាប់ភាគីវិវាទ ដោយសារតែភាគីជម្លោះយល់ឃើញថាវិធីនេះចំណាយសោហ៊ុយអស់តិច មានភាពងាយស្រួលជាងការដោះស្រាយ តាមប្រព័ន្ធតុលាការ ហើយភាគីវិវាទសុទ្ធតែជាអ្នកមានសិទ្ធិក្នុងការជ្រើសរើសប្រព័ន្ធនៃការដោះស្រាយជំលោះរបស់ខ្លួន។

វិនិយោគិនទាំងអស់អាចជ្រើសរើសយកការដោះស្រាយវិវាទរបស់ខ្លួនតាមរយៈមជ្ឈត្តការផ្នែកពាណិជ្ជកម្ម។ ការដោះស្រាយវិវាទតាមរយៈមជ្ឈត្តការផ្នែកពាណិជ្ជកម្ម បានផ្តល់នូវផលប្រយោជន៍ជាច្រើនដល់អ្នកវិនិយោគដែលធ្វើការវិនិយោគនៅកម្ពុជា។ ការដោះស្រាយជម្លោះពាណិជ្ជកម្មតាមរយៈមជ្ឈត្តការពាណិជ្ជកម្ម អាចដោះស្រាយតាមរយៈការផ្សះផ្សា និងការរៀបចំវេទិកាមជ្ឈត្តកម្មនៃវិវាទពាណិជ្ជកម្ម តាមសំណើរបស់គូភាគីជម្លោះ និងណែនាំអំពីនីតិវិធីនៃការផ្សះផ្សា។ ក្នុងការដោះស្រាយភាគីវិវាទមានសិទ្ធិកំណត់ចំនួនមជ្ឈត្តករ។ មជ្ឈត្តករចាំបាច់ត្រូវតែមានចំនួនសេស អាច០១(មួយ)រូប ឬ០៣(បី)រូប។ ក្នុងករណីដែលមានមជ្ឈត្តករតែមួយរូប ចាំបាច់ត្រូវតែមានសញ្ជាតិផ្សេងពីគូវិវាទ ប៉ុន្តែក្នុងករណីដែលមានមជ្ឈត្តករ០៣(បី)រូប ភាគីជម្លោះម្នាក់ៗត្រូវធ្វើការជ្រើសរើសមជ្ឈត្តករម្នាក់មួយរូប ហើយមជ្ឈត្តករទាំងពីររូបនេះធ្វើការជ្រើសរើសមជ្ឈត្តករទី៣។ ប្រសិនបើភាគីណាមួយ ពុំបានជ្រើសរើសមជ្ឈត្តករក្នុងរយៈពេល៣០(សាមសិប)ថ្ងៃ ក្រោយពេលទទួលសំណើជ្រើសតាំងពីភាគីម្ខាងទៀត ឬប្រសិនបើមជ្ឈត្តករទាំង០២(ពីរ) រូប ពុំបានព្រមព្រៀងលើការតែងតាំងមជ្ឈត្តករទី៣រយៈពេល៣០(សាមសិប)ថ្ងៃ ក្រោយពីត្រូវបានគេជ្រើសតាំងរួចមកតុលាការ (តុលាការពាណិជ្ជកម្ម ឬ សាលាឧទ្ធរណ៍ ឬតុលាការកំពូល) ឬមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ដូចមានចែងនៅក្នុងមាត្រា៦នៃច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ត្រូវជ្រើស

[23] ច្បាប់ស្តីពីវិសោធនកម្ម ច្បាប់វិនិយោគ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី២៤ ខែមិនា ឆ្នាំ២០០៣។

រើសមជ្ឈត្តករទី៣តាមការស្នើសុំនៃភាគីវិវាទណាមួយ[24]។ នៅក្រោយពេលជ្រើសតាំងរួចរាល់ហើយ ដំណើរការមជ្ឈត្តករចាប់ផ្តើមដំណើរការនៅក្នុងដំណើរការនីតិវិធីនេះ គូវិវាទមានសិទ្ធិក្នុងការបង្ហាញនូវរាល់ភស្តុតាងទាំងអស់នៅមជ្ឈត្តវិនិច្ឆ័យ និងមានសិទ្ធិជ្រើសរើសយកភាសាមកប្រើប្រាស់ ប្រសិនបើមានការព្រមព្រៀងពីគូវិវាទ។ ក្នុងករណីគ្មានការឯកភាពលើភាសាទេ វេទិកាមជ្ឈត្តកម្មត្រូវកំណត់ភាសាណាមួយ ឬលើសពីមួយដែលត្រូវប្រើប្រាស់ក្នុងដំណើរការមជ្ឈត្តការ[25] ។ វេទិការមជ្ឈត្តកម្មអាចបង្គាប់អោយមានការបកប្រែភ្ជាប់ជាមួយនឹងឯកសារ ភស្តុតាងដោយប្រើប្រាស់ភាសាណាមួយ ឬលើសពីមួយ ដែលបានឯកភាពដោយភាគីវិវាទ ឬដែលបានកំណត់ដោយវេទិការមជ្ឈត្តកម្ម។ មជ្ឈត្តវិនិច្ឆ័យត្រូវសម្រេចពីវិវាទទៅតាមវិធាននៃច្បាប់ដែលប្រើប្រាស់ដោយគូវិវាទ និងដែលត្រូវបានអនុវត្តចំពោះកម្មវត្ថុនៃវិវាទនេះ។ ក្នុងករណីដែលមានការកំណត់យកច្បាប់ ឬប្រព័ន្ធច្បាប់នៃប្រទេសណាមួយដែលត្រូវយកទៅបកស្រាយ គឺមិនត្រូវបកស្រាយដោយសម្អាងលើភាពផ្ទុយគ្នានៃច្បាប់ ឬវិធាននៃច្បាប់នោះឡើយ វៀរលែងតែមានការបញ្ជាក់ផ្សេងពីនេះ។ ការប្រើប្រាស់ច្បាប់ណាដែលយល់ថាអាចអនុវត្តបាន ក្នុងករណីដែលភាគីវិវាទមិនបានធ្វើការកំណត់លើប្រព័ន្ធច្បាប់ទេនោះ។ ក្នុងការធ្វើមជ្ឈត្តកម្មគេត្រូវធ្វើមជ្ឈត្តវិនិច្ឆ័យស្របតាមសមធម៌ ឬតាមការស្រុះស្រួល តែក្នុងករណីដែលភាគីវិវាទអនុញ្ញាតច្បាស់លាស់អោយធ្វើដូច្នេះ មិនអោយស្របតាមលក្ខខណ្ឌកិច្ចសន្យា និងត្រូវយកចិត្តទុកដាក់ផងដែរ ដល់ទម្លាប់ពាណិជ្ជកម្មដែលអនុវត្តន៍បានចំពោះមុខជំនាញនោះ[26]។ ភាគីវិវាទអាចធ្វើការប្តឹងទាស់ទៅនឹងមជ្ឈត្តវិនិច្ឆ័យតាមទ្រង់ទ្រាយជាការប្តឹងបដិសេធ និងតាមបែបបទអនុលោមទៅនឹងមាត្រា៥៤នៃច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម។ ក្រៅពីការដោះស្រាយវិវាទដោយមជ្ឈត្តកម្ម ភាគីវិវាទក៏អាចធ្វើការដោះស្រាយវិវាទតាមរយៈប្រព័ន្ធតុលាការបានដែរ។

### ៣.៣. ការដោះស្រាយតាមផ្លូវតុលាការកម្ពុជា

ការដោះស្រាយជម្លោះតាមផ្លូវតុលាការជាវិធីសាស្ត្រចុងក្រោយដែលភាគីវិវាទមានសិទ្ធិគ្រប់គ្រាន់ក្នុងការដោះស្រាយវិវាទរបស់ខ្លួនដែលទាក់ទងនឹងពាណិជ្ជកម្ម ដោយអនុវត្តទៅតាមនីតិវិធីដែលបានអនុវត្តកន្លងមកនៅកម្ពុជា។ អនុលោមតាមរដ្ឋធម្មនុញ្ញ ឆ្នាំ១៩៩៣ បានកំណត់ថា អំណាច

[24] មាត្រា ១៩ នៃច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្មឆ្នាំ២០០៦។
[25] មាត្រា ៣០ នៃច្បាប់ស្តីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ឆ្នាំ២០០៦។
[26] មាត្រា ៣០ នៃច្បាប់ស្តីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ឆ្នាំ២០០៦។

តុលាការគ្របដណ្តប់លើគ្រប់រឿងក្តីទាំងអស់រួមទាំងរឿងរដ្ឋបាលផងដែរ[27]។ ក្នុងន័យនេះតុលាការកម្ពុជាមានសមត្ថកិច្ចទៅលើគ្រប់រឿងក្តីទាំងអស់ដែលកើតមានឡើង មិនថារឿងក្តីនោះពាក់ព័ន្ធនឹងពាណិជ្ជកម្ម ការងារ ឬ វិវាទរដ្ឋបាលអ្វីឡើយ ចាំបាច់ត្រូវតែស្ថិតនៅក្រោមសមត្ថកិច្ចនៃតុលាការនៃនីតិរួមទាំងអស់។ ការដោះស្រាយតាមផ្លូវតុលាការ ជានីតិវិធីដោះស្រាយមួយដែលវិវាទពាក់ព័ន្ធនឹងរឿងក្តីពាណិជ្ជកម្ម គេមិនសូវធ្វើការ ដោះស្រាយ វិវាទដែលពាក់ព័ន្ធនឹងរឿងពាណិជ្ជកម្មភាគច្រើនគេធ្វើការដោះស្រាយដោយមជ្ឈត្តការផ្នែកពាណិជ្ជកម្ម។ ប៉ុន្តែក្រោយពេលដែលកម្ពុជាបង្កើតតុលាការពាណិជ្ជកម្ម គ្រប់រឿងក្តីទាំងអស់ដែលពាក់ព័ន្ធនឹងរឿងពាណិជ្ជកម្មត្រូវស្ថិតនៅក្រោមសមត្ថកិច្ចរបស់តុលាការពាណិជ្ជកម្ម តែគូវិវាទមានសិទ្ធិ ក្នុងការជ្រើសរើសយករបៀបដោះស្រាយណាមួយដែលបានព្រមព្រៀងគ្នា ការដោះស្រាយតាមផ្លូវតុលាការត្រូវតែគោរពទៅតាមនីតិវិធីដែលបានកំណត់នៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦។ជាពិសេសរបៀបដាក់ពាក្យបណ្តឹង និងចំណុចដែលត្រូវសរសេរក្នុងពាក្យបណ្តឹង[28]។

ការដោះស្រាយតាមផ្លូវតុលាការចាំបាច់ដំណាក់កាលនៃការផ្សះផ្សាត្រូវធ្វើឡើងជាចាំបាច់ដែលការផ្សះផ្សានោះ ត្រូវតែមានភ្ជាប់មកជាមួយនឹងកំណត់ហេតុជាលាយលក្ខណ៍អក្សរអំពីការផ្សះផ្សានោះ ទោះបីជាការផ្សះផ្សានោះទទួលបានជោគជ័យ ឬបរាជ័យក៏ដោយ។ ប្រសិនបើការផ្សះផ្សាមានការបរាជ័យ តុលាការត្រូវធ្វើការរៀបចំសំណុំរឿងក្តីនោះដើម្បីធ្វើការស៊ើបអង្កេត។ ក្នុងដំណាក់កាលនៃការស៊ើបអង្កេតនេះ តុលាការធ្វើការប្រមូលភស្តុតាងយកចំលើយបំភ្លឺរបស់អ្នកចូលរួមក្នុងនីតិវិធីសិក្សាអំពីកម្មវត្ថុនៃវិវាទ វាយតម្លៃ និងបកស្រាយភស្តុតាងទាំងនោះ ដើម្បីបំភ្លឺការងារជំនុំជម្រះអោយប្រព្រឹត្តទៅនឹងសម្រេចបានត្រឹមត្រូវតាមអង្គហេតុ និងអង្គច្បាប់នៃរឿងក្តី។

ភស្តុតាងអាចត្រូវបានផ្តល់អោយ តាមរយៈគ្រប់មធ្យោបាយទាំងអស់ចំពោះរាល់វិវាទដែលទាក់ទងនឹងរឿងពាណិជ្ជកម្ម។ នៅពេលទទួលបានភស្តុតាងគ្រប់គ្រាន់ហើយ គឺឈានដល់នីតិវិធីនៃការជំនុំជម្រះចេញសេចក្តីសម្រេចដែលគូវិវាទចាំបាច់ត្រូវតែគោរពតាមសេចក្តីសម្រេចនោះជាដាច់ខាត។ ប្រសិនបើនៅក្នុងនីតិវិធីមានការខកខានមិនបានអនុវត្តនូវការផ្សះផ្សាធ្វើអោយសាលក្រម ឬសេចក្តីសម្រេចនោះត្រូវទុកជាមោឃៈដោយកំហុសនៃនីតិវិធី។ ក្រោយពេលដោះស្រាយវិវាទរួចរាល់ ហើយក្នុងករណីដែលអ្នកវិនិយោគមានបំណងចង់បញ្ចប់សកម្មភាពរបស់ខ្លួននៅព្រះរាជាណាចក្រកម្ពុជា អ្នកវិនិយោគនោះត្រូវផ្តល់ពត៌មានទៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាតាមរយៈ លិខិតអនុ

[27] មាត្រា ១២៨ថ្មី រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣។
[28] មាត្រា ៧៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦ ។

សិដ្ឋ ឬលិខិតប្រគល់ផ្ទាល់ដៃដោយមានបញ្ជាក់ពីមូលហេតុនៃការបញ្ចប់សកម្មភាពនោះ និងចុះហត្ថលេខាដោយអ្នកវិនិយោគ ឬមេធាវីតំណាងផ្ទាល់[29]។

**កថាខណ្ឌទី២: អាជ្ញាប័ណ្ណវិនិយោគនៅប្រទេសចិន**

**១. នីតិវិធីក្នុងការដាក់ពាក្យស្នើសុំអាជ្ញាប័ណ្ណវិនិយោគ**

ដោយអនុលោមតាមច្បាប់នៃសាធារណៈរដ្ឋប្រជាមានិតចិន សម្រាប់ការវិនិយោគបរទេសដែលចង់បង្កើតសហគ្រាស គឺជាកម្មវត្ថុនៃការត្រួតពិនិត្យ ការអនុម័ត និងការចុះបញ្ជីដោយរដ្ឋាភិបាលពីគម្រោងមួយទៅគម្រោងមួយ។ បទបញ្ញាត្តិនេះត្រូវបានបង្កើតឡើងដោយអនុលោមតាមច្បាប់នៃសាធារណៈរដ្ឋប្រជាមានិតចិន ច្បាប់ក្រុមហ៊ុន និងបទបញ្ញាត្តិផ្សេងទៀតដែលពាក់ព័ន្ធនឹងការវិនិយោគបរទេស ក្នុងគោលបំណងគ្រប់គ្រងការវិនិយោគរបស់សហគ្រាសវិនិយោគបរទេស។ ការវិនិយោគរបស់សហគ្រាសវិនិយោគបរទេសនៅលើទឹកដីប្រទេសចិន ត្រូវអនុវត្តតាមច្បាប់របស់ប្រទេសចិន។ ហើយការវិនិយោគនៅលើទឹកដីប្រទេសចិនត្រូវធ្វើឡើងដោយយោងតាមបទបញ្ញាត្តិស្តីអំពីការវិនិយោគ និងបញ្ជីណែនាំស្តីពីសហគ្រាសវិនិយោគ[30]។

វិនិយោគិនត្រូវគោរពតាមលក្ខខណ្ឌមួយចំនួន ដែលមានចែងនៅក្នុងបទបញ្ញាត្តិស្តីពីការបង្កើតក្រុមហ៊ុនវិនិយោគបរទេសដោយវិនិយោគិនបរទេស។

នីតិវិធីនៃការបង្កើតសហគ្រាសវិនិយោគបរទេស គឺមានលក្ខណៈសាមញ្ញ។ ពាក្យស្នើសុំគម្រោងដំបូងដែលត្រូវបានអនុម័តដោយក្រសួង ត្រួតពិនិត្យ និងផ្តល់សច្ចាប័នរួចមក វិនិយោគិនអាចបញ្ជូនពាក្យស្នើសុំផ្លូវការ ដែលមានភ្ជាប់ជាមួយនឹងប្រការ និងឯកសារដែលតម្រូវអោយមានមួយចំនួនទៀត។ នៅលើបង្កាន់ដៃវិញ្ញាបនបត្រ អ្នកវិនិយោគទាំងនោះអាចចាត់ចែងរបៀបរបបចុះបញ្ជីដោយគ្រាន់តែបង្ហាញនូវវិញ្ញាបនបត្រដែលមាន។

សហគ្រាសវិនិយោគបរទេសត្រូវបានអនុញ្ញាតអោយវិនិយោគប្រសិនបើគោរពនូវលក្ខខណ្ឌដូចខាងក្រោម(យោងតាមមាត្រា៥ )៖

ក. ការចុះបញ្ជីមូលធនត្រូវធ្វើបានរួចរាល់

ខ. ការទទួលបាននូវផលចំណេញ

គ. កិច្ចប្រតិបត្តិការត្រូវមានលក្ខណៈស្របច្បាប់

---

[29] មាត្រា ២១ នៃច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីវិនិយោគព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី២៤ ខែមិនា ឆ្នាំ២០០៣។

[30] មាត្រា៣ បទបញ្ញាត្តិស្តីពី ការបង្កើតក្រុមហ៊ុនវិនិយោគបរទេសដោយវិនិយោគិនបរទេស។

### ២. ស្ថាប័នទទួលបន្ទុកកិច្ចការវិនិយោគ

អនុលោមតាមច្បាប់នៃប្រទេសចិន រដ្ឋអាចទទួលយកនូវប្រព័ន្ធនៃការបែងចែករដ្ឋបាលសម្រាប់វិនិយោគបរទេស។ នៅតាមខេត្ត-ក្រុង និងតំបន់ស្វ័យត ដែលបានដាក់ក្នុងផែនការរដ្ឋ មានសមត្ថកិច្ចត្រួតពិនិត្យ និងទទួលយកការវិនិយោគដែលតិចជាង៣០.០០០.០០០(សាមសិបលាន) ដុល្លារអាមេរិក នៅក្នុងតំបន់ដែលទទួលបានការអនុញ្ញាតពីរដ្ឋ។ ប៉ុន្តែនៅពេលដែលចំនួនវិនិយោគទុនមានតម្លៃលើសពីចំនួនខាងលើ គម្រោងស្នើសុំ និងរបាយការណ៍ ត្រូវតែត្រួតពិនិត្យ និងយល់ព្រមដោយគណៈកម្មាធិការមួយ គឺគណៈកម្មាធិការផែនការអភិវឌ្ឍន៍ (State Development Planning Commission) ឬគណៈកម្មាធិការសេដ្ឋកិច្ច និងពាណិជ្ជកម្ម (State Economic and Trade Commission) ស្របពេលដែលកិច្ចសន្យា និងប្រការនៃសាជីវកម្មត្រូវតែត្រួតពិនិត្យ និងអនុម័តដោយក្រសួងសហប្រតិបត្តិការពាណិជ្ជកម្ម និងសេដ្ឋកិច្ចបរទេស។ ខេត្ត-ក្រុង ក៏ដូចជាតំបន់ស្វ័យតមួយចំនួនដែលស្ថិតក្រោមការគ្រប់គ្រងផ្ទាល់របស់រដ្ឋាភិបាល បានបង្កើតនូវសេវាកម្មវិនិយោគបរទេសកណ្តាល ដែលអាចផ្តល់អោយវិនិយោគិននូវសេវាកម្ម **one-stop-service** ដែលរៀបចំជាលំដាប់ពីការប្រឹក្សាគតិយុត្ត រហូតដល់ការផ្តល់អោយនូវការអនុម័តលើគម្រោង។ ជាមួយនឹងប្រព័ន្ធសេវាកម្មសង្គមរបស់ប្រទេសចិន (China's social service system) ភ្នាក់ងារសេវាកម្មអន្តរការីដែលរួមទាំងក្រុមហ៊ុនប្រឹក្សាយោបល់ មេធាវី និងគណនេយ្យករ សុទ្ធតែត្រូវបានគេជឿជាក់ថាអាចផ្តល់អោយអ្នកវិនិយោគនូវសេវាកម្មដែលប្រកប ដោយប្រសិទ្ធិភាព និងគុណភាព។

### ៣. នីតិវិធីដោះស្រាយវិវាទវិនិយោគ

ជាមួយនឹងការអនុវត្តកិច្ចការជំនួញនៅក្នុងប្រទេសចិន ក្រុមហ៊ុនបរទេសតែងតែជួបប្រទះនូវភាពស្មុគស្មាញឬការកើតឡើងនូវជម្លោះជាមួយនឹងរូបវន្តបុគ្គលចិន ក្រុមហ៊ុន ឬរដ្ឋាភិបាលចិន។ ដោយមើលឃើញពីបញ្ហាជម្លោះដែលកើតមានឡើង និងមានភាពខុសគ្នាពីរឿងមួយទៅរឿងមួយបែបនេះ នាយកដ្ឋានពាណិជ្ជកម្ម(DOC) បានសម្រេចដាក់ចេញនូវគោលការណ៍ណែនាំមួយចំនួនស្តីពីវិវាទវិនិយោគដែលបានចូលជាធរមាននៅថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១០ ដែលនៅក្នុងគោលការណ៍ណែនាំនោះមានដូចជាការចរចារ សន្ធានកម្ម មជ្ឈត្តកម្ម និងការដោះស្រាយតាមផ្លូវតុលាការ។

#### ៣.១. ការចចារ

ការចចាររវាងគូភាគីគឺជាមធ្យោបាយដ៏ល្អបំផុតសម្រាប់ដោះស្រាយវិវាទ។ ការចចារគឺជាវិធីសាស្ត្រមួយដែលមានការចំណាយតិច ហើយអាចរក្សាទំនាក់ទំនងរវាងភាគីបានល្អផងដែរ។ជាទូ

ទៅនៅក្នុងកិច្ចសន្យាអាជីវកម្មភាគច្រើនរបស់ប្រទេសចិន តែងតែមានបញ្ញត្តិថាការចចារត្រូវតែប្រើប្រាស់មុននឹងប្រើប្រាស់យន្តការផ្សេងៗទៀតក្នុងការដោះស្រាយវិវាទ។ក្នុងករណីដែលភាគីបរទេសមានភាពលំបាកក្នុងការចរចារដោយផ្ទាល់ជាមួយនឹងភាគីចិន ក្រុមហ៊ុនទាំងនោះអាចស្វែងរកជំនួយការពីមន្ត្រីរដ្ឋាភិបាលដែលអាចជំរុញអោយភាគីចិនក្នុងការគោរពនូវកិច្ចសន្យា។ ហើយក្រុមហ៊ុនបរទេសទាំងនោះក៏ត្រូវកំណត់អោយបានច្បាស់ផងដែរពីដំណើរការនៃការចចារ។ ទោះបីជាយ៉ាងណាការចចារមិនមែនសុទ្ធតែទទួលបានដំណោះស្រាយមួយសមរម្យនោះទេ។

**៣.២.សន្ធានកម្ម**

គោលការណ៍នៃសន្ធានកម្មគឺភាគីត្រូវផ្ញើសំណើរបស់ពួកគេ ទៅកាន់សន្ធានការីដែលភាគីជឿជាក់ថាអាចផ្តល់នូវដំណោះស្រាយសមរម្យដល់ភាគី។ សន្ធានកម្ម គឺជាការដោះស្រាយវិវាទពាណិជ្ជកម្មរវាងភាគីបរទេសនិងភាគីចិនដែលមានប្រសិទ្ធិភាព។ នៅក្នុងដំណាក់កាលមជ្ឍត្តកម្មនិងការប្តឹងទៅតុលាការ សន្ធានកម្ម ឬការសម្រុះសម្រួលគឺនៅតែជាជំហានដំបូងដែលគេប្រើប្រាស់ដើម្បីដោះស្រាយវិវាទ។ មុននឹងឈានចូលដល់ដំណាក់កាលប្តឹងទៅតុលាការ គេជំរុញអោយភាគីចូលរួមក្នុងការសម្រុះសម្រួលជាមួយនឹងសន្ធានការី ដែលបានជ្រើសរើសដោយអាជ្ញាកណ្តាល។ ការប្រឈមមុខគ្នាតិចតួចនៅក្នុងដំណាក់កាលនេះអាចជួយរក្សាទំនាក់ទំនងពាណិជ្ជកម្មរវាងភាគីទាំងពីរបាន។

**៣.៣. មជ្ឍត្តកម្ម ឬ អាជ្ញាកណ្តាលចិន**

អាជ្ញាកណ្តាលជាវិធីដ៏សមរម្យមួយ សម្រាប់ដោះស្រាយជម្លោះនៅក្នុងប្រទេសចិន ហើយប្រហែលជាង៩០%នៃជម្លោះដែលទាក់ទងនឹងចិន គឺត្រូវបានដោះស្រាយនៅក្នុងប្រទេសនេះ។ ដោយសារតែកម្រមានភាគីណាមួយនៃជម្លោះ យល់ព្រមទទួលយកអាជ្ញាកណ្តាលនេះ បន្ទាប់ពីជម្លោះបានកើតឡើងក្នុងកិច្ចសន្យា ឬកិច្ចព្រមព្រៀងនីមួយៗ ត្រូវបញ្ជាក់អោយបានច្បាស់ថាអាជ្ញាកណ្តាលណាមួយនឹងត្រូវប្រើប្រាស់នៅក្នុងការដោះស្រាយជម្លោះ ។ នៅក្នុងប្រទេសចិន កិច្ចសន្យាស្តីពីអាជ្ញាកណ្តាលដែលមានសុពលភាព ត្រូវតែបង្ហាញអំពីឆន្ទៈពិត ក្នុងការទទួលយកយន្តការនេះ និងបញ្ជាក់អោយបានច្បាស់ពីស្ថាប័នអាជ្ញាកណ្តាលណា ដែលនឹងត្រូវត្រួតត្រាលើករណីនីមួយៗ។ ដូច្នេះមានន័យថា អាជ្ញាកណ្តាលមានអានុភាពគតិយុត្តក្នុងការដោះស្រាយជម្លោះដែលកើតមានឡើងនៅក្នុងកិច្ចសន្យា ព្រោះបើមិនដូច្នេះទេ ជម្លោះនឹងត្រូវបានដោះស្រាយដោយតុលាការវិញ។ វាមានភាពខុសប្លែកគ្នាច្រើន រវាងអាជ្ញាកណ្តាលនៅក្នុងប្រទេសចិន និងអាជ្ញាកណ្តាលនៅក្នុងបណ្តាប្រទេសដទៃ។ ឧទាហរណ៍ អាជ្ញាកណ្តាលបណ្តោះអាសន្ន គឺមិនត្រូវបានទទួលស្គាល់ដោយច្បាប់

ប្រទេសចិនឡើយ នៅពេលវាត្រូវបានគេអនុវត្តនៅក្នុងប្រទេសនេះ។ ផ្ទុយទៅវិញអាជ្ញាកណ្តាលតែងតែត្រូវបានគេប្រើប្រាស់នៅក្នុងស្ថាប័នអាជ្ញាកណ្តាលជាក់លាក់ណាមួយ ដែលទទួលបានការទទួលស្គាល់ស្របច្បាប់ណាមួយ ។ ព្រោះតែហេតុនេះហើយ បានជាភាគីដែលជ្រើសរើសប្រទេសចិនជាទីតាំងសម្រាប់ការអនុវត្តយន្តការអាជ្ញាកណ្តាល និងត្រូវបានគេរារាំងពីជម្រើសរបស់គេ ដែលមានចែងនៅក្នុងខ្លឹមសារ និងនីតិវិធីច្បាប់របស់អាជ្ញាកណ្តាល។ ហើយប្រសិនបើអាជ្ញាកណ្តាលពិតជាសំខាន់ខ្លាំង ពួកគេនឹងត្រូវបានគេទាមទារអោយជ្រើសរើសជនជាអាជ្ញាកណ្តាលណាមួយដែលមានការចាត់តាំងស្រាប់នៅក្នុងស្ថាប័នអាជ្ញាកណ្តាល ដែលពួកគេបានជ្រើសរើសតាំងពីដំបូង។ គុណវិបត្តិដ៏ធំនោះគឺការធ្វើអោយបាននូវសេចក្តីសម្រេចចុងក្រោយ។ សម្រាប់សេចក្តីសម្រេចរបស់តុលាការ គេអាចប្តឹងបន្តទៅឧទ្ធរណ៍បាន ដែលនេះមានន័យថាដំណើរការនៃរឿងក្តីនោះនឹងត្រូវបានបន្លាយក្នុងរយៈពេលកាន់តែយូរឆ្នាំ ។ ចៅក្រមនៅប្រទេសចិនភាគច្រើនមិនមានគុណសម្បត្តិគ្រប់គ្រប់គ្រាន់ រីឯវាគ្មិននៃអាជ្ញាកណ្តាលវិញ សុទ្ធតែជាបណ្តុំអ្នកជំនាញដែលអាចដឹកនាំសវនាការប្រកបដោយគុណភាពខ្ពស់។ លើសពីនេះទៅទៀតនីតិវិធី និងវិធាននៃអាជ្ញាកណ្តាលតែងមានតម្លាភាពជាងនីតិវិធីរបស់តុលាការ។ បញ្ហាចុងក្រោយ ហើយក៏ជាបញ្ហាស្មុគស្មាញនៃអាជ្ញាកណ្តាលនៅក្នុងប្រទេសចិននោះគឺ ច្បាប់ថ្មីមួយដែលរដ្ឋាភិបាលចិនបានអនុម័តដែលច្បាប់នេះបានកម្រិតលទ្ធភាពរបស់មន្ត្រីកុងស៊ុលបរទេស ក្នុងការដើរតួតំណាងអោយភាគីណាមួយដែលជាជនជាតិរបស់គេ។កាលពីពេលកន្លងទៅក្រុមហ៊ុនអាមេរិកកាំងមួយចំនួនបានយល់ព្រមជាមួយនឹងអាជ្ញាកណ្តាលចិន ដោយសារតែពួកគេពេលនោះអាចមានលទ្ធភាពសុំជំនួយពីមន្ត្រីកុងស៊ុលរបស់គេនៅពេលគេមានជម្លោះនៅក្នុងប្រទេសនេះ។ ប៉ុន្តែចាប់តាំងតែពីច្បាប់នេះត្រូវបានគេអនុម័ត និងចូលជាធរមាននៅថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០០២ កន្លងមក អ្នកច្បាប់ដែលជាជនបរទេសត្រូវបានគេកំណត់លទ្ធភាពក្នុងការតំណាងជាកុងស៊ុលក្នុងនីតិវិធីនៃអាជ្ញាកណ្តាល ទោះបីជាគេបានទទួលរបាយការណ៍មិនផ្លូវការ ថាអ្នកច្បាប់បរទេសអាចត្រូវបានគេអនុញ្ញាតអោយ បន្តធ្វើជាកុងស៊ុល ក្នុងនីតិវិធីដែលបានគេចាប់ផ្តើមមុនពេលដែលច្បាប់ថ្មីនេះត្រូវបានគេដាក់អោយមានអនុភាពប្រើប្រាស់មកម្លេះ ។

**៣.៤. ការដោះស្រាយតាមផ្លូវតុលាការ**

ដំណាក់កាលចុងក្រោយនៃការដោះស្រាយវិវាទពាណិជ្ជកម្ម គឺការដាក់ពាក្យប្តឹងទៅតុលាការប្រទេស។ នៅក្នុងប្រទេសចិន រូបវន្តបរទេស និងក្រុមហ៊ុនមានសិទ្ធិក្នុងការដាក់ពាក្យប្តឹងទៅតុលាការចិនដូចប្រជាជននិងក្រុមហ៊ុនចិនដែរ។ ប្រព័ន្ធតុលាការនៅប្រទេសចិនចែកចេញជា៤ថ្នាក់ ដែលរាល់ទីក្រុងធំៗគឺមានតុលាការមូលដ្ឋាននិងតុលាការអន្តរកម្ម។ ហើយតុលាការខេត្តជាន់ខ្ពស់

ជាអ្នកត្រួតពិនិត្យតុលាការទាំងពីរខាងលើ។ ចំណែកឯតុលាការជាន់ខ្ពស់ ឬតុលាការកំពូលដែលមានទីតាំងនៅទីក្រុងប៉េកាំង គឺមានអំណាចយុត្តាធិការទៅលើតុលាការទាំងអស់របស់ចិន។ រឿងក្តីដែលពាក់ព័ន្ធជាមួយនឹងផលប្រយោជន៍របស់បរទេស គឺអាចដាក់ពាក្យប្តឹងទៅតុលាការមូលដ្ឋាន ឬតុលាការអន្តរកម្មដោយអាស្រ័យទៅលើរឿងក្តី។

យ៉ាងណាមិញអ្នកសង្កេតការណ៍មួយចំនួនបានអោយដឹងថា តុលាការចិនពុំទាន់មានលក្ខណ:ជាស្តង់ដារអន្តរជាតិនៅឡើយទេ។ចៅក្រមភាគច្រើនគឺបានទទួលការបណ្តុះបណ្តាលបានតិចតួច ហើយពេលខ្លះមន្ត្រីទាំងនោះបានទទួលសំណូក និងភាគច្រើនគឺមានលក្ខណ:ការការពារនិយមនៅក្នុងតំបន់។ ម្យ៉ាងវិញទៀតតុលាការទាំងនោះគឺទទួលបានជំនួយពីរដ្ឋាភិបាលក្នុងតំបន់ដែលជាហេតុធ្វើអោយប៉ះពាល់ដល់ឯករាជ្យភាពរបស់ពួកគេ។

## កថាខណ្ឌទី៣: ការប្រៀបធៀបអាជ្ញាប័ណ្ណវិនិយោគរវាងប្រទេសកម្ពុជា និងប្រទេសចិន

### ១. ប្រសិទ្ធភាពនៃការគ្រប់គ្រង

មុននឹងអាចធ្វើសកម្មភាពវិនិយោគ នៅក្នុងប្រទេសណាមួយឲ្យចេញរូបរាងនោះ ជាការពិតណាស់ បុគ្គលដែលមានបំណងចង់ធ្វើការវិនិយោគនោះត្រូវតែបំពេញលក្ខខណ្ឌចាំបាច់មួយចំនួនដែលច្បាប់វិនិយោគនៃប្រទេសនោះតម្រូវ ដើម្បីឲ្យក្លាយខ្លួនជាវិនិយោគិនដែលស្របច្បាប់។ នៅពេលក្លាយខ្លួនជាវិនិយោគិនស្របច្បាប់ហើយនោះ ពួកគេនឹងអាចទទួលបាននូវផលប្រយោជន៍ផ្សេងៗដែលច្បាប់វិនិយោគនៃប្រទេសទាំងនោះបានផ្តល់ឲ្យ ដែលមានដូចជាការធានា និងការលើកទឹកចិត្តទៅលើគម្រោងវិនិយោគរបស់ពួកគេជាដើម។ ជាក់ស្តែងសម្រាប់នៅប្រទេសកម្ពុជា ក៏ដូចជានៅសាធារណ:ប្រជាមានិតចិន ដើម្បីក្លាយខ្លួនទៅជាវិនិយោគិនស្របតាមច្បាប់នោះ វិនិយោគិនត្រូវបំពេញលក្ខខណ្ឌចាំបាច់មួយចំនួនដែលច្បាប់វិនិយោគតម្រូវ។ វិនិយោគិនស្របច្បាប់ គឺជាវិនិយោគិនដែលទទួលបាននូវវិញ្ញាបនបត្រចុះបញ្ជីជាស្ថាពរ។ សូមបញ្ជាក់ផងដែរថា វិញ្ញាបនបត្រចុះបញ្ជីជាស្ថាពរ គឺសំដៅដល់អាជ្ញាប័ណ្ណវិនិយោគដែលអាជ្ញាប័ណ្ណវិនិយោគនេះនឹងត្រូវចេញអោយដោយស្ថាប័នដែលទទួលបន្ទុកកិច្ចការវិនិយោគ ដែលនៅកម្ពុជាមានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ចំពោះគម្រោងវិនិយោគដែលមានទំហំទឹកប្រាក់លើសពី០២(ពីរ)លានដុល្លារអាមេរិក និងអនុគណ:កម្មាធិការវិនិយោគខេត្ត-ក្រុង ចំពោះគម្រោងវិនិយោគដែលមានទំហំទឹកប្រាក់ក្រោម០២(ពីរ)លានដុល្លារអាមេរិក។ សម្រាប់នៅសាធារណ:ប្រជាមានិតចិនវិញ ស្ថាប័នដែលទទួលបន្ទុកកិច្ចការវិនិយោគមានគណ:កម្មាធិការផែនការអភិវឌ្ឍន៍ (State Development Planning Commission) ឬគណ:កម្មាធិការសេដ្ឋកិច្ច និងពាណិជ្ជកម្ម (State Economic and Trade Commission) ចំពោះ

គម្រោងវិនិយោគដែលមានទំហំទឹកប្រាក់លើសពី៣០.០០០.០០០(សាមសិបលាន)ដុល្លាអាមេរិក ហើយចំពោះគម្រោងវិនិយោគ ដែលមានទំហំទឹកប្រាក់តិជាង៣០.០០០.០០០(សាមសិបលាន) ដុល្លារអាមេរិកវិញ ជាសមត្ថកិច្ចរបស់ខេត្ត-ក្រុង និងតំបន់ស្វ័យតដែលបានដាក់ក្នុងផែនការរដ្ឋ ទើបមានសមត្ថកិច្ចត្រួតពិនិត្យ និងទទួលយកការវិនិយោគនោះ។ ទន្ទឹមនឹងនេះលក្ខខណ្ឌផ្សេងៗដែលតម្រូវឲ្យវិនិយោគិនត្រូវបំពេញដើម្បីស្នើសុំអាជ្ញាប័ណ្ណវិនិយោគនេះ មិនថានៅប្រទេសកម្ពុជាក្តី ឬនៅសាធារណៈរដ្ឋប្រជាមានិតចិនក្តី គឺមានលក្ខណៈស្រដៀងៗគ្នា ហើយក៏មានលក្ខណៈខុសប្លែកគ្នានូវចំណុចមួយចំនួនផងដែរ អាស្រ័យទៅតាមកំណត់ដែលមានចែងក្នុងច្បាប់វិនិយោគនៃប្រទេសនីមួយៗ។ ប៉ុន្តែជាទូទៅ យើងសង្កេតឃើញថា ដើម្បីទទួលបាននូវអាជ្ញាប័ណ្ណវិនិយោគនេះ អ្នកវិនិយោគទាំងនោះត្រូវតែបំពេញនូវលក្ខខណ្ឌមួយចំនួនជាគោល ដូចជាការបំពេញលក្ខខណ្ឌតម្រូវដែលមានកំណត់នៅក្នុងពាក្យស្នើសុំអាជ្ញាប័ណ្ណវិនិយោគ ព្រមទាំងត្រូវដាក់ពាក្យស្នើសុំអាជ្ញាប័ណ្ណវិនិយោគនោះនៅក្រសួងមានសមត្ថកិច្ចជាដើម ដើម្បីអោយស្ថាប័នមានសមត្ថកិច្ចពិនិត្យ និងសម្រេចថាគួរចេញអាជ្ញាប័ណ្ណវិនិយោគទៅឲ្យអ្នកស្នើសុំ ឬក៏ត្រូវបដិសេធពាក្យស្នើសុំនោះ។ ដទៃពីនេះទៀត ខណៈពេលវិនិយោគិនទទួលបាននូវអាជ្ញាប័ណ្ណវិនិយោគហើយនោះ វិនិយោគិននោះត្រូវតែអនុវត្តនូវសកម្មភាពដែលខ្លួនបានស្នើសុំនៅក្នុងអាជ្ញាប័ណ្ណ ដោយមិនត្រូវអនុវត្តសកម្មភាពណាមួយដែលផ្ទុយទៅនឹងអ្វី ដែលបានស្នើសុំនៅក្នុងអាជ្ញាប័ណ្ណវិនិយោគនោះឡើយ ពុំនោះទេអាជ្ញាប័ណ្ណវិនិយោគនឹងត្រូវបានដកហូតមកវិញ ឬត្រូវលុបចោលជាក់ជាមិនខាន។

## ផ្នែកទី៣: រូបភាពនៃការវិនិយោគនៃប្រទេសកម្ពុជា និងប្រទេសចិន

### កថាខណ្ឌទី១: របបគតិយុត្តនៃក្រុមហ៊ុនវិនិយោគនៅប្រទេសកម្ពុជា

#### ១. ទម្រង់ក្រុមហ៊ុនវិនិយោគ

យោងតាមមាត្រា១៣ ជំពូក៤ នៃអនុក្រឹត្យស្តីពីការអនុវត្តច្បាប់វិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រ កម្ពុជាលេខ១១១ អនក្រ.បក ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០០៥ រូបភាពវិនិយោគដែលត្រូវបានអនុញ្ញាតិ រួមមានប្រភេទក្រុមហ៊ុនដែលបង្កើតឡើងរវាងនីតិបុគ្គលសញ្ជាតិខ្មែរនិងនីតិបុគ្គលមានសញ្ជាតិខ្មែរ នីតិបុគ្គលសញ្ជាតិបរទេស និងនីតិបុគ្គលសញ្ជាតិបរទេស (១.១) នីតិបុគ្គលសញ្ជាតិខ្មែរនិងនីតិបុគ្គលសញ្ជាតិបរទេស (១.៣) និងរួមបញ្ចូលផងដែរសម្ព័ន្ធអាជីវកម្មជាមួយស្ថាប័ននានាជាមួយរាជរដ្ឋាភិបាល ឬក្រុមហ៊ុនចម្រុះ(១.២)។

**១.១. ក្រុមហ៊ុនភាគទុន ១០០%ជាខ្មែរ ឬ បរទេស**

យោងតាមច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា ក្រុមហ៊ុនភាគទុន

១០០% ត្រូវបានគេអោយនិយមន័យថាជាប្រភេទក្រុមហ៊ុនដែលមានភាគហ៊ុន១០០% ជារបស់វិនិយោគិនខ្មែរ ដែលគ្មានដៃគូសហការជាមួយក្រុមហ៊ុនដទៃឡើយ។ សម្រាប់ក្រុមហ៊ុនបរទេស គឺមានសិទ្ធិនិងកាតព្វកិច្ចពេញលេញក្នុងការដឹកនាំក្រុមហ៊ុននិងអនុវត្តនូវកាតព្វកិច្ចរបស់ខ្លួន តែរាល់ការអនុវត្តកាតព្វកិច្ចគឺត្រូវស្ថិតក្រោមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។

**១.២. ក្រុមហ៊ុនចម្រុះ**

ក្រុមហ៊ុនចម្រុះ គឺជាក្រុមហ៊ុនដែលត្រូវបានបង្កើតឡើងតាមគោលការណ៍ និងបែបបទទាំងឡាយនៃនីតិក្រុមហ៊ុនពាណិជ្ជកម្ម ហើយដើមទុនត្រូវបានកាន់កាប់រួមគ្នាដោយនីតិបុគ្គល ឬរូបវន្តបុគ្គល ឬបុគ្គលឯកជន ឬនីតិបុគ្គលរដ្ឋ។ កាលណាភាគកម្មសាធារណៈលើសពី៥០% នៃដើមទុន ឬសិទ្ធិបោះឆ្នោត ក្រុមហ៊ុនចម្រុះត្រូវបានចាត់ទុកជាគ្រឹះស្ថានសាធារណៈ។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រ៉ាប់រងខាងផ្នែករដ្ឋបាល លើភាគកម្មសាធារណៈ ហើយប្រតិបត្តិការហិរញ្ញវត្ថុភាគកម្មសាធារណៈ ត្រូវធ្វើបានអោយសម្រេចដោយអនុលោមតាមបញ្ញាត្តិដែលមានចែងក្នុងច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ និងច្បាប់ហិរញ្ញវត្ថុជាធរមាន។ បដិបញ្ញាត្តិលើគោលការណ៍ និងបែបបទទាំងឡាយនៃនីតិក្រុមហ៊ុនពាណិជ្ជកម្ម រដ្ឋ គ្រឹះស្ថានសាធារណៈ និងក្រុមហ៊ុន រដ្ឋត្រូវបានលើកលែងការតម្កល់ភាគហ៊ុនធានា សម្រាប់តំណាងក្រុមប្រឹក្សាភិបាលសហគ្រាសដែលខ្លួនបានចូលរួម។

តំណាងរបស់រដ្ឋ ឬតំណាងរបស់គ្រឹះស្ថានសាធារណៈ នៅក្នុងក្រុមប្រឹក្សាភិបាលនៃក្រុមហ៊ុនចម្រុះ ត្រូវបានតែងតាំងដោយអនុក្រឹត្យតាមសំណើរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ តំណាងរបស់ក្រសួងរដ្ឋនៅក្រុមប្រឹក្សាភិបាលនៃក្រុមហ៊ុនចម្រុះ ត្រូវបានតែងតាំងដោយសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលនៃក្រុមហ៊ុននោះ ក្រោយពីមានយោបល់ឯកភាពពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ តំណាងរបស់រដ្ឋ របស់គ្រឹះស្ថានសាធារណៈ ឬរបស់ក្រុមហ៊ុនរដ្ឋនៅក្នុងក្រុមប្រឹក្សាភិបាលនៃក្រុមហ៊ុនចម្រុះ ត្រូវបានជ្រើសរើសដោយផ្អែកលើគុណសម្បត្តិ និងបទពិសោធន៍របស់ខ្លួន ឬពីក្នុងចំណោមមន្ត្រីរាជការ បម្រើការងារយ៉ាងតិច០៥(ប្រាំ)ឆ្នាំ ឬចូលនិវត្តន៍តែមានអាយុមិនលើសពី៦៥(ហុកសិបប្រាំ)ឆ្នាំ ឬក្នុងចំណោមឥស្សរជនខ្មែរដែលមានសមត្ថភាពខាងសេដ្ឋកិច្ច ឬខាងនីតិសាស្ត្រ ឬខាងវិទ្យាសាស្ត្រ ដោយតំណាងទាំងនោះអាចឲ្យរួចផុតពីការបង់ប្រាក់ធានាសម្រាប់មុខតំណែងនៅក្នុងក្រុមប្រឹក្សាភិបាល តែមិនត្រូវមានភាគហ៊ុននៅក្នុងសហគ្រាសឡើយ។ ការទទួលខុសត្រូវផ្នែករដ្ឋប្បវេណីរបស់តំណាងទាំងនោះ នៅក្នុងការបំពេញភារកិច្ច នៅក្នុងក្រុមប្រឹក្សាភិបាលនៃក្រុមហ៊ុនចម្រុះ ត្រូវធ្លាក់ទៅលើរដ្ឋ លើគ្រឹះស្ថានសាធារណៈ ឬលើក្រុមហ៊ុនរដ្ឋ តែតំណាងត្រូវទទួលខុសត្រូវដោយខ្លួនឯងផ្នែកព្រហ្មទណ្ឌ។ មួយវិញទៀតមិនអនុញ្ញាតអោយមន្ត្រីសាធារណៈ

ដែលធ្លាប់ធ្វើជា តំណាងរបស់រដ្ឋ របស់គ្រឹះស្ថានសាធារណៈរបស់រដ្ឋ ឬរបស់ក្រុមហ៊ុនចម្រុះ ចូលធ្វើការនៅក្នុងមុខតំណែងណាមួយ ក្នុងសហគ្រាសដែលខ្លួនធ្លាប់ពាក់ព័ន្ធ នៅមុនកាលផុតរយៈពេល ០៣(បី)ឆ្នាំ គិតចាប់ពីថ្ងៃឈប់ធ្វើការរបស់តំណាងនោះ លើកលែងតែមានការអនុញ្ញាតពិសេសពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ លើសពីនេះទៅទៀតត្រូវមានអាណត្តិគាហកៈមួយរូបតំណាងរដ្ឋនៅក្នុងមហាសន្និបាតក្រុមហ៊ុនចម្រុះ ប៉ុន្តែអាណត្តិគាហកៈពិសេសមានវិសមិតភាពជាមួយតំណែងជាអគ្គនាយកនៃសហគ្រាសនោះ[31]។

**១.៣. កិច្ចសន្យាសហប្រតិបត្តិការ**

កិច្ចសន្យាសហប្រតិបត្តិការ គឺជាកិច្ចព្រមព្រៀងរវាងភាគីពីរ ឬច្រើន ដែលបានបង្កើតកាតព្វកិច្ចរួមគ្នា និងទទួលស្គាល់ដោយច្បាប់។ យោងតាមច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម កិច្ចសន្យាសហប្រតិបត្តិការ គឺជាកិច្ចព្រមព្រៀងដែលវិនិយោគិនបរទេស និងភាគីម្ខាងទៀតជាដៃគូប្រតិបត្តិការកម្ពុជាសម្រាប់គម្រោងអាជីវកម្មមួយ។ ភាគីបរទេស និងភាគីកម្ពុជាអនុវត្តនូវសកម្មភាពពាណិជ្ជកម្មដោយគ្មានការបង្កើតនូវអ្នកកាត់សេចក្តីនៅក្នុងព្រះរាជាណាចក្រកម្ពុជាឡើយ។

យោងតាមបទបញ្ញត្តិស្តីពីសហគ្រាសពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា កិច្ចសន្យាសហប្រតិបត្តិការត្រូវតែបញ្ញត្តិអំពី ពត៌មានលម្អិតរបស់ភាគីដែលមានដូចជា ឈ្មោះ សញ្ជាតិ និងការកំណត់ពីផលប្រយោជន៍ និងការកំណត់ពីការទទួលខុសត្រូវ នូវរាល់ហានិភ័យដែលបានកើតឡើង។ ការបង្កើតកិច្ចសន្យាសហប្រតិបត្តិការនេះ ក៏ត្រូវកំណត់ពីសិទ្ធិនិងកាតព្វកិច្ចរបស់ភាគីក្នុងការជ្រើសរើស មធ្យោបាយក្នុងការដោះស្រាយជម្លោះផងដែរ។ នៅក្នុងកិច្ចសន្យា ភាគីក៏ត្រូវកំណត់ផងដែរពីសកម្មភាពនៃការផលិត ក៏ដូចជាការកេងប្រវ័ញ្ច និងត្រូវបញ្ជាក់រាល់សម្ភារៈ និងវត្ថុធាតុផ្សេងៗដែលជាតម្រូវការរបស់សហគ្រាសយកមកពិភាក្សា។

រាល់លក្ខខណ្ឌនិងការកែប្រែផ្សេងៗរបស់កិច្ចសន្យាសហប្រតិបត្តិការ នឹងត្រូវកំណត់ដោយក្រុមប្រឹក្សាអភិវឌ្ឍកម្ពុជា (CDC)។ មានន័យថាកិច្ចសន្យាសហប្រតិបត្តិការត្រូវដាក់ជូនក្រុមប្រឹក្សាអភិវឌ្ឍកម្ពុជាមុននឹងភាគីទទួលបានភាពស្របច្បាប់។ ម្យ៉ាងវិញទៀតរាល់ការផ្ទេរសិទ្ធិនិងកាតព្វកិច្ចទៅកាន់ភាគីទី៣ ភាគីត្រូវឆ្លងកាត់សមត្ថកិច្ចត្រួតពិនិត្យរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាជាមុនសិន។ ទាក់ទិនទៅនឹងរយៈពេលនៃកិច្ចសន្យាសហប្រតិបត្តិការ ភាគីត្រូវតែបញ្ជូនរបាយការណ៍ទៅកាន់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាអោយបានទៀតទាត់។ កិច្ចសន្យានឹងត្រូវរលត់នៅពេលណាដែលកម្មវត្ថុនៃកិច្ចសន្យាត្រូវបានបញ្ចប់ ឬភាគីណាមួយនៃកិច្ចសន្យាបានរំលោភបំពានកិច្ចសន្យា។ ម្យ៉ាង

[31] អ៊ីវ ប៉ូលី, *នីតិក្រុមហ៊ុន*(២០០៨), ២៦។

វិញទៀត ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក៏មានសិទ្ធិក្នុងការដកហូតអភ័យឯកសិទ្ធិរបស់វិនិយោគិន ប្រសិនបើសកម្មភាពទាំងនោះមានផលប៉ះពាល់ទៅដល់ផលប្រយោជន៍ជាតិ។ យោងតាមច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា រាល់វិវាទដែលកើតមាន ភាគីកម្ពុជានិងភាគីបរទេសត្រូវដោះស្រាយវិវាទតាមរយៈការចរចារ។ ប្រសិនបើវិវាទពុំអាចដោះស្រាយបានតាមរយៈការចរចារ ភាគីត្រូវបញ្ជូនករណីវិវាទទៅកាន់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។ ទោះបីជាយ៉ាងណា ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ពុំមានសមត្ថកិច្ចក្នុងការសម្រេចលើរឿងក្តីឡើយ គ្រាន់តែអាចជួយអោយភាគីស្វែងរកដំណោះស្រាយតាមរយៈសន្ធានកម្ម មជ្ឈត្តកម្ម ឬតាមផ្លូវតុលាការ តាមរយៈការព្រមព្រៀងរបស់ភាគី។

## កថាខណ្ឌទី២ : របបគតិយុត្តនៃក្រុមហ៊ុនវិនិយោគនៅប្រទេសចិន

### ១. ទម្រង់ក្រុមហ៊ុនវិនិយោគ

សហគ្រាសវិនិយោគបរទេសនៃសាធារណៈរដ្ឋប្រជាមានិតចិន(PRCFIEs) ដែលនឹងរៀបរាប់ខាងក្រោមនេះគឺជា សហគ្រាសទាំងឡាយណាដែលបានបង្កើតឡើងនៅក្នុងប្រទេសចិន និងដោយអនុលោមតាមបទបញ្ញាត្តិស្តីពីច្បាប់វិនិយោគរបស់ប្រទេសចិន ដែលស្របតាមគោលនយោបាយក្នុងការទាក់ទាញការវិនិយោគបរទេស ដែលមានសាធារណៈរដ្ឋប្រជាមានិតចិនជាម្ចាស់ផ្ទះ។

ប្រភេទសហគ្រាសវិនិយោគចិនដំបូងគឺ ក្រុមហ៊ុនបណ្តាក់ទុនរួមគ្នា ត្រូវបានបង្កើតឡើងបន្ទាប់ពីគោលនយោបាយបើកចំហ ត្រូវបានអនុម័តដោយរដ្ឋាភិបាលចិននៅឆ្នាំ១៩៧៩។ បន្ទាប់មកសហគ្រាសវិនិយោគបរទេសតែមួយគត់( Sole Foreign Investment Enterprise) និងសហគ្រាសសហប្រតិបត្តិការ(Co-operative Enterprise) ក៏ត្រូវបានបង្កើតឡើង។ ហើយប្រភេទសហគ្រាសវិនិយោគបរទេសផ្សេងៗទៀត ដូចជាសហគ្រាសវិនិយោគបរទេសទទួលខុសត្រូវមានកម្រិត (Foreign Investment Enterprises Limited by Shares) ក្រុមហ៊ុនវិនិយោគបរទេស(Investment Companies) និងកិច្ចសន្យាសាងសង់-អាជីវកម្ម-ផ្ទេរ (Built-Operate-Transfer) ក៏ត្រូវបានបង្កើតឡើងផងដែរនាពេលថ្មីៗនេះ។

#### ១.១. ក្រុមហ៊ុនបណ្តាក់ទុនរួមគ្នា/ ក្រុមហ៊ុនរួមសម្ព័ន្ធអាជីវកម្ម( Joint Venture)

ក្រុមហ៊ុនបណ្តាក់ទុនរួមគ្នា គឺជាការរៀបចំអាជីវកម្មនៃភាគីពីរឬច្រើន ដែលបានឯកភាពគ្នាក្នុងការបណ្តាក់ទុនរួមគ្នា ក្នុងគោលបំណងបំពេញភារកិច្ចជាក់លាក់មួយ។ ភារកិច្ចនេះអាចជាគម្រោងថ្មី ឬសកម្មភាពអាជីវកម្មផ្សេងៗទៀត។ ក្នុងការបណ្តាក់ទុនរួមគ្នា ភាគីនីមួយៗត្រូវទទួលខុសត្រូវលើប្រាក់ចំណេញ ការខាតបង់ និងការចំណាយផ្សេងៗដែលពាក់ព័ន្ធ។

ក្រុមហ៊ុនបណ្តាក់ទុនរួមគ្នា គឺជាក្រុមហ៊ុនវិនិយោគមួយដ៏សំខាន់របស់សាធារណៈរដ្ឋប្រជាមានិតចិន។ ក្រុមហ៊ុនបណ្តាក់ទុនរួមគ្នា គឺជាសហគ្រាសដែលបង្កើតរួមគ្នា វិនិយោគរួមគ្នា ប្រតិបត្តិការរួមគ្នាដោយសហគ្រាសបរទេស ក្រុមហ៊ុនបរទេស និងក្រុមហ៊ុនសេដ្ឋកិច្ចផ្សេងៗទៀត ឬរូបវន្តបុគ្គល(ភាគីបរទេស)ដែលនៅក្នុងទឹកដីសាធារណៈរដ្ឋប្រជាមានិតចិន ជាមួយក្រុមហ៊ុន ឬសហគ្រាសចិនដែលអនុលោមតាមបទបញ្ញត្តិនៃគោលការណ៍សមភាព និងផលប្រយោជន៍រួម ហើយត្រូវទទួលបានការអនុម័តដោយរដ្ឋាភិបាលចិន។ ភាគីចិននិងភាគីបរទេសត្រូវរួមចំណែកក្នុងការទទួលខុសត្រូវលើប្រាក់ចំណេញ ហានិភ័យ និងការខាតបង់របស់ក្រុមហ៊ុន។ សមាមាត្រនៃការបណ្តាក់ទុនដែលបានផ្តល់អោយដោយភាគីនីមួយៗ គឺត្រូវសមាមាត្រនឹងចំណែកដែលខ្លួនបានចូលហ៊ុនដែលជាទូទៅគឺមិនអោយតិចជាង២៥%នៃភាគហ៊ុនសរុប។

**១.២. ក្រុមហ៊ុនសហប្រតិបត្តិការ ( Co-operative Enterprise)**

ក្រុមហ៊ុនសហប្រតិបត្តិការត្រូវបានបង្កើតឡើង និងគ្រប់គ្រងដោយបុគ្គលមួយក្រុម ឬនីតិបុគ្គលដែលមានឆន្ទៈក្នុងការបណ្តាក់ដើមទុនរួមគ្នាទៅក្នុងអាជីវកម្មរបស់ពួកគេ ដើម្បីទទួលបានផលប្រយោជន៍។

ប្រភេទនៃក្រុមហ៊ុនសហប្រតិបត្តិការត្រូវបានចែកចេញជាច្រើនប្រភេទ ប៉ុន្តែខាងក្រោមនេះគេលើកយកមកពិភាក្សាតែទៅលើសហគ្រាសពីរប្រភេទប៉ុណ្ណោះ គឺសហប្រតិបត្តិការអ្នកផលិត (Producers´ Cooperative) និងសហប្រតិបត្តិការអ្នកប្រើប្រាស់ (Consumers´ Cooperative)។

សហប្រតិបត្តិការអ្នកផលិត (Producers´ Cooperative) ឬ ត្រូវបានហៅម្យ៉ាងទៀតថា សហគមន៍សហប្រតិបត្តិការកសិករ (Farmer´s Cooperative Society) ត្រូវបានបង្កើតឡើងដោយកសិករដែលជាផលិតករ។ សង្គមទាំងមូលធ្វើការលើកទឹកចិត្តសមាជិករបស់ខ្លួន ក្នុងការរួមបញ្ចូលនិងផលិតនូវផលិតផលរបស់ពួកគេ ដើម្បីទទួលបានលទ្ធផល និងផលប្រយោជន៍ក្នុងលក្ខណៈទ្រង់ទ្រាយធំ ដោយសារតែការផលិតរួមគ្នាវាអាចផ្តល់ផលប្រយោជន៍បានច្រើនជាងលក្ខណៈបុគ្គល។ ផលិតផលដែលបានលក់ និងប្រាក់ចំណេញដែលទទួលបានត្រូវបែងចែកនៅក្នុងចំណោមសមាជិករបស់ខ្លួន។ ចំណែកឯសហប្រតិបត្តិការអ្នកប្រើប្រាស់ (Consumers´ cooperative)វិញ ត្រូវបានបង្កើតឡើងដោយរូបវន្តបុគ្គលដែលបានប្រើប្រាស់ដើមទុនរបស់ខ្លួនក្នុងការទិញ ផលិតផលក្នុងអត្រាការប្រាក់ទាបពីអ្នកផលិត។ ពួកគេធ្វើការវិនិយោគដោយផ្ទាល់ជាមួយនឹងអ្នកផលិតក្នុងតម្លៃទាបដោយពុំត្រូវការសេវាកម្មពីឈ្មួញកណ្តាលដែលទារថ្លៃឈ្នួលខ្ពស់ពីពួកគេឡើយ។

ប្រភពដើមទុននៃសហគ្រាស នេះត្រូវបានប្រមូលតាមរយៈការចូលហ៊ុនរបស់ភាគី។ ហើយ

ប្រភពផ្សេងៗទៀតគឺទទួលបានពី កម្ចីពីស្ថាប័នហិរញ្ញវត្ថុ ការឧបត្ថម្ភធនដោយរដ្ឋាភិបាល និងការរក្សាទុកដើមទុនដោយសហករណ៍។

ក្រុមហ៊ុនសហប្រតិបត្តិការបានផ្តល់នូវគុណប្រយោជន៍ដូចជា៖

ក.សមាជិកភាពធ្វើឡើងដោយការស្ម័គ្រចិត្ត

ខ.ភាគីមានការតាំងចិត្តក្នុងការប្រកបអាជីវកម្ម ដោយសារតែពួកគេជាម្ចាស់ធនធានអាជីវកម្មរួមគ្នា។

គ.ភាគីអាចទទួលបានលទ្ធផលច្រើន ដោយសារតែអាជីវកម្មរបស់ពួកគេពុំមែនជាលក្ខណៈបុគ្គលតែមានលក្ខណៈជាក្រុម។ សម្រាប់អ្នកផលិត គឺអាចទទួលបានផលប្រយោជន៍ក្នុងលក្ខណៈទ្រង់ទ្រាយធំនៃផលិតផល ស្របពេលដែលអ្នកទិញអាចទិញផលិតផលទាំងនោះក្នុងអត្រាការប្រាក់ទាប។

ឃ.ភាគីអាចទទួលបានគុណប្រយោជន៍ពីការឧបត្ថម្ភរបស់រាជរដ្ឋាភិបាល។

ង.សហប្រតិបត្តិការក្រុមហ៊ុនមានលក្ខណៈប្រជាធិបតេយ្យ ដោយភាគីម្នាក់មានសម្លេងមួយដែលមានន័យថា ភាគីទាំងអស់មានសិទ្ធិស្មើៗគ្នាក្នុងការសម្រេចចិត្តលើបញ្ហាដែលពាក់ព័ន្ធនឹងអាជីវកម្មរបស់ខ្លួន។

ច.មានការជំទាស់តិចតួចដែលអាចកើតឡើងរវាងអ្នកគ្រប់គ្រង និងកម្មករនិយោជិក ដោយសារថាការគ្រប់គ្រងអាជីវកម្ម គឺត្រូវបានគ្រប់គ្រងដោយបុគ្គលដែលជាប់ឆ្នោត ដែលភាគីមានឆន្ទៈអោយអាជីវកម្មរបស់ខ្លួនដំណើរការបានល្អ។

ឆ.ក្រុមហ៊ុនសហប្រតិបត្តិការអាចផ្តល់ប្រាក់កម្ចី ដល់សមាជិករបស់ខ្លួនក្នុងអត្រាការប្រាក់ទាប។

ទោះបីជាយ៉ាងណា សហគ្រាសប្រតិបត្តិការក៏មានគុណវិបត្តិមួយចំនួនដូចខាងក្រោម ៖

១-សមាជិកដែលបានជាប់ឆ្នោត គ្រប់គ្រងអាជីវកម្ម មិនមានចំណេះដឹង ជំនាញ និងសមត្ថភាពច្បាស់លាស់ក្នុងការគ្រប់គ្រងអាជីវកម្មអោយមានប្រសិទ្ធិភាព ដោយពួកគេអាចត្រូវបានជាប់ឆ្នោតដោយប្រជាប្រិយភាពរបស់ពួកគេ។ ដូច្នេះវាអាចធ្វើអោយអាជីវកម្ម មិនអាចទទួលបានអត្ថប្រយោជន៍ច្រើន។

២-ក្រុមហ៊ុននេះតម្រូវអោយមានធនធានហិរញ្ញវត្ថុច្រើន ក្នុងការពង្រីកអាជីវកម្ម ប៉ុន្តែសមាជិកភាគច្រើន គឺជាកសិករដែលពួកគេមានការលំបាកក្នុងការផ្គត់ផ្គង់ប្រាក់ទាំងនោះ។

៣-សម្រាប់សមាជិកដែលមានទទួលប្រាក់កម្ចីពីក្រុមហ៊ុនហាក់មានភាពលំបាកក្នុងការសង

ប្រាក់ទាំងនោះមកសហគ្រាសវិញ។ ក្នុងករណីខ្លះសមាជិកចាប់ផ្តើមអវត្តមានក្នុងកិច្ចប្រជុំ និង ក្រោយមកមានភាពអសកម្មនៅក្នុងក្រុមហ៊ុន។

៤-សមាជិកភាគច្រើន គឺជាអនក្ខរជន។ ដូច្នេះពួកគេទទួលអារម្មណ៍ថាត្រូវបានគេបោក ប្រាសរាល់ពេលដែលឯកសារត្រូវបានដាក់បង្ហាញ តែពួកគេពុំអាចស្វែងយល់ពីលក្ខខណ្ឌនៃកិច្ចសន្យាមុននឹងធ្វើការទទួលយក។

នៅពេលដែលភាគីចិន និងភាគីបរទេសបង្កើតក្រុមហ៊ុនមួយនេះ បទបញ្ញត្តិមួយចំនួនដែលស្តីអំពីម្ចាស់ក្រុមហ៊ុន ការបែងចែកភាគហ៊ុន ការទទួលខុសត្រូវចំពោះហានិភ័យនិងការបាត់បង់ វិធីសាស្ត្រក្នុងការគ្រប់គ្រងអាជីវកម្ម និងភាពជាម្ចាស់ទៅលើទ្រព្យសម្បត្តិបន្ទាប់ពីផុតរយៈពេលវិនិយោគត្រូវតែបញ្ញាត្តិនៅក្នុងកិច្ចសន្យារវាងភាគីដោយអនុលោមតាមច្បាប់ប្រទេសចិន។

ភាពងាយស្រួលនិងភាពបត់បែន គឺជាបុគ្គលិកលក្ខណៈនៃក្រុមហ៊ុនវិនិយោគបរទេសប្រភេទនេះដែលបង្កអោយមានភាពងាយស្រួល សម្រាប់ភាគីក្នុងការសម្រេចកិច្ចព្រមព្រៀងផ្សេងៗ។ ក្រុមហ៊ុនសហប្រតិបត្តិការនេះ នឹងទទួលបានលក្ខណៈសម្បត្តិជានីតិបុគ្គលរបស់ចិនដោយអនុលោមតាមបទបញ្ញត្តិស្តីពីនីតិបុគ្គលរបស់ប្រទេសចិន។

ការអនុវត្តទូទៅនៃកិច្ចសហប្រតិបត្តិការ គឺជាការវិនិយោគដែលបានផ្តល់អោយដោយភាគីបរទេសក្នុងទម្រង់ជាសាច់ប្រាក់ សម្ភារៈ និងបច្ចេកវិទ្យា ហើយដែលបានផ្តល់អោយដោយភាគីចិនក្នុងទម្រង់ជាសិទ្ធិក្នុងការប្រើប្រាស់ដី ពលកម្ម និងសេវាកម្មផ្សេងៗទៀតដែលពាក់ព័ន្ធ។

**១.៣. ក្រុមហ៊ុនវិនិយោគបរទេសតែមួយគត់ (Sole Foreign Investment Enterprises)**

ក្រុមហ៊ុនវិនិយោគបរទេសទទួលខុសត្រូវមានកម្រិត គឺជាក្រុមហ៊ុនទាំងឡាយណាដែលបានបង្កើតឡើងនៅក្នុងទឹកដីសាធារណៈរដ្ឋប្រជាមានិតចិន ដោយយោងតាមច្បាប់ដែលពាក់ព័ន្ធរបស់ប្រទេសចិន ហើយដើមទុនសរុបគឺបានមកពីភាគីបរទេសទាំងស្រុង។ វាមិនត្រូវបានរាប់បញ្ចូលឡើយនូវសាខាដែលមាននៅក្នុងប្រទេសចិន ឬអង្គភាពសេដ្ឋកិច្ចផ្សេងៗទៀត។ វាគឺជាស្ថាប័នដែលបានចុះបញ្ជីនៅក្នុងប្រទេសចិន និងត្រូវបានការពារដោយច្បាប់របស់ប្រទេសចិន។ ក្រុមហ៊ុនដែលបានបង្កើតឡើងត្រូវតែផ្តល់ផលប្រយោជន៍ដល់សេដ្ឋកិច្ចជាតិចិន។ ក្រុមហ៊ុនវិនិយោគប្រភេទនេះ ត្រូវបានហាមឃាត់ ឬកម្រិតក្នុងការធ្វើអាជីវកម្ម ដោយអនុលោមតាម បទបញ្ញត្តិណែនាំរបស់ក្រុមហ៊ុនវិនិយោគបរទេស ដែលបានចងក្រងដោយ គណៈកម្មាធិការរៀបចំផែនការរដ្ឋរួមជាមួយនឹងនាយកដ្ឋានពាក់ព័ន្ធ ក្រោមការត្រួតពិនិត្យរបស់ក្រុមប្រឹក្សារដ្ឋរបស់សាធារណៈរដ្ឋប្រជាមានិតចិន។

**១.៤. ក្រុមហ៊ុនវិនិយោគបរទេសទទួលខុសត្រូវតាមកម្រិតភាគហ៊ុន (Foreign Investment Enterprises Limited by Shares)**

ក្រុមហ៊ុនវិនិយោគបរទេសទទួលខុសត្រូវមានកម្រិត សំដៅទៅលើក្រុមហ៊ុនសាជីវកម្ម ដែលមានដើមទុនសរុបស្មើនឹងតម្លៃហ៊ុនសរុបរបស់ក្រុមហ៊ុន ហើយសមាជិកហ៊ុនម្នាក់ៗទទួលខុសត្រូវតាមកម្រិតភាគហ៊ុនដែលខ្លួនបានទិញតែប៉ុណ្ណោះ ដោយមិនយកទ្រព្យសម្បត្តិទាំងអស់របស់ម្ចាស់ភាគហ៊ុន ទៅទូទាត់ជាមួយបំណុលរបស់ក្រុមហ៊ុនឡើយ។ ក្រុមហ៊ុននេះមានភាគហ៊ុនដែលត្រូវបានកាន់កាប់រួមគ្នាដោយជនជាតិចិន និងជនជាតិបរទេសដោយក្នុងភាគហ៊ុនដែលទិញនិងកាប់កាប់ដោយជនបរទេស មានលើសពី ២៥% នៃដើមទុនរបស់ក្រុមហ៊ុនដែលបានចុះបញ្ជី។ ក្រុមហ៊ុនអាចអនុម័តនូវវិធីភាគហ៊ុនអណ្តែត(Share float method)ដើម្បីបង្កើតក្រុមហ៊ុន។ ដើមទុនរបស់ក្រុមហ៊ុនដែលធ្វើការចុះបញ្ជី ត្រូវមានចំនួនស្មើនឹងចំនួនដើមទុនសរុប(គិតបញ្ចូលទាំងភាគហ៊ុនដែលនឹងចេញនាពេលបន្ទាប់) ដែលក្រុមហ៊ុនបានធ្វើការចុះបញ្ជីជាមួយនឹងអាជ្ញាធរទទួលបន្ទុកចុះបញ្ជី។ ចំនួនអប្បរមានៃដើមទុនដែលត្រូវចុះបញ្ជីសម្រាប់ក្រុមហ៊ុនមួយគឺ30 000 000 00 RMB។

**១.៥. ក្រុមហ៊ុនវិនិយោគទុនបរទេស ( Investment -Type Companies/ Investment Companies)**

ក្រុមហ៊ុនវិនិយោគទុនបរទេស ឬក្រុមហ៊ុនចំណែកហ៊ុន (Holding Companies) សំដៅទៅដល់ក្រុមហ៊ុនទាំងឡាយណាដែលបានបង្កើតឡើងនៅក្នុងប្រទេសចិន ដោយអាជីវកម្ម មូលនិធិបរទេសតែមួយគត់ ឬអាជីវកម្មតែមួយគត់ដែលបានបង្កើតឡើងដោយវិនិយោគិនចិន ដោយបានផ្សាភ្ជាប់ក្នុងការវិនិយោគផ្ទាល់។ ក្រុមហ៊ុននេះត្រូវធ្វើការចុះបញ្ជីមូលធនដែលមូលធនសរុបមិនតិចជាង៣០លានដុល្លាអាមេរិក។ វិសាលភាពនៃក្រុមហ៊ុនវិនិយោគនេះ គឺត្រូវបានកំណត់ដោយច្បាប់ប្រទេសចិន។

**១.៦. កិច្ចសន្យាសាងសង់ -អាជីវកម្ម -ផ្ទេរ (Built-Operate-Transfer)**

កិច្ចសន្យាសាងសង់-អាជីវកម្ម-ផ្ទេរ គឺជាប្រភេទ វិនិយោគអាជីវកម្មឯកជន ដែលត្រូវបានប្រើប្រាស់ដោយរដ្ឋាភិបាលក្នុងការសាងសង់ហេដ្ឋារចនាសម្ព័ន្ធ។ រហូតមកដល់បច្ចុប្បន្ន BOT ត្រូវបានប្រើប្រាស់ដោយរដ្ឋាភិបាលចិន ក្នុងការលើកទឹកចិត្តដល់វិនិយោគបរទេសក្នុងការវិនិយោគក្នុងគម្រោងហេដ្ឋារចនាសម្ព័ន្ធ។ ការប្តេជ្ញារបស់រដ្ឋាភិបាល គឺជាកត្តាដ៏សំខាន់សម្រាប់BOT ប៉ុន្តែការប្តេជ្ញារបស់រដ្ឋាភិបាលនេះពុំមែនបានមកដោយស្រួលឡើយ។

# ជំពូកទី២

# ឱកាសចំពោះការវិនិយោគនៃប្រទេសកម្ពុជា និងប្រទេសចិន

# ជំពូកទី ២

# ឱកាសចំពោះការវិនិយោគនៃប្រទេសកម្ពុជា និងប្រទេសចិន

ជាទូទៅដើម្បីជំរុញអោយមានការវិនិយោគកើនឡើងនៅក្នុងប្រទេសនោះ រដ្ឋាភិបាលតែងតែព្យាយាមធ្វើខ្លួនយ៉ាងណាអោយក្លាយទៅជាទីចំណាប់អារម្មណ៍របស់អ្នកវិនិយោគ មិនថាចំពោះវិនិយោគិនជាតិ ឬ បរទេសនោះឡើយ។ ពិតណាស់ដើម្បីអន្ទងចិត្តវិនិយោគិនទាំងនោះ អោយមកធ្វើការវិនិយោគនៅក្នុងប្រទេសរបស់ខ្លួននោះ រាជរដ្ឋាភិបាលកម្ពុជា ក៏ដូចជារដ្ឋាភិបាលនៃសាធារណៈប្រជាមានិតចិន បានរិះរកនូវគោលនយោបាយសំខាន់ៗ ដែលអាចដាក់ចេញអោយអនុវត្តនឹងប្រកបទៅដោយប្រសិទ្ធិភាពខ្ពស់។ ដូចនេះដើម្បីអោយដឹងថា តើមានគោលនយោយបាយសំខាន់ៗអ្វីខ្លះដែលបានដាក់ចេញដោយរដ្ឋាភិបាលកម្ពុជា និងចិននោះ យើងនឹងធ្វើការបកស្រាយនៅក្នុង **ផ្នែកទី១: គោលនយោបាយការជំរុញអោយមានការវិនិយោគនៅប្រទេសកម្ពុជា និងប្រទេសចិន** ។ ស្របពេលជាមួយគ្នានោះ ដើម្បីជំរុញឲ្យមានសន្ទុះនៃការវិនិយោគនៅក្នុងប្រទេសរបស់ខ្លួនកាន់តែខ្លាំងក្លានោះ រដ្ឋាភិបាលនៃប្រទេសទាំងពីរក៏បានដាក់ចេញនូវយុទ្ធសាស្ត្រក្នុងការលើកទឹកចិត្ត ក៏ដូចជាធ្វើការធានាផ្សេងៗ ទៅលើគម្រោងវិនិយោគដែលបានបង្កើតឡើងផងដែរ ដែលត្រូវសិក្សានៅក្នុង**ផ្នែកទី២ : យុទ្ធសាស្ត្រនៃការជំរុញអោយមានការវិនិយោគនៅប្រទេសកម្ពុជា និង ប្រទេសចិន**។

## ផ្នែកទី១: គោលនយោបាយការជំរុញអោយមានការវិនិយោគនៅប្រទេសកម្ពុជា និងប្រទេសចិន

### កថាខណ្ឌទី១: គោលនយោបាយការជំរុញអោយមានការវិនិយោគនៅប្រទេសកម្ពុជា

#### ១. អត្ថន័យនៃគោលនយោបាយ

##### ១.១. អភិបាលកិច្ចល្អ

អភិបាលកិច្ចល្អតម្រូវឲ្យមានការចូលរួមយ៉ាងទូលំទូលាយ មានការលើកកម្ពស់ ការរំលែកពត៌មាន មានគណនេយ្យភាព និងតម្លាភាពមានលក្ខណៈស្មើភាព និងមានការប្រតិបត្តិតាមវិធាននៃច្បាប់។ ការអនុវត្តបាននូវអភិបាលកិច្ចល្អ នឹងធានាអោយមានការកាត់បន្ថយអំពើពុករលួយអោយស្ថិតនៅក្នុងកំរិតអប្បរមា ដើម្បីសម្រេចបាននូវគោលដៅនេះ រដ្ឋាភិបាលនឹងជំរុញការអនុម័តច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ និងការបង្កើតស្ថាប័នឯករាជ្យអព្យាក្រឹតមួយសម្រាប់ប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ ព្រមទាំងជំរុញការលើកកម្ពស់ប្រសិទ្ធិភាព តម្លាភាព និងគណនេយ្យភាពក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជាពិសេសតាមរយៈការពង្រឹងការងារសវនកម្ម និងលទ្ធកម្ម

សាធារណៈ។ អភិបាលកិច្ចល្អ គឺជាស្នូលនៃយុទ្ធសាស្ត្រចតុកោណរបស់រដ្ឋាភិបាលដែលធ្វើការពង្រឹងអភិបាលកិច្ចពីថ្នាក់កណ្តាលរហូតដល់មូលដ្ឋាន ការធ្វើកំណែទម្រង់អភិបាលកិច្ចល្អនេះ ដើម្បីធានាភាពយុត្តិធម៌ និងតម្លាភាពជូនប្រជាពលរដ្ឋ ជាពិសេសចំពោះអ្នកវិនិយោគទុន ដើម្បីធានានូវតម្លាភាពជូនដល់អ្នកវិនិយោគទុនទាំងអស់ដែលចូលមកវិនិយោគនៅកម្ពុជា។ រាជរដ្ឋាភិបាលបានបញ្ញាត្តិ និងកំណត់ពីកំណែទម្រង់នីតិវិធីមួយចំនួននៅក្នុងគណៈកម្មាធិការវិនិយោគកម្ពុជា សំដៅជំរុញឲ្យបានឆាប់រហ័ស និងកាត់បន្ថយការិយាល័យអធិបតេយ្យក្នុងដំណើរការចុះបញ្ជី និងផ្តល់ការអនុញ្ញាតដល់បណ្តាអ្នកវិនិយោគទុនណា ដែលស្វែងរកអភ័យឯកសិទ្ធិតាមច្បាប់វិនិយោគ និងមានការធ្វើវិសោធនកម្មច្បាប់វិនិយោគដើម្បីធ្វើឲ្យអ្នកវិនិយោគទុកចិត្ត និងធ្វើការលើកទឹកចិត្តច្រើនដល់អ្នកវិនិយោគទុនដែលមកវិនិយោគនៅកម្ពុជាដូចដែលមានកំណត់នៅក្នុងច្បាប់វិនិយោគ និងអនុក្រឹត្យមួយចំនួនដែលពាក់ព័ន្ធ។

**១.២. តំបន់សេដ្ឋកិច្ចពិសេស**

អនុលោមតាមយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាបានបង្ហាញពីបំណងកាត់បន្ថយភាពក្រីក្រ បង្កើនការងារជូនប្រជាពលរដ្ឋ និងធ្វើអោយសេដ្ឋកិច្ចជាតិមានការរីកចម្រើន និងជួយសម្រួលដល់ការអភិវឌ្ឍរបស់ប្រទេស រដ្ឋាភិបាលកម្ពុជាបានបង្ហាញការចាប់អារម្មណ៍យ៉ាងខ្លាំងក្នុងការបង្កើនការនាំចេញរបស់ខ្លួន តាមរយៈតំបន់សេដ្ឋកិច្ចពិសេស(SEZs)។ រដ្ឋាភិបាលបានអនុម័តអនុក្រឹត្យស្តីពីការបង្កើតតំបន់សេដ្ឋកិច្ចពិសេសដែលបានកំណត់តំបន់សេដ្ឋកិច្ចពិសេស និងការបង្កើតវិធានច្បាប់ប្រព្រឹត្តទៅរបស់តំបន់ទាំងនោះ។ នៅខែធ្នូឆ្នាំ២០១៥ គណៈរដ្ឋមន្ត្រីបានអនុម័តអនុក្រឹត្យស្តីពីការបង្កើតនិងការគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេសដើម្បីបង្កើនល្បឿននៃការវិនិយោគ។ ចាប់តាំងពីការអនុវត្តន៍អនុក្រឹត្យនេះ ក្រុមប្រឹក្សាភិបាលតំបន់សេដ្ឋកិច្ចពិសេសកម្ពុជាបានអនុម័ត២៥តំបន់សេដ្ឋកិច្ចពិសេស ដែលមាន៩(ប្រាំបួន)តំបន់កំពុងដំណើរការ។ តំបន់សេដ្ឋកិច្ចពិសេសទាំងនេះមានទីតាំងស្ថិតនៅក្បែរព្រំដែនប្រទេសថៃនិងវៀតណាម និងនៅក្នុងរាជធានីភ្នំពេញ ខេត្តកំពត និងក្រុងព្រះសីហនុ ចំណែកឯតំបន់ផ្សេងទៀតកំពុងស្ថិតនៅក្នុងដំណាក់កាលផ្សេងគ្នានៃការអភិវឌ្ឍនិងមួយចំនួននៅតែកំពុងអភិវឌ្ឍ។ អនុក្រឹត្យស្តីពីការបង្កើតនិងការគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេសបានកំនត់ពីនីតិវិធីលក្ខខណ្ឌ និងការលើកទឹកចិត្តសម្រាប់វិនិយោគិនក្នុងតំបន់ផងដែរ។ ការបង្កើតតំបន់សេដ្ឋកិច្ចពិសេសនេះ គឺដើម្បីបង្កើនបរិយាសកាសវិនិយោគ ដែលអំណោយផលដល់ការធ្វើឲ្យកាន់តែប្រសើរឡើងនូវផលិតភាពក្នុងការផលិតទំនិញ ការប្រជែងឈ្នះជំរុញការនាំចេញដោះស្រាយការងារជូនប្រជាពលរដ្ឋដើម្បីកាត់បន្ថយភាព

ក្រីក្រ។ ជាងនេះទៅទៀតការកំណត់អំពីនីតិវិធីនិងបទបញ្ញាត្តិទាំងឡាយដែលទាក់ទងដល់ការបង្កើត ការគ្រប់គ្រង សម្របសម្រួលរាល់ការវិនិយោគ និងជំរុញការលើកទឹកចិត្តការដល់វិនិយោគរបស់អ្នកអភិវឌ្ឍន៍តំបន់ អ្នកវិនិយោគក្នុងតំបន់សេដ្ឋកិច្ចពិសេសនៅក្នុងព្រះរាជាណាចក្រកម្ពុជា[32]។ យោងតាមគោលដៅខាងលើនេះ រាជរដ្ឋាភិបាលនឹងលើកស្ទួយតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា ដើម្បីអនុវត្តនូវគោលការណ៍នឹងលក្ខខណ្ឌដែលធានាបាននូវតម្លាភាព និងប្រតិបត្តិការឆាប់រហ័ស គណនេយ្យភាពចំពោះអ្នកវិនិយោគ ការទទួលបាននូវតម្រូវការពត៌មាន និងភាពស៊ីចង្វាក់គ្នាទៅជាមួយនឹងកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលដែលបានដាក់ចុះកន្លងមក។ តំបន់សេដ្ឋកិច្ចពិសេសត្រូវបានអនុញ្ញាតឲ្យបង្កើតឡើងនៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា នៅតាមតំបន់សមស្រប និងប្រកបដោយយុទ្ធសាស្ត្រតាមការសម្រេចរបស់រាជរដ្ឋាភិបាលកម្ពុជា ដោយអនុលោមតាមស្មារតីសម្រេចរបស់យន្តការច្រកចេញតែមួយនៃក្រុមប្រឹក្សា[33]។ ដោយមានការកំណត់ពីតំបន់សេដ្ឋកិច្ចពិសេសនេះ វាបានធ្វើអោយអ្នកវិនិយោគទុនមានការចាប់អារម្មណ៍យ៉ាងខ្លាំង និងចូលមកវិនិយោគនៅតំបន់នោះ ពីព្រោះនៅក្នុងអនុក្រឹត្យស្តីពីការបង្កើត និងការគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេស បានលើកទឹកចិត្តយ៉ាងច្រើនដល់វិនិយោគិនគ្រប់រូបនៅក្នុងតំបន់សេដ្ឋកិច្ចពិសេស ដូចជាមានការលើកលែងពន្ធលើប្រាក់ចំណេញ និងពន្ធផ្សេងៗទៀតដែលមានកំណត់នៅក្នុងអនុក្រឹត្យនេះ។

អ្នកវិនិយោគនៅតំបន់សេដ្ឋកិច្ចពិសេសត្រូវបំពេញនូវលក្ខខណ្ឌមួយចំនួនខាងក្រោម៖

១-អ្នកអភិវឌ្ឍន៍តំបន់[34]ទាំងឡាយ ដែលមានបំណងចង់បណ្តាក់ទុនធ្វើការអភិវឌ្ឍន៍តំបន់សេដ្ឋកិច្ចពិសេសនៅភូមិសាស្ត្រណាមួយ ត្រូវធ្វើសំណើសុំគោលការណ៍អភិវឌ្ឍន៍តំបន់គណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា និងចុះបញ្ជីជាគម្រោងវិនិយោគដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ជាមុនសិន។ គណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជាមានភារកិច្ចធ្វើការសន្និដ្ឋានលើសំណើ ហើយលើកយកយោបល់ដាក់ជូនកិច្ចប្រជុំច្រកចេញ-ចូលតែមួយនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាដើម្បីធ្វើការសម្រេចផ្តល់គោលការណ៍ ឬបដិសេធគោលការណ៍សុំបង្កើតតំបន់។ អ្នកអភិវឌ្ឍ

[32] មាត្រា ១ ចំណុច ១.១ នៃអនុក្រឹត្យស្តីអំពីការបង្កើត និងការគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេស ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៥។

[33] មាត្រា ៣ ចំណុច ៣.១(១) នៃអនុក្រឹត្យស្តីអំពីការបង្កើត និងការគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេស ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៥។

[34] អ្នកអភិវឌ្ឍន៍តំបន់: សំដៅដល់អ្នកអនុវត្តគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ទោះជារូបវន្តបុគ្គល ឬនីតិបុគ្គលមានសញ្ជាតិខ្មែរក្តី ឬនិងបរទេសក្តី ដែលបានទទួលអនុញ្ញាតឲ្យធ្វើការវិនិយោគទុនដើម្បីអភិវឌ្ឍន៍សាងសង់ហេដ្ឋារចនាសម្ព័ន្ធរូបវន្តនៅក្នុងតំបន់ និងចាត់តាំងការធ្វើអាជីវកម្ម សេវាកម្ម ផ្តល់សុវត្ថិភាពផ្នែកសន្តិសុខនានា បម្រើឲ្យអ្នកវិនិយោគក្នុងតំបន់។

តំបន់ត្រូវបង់ថ្លៃដាក់ពាក្យសុំបង្កើតតំបន់សេដ្ឋកិច្ចពិសេសនៅពេលដាក់ពាក្យចំនួន៧.០០០.០០០(ប្រាំពីរលាន)រៀល។

២-គណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា ត្រូវឆ្លើយតបអំពីលទ្ធផលវិជ្ជមាន ឬអវិជ្ជមានរបស់សំណើក្នុងរយៈពេលយ៉ាងយូរបំផុត២៨(ម្ភៃប្រាំបី)ថ្ងៃនៃថ្ងៃធ្វើការ ជូនទៅអ្នកអភិវឌ្ឍន៍តំបន់វិញ។

៣-អ្នកអភិវឌ្ឍន៍តំបន់ ដែលបានទទួលគោលការណ៍ឲ្យអភិវឌ្ឍន៍ពីគណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា អាចមានពេលចំនួន១៨០(មួយរយប៉ែតសិប)ថ្ងៃនៃថ្ងៃធ្វើការ និងអាចពន្យារបានក្នុងករណីមានមូលហេតុច្បាស់លាស់ ដើម្បីធ្វើគម្រោងសិក្សាសមិទ្ធិភាពសេដ្ឋកិច្ចលម្អិត ដែលរួមមានការបង្ហាញប្លង់មេ ស្តីពីបណ្តាហេដ្ឋារចនាសម្ព័ន្ធតំបន់ ផ្លូវគមនាគមន៍ ភ្ជាប់ពីក្នុងតំបន់មកក្រៅ ប្រព័ន្ធទឹក-ភ្លើង ប្រព័ន្ធការពារបរិស្ថាន តម្លៃសេវាកម្មនានាក្នុងតំបន់ តម្លៃជួលដី ជួលរោងចក្រ ទឹក ភ្លើង ទូរស័ព្ទ សន្តិសុខ និងតម្លៃប្រើប្រាស់ទីលានសាធារណៈក្នុងតំបន់របស់អ្នកវិនិយោគទុនក្នុងតំបន់ សម្រាប់កម្មវនិយោជិត និយោជកស្នាក់នៅនិងមណ្ឌលបណ្តុះបណ្តាល។ល។ ឯកសារដែលពាក់ព័ន្ធនានា ឬលិខិតបញ្ជាក់ផ្សេងៗទៀត ដែលគណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជាតម្រូវទៅតាមសំណូមពររបស់ក្រសួង ស្ថាប័នមានសមត្ថកិច្ច ដោយតម្រូវការទាំងនោះ ត្រូវកំណត់នៅក្នុងវិញ្ញាបនបត្រចុះបញ្ជីមានលក្ខខណ្ឌជូនអ្នកអភិវឌ្ឍន៍តំបន់។

៤-ក្នុងរយៈពេលយ៉ាងយូរ១០០(មួយរយ)ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃដែលអ្នកអភិវឌ្ឍន៍តំបន់ដាក់គម្រោងជូនគណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា ដូចមានចែងក្នុងកថាខណ្ឌខាងលើគណៈកម្មាធិការតំបន់សេដ្ឋកិច្ចសពិសេសកម្ពុជា ត្រូវទទួលយកជំនួសមុខឲ្យអ្នកអភិវឌ្ឍន៍តំបន់នូវការយល់ព្រម ការអនុញ្ញាត អាជ្ញាប័ណ្ណ លិខិតរាជរដ្ឋាភិបាល ដែលមានភារកិច្ចផ្តល់ឯកសារទាំងនោះ ព្រមជាមួយគ្នានេះដែរ ការចេញជូនវិញ្ញាបនបត្រចុះបញ្ជីជាស្ថាពរដល់អ្នកអភិវឌ្ឍន៍ តំបន់តាមការកំណត់នៃកថាខណ្ឌនេះ។

៥-ការបង្កើតតំបន់សេដ្ឋកិច្ចពិសេស និងព្រំដែនខ័ណ្ឌសីមារបស់តំបន់សេដ្ឋកិច្ចពិសេសនីមួយៗ និងត្រូវកំណត់ដោយអនុក្រឹត្យ ស្របពេលដែលគណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា ផ្តល់វិញ្ញាបនបត្រចុះបញ្ជីជាស្ថាពរជូនអ្នកអភិវឌ្ឍ៍តំបន់[35]។

---

[35] មាត្រា ៣ ចំណុច ៣.២ (១) , (២) , (៣) , (៤) , និង (៥) នៃអនុក្រឹត្យស្តីអំពីការបង្កើត និងការគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេស ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ ២០០៥។

**១.៣. ការប្រើប្រាស់ដីធ្លី**

វិនិយោគគិនទាំងអស់ ត្រូវបានអនុញ្ញាតដោយរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាអោយមានសិទ្ធិប្រើប្រាស់ដីធ្លីនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ប៉ុន្តែពុំមែនមានន័យថា វិនិយោគគិនទាំងនោះមិនមែនសុទ្ធតែក្លាយជាកម្មសិទ្ធិករលើដីធ្លីទាំងនោះទេ។ មានតែរូបវន្តបុគ្គល ឬនីតិបុគ្គលដែលមានសញ្ជាតិជាខ្មែរទេ ទើបមានសិទ្ធិជាកម្មសិទ្ធិករលើដីធ្លី[36]។ វិនិយោគិនអាចទទួលបានសិទ្ធិក្នុងការប្រើប្រាស់តាមរយៈកិច្ចសន្យាសម្បទាន ឬកិច្ចសន្យាជួល។ ការទទួលបានដីសម្បទានសេដ្ឋកិច្ចយ៉ាងធំបំផុតត្រឹមតែ១០.០០០(មួយម៉ឺន) ហិចតា តែប៉ុណ្ណោះ[37] កិច្ចសន្យាសម្បទានមានរយៈពេល៩៩ឆ្នាំ[38] ក្នុងន័យនេះរយៈពេលសម្រាប់សម្បទានអាចមានរយៈពេលតិចជាងរយៈពេល៩៩ឆ្នាំ ប៉ុន្តែមិនអាចមានរយៈពេលលើសពី៩៩ឆ្នាំបានឡើយ។ ដីសម្បទានមិនអាចប្រគល់ឲ្យដល់ឥតគិតថ្លៃទេ[39] មានន័យថា អ្នកវិនិយោគិនទាំងអស់ដែលទទួលបានដីសម្បទានសេដ្ឋកិច្ច ត្រូវតែមានការបង់ថ្លៃទៅតាមកិច្ចសន្យាសម្បទានដែលបានកំណត់ ហើយនៅពេលដែលផុតរយៈពេលកំណត់នៅក្នុងកិច្ចសន្យាដី សម្បទានសេដ្ឋកិច្ចនោះ ការកាន់កាប់ និងការប្រើប្រាស់ក៏ត្រូវចប់ផងដែរ។

វិនិយោគគិនអាចទទួលបានដីធ្លីប្រើប្រាស់តាមរយៈកិច្ចសន្យា អាចជាការជួលរយៈពេលមិនកំណត់ និងការជួលរយៈពេលកំណត់។ ការជួលរយៈពេលកំណត់មានការជួលរយៈពេលខ្លីអាចបន្តជាថ្មីបាន និងការជួលរយៈពេលវែង១៥ឆ្នាំ ឬលើសការជួលត្រូវធ្វើឡើងតាមរយៈកិច្ចសន្យាជួល។ នីតិបុគ្គលសញ្ជាតិបរទេសអាចប្រើប្រាស់ដីធ្លីតាមរូបភាពផ្សេងៗ ដូចជាសម្បទាន និងការជួលការប្រើប្រាស់ដីធ្លីនេះរាប់បញ្ចូលទាំងសិទ្ធិលើសំណង់ ការរៀបចំ ឬការកែលម្អទាំងឡាយដែលបានធ្វើឡើងដោយអ្នកជួសជុលក្នុងរយៈពេលកំណត់នៃកិច្ចសន្យា តែត្រូវអនុវត្តតាមច្បាប់ជាធរមាន។ អ្នកវិនិយោគមានសិទ្ធិកាន់កាប់ និងដាក់បញ្ចាំសម្រាប់ធានា និងផ្ទេរនូវចលនទ្រព្យ និងអចលនទ្រព្យដែលស្ថិតនៅលើដី និងដីគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ប្រើប្រាស់ដោយរយៈពេលមិនលើសពីរយៈដែលមានកំណត់នៅក្នុងកិច្ចសន្យា ឬកិច្ចសន្យាជួលដូចដែលបានអនុញ្ញាតដោយច្បាប់ភូមិបាល២០០១ ចំពោះដីសម្បទានណា ដែលពុំទាន់បានដំណើរការ អ្នកវិនិយោគមិនអាចផ្ទេរ ឬបញ្ចាំបន្តទៀតជាដាច់ខាត[40]។

---

[36] មាត្រា ៤៤ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣។

[37] មាត្រា ៥៩ នៃច្បាប់ភូមិបាលឆ្នាំ២០០១។

[38] មាត្រា ៦១ នៃច្បាប់ភូមិបាលឆ្នាំ២០០១។

[39] មាត្រា ៥១ នៃច្បាប់ភូមិបាលឆ្នាំ២០០១។

[40] មាត្រា ១៦ នៃច្បាប់វិសោធនកម្មច្បាប់វិនិយោគនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៣។

## កថាខណ្ឌទី២: គោលនយោបាយនៃការជំរុញអោយមានការវិនិយោគនៅប្រទេសចិន

### ១. អត្ថន័យនៃគោលនយោបាយ

#### ១.១. Going Global

គោលនយោបាយ "Going Global" ត្រូវបានបង្កើតឡើងសភាប្រជាជនជាតិ តាំងពីឆ្នាំ ២០០១។ ដោយសារតែការអនុវត្តប្រកបដោយភាពជោគជ័យ គោលនយោបាយនេះ ត្រូវបានចែកចេញជាបីដំណាក់កាលៈ ដំណាក់កាលទី១ Tenth 5 Year Plan (2001-2005), ដំណាក់កាលទី២ Eleventh 5 Year plan(2006-2010), Twelfth 5 Year plan(2011-2015)[41]។ ប៉ុន្តែខាងក្រោមនេះនឹងលើយកតែគម្រោងចុងក្រោយមកពិភាក្សាតែប៉ុណ្ណោះ៖

គម្រោងប្រាំឆ្នាំ( ២០១១-២០១៥) ត្រូវបានអនុវត្តចាប់តាំងពីខែមិនា ឆ្នាំ២០១១។ សាធារណៈរដ្ឋប្រជាមានិតចិន បានបន្តការរួមបញ្ចូលនូវគោលនយោបាយ" Bring in" និង"Bring Out"[42] បន្តយកចិត្តទុកដាក់ក្នុងវិស័យវិនិយោគទាំងវិនិយោគបរទេសនៅក្នុងប្រទេសចិន និងវិនិយោគចិននៅឯបរទេស ក្នុងគោលបំណងបង្កើននូវទីផ្សារ និងការប្រើប្រាស់ធនធានអោយកាន់តែមានសុវត្ថិភាព និងប្រសិទ្ធិភាព។ ការបង្កើននូវកម្រិតប្រើប្រាស់ធនធានធ្វើអោយសាធារណៈរដ្ឋប្រជាមានិតចិនមានភាពប្រសើរឡើងខាងរចនាសម្ព័ន្ធមូលធនបរទេស ការណែនាំ ការវិនិយោគបរទេសសម្រាប់វិស័យនានា បច្ចេកវិទ្យាចុងក្រោយ ភាពរីកចម្រើនខាងផ្នែកផលិតកម្ម ការអភិរក្សធនធានរ៉ែ និងសេវាកម្មឧស្សាហកម្មជាដើម។ ហើយវាក៏បានលើកទឹកចិត្តផងដែរ ដល់វិនិយោគិននានាអោយមកបណ្តាក់ទុននៅក្នុងភាគកណ្តាលនិងភាគខាងលិចនៃប្រទេសចិន។

សាធារណៈរដ្ឋប្រជាមានិតចិន ក៏បានជំរុញអោយវិនិយោគិនក្នុងការប្រើប្រាស់មធ្យាបាយផ្សេងៗគ្នាដូចជាការទិញភាគហ៊ុន ការបណ្តាក់ទុនរួមគ្នាជាដើមក្នុងការដាក់បញ្ចូលគ្នានូវសហគ្រាសក្នុងស្រុកផងដែរ។ សាធារណៈរដ្ឋប្រជាមានិតចិន ក៏បាននាំមកនូវអ្នកជំនាញ និងបច្ចេកវិទ្យាពីបរទេសក៏ដូចជាប្រព័ន្ធនៃការគ្រប់គ្រងជាលក្ខណៈអន្តរជាតិ ក្នុងគោលដៅធ្វើសមាហរណកម្មទីផ្សាររបស់ចិនទៅក្នុងពិភពលោក ធ្វើអោយប្រសើរឡើងនូវបរិបទវិនិយោគនៅក្នុងប្រទេស ក៏ដូចជាធានានិងការពារដល់សិទ្ធិស្របច្បាប់របស់វិនិយោគិនផងដែរ។

ម្យ៉ាងវិញទៀត សាធារណៈរដ្ឋប្រជាមានិតចិន ក៏បានបង្កើនល្បឿនក្នុងការអនុវត្តនូវគោលនយោបាយគម្រោង៥(ប្រាំ)ឆ្នាំ ដើម្បីអនុវត្តនូវគោលការណ៍ទីផ្សារ និងគោលការណ៍ស្ម័គ្រចិត្ត ដើម្បី

[41] IISD and IIER, Chinese Outward investment) an emerging policy framework, 22។

[42] IISD and IIER, Chinese Outward investment) an emerging policy framework, 22។

ណែនាំទៅដល់សហគ្រិនទាំងអស់ អំពីឥរិយាបថក្នុងការអភិវឌ្ឍ កិច្ចសហប្រតិបត្តិការនាក្រៅប្រទេស។

សាធារណៈរដ្ឋប្រជាមានិតចិន នឹងបន្តការអភិវឌ្ឍធនធានរ៉ែអោយកាន់តែស៊ីជម្រៅ និងដំណើរការសហប្រតិបត្តិការដែលផ្តល់ផលប្រយោជន៍រួម។ សាធារណៈរដ្ឋប្រជាមានិតចិននឹងគាំទ្រការអនុវត្តសហប្រតិបត្តិការបច្ចេកវិទ្យាវិនិយោគបរទេស និងលើកទឹកចិត្តសហគ្រាសឧស្សាហកម្មទាំងអស់ក្នុងការបង្កើតទីផ្សារអន្តរជាតិ និងបណ្តាញលក់ ក៏ដូចជាម៉ាកល្បីៗផងដែរ។ សាធារណៈរដ្ឋប្រជាមានិតចិន នឹងពង្រីកសហប្រតិបត្តិការអន្តរជាតិនៅក្នុងវិស័យកសិកម្មនិងអភិវឌ្ឍន៍គម្រោងកិច្ចសន្យាបរទេស សហប្រតិបត្តិការការងារដែលអាចធ្វើអោយមានភាពរីកចម្រើនខាងស្ថានភាពរស់នៅរបស់ប្រជាពលរដ្ឋក្នុងតំបន់។ សាធារណៈរដ្ឋប្រជាមានិតចិនក៏នឹងអភិវឌ្ឍន៍ជាបន្តបន្ទាប់នូវសហប្រតិបត្តិការឆ្លងប្រទេសទ្រង់ទ្រាយធំ និងស្ថាប័នហិរញ្ញវត្ថុឆ្លងប្រទេសផងដែរដើម្បីបង្កើននូវកម្រិតសហប្រតិបត្តិការអន្តរជាតិ។ ប្រទេសមួយនេះក៏នឹងមានគម្រោងធ្វើការសិក្សាស្រាវជ្រាវលើការវិនិយោគក្រៅប្រទេស និងបង្កើននូវគម្រោងវិនិយោគទាក់ទិនទៅនឹងការផ្លាស់ប្តូរវិទ្យាសាស្ត្រផងដែរ។ ប្រទេសចិនក៏នឹងបង្កើនសមត្ថភាពរបស់ខ្លួនឱ្យបានគ្រប់ជ្រុងជ្រោយទាំងអស់ ជុំវិញការពិចារណាលើការបង្កើនប្រសិទ្ធិភាពប្រព័ន្ធទីភ្នាក់ងារសម្របសម្រួលឆ្លងប្រទេស និងបង្កើននូវការណែនាំ និងសេវាកម្ម ដើម្បីអនុវត្តគោលនយោបាយ "Going Global"។

ការបង្កើតច្បាប់និងបទបញ្ញត្តិដែលផ្តោតទៅលើការវិនិយោគនៅក្រៅប្រទេស នឹងត្រូវបានពន្លឿន។ ប្រទេសចិនបានពិភាក្សាយ៉ាងសកម្មក្នុងការចុះកិច្ចព្រមព្រៀងស្តីអំពីការការពារការវិនិយោគ និងកិច្ចព្រមព្រៀងស្តីអំពីការជៀងវាងលើការយកពន្ធទ្វេដង ក៏ដូចជាកិច្ចព្រមព្រៀងទ្វេភាគី និងពហុភាគីផងដែរ។ ប្រព័ន្ធផ្សព្វផ្សាយវិនិយោគចិននៅឯបរទេស នឹងត្រូវធ្វើអោយកាន់តែប្រសើរឡើង ដើម្បីជួយសម្រួលដល់សហគ្រាសដែលវិនិយោគនៅឯបរទេស និងការការពារនូវសិទ្ធិវិនិយោគរបស់សហគ្រាសទាំងនោះ និងជៀសវាងនូវហានិភ័យផ្សេងៗដែលកើតឡើង។ សម្រាប់សហគ្រាសដែលវិនិយោគនៅឯបរទេស និងគម្រោងសហប្រតិបត្តិការបរទេសត្រូវកំណត់ពីការទទួលខុសត្រូវក្នុងការនាំមកនូវផលប្រយោជន៍សម្រាប់ប្រជាជនក្នុងតំបន់។

សាធារណៈរដ្ឋប្រជាមានិតចិន បានចូលរួមយ៉ាងសកម្មទាក់ទងនឹងអភិបាលកិច្ចសេដ្ឋកិច្ចពិភពលោក និងកិច្ចសហប្រតិបត្តិការក្នុងតំបន់ ក្នុងគោលបំណងពង្រីកការផ្លាស់ប្តូរ និងកិច្ចសហប្រតិបត្តិការជាមួយប្រទេសអភិវឌ្ឍន៍ដើម្បីបង្កើននូវទំនុកចិត្ត និងសហប្រតិបត្តិការខ្ពស់ជាមួយប្រទេសទាំងនោះ។ ជាមួយគ្នានេះ សាធារណៈរដ្ឋប្រជាមានិតចិន ក៏បានបង្កើតទំនាក់ទំនងយ៉ាង

ជិតស្និទ្ធិ និងកិច្ចសហប្រតិបត្តិការយូរអង្វែងជាមួយប្រទេសជិតខាងដើម្បីធានាដល់សន្តិភាពនិង ស្ថេរភាព ក៏ដូចជាភាពរីកចម្រើននៅក្នុងតំបន់។ យ៉ាងណាមិញប្រទេសចិនក៏នឹងពង្រឹងកិច្ចសហប្រតិបត្តិការជាមួយនឹងប្រទេសកំពុងអភិវឌ្ឍន៍ផងដែរ ដើម្បីរក្សាផលប្រយោជន៍រួមនឹងទំនាក់ទំនងបែបប្រពៃណីជាមួយគ្នា។ កិច្ចសហប្រតិបត្តិការពហុភាគី ក៏ត្រូវបានធ្វើអោយប្រសើរឡើងផងដែរ។ សាធារណៈរដ្ឋប្រជាមានិតចិន នឹងជំរុញអោយមានការកែទម្រង់ប្រព័ន្ធសេដ្ឋកិច្ចអន្តរជាតិ ដើម្បីអោយមានការអភិវឌ្ឍន៍ប្រកបដោយយុត្តិធម៌និងចំគោលដៅ។

សាធារណៈប្រជាមានិតចិននឹងចូលរួមក្នុងយន្តការអភិបាលកិច្ចសេដ្ឋកិច្ចសកលរបស់ G20 ដើម្បីលើកតម្កើង និងកសាងបន្ថែមនូវស្ថានភាពដែលមានតុល្យភាព និងភាពឈ្នះៗក្នុងប្រព័ន្ធពាណិជ្ជកម្មពហុភាគី។ លើសពីនេះទៀតសាធារណៈរដ្ឋប្រជាមានិតចិននឹងលើកតម្កើងយ៉ាងសកម្មនូវកំណែទម្រង់នៃប្រព័ន្ធហិរញ្ញវត្ថុអន្តរជាតិ និងរូបិយប័ណ្ណអន្តរជាតិផងដែរ។ កិច្ចសហប្រតិបត្តិការជាមួយនឹងគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចរបស់ស្ថាប័នធំៗនឹងត្រូវបានពង្រឹងបន្ថែម។ ចុងបញ្ចប់សាធារណៈរដ្ឋប្រជាមានិតចិននឹងចូលរួមយ៉ាងសកម្មក្នុងការពង្រាង និងធ្វើវិសោធនកម្មលើគោលការណ៍ និងស្តង់ដារអន្តរជាតិដើម្បីបង្កើនឥទ្ធិពលរបស់ខ្លួននៅក្នុងអង្គការហិរញ្ញវត្ថុ និងសេដ្ឋកិច្ចអន្តរជាតិ។ សាធារណៈរដ្ឋប្រជាមានិតចិន ក៏នឹងពន្លឿននូវការបង្កើតតំបន់សេដ្ឋកិច្ចសេរី ព្រមទាំងបង្កើននូវកិច្ចសហប្រតិបត្តិការស៊ីជម្រៅ ជាមួយនឹងប្រទេសដែលមានភាពលូតលាស់ខាងសេដ្ឋកិច្ចផងដែរ។

សាធារណៈរដ្ឋប្រជាមានិតចិន ក៏បានកំពុងពិចារណាពីការតែប្រើ APEC ក៏ដូចជាយន្តការក្នុងតំបន់ ឬយន្តការអន្តរជាតិ ក្នុងការជំរុញអោយមាននូវកិច្ចសហប្រតិបត្តិការក្នុងតំបន់ក៏ដូចជាទំនាក់ទំនងជាមួយប្រទេសក្នុងតំបន់។

## កថាខណ្ឌទី៣: ការរៀបចំគោលនយោបាយនៃការជំរុញអោយមានការវិនិយោគរវាង ប្រទេសកម្ពុជា និងប្រទេសចិន

### ១. អត្ថន័យនៃគោលនយោបាយ

នៅប្រទេសកម្ពុជា រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា បានផ្តោតសំខាន់លើការវិនិយោគយ៉ាងខ្លាំងដោយធ្វើយ៉ាងណាទាក់ទាញ អ្នកវិនិយោគអោយបានច្រើនអោយមកបណ្តាក់ទុននៅក្នុងព្រះរាជាណាចក្រកម្ពុជា ពីព្រោះថាការកើនឡើងនូវអ្នកវិនិយោគគឺជាកម្លាំងចលករនៃការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិទាំងមូល។ ជាក់ស្តែងរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាបានបង្កើតនូវគោលការណ៍អភិបាលកិច្ចល្អ ដើម្បីជាការចូលរួមចំណែកក្នុងការលើកកម្ពស់ ការចែករំលែក និង

ការធានាអោយមាននូវតម្លាភាព ជូនដល់អ្នកវិនិយោគទាំងអស់ដែលបានចូលមកវិនិយោគនៅព្រះរាជាណាចក្រកម្ពុជា។ ជាងនេះទៀត រដ្ឋាភិបាលក៏បានដាក់ចេញនូវការគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេសតាមរយៈយុទ្ធសាស្ត្រចតុកោណ ដើម្បីជាការពន្លឿនដល់ការវិនិយោគនៅក្នុងប្រទេស។ ការបង្កើតនូវការគ្រប់គ្រងបែបនេះ គឺបានបង្កើតនូវបរិយកាសវិនិយោគដែលមានភាពអំណោយផលទៅដល់វិនិយោគិនទាំងអស់ដែលបានមកវិនិយោគនៅប្រទេសកម្ពុជា ហើយវាក៏បានជំរុញអោយមានការអភិវឌ្ឍនៅតំបន់ទាំងនោះផងដែរ។ អ្វីដែលសំខាន់ជាងនេះ រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា បានដាក់ចេញនូវកម្មវិធីនយោបាយសម្រាប់ការអភិវឌ្ឍ និងការទាក់ទាញការវិនិយោគផងដែរ ដោយរដ្ឋាភិបាលបានបន្តជំរុញ ការវិនិយោគក្នុងស្រុក និងជំរុញសហគ្រិនភាពដើម្បីពន្លឿនដល់ការអភិវឌ្ឍសេដ្ឋកិច្ចនិងការបង្កើតការងារ។ រដ្ឋាភិបាលក៏បានបន្តខិតខំធ្វើអោយបរិស្ថានវិនិយោគនៅព្រះរាជាណាចក្រកម្ពុជា កាន់តែមានភាពអំណោយផលនិងមានភាពប្រសើរឡើង ដើម្បីធ្វើអោយព្រះរាជាណាចក្រកម្ពុជា ក្លាយទៅជាគោលដៅវិនិយោគមួយដែលកាន់តែមានភាពទាក់ទាញនៅក្នុងតំបន់ និងបង្កើនបាននូវភាពប្រកួតប្រជែងនិងផលិតភាពកាន់តែខ្ពស់សម្រាប់ព្រះរាជាណាចក្រកម្ពុជា។ រដ្ឋាភិបាលក៏បានធានាដល់បរិស្ថានវិនិយោគប្រកបដោយអំណោយផលក្នុងការទទួលការវិនិយោគទាំងក្នុងប្រទេសនិងក្រៅប្រទេស ក្នុងការដាក់ចេញនូវវិធានសំខាន់ៗដែលផ្តោតសំខាន់លើការធានា ការសម្រួលពាណិជ្ជកម្ម ការលុបបំបាត់ចំណាយក្រៅផ្លូវការជាដើម។ ចំណែកឯនៅសាធារណៈរដ្ឋប្រជាមានិតចិនឯណោះវិញ រដ្ឋាភិបាលក៏បានយកចិត្តទុកដាក់យ៉ាងខ្លាំងក្នុងការធ្វើយ៉ាងណាអោយមានវិនិយោគិន មកបណ្តាក់ទុននៅប្រទេសចិនអោយបានច្រើន ដើម្បីជាការទ្រទ្រង់ដល់សេដ្ឋកិច្ចជាតិទាំងមូល។ គោលនយោបាយមួយ គឺគោលនយោបាយ"Going Global" ត្រូវបានបង្កើតឡើងតាំងពីឆ្នាំ២០០១ ដែលគោលនយោបាយនេះមានគោលបំណងក្នុងការបង្កើននូវកម្រិតទីផ្សារវិនិយោគនៅក្នុងប្រទេសចិន តាមរយៈការបង្កើតទីផ្សារវិនិយោគ និងធ្វើអោយមានភាពប្រសើរឡើងនូវវិស័យនានា ក៏ដូចជាការប្រព័ន្ធបច្ចេកវិទ្យាចុងក្រោយ។ ហើយគោលនយោបាយនេះក៏បានលើកទឹកចិត្តទៅដល់វិនិយោគិនទាំងអស់អោយមកវិនិយោគនៅភាគកណ្តាល និងភាគខាងលិចនៃប្រទេសចិនអោយបានច្រើន។ ប្រទេសចិនក៏បានពន្លឿននូវការអនុវត្តគោលនយោបាយនេះផងដែរ តាមរយៈការណែនាំទៅដល់សហគ្រិនទាំងអស់អំពីឥរិយាបថក្នុងការអភិវឌ្ឍក៏ដូចជាកិច្ចសហប្រតិបត្តិការវិនិយោគផងដែរ។ ក្រៅពីការផ្តោតសំខាន់លើកិច្ចសហប្រតិបត្តិការវិនិយោគនៅក្នុងស្រុក សាធារណៈរដ្ឋប្រជាមានិតចិន ក៏នឹងបង្កើតនូវកិច្ចសហប្រតិបត្តិការដែលមានទ្រង់ទ្រាយធំបែបអន្តរជាតិផងដែរ។ សាធារណៈរដ្ឋប្រជាមានិតចិនក៏មានគម្រោងសិក្សាស្រាវជ្រាវ

ដើម្បីបង្កើននូវសមត្ថភាពរបស់ខ្លួនទាក់ទិននឹងវិស័យវិនិយោគទាំងក្នុង និងក្រៅប្រទេស។

**២. ប្រសិទ្ធិភាពនៃការអនុវត្ត**

ការអនុវត្តនូវគោលនយោបាយរវាងប្រទេសទាំងពីរ គឺក្នុងគោលបំណងតែមួយគឺពង្រីកសេដ្ឋកិច្ចទីផ្សារដើម្បីទាក់ទាញការវិនិយោគ និងអភិវឌ្ឍន៍ដល់សេដ្ឋកិច្ចជាតិប្រទេសទាំងពីរ។ ទោះបីជាយ៉ាងណា ការអនុវត្តគោលនយោបាយរវាងប្រទេសទាំងពីរហាក់មានភាពខុសគ្នាត្រង់ថាប្រទេសកម្ពុជា បានដាក់ចេញនូវវិធានការណ៍ គោលនយោបាយ និងបទបញ្ញាត្តិផ្សេងៗ ដើម្បីជាការធានាដល់ការអភិវឌ្ឍក្នុងស្រុក និងទាក់ទាញអ្នកវិនិយោគអោយមកវិនិយោគនៅព្រះរាជាណាចក្រកម្ពុជាអោយបានច្រើន។ ចំណែកឯការអនុវត្តគោលនយោបាយនៅក្នុងសាធារណៈប្រជាមានិតចិនវិញ គឺផ្តោតសំខាន់ទាំងការវិនិយោគទាំងនៅក្នុងស្រុកនិងនៅក្រៅប្រទេស។ ពោលគឺរដ្ឋាភិបាលចិនធ្វើយ៉ាងណាអោយប្រទេសខ្លួនអាចទាក់ទាញវិនិយោគិន អោយមកវិនិយោគក្នុងស្រុកអោយបានច្រើន ជាពិសេសគឺនៅភាគខាងលិច និងភាគកណ្តាលប្រទេសចិន។ ហើយចិនក៏បានយកចិត្តទុកដាក់លើការពង្រីកទីផ្សារ និងកិច្ចសហប្រតិបត្តិការទ្រង់ទ្រាយធំជាលក្ខណៈអន្តរជាតិផងដែរ។

## ផ្នែកទី២ : យុទ្ធសាស្ត្រនៃការជំរុញអោយមានការវិនិយោគនៅប្រទេសកម្ពុជា និង ប្រទេសចិន

### កថាខណ្ឌទី១: យុទ្ធសាស្ត្រនៃការជំរុញអោយមានការវិនិយោគនៅប្រទេសកម្ពុជា

**១. អត្ថន័យនៃយុទ្ធសាស្ត្រ**

រាជរដ្ឋាភិបាលកម្ពុជាបានធ្វើស្វាគមន៍ ចំពោះការវិនិយោគដែលធ្វើឡើងនៅក្នុងព្រះរាជាណាចក្រកម្ពុជា ពីសំណាក់បុគ្គលសញ្ជាតិខ្មែរ និងបរទេស លើគ្រប់វិស័យទាំងអស់ លើកលែងតែសកម្មភាពវិនិយោគមួយចំនួន ដែលត្រូវបានហាមឃាត់ដូចមានចែងនៅក្នុងឧបសម្ព័ន្ធទី១ ផ្នែកទី១ នៃអនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីវិសោធនកម្មច្បាប់វិនិយោគនៃព្រះរាជាណាចក្រកម្ពុជា និងដូចមានចែងក្នុងមាត្រា៧ នៃច្បាប់វិនិយោគឆ្នាំ១៩៩៤។ ទន្ទឹមនឹងនេះដើម្បីទាក់ទាញអ្នកវិនិយោគជាតិឬបរទេសឲ្យមកវិនិយោគនៅកម្ពុជានោះ រាជរដ្ឋាភិបាលកម្ពុជា តាមរយៈច្បាប់ស្តីពីវិនិយោគបានធ្វើការធានា(១.១) ក៏ដូចជាការលើកទឹកចិត្ត(១.២) ចំពោះគម្រោងវិនិយោគនានា ដែលនេះជាយុទ្ធសាស្ត្រមួយជំរុញឲ្យមានការវិនិយោគនៅកម្ពុជាពីសំណាក់ វិនិយោគិនខ្មែរ និងបរទេសកើនឡើងគួរឲ្យកត់សម្គាល់ និងមានលក្ខណៈល្អប្រសើរថែមទៀត។

**១.១. ការធានា**

ដើម្បីផ្តល់ទំនុកចិត្តដល់អ្នកវិនិយោគ វិធានគតិយុត្តបានកំណត់ពីការធានាមួយចំនួនដូចជា៖ សមភាព កម្មសិទ្ធិឯកជន សេរីភាពកំណត់តម្លៃ និងចរាចរូបិយប័ណ្ណជាដើម។

**១.១.១. ការធានាសមភាព**

អ្នកវិនិយោគត្រូវបានទទួលស្គាល់ និងចាត់ទុកដោយស្មើគ្នាចំពោះមុខច្បាប់ គ្មានការរើសអើងសញ្ជាតិ ឬពូជសាសន៍អ្វីនោះទេ[43]។

**១.១.២. ការធានាកម្មសិទ្ធិឯកជន**

តាមច្បាប់វិនិយោគនៃព្រះរាជាណាចក្រកម្ពុជា បានចែងថារាជរដ្ឋាភិបាលនឹងមិនធ្វើជាតូបនីយកម្មដែលនាំឲ្យប៉ះពាល់ដល់ទ្រព្យសម្បត្តិរបស់អ្នកវិនិយោគឡើយ[44]។ ហេតុដូច្នេះទ្រព្យសម្បត្តិឯកជនរបស់អ្នកវិនិយោគ ទោះបីជាជនជាតិណាក៏ដោយត្រូវបានទទួលការការពារស្របច្បាប់ ព្រមទាំងអាចគេចផុតពីការរឹបអូសតាមការធ្វើជាតូបនីយកម្ម ឬអស្សាមិករណ៍។

**១.១.៣. ការធានាសេរីភាពកំណត់តម្លៃ**

រាជរដ្ឋាភិបាលមិនត្រួតពិនិត្យលើថ្លៃផលិតផល ឬថ្លៃសេវានានារបស់អ្នកវិនិយោគ ដែលបានទទួលការអនុញ្ញាតរួចហើយនោះទេ។ ក្នុងន័យនេះរាជរដ្ឋាភិបាលមិនប្រើប្រាស់នូវសិទ្ធិអំណាចលើដែនដីអធិបតេយ្យនៃរដ្ឋរបស់ខ្លួន ក្នុងការដាក់កំហិត និងត្រួតពិនិត្យលើតម្លៃទំនិញ ឬថ្លៃសេវាកម្មផ្សេងៗដែលពាក់ព័ន្ធនឹងវិនិយោគឡើយ[45]។ ដូចនេះពាក់ព័ន្ធនឹងវិស័យវិនិយោគនៅកម្ពុជា ច្បាប់ធានា និងទទួលស្គាល់សិទ្ធិសេរីភាពពេញលេញរបស់អ្នកវិនិយោគជាតិ និងបរទេសក្នុងការកំណត់ ឬកែប្រែតម្លៃទំនិញ និងសេវាកម្មចំពោះគម្រោងវិនិយោគដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់។

**១.១.៤. ការធានាចរាចរូបិយប័ណ្ណ**

ដោយអនុវត្តតាមច្បាប់ទាំងឡាយដែលពាក់ព័ន្ធ ព្រមទាំងបទប្បញ្ញត្តិទាំងឡាយដែលបានកំណត់ និងប្រកាសផ្សព្វផ្សាយដោយធានាគារជាតិនៃកម្ពុជា រាជរដ្ឋាភិបាលបានអនុញ្ញាតដល់អ្នកវិនិយោគមានសិទ្ធិទិញរូបិយប័ណ្ណបរទេសតាមរយៈប្រព័ន្ធធានាគារ សម្រាប់បង្វិលទៅបរទេសវិញ ដើម្បីទូទាត់កាតព្វកិច្ចខាងហិរញ្ញវត្ថុដែលពាក់ព័ន្ធនឹងការវិនិយោគរបស់ខ្លួន។

ការទូទាត់ខាងលើនេះរួមមាន៖

---

[40] មាត្រា៨ នៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៤។
[44] មាត្រា៩ នៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៤។
[45] មាត្រា១០ នៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៤។

.ការទូទាត់លើការនាំចូល និងការបង្វិលទៅក្រៅប្រទេស ទាំងដើម ទាំងការនូវប្រាក់ចងការ

.ការទូទាត់ចំណាយសួយសារ និងថ្លៃសេវាគ្រប់គ្រង

.ការផ្ទេរប្រាក់ចំណេញ

.ការបង្វិលដើមទុនវិនិយោគទៅក្រៅប្រទេសវិញ។

**១.២. ការលើកទឹកចិត្ត**

ដើម្បីទាក់ទាញអ្នកវិនិយោគជាតិ និងបរទេសឲ្យមកធ្វើការវិនិយោគនៅកម្ពុជា រាជរដ្ឋាភិបាល តាមរយៈច្បាប់វិនិយោគនៃព្រះរាជាណាចក្រកម្ពុជា បានធ្វើការលើកទឹកចិត្តដល់គម្រោងវិនិយោគទាំងឡាយណា ធ្វើឡើងដោយស្របតាមច្បាប់វិនិយោគនៃព្រះរាជាណាចក្រកម្ពុជា។ ទន្ទឹមនឹងនេះដើម្បីទទួលបានការលើកទឹកចិត្តនេះ អ្នកវិនិយោគជាតិ ឬបរទេស ត្រូវដាក់ពាក្យសុំការលើកទឹកចិត្តនៅគណៈកម្មាធិការវិនិយោគកម្ពុជា ដែលជាផ្នែកមួយនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC)។ ការលើកទឹកចិត្តដែលបានផ្តល់ឲ្យអ្នកវិនិយោគតាមរយៈច្បាប់វិនិយោគនៃព្រះរាជាណាចក្រកម្ពុជា គឺចង់សំដៅដល់ការលើកលែងពន្ធ និងអាករ ដែលមានដូចជា៖ ពន្ធលើប្រាក់ចំណេញ ការលើកលែងពន្ធគយ និងអាករពេលនាំចេញ និង ការលើកលែងពន្ធលើសម្ភារៈ បរិក្ខារផលិតកម្ម សម្ភារៈសំណង់ ធាតុចូលផលិតកម្ម។

**១.២.១. ការលើកលែងពន្ធលើប្រាក់ចំណេញ**

តាមរយៈច្បាប់វិនិយោគនៃព្រះរាជាណាចក្រកម្ពុជា បានផ្តល់ការលើកទឹកចិត្តដល់គម្រោងវិនិយោគដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ទាំងអស់ ដោយមានសិទ្ធិទទួលបាននូវការលែកលែងពន្ធលើប្រាក់ចំណេញដែលមានកំណត់នៅក្នុងច្បាប់ស្តីពីសារពើពន្ធ ដោយទទួលបាននូវរយៈពេលលើកលែងពន្ធលើប្រាក់ចំណេញ។

រយៈពេលលើកលែងពន្ធលើប្រាក់ចំណេញរួមមាន៖ រយៈពេល គន្លឹះបូករយៈពេល៣(បី)ឆ្នាំ បូករយៈពេលអាទិភាព។ រយៈពេលអាទិភាពនឹងត្រូវកំណត់នៅក្នុងច្បាប់ ស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុ។ រយៈពេលគន្លឹះជាអតិបរមា គឺជាឆ្នាំទី១(មួយ) ដែលគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ទទួលបានប្រាក់ចំណេញ ឬរយៈពេល៣(បី)ឆ្នាំ បន្ទាប់ពីគម្រោងវិនិយោគនោះទទួលបានប្រាក់ចំណូលដំបូងរបស់ខ្លួនដោយជ្រើសរើសយកវិធីណាមួយដែលឆាប់ជាង[46]។

យោងតាមអនុក្រឹត្យស្តីពីការអនុវត្ត ច្បាប់ស្តីពីវិសោធនកម្មច្បាប់វិនិយោគនៃព្រះរាជាណា

[46] មាត្រា ១៤ថ្មី ចំណុចទី ១ នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីវិនិយោគឆ្នាំ២០០៣។

ចក្រកម្ពុជា ជំពូកទី៥ មាត្រា១៥ វាក្យខណ្ឌទី១: *"រយៈពេលលើកលែងពន្ធលើប្រាក់ចំណេញដែលរួមមានរយៈពេលគន្លឹះ បូក រយៈពេលអាទិភាព បូក រយៈពេលអាទិភាព"* គឺត្រូវកំណត់ដូចតទៅៈ

១-រយៈពេលគន្លឹះនៃរយៈពេលលើកលែងពន្ធលើប្រាក់ចំណេញ គឺជារយៈពេលចាប់ផ្តើមពីថ្ងៃចេញវិញ្ញាបនបត្រចុះបញ្ជីជាស្ថាពរ និងបញ្ចប់នៅថ្ងៃចុងក្រោយនៃឆ្នាំសារពើពន្ធណាមួយដែលឆាប់ជាង ៖

-ប្រសិនបើគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់មានប្រាក់ចំណេញ គឺជាឆ្នាំសារពើពន្ធមុនឆ្នាំដែលគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ មានប្រាក់ចំណូលដំបូង។

-ប្រសិនបើគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ មានប្រាក់ចំណូលពីសកម្មភាពវិនិយោគ ចំពោះការលក់ទំនិញ ឬសេវា គឺជាឆ្នាំសារពើពន្ធទី០៣(បី) បន្ទាប់ពីគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ទទួលបានប្រាក់ចំណូលដំបូង[47]។

២-រយៈពេល០៣(បី)ឆ្នាំ: គឺចាប់ផ្តើមគិតភ្លាមពីឆ្នាំសារពើពន្ធ បន្ទាប់ពីរយៈពេលគន្លឹះ និង០២(ពីរ)ឆ្នាំបន្ទាប់មកទៀត[48]។

៣-រយៈពេលអាទិភាព: ត្រូវបានកំណត់នៅក្នុងច្បាប់ស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុ ដោយចាប់ផ្តើមគិតភ្លាម បន្ទាប់ពីឆ្នាំសារពើពន្ធទី០៣(បី) នៃរយៈពេល០៣ឆ្នាំដូចមានកំណត់នៅក្នុងចំណុចទី២ខាងលើនេះ[49]។

### ១.២.២. ការលើកលែងពន្ធគយនាំចេញ

គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ មានសិទ្ធិទទួលបាននូវការលើកលែងពន្ធនាំចេញ១០០% ។ ប្រភេទទំនិញនាំចេញដែលបានទទួលការលើកលែងពន្ធគយ១០០% គឺផលិតផលសម្រេច។ រាល់ក្រុមហ៊ុនទាំងឡាយដែលបានចុះបញ្ជីនៅក្រសួងពាណិជ្ជកម្មដោយមិនគិតពីភាគហ៊ុនបរទេស ត្រូវបានអនុញ្ញាតឲ្យធ្វើការនាំចេញដោយសេរី។ ជាទូទៅកិច្ចការនាំចេញមិនតម្រូវឲ្យមានការអនុញ្ញាតណាមួយទេ លើកលែងចំពោះទំនិញមួយចំនួនដែលត្រូវបានគេចាត់ទុកថាត្រូវបានហាមឃាត់[50]។

---

47 មាត្រា១៥ ចំណុច១៥.២ នៃអនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីវិសោធនកម្មច្បាប់វិនិយោគនៃព្រះរាជាណាចក្រកម្ពុជា។
48 មាត្រា១៥ ចំណុច១៥.៣ នៃអនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីវិសោធនកម្មច្បាប់វិនិយោគនៃព្រះរាជាណាចក្រកម្ពុជា។
49 មាត្រា១៥ ចំណុច១៥.៤ នៃអនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីវិសោធនកម្មច្បាប់វិនិយោគនៃព្រះរាជាណាចក្រកម្ពុជា។
50 មាត្រា ១៤ ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់វិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ២០០៣។

### ១.២.៣. ការលើកលែងពន្ធលើសម្ភារៈ បរិក្ខារផលិតកម្ម សម្ភារៈសំណង់ ធាតុចូលផលិតកម្ម

ការលើកលែងពន្ធគយលើសម្ភារៈបរិក្ខារផលិតកម្ម និងសម្ភារៈសាងសង់របស់គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដែលបម្រើទីផ្សារក្នុងស្រុកៈ អនុលោមតាមមាត្រា១៤ ចំណុច១៤.៥ នៃច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគ គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដែលបម្រើទីផ្សារក្នុងស្រុក ត្រូវបានលើកលែងពន្ធគយ លើការនាំចូលសម្ភារៈបរិក្ខារផលិតកម្ម និងសម្ភារៈសំណង់តែប៉ុណ្ណោះ។ ក្នុងករណីដែលគម្រោងប្រភេទនេះ មានលទ្ធភាពនាំចេញនូវផ្នែកណាមួយនៃផលិតផលដែលបានផលិតដោយផ្ទាល់ ឬបានផ្គត់ផ្គង់ដល់ឧស្សាហកម្មនាំចេញបរិមាណ ធាតុចូលផលិតកម្ម ដែលបានបង់ពន្ធនាំចូលរួចយកទៅបម្រើការនាំចេញដោយផ្ទាល់ ឬដោយប្រយោលនោះ ត្រូវបានទទួលការលើកលែងពន្ធគយក្រោយពីការត្រួតពិនិត្យរបាយការណ៍ប្រចាំត្រីមាស[51]។

គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដែលបម្រើឲ្យការនាំចេញ ត្រូវបានលើកលែងពន្ធគយលើការនាំចេញ សម្ភារៈបរិក្ខារផលិតកម្ម សម្ភារៈសំណង់ និងធាតុចូលផលិតកម្ម។ ដោយឡែកគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដើម្បីបម្រើការនាំចេញ ដែលស្ថិតនៅក្រោមយន្តការភណ្ឌាគារផលិតកម្ម ក្រោយការគ្រប់គ្រងរបស់គយ ការលើកលែងពន្ធត្រូវបានអនុវត្តទៅតាមច្បាប់ និងបទបញ្ញត្តិគយជាធរមានរបស់យន្តការនេះ។ ធាតុចូលផលិតកម្មដែលកែច្នៃហើយមិនបាននាំចេញ ត្រូវបង់ពន្ធគយ និងអាករឡើងវិញ លើធាតុផលិតកម្មនាពេលនាំចូលក្រោយពីការត្រួតពិនិត្យរបាយការណ៍ប្រចាំត្រីមាស[52]។ គម្រោងវិនិយោគដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដែលជាឧស្សាហកម្មគាំទ្រត្រូវបានលើកលែងពន្ធគយ លើការនាំចូលសម្ភារៈបរិក្ខារផលិតកម្ម សម្ភារៈសំណង់ និងធាតុចូលផលិតកម្ម។ ប៉ុន្តែករណីដែលគម្រោងវិនិយោគទាំងនេះមិនបានធ្វើការផ្គត់ផ្គង់១០០%នៃផលិតផលដែលបានផលិតបានទៅដល់ឧស្សាហកម្ម នាំចេញ ឬនាំចេញដោយផ្ទាល់ទេនោះ គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ទាំងនោះ ត្រូវបង់ពន្ធគយ និងអាករឡើងវិញ លើធាតុចូលផលិតកម្ម នាពេលនាំចូលនូវបរិមាណដែលមិនបានផ្គត់ផ្គង់អោយឧស្សាហកម្មនាំចេញ ឬនាំចេញដោយផ្ទាល់ក្រោយពីការត្រួតពិនិត្យប្រចាំត្រីមាស[53]។

[51] មាត្រា១៦ ចំណុច១៦.១ នៃអនុក្រឹត្យស្តីពីគារអនុវត្តច្បាប់ស្តីពីវិសោធនកម្មច្បាប់វិនិយោគនៃព្រះរាជាណាចក្រកម្ពុជា។
[52] មាត្រា១៦ ចំណុច១៦.២ នៃអនុក្រឹត្យស្តីពីគារអនុវត្តច្បាប់ស្តីពីវិសោធនកម្មច្បាប់វិនិយោគនៃព្រះរាជាណាចក្រកម្ពុជា។
[53] មាត្រា១៦ ចំណុច១៦.៣ នៃអនុក្រឹត្យស្តីពីគារអនុវត្តច្បាប់ស្តីពីវិសោធនកម្មច្បាប់វិនិយោគនៃព្រះរាជាណាចក្រកម្ពុជា។

### ១.២.៤. កាលបរិច្ឆេទនៃសិទ្ធិទទួលបានការលើកលែងពន្ធលើពន្ធគយ និងអាករ

កាលបរិច្ឆេទមានប្រសិទ្ធិភាពនៃការលើកលែងពន្ធគយណាមួយ ចំពោះពន្ធលើប្រាក់ចំណេញពន្ធគយ និងអាករនាពេលនាំចូល គឺជាកាលបរិច្ឆេទនៃការយល់ព្រមរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក៏ប៉ុន្តែមិនអាចមុនកាលបរិច្ឆេទដែលសហគ្រាសវិនិយោគបានចុះបញ្ជីនៅនាយកដ្ឋានពន្ធដារ និងទីចាត់ការគយ និងរដ្ឋាករ ទៅតាមនីតិវិធីចុះបញ្ជីដែលនាយកដ្ឋានទាំងនេះបានកំណត់ និងត្រូវបាននាយកដ្ឋានពន្ធដារផ្តល់ឲ្យនូវលេខអត្តសញ្ញាណកម្មសារពើពន្ធ។ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ត្រូវទទួលខុសត្រូវក្នុងការផ្តល់ឯកសារសមស្របទាំងអស់ ជូនដល់នាយកដ្ឋានពន្ធដារ និងទីចាត់ការគយ និងរដ្ឋាករដែលក្នុងនោះត្រូវមាន៖

១.ច្បាប់ចម្លងមួយច្បាប់នៃពត៌មានទាំងអស់ ដែលអ្នកវិនិយោគបានផ្តល់ឲ្យនៅក្នុងដំណើរការដាក់ពាក្យសុំ និងកិច្ចព្រមព្រៀងទាំងអស់ ដែលបានធ្វើរវាងអ្នកវិនិយោគជាមួយនឹងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។

២.ឯកសារយល់ព្រមរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្នុងនោះមានទាំងពត៌មានទាំងអស់ទាក់ទិននឹងចរន្តហិរញ្ញវត្ថុរបស់ការងារវិនិយោគ សម្បទានខាងពន្ធ និងបញ្ជីរាយលម្អិតអំពីមុខវិជ្ជាទាំងអស់ ដែលបានទទួលការលើកលែងពន្ធ និងអាករនាពេលនាំចូល។ ក្នុងរយៈពេលមួយសប្តាហ៍ក្រោយពីថ្ងៃបានទទួលពាក្យស្នើសុំចុះបញ្ជីដែលបានបំពេញតាមបែបបទត្រឹមត្រូវ និងគ្រប់គ្រាន់ ហើយនឹងពត៌មានផ្សេងៗទៀតដែលមានការពាក់ព័ន្ធ។ នាយកដ្ឋានពន្ធដារត្រូវផ្តល់អត្តសញ្ញាណកម្មសារពើពន្ធសម្រាប់សហគ្រាសវិនិយោគ ជូនក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ជាអ្នកទទួលខុសត្រូវក្នុងការប្រគល់អត្តសញ្ញាណកម្មសារពើពន្ធឲ្យដល់សហគ្រាសវិនិយោគ និងការពន្យល់លម្អិតអំពីតម្រូវការផ្សេងៗ ចំពោះការប្រើប្រាស់លេខ អត្តសញ្ញាណកម្មសារពើពន្ធ។ ក្នុងករណីខាងលើនេះ ក៏អនុវត្តផងដែរចំពោះក្រុមហ៊ុនវិនិយោគដែលមានស្រាប់នៅកម្ពុជា។

### ១.២.៥. ពន្ធដែលត្រូវបង់ក្រោយពេលផុតរយៈពេលលើកទឹកចិត្ត

គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ត្រូវជាប់ពន្ធដែលរយៈពេលលើកទឹកចិត្តដែលផ្តល់ឲ្យដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាត្រូវបានបញ្ចប់។ បន្ទាប់ពីផុតរយៈពេលលើកលែងពន្ធគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ត្រូវជាប់ពន្ធលើប្រាក់ចំណេញ។ ផ្អែកតាមមាត្រា ២០ នៃច្បាប់ស្តីពីសារពើពន្ធ គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ត្រូវជាប់ពន្ធ ២០% ចំពោះប្រាក់ចំណេញដែលសម្រេចបានក្នុងការធ្វើអាជីវកម្មរបស់ខ្លួន និង៣០%ចំពោះប្រាក់ចំណេញដែលសម្រេចបានក្រោមកិច្ចសន្យាបែងចែកផលិតផលប្រេងកាត និងឧស្ម័នធម្មជាតិ ឬ

សម្រេចបានពីការធ្វើអាជីវកម្មលើធនធានធម្មជាតិ រួមទាំងព្រៃឈើ រ៉ែមាស ឬត្បូងថ្មមានតម្លៃនានា។ គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ បន្ទាប់ពីផុតរយៈពេលលើកលែងពន្ធ អាចជាប់ពន្ធតាមរបបពិត ឬតាមរបបមៅការអាស្រ័យលើទ្រង់ទ្រាយអាជីវកម្ម ប្រភេទសកម្មភាពអាជីវកម្ម និងកម្រិតផលរបរ។ ប្រសិនបើក្រុមហ៊ុនវិនិយោគនោះជាប់ពន្ធតាមរបបពិត អ្នកជាប់ពន្ធលើប្រាក់ចំណេញត្រូវបង់ពន្ធតាមរបបពិត និងផ្ញើឯកសារជារៀងរាល់ឆ្នាំ ទៅរដ្ឋបាលសារពើពន្ធនូវលិខិតប្រកាសប្រាក់ចំណេញដែលខ្លួនបានសម្រេច។ លិខិតប្រកាសនោះត្រូវចុះបញ្ជីដាច់ខាតក្នុងរយៈពេល០៣(បី)ខែ ក្រោយពីដំណាច់ឆ្នាំសារពើពន្ធ។ អ្នកជាប់ពន្ធតាមរបបពិតត្រូវដាក់លិខិតប្រកាសសារពើពន្ធជូនរដ្ឋបាលសារពើពន្ធ ដោយភ្ជាប់មកជាមួយនូវ[54] : តារាងតុល្យការ គណនេយ្យលទ្ធផល និងតារាងពត៌មានបន្ថែម។ ប៉ុន្តែប្រសិនបើជាប់ពន្ធតាមរបបមៅការ អ្នកជាប់ពន្ធត្រូវដាក់លិខិត ប្រកាសសារពើពន្ធជូនរដ្ឋបាលសារពើពន្ធជារៀងរាល់ឆ្នាំ យ៉ាងយឺតបំផុតនៅថ្ងៃទី៣១ ខែតុលា តាមគំរូដែលរដ្ឋបាលសារពើពន្ធបានផ្តល់ជូន។ ចំនួនទឹកប្រាក់មៅការត្រូវកំណត់ដោយរដ្ឋបាលសារពើពន្ធបន្ទាប់ពីពិនិត្យ និងពិភាក្សាជាមួយអ្នកជាប់ពន្ធ ឬអ្នកតំណាង ប្រាក់ចំណេញមៅការនេះ ត្រូវគិតតាមអត្រាចំណេញទៅតាមប្រភេទ និងតាមមុខរបរអាជីវកម្មដែលត្រូវកំណត់ដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ កម្រិតពន្ធលើប្រាក់ចំណេញមៅការ ត្រូវកំណត់ជាសារវន្តសម្រាប់រយៈពេលមួយមានកំណត់០៣(បី)ខែ ០៦(ប្រាំមួយ)ខែ ឬ០៣(បី)ឆ្នាំ។ អ្នកជាប់ពន្ធនេះជា រៀងរាល់ខែត្រូវបង់ពន្ធលើប្រាក់ចំណេញទៅរដ្ឋបាលសារពើពន្ធ តាមពេលវេលាដែលរដ្ឋបាលសារពើពន្ធបានកំណត់។ ក្រៅពីពន្ធទាំងពីរខាងលើនេះ នៅមានពន្ធផ្សេងៗទៀតដែលបានកំណត់ដោយច្បាប់ស្តីពីសារពើពន្ធឆ្នាំ២០០៣។

## កថាខណ្ឌទី២: យុទ្ធសាស្ត្រនៃការជំរុញអោយមានការវិនិយោគនៅប្រទេសចិន

### ១. អត្ថន័យនៃយុទ្ធសាស្ត្រ

សាធារណៈរដ្ឋប្រជាមានិតចិន មានការយកចិត្តទុកដាក់យ៉ាងខ្លាំងទៅលើវិស័យវិនិយោគធ្វើយ៉ាងណាទាក់ទាញអ្នកវិនិយោគអោយបានច្រើនក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ។ ប្រទេសចិនបានដាក់នូវក្របខណ្ឌគតិយុត្តមួយចំនួនដើម្បីកំណត់ពីអាទិភាពនិង ធ្វើការត្រួតពិនិត្យទាក់ទងទៅនឹងការវិនិយោគនៅក្នុងប្រទេស។ លិខិតគតិយុត្តជាច្រើនត្រូវបានចេញផ្សាយដោយភ្នាក់ងារផ្សេងៗរបស់ស្ថាប័នចិន ដែលមានដូចជា វិធានការទាំងប្រាំដែលបានប្រកាសដោយរដ្ឋាភិបាលចិន (១.១) គោលការណ៍ទាំង៩ ដែលស្តីពីការលើកទឹកចិត្ត (១.២) ដែលធ្វើអោយមានលក្ខណៈស្តង់ដារសម្រាប់

[54] មាត្រា២៩ នៃច្បាប់ស្តីពីសារពើពន្ធ២០០៣។

វិស័យវិនិយោគ និងគោលការណ៍ជាច្រើនទៀត ដើម្បីធានាអោយមាននិរន្តរភាព និងការអភិវឌ្ឍក្នុងវិស័យសេដ្ឋកិច្ច។ប៉ុន្តែខាងក្រោមនេះ យើងនឹងបង្ហាញតែយុទ្ធសាស្រ្តចំនួនពីរសំខាន់ៗតែប៉ុណ្ណោះ។

**១.១ . វិធានការទាំងប្រាំដែលបានប្រកាសដោយរដ្ឋាភិបាលចិន ( ខែកញ្ញា ឆ្នាំ២០០៥)**

ក.រដ្ឋាភិបាលចិន បានសម្រេចចិត្តដាក់ចេញនូវយុទ្ធសាស្រ្តក្នុងការមិនយកពន្ធលើទំនិញ ពីប្រទេសកំពុងអភិវឌ្ឍចំនួន៣៩ ដែលមានទំនាក់ទំនងការទូតជាមួយសាធារណៈរដ្ឋប្រជាមានិតចិន ដែលភាគច្រើននៃការនាំចេញរបស់ប្រទេសចិន គឺមានទំនាក់ទំនងជាមួយប្រទេសទាំងនេះ។

ខ.សាធារណៈរដ្ឋប្រជាមានិតចិន នឹងបន្តពង្រីកនូវកម្មវិធីផ្តល់ជំនួយរបស់ខ្លួនទៅកាន់ប្រទេសកំពុងអភិវឌ្ឍ និងប្រទេសដែលជាប់បំណុលច្រើន និងតាមរយៈមធ្យោយទ្វេភាគី ហើយក្រោយមកចិនអាចលើកលែងបំណុលទៅដល់ប្រទេសទាំងនោះ ឬយកការប្រាក់ទាបពីបណ្តាប្រទេសដែលជាប់បំណុលចិន។ ដូច្នេះចិនអាចបង្កើនទំនាក់ទំនងការទូត ក៏ដូចជាទំនាក់ទំនងវិនិយោគជាមួយប្រទេសទាំងនោះ។

គ.នៅក្នុងរយៈពេល០៣(បី)ឆ្នាំបន្ទាប់ សាធារណៈរដ្ឋប្រជាមានិតចិននឹងនៅតែបន្តផ្តល់ប្រាក់កម្ចីសម្បទាន និងឥណទានអនុគ្រោះទៅកាន់ប្រទេសកំពុងអភិវឌ្ឍន៍ជាច្រើន ដើម្បីធ្វើអោយមានភាពរីកចម្រើនខាងផ្នែកហេដ្ឋារចនាសម្ព័ន្ធ និងកិច្ចសហប្រតិបត្តិការ រវាងសហគ្រាសប្រទេសទាំងពីរ។

ឃ.ក្នុងរយៈពេល០៣(បី)ឆ្នាំបន្ទាប់ សាធារណៈរដ្ឋប្រជាមានិតចិន នឹងបង្កើនជំនួយរបស់ខ្លួនទៅកាន់ប្រទេសកំពុងអភិវឌ្ឍន៍ ជាពិសេសគឺប្រទេសអាហ្វ្រិក។ កម្មវិធីពិសេសនេះនឹងត្រូវអនុវត្តតាមរយៈយន្តការវេទិកាសហប្រតិបត្តិការរវាងចិន និងអាហ្វ្រិក ក៏ដូចជាបណ្តាញទ្វេភាគីផងដែរ។

ង.សាធារណរដ្ឋប្រជាមានិតចិន នឹងផ្តល់ការបណ្តុះបណ្តាលបុគ្គលិកជំនាញចំនួន៣០.០០០ (បីម៉ឺន)នាក់ដែលមកពីប្រទេសកំពុងអភិវឌ្ឍ ក្នុងការជួយពន្លឿននូវធនធានមនុស្សសម្រាប់ការអភិវឌ្ឍខាងផ្នែកវិនិយោគ[55]។

**១.២. គោលការណ៍ទាំង៩ក្នុងការលើកទឹកចិត្តការវិនិយោគ (ក្រុមប្រឹក្សារដ្ឋ, ខែតុលា ឆ្នាំ ២០០៦)**

ក្នុងគោលបំណងចាប់យកឱកាសសេដ្ឋកិច្ច និងសកលភាវូបនីយកម្ម សម្រាប់សហប្រតិបត្តិការក្នុងតំបន់ ក៏ដូចជាការលើកទឹកចិត្តទៅដល់សហគ្រាសដែលមានលក្ខណៈគ្រប់គ្រាន់ក្នុងការចូល

[55]IISD and IIER, Chinese Outward investment) an emerging policy framework, ១៩។

រួមក្នុងការអភិវឌ្ឍន៍ និងកិច្ចប្រតិបត្តិការសេដ្ឋកិច្ចនិងបច្ចេកវិទ្យាអន្តរជាតិ គេបានយកចិត្តទុកដាក់ក្នុងការលើកកម្ពស់ទៅលើសកម្មភាពមួយចំនួនដូចជា៖

ក.បង្កើតអោយមានការគោរព និងធ្វើការយកចិត្តទុកដាក់លើសមភាព ផលប្រយោជន៍រួម និងកិច្ចសហប្រតិបត្តិការឈ្នះឈ្នះរវាងគ្រប់ភាគី។

ខ.ពង្រឹងការណែនាំលើគោលនយោបាយ ការសម្របសម្រួល និងការធ្វើអោយស្របតាមស្តង់ដារគុណភាព ការការពារការប្រកួតប្រជែងមិនស្មោះត្រង់ និងធ្វើការការពារទៅលើផលប្រយោជន៍ជាតិ។

គ.កែលម្អលើយន្តការនៃការបង្កើតគោលនយោបាយ ការអនុវត្តរបស់សហគ្រាសវិនិយោគនៅបរទេស ការសិក្សាទៅលើការស្រាវជ្រាវដោយស្វ័យភាព និងការសម្រេចចិត្តដោយត្រឹមត្រូវ ក៏ដូចជាការការពារហានិភ័យនៃការវិនិយោគនិងកិច្ចសហប្រតិបត្តិការ។

ឃ.ការពង្រឹងលើការត្រួតពិនិត្យលើទ្រព្យសម្បត្តិរដ្ឋ និងទៅលើការវាយតម្លៃនៃប្រព័ន្ធត្រួតពិនិត្យ ក៏ដូចជាការបង្កើតនូវប្រព័ន្ធគណនេយ្យនិងប៉ាន់ប្រមាណលើហានិភ័យ និងការពារការកើនឡើងនូវតម្លៃអចលនវត្ថុ។

ច.ជំរុញអោយមានការអនុវត្តច្បាប់ និងបទបញ្ញត្តិក្នុងស្រុក និងប្រកាន់អោយបានខ្ជាប់ខ្ជួននូវគម្រោងការងារសាធារណៈដែលប្រកបដោយតម្លាភាព ក៏ដូចជាការទទួលខុសត្រូវក្នុងការការពារសិទ្ធិនិងផលប្រយោជន៍របស់កម្មករនិយោជិតក្នុងស្រុក និងការការពារផលប្រយោជន៍របស់ប្រជាជនក្នុងការរស់នៅតាមតំបន់សហគមន៍ និងធ្វើអោយប្រជាជនមានជីវភាពកាន់តែប្រសើរឡើង។

ឆ.បង្កើនកម្រិតនៃការសាងសង់តំបន់សេដ្ឋកិច្ចពិសេស អភិវឌ្ឍន៍គុណភាពផលិតផលឲ្យកាន់តែមានប្រសិទ្ធិភាព និងលើកកម្ពស់សមត្ថភាពប្រកួតប្រជែង។

ជ.ពង្រឹងនូវសមត្ថភាពបណ្តុះបណ្តាល ធ្វើអោយប្រសើរឡើងនូវទំនួលខុសត្រូវខាងផ្នែកផលិតផល និងបង្កើនការការពារសហគ្រាសមូលធនបរទេស និងស្ថាប័នវិនិយោគផ្សេងៗទៀត។

ឈ.ពន្លឿននូវការបណ្តុះបណ្តាលបុគ្គលិកលក្ខណៈ និងយកចិត្តទុកដាក់លើសមត្ថភាពគ្រប់គ្រងកិច្ចប្រតិបត្តិការពាណិជ្ជកម្ម។

ញ.បង្កើតអោយមាននូវការទទួលយកមតិសាធារណៈ គោលនយោបាយអភិវឌ្ឍន៍ និងការការពារដើម្បីកេរ្តិ៍ឈ្មោះ និងសហប្រតិបត្តិការល្អ[56]។

[56] IISD and IIER, Chinese Outward investment) an emerging policy framework, ២០។

## កថាខណ្ឌទី៣: ការប្រៀបធៀបយុទ្ធសាស្ត្រនៃការជំរុញអោយមានការវិនិយោគរវាងប្រទេសកម្ពុជា និងប្រទេសចិន

### ១. អត្ថន័យនៃយុទ្ធសាស្ត្រ

ដើម្បីទាក់ទាញការវិនិយោគអោយបានច្រើនសម្រាប់ប្រទេសកម្ពុជា រដ្ឋាភិបាលបានយកចិត្តទុកដាក់យ៉ាងខ្លាំងចំពោះវិស័យមួយនេះ។ រដ្ឋាភិបាលតែងតែស្វាគមន៍ចំពោះវត្តមានវិនិយោគរបស់ក្រុមហ៊ុនវិនិយោគនានាពីបរទេស លើកលែងតែសកម្មភាពវិនិយោគណាមួយនោះបង្កផលប៉ះពាល់ទៅដល់ផលប្រយោជន៍ជាតិ។ រាជរដ្ឋាភិបាលបានចេញជាយុទ្ធសាស្ត្រក្នុងការធានា លើកទឹកចិត្ត និងផ្តល់ទំនុកចិត្តដល់អ្នកវិនិយោគទាំងអស់ដែលមកវិនិយោគនៅព្រះរាជាណាចក្រកម្ពុជា។ វិធានគតិយុត្តមួយចំនួនបានដាក់ចេញនូវការធានាមួយចំនួន ដូចជាការធានានូវការការពារផលប្រយោជន៍នូវសិទ្ធិស្របច្បាប់ និងគ្មានការរើសអើងចំពោះការវិនិយោគណាមួយឡើយ។ បន្ថែមពីនេះទៀត រដ្ឋាភិបាលក៏បានដាក់ចេញនូវការលើកទឹកចិត្តទៅដល់វិនិយោគិទាំងអស់តាមរយៈការលើកលែងពន្ធ និងអាករជាដើម។ ការធ្វើបែបនេះវាបានផ្តល់នូវភាពជឿជាក់ និងទំនុកចិត្តដល់ក្រុមហ៊ុនវិនិយោគទាំងអស់ដែលបានមកវិនិយោគនៅប្រទេសកម្ពុជា ហើយក៏អាចទាក់ទាញអ្នកវិនិយោគបានច្រើនជាងមុនផងដែរ។

មិនខុសពីព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋប្រជាមានិតចិន បានដាក់ចេញនូវគោលការណ៍និងការត្រួតពិនិត្យសម្រាប់ការទាក់ទាញការវិនិយោគ។ ជាក់ស្តែងគោលការណ៍ទាំងប្រាំដែលបានប្រកាសដោយរដ្ឋាភិបាលចិន គឺរដ្ឋាភិបាលបានសម្រេចដាក់ចេញនូវយុទ្ធសាស្ត្រដែលមិនយកពន្ធលើទំនិញ និងបង្កើនទំនាក់ទំនងពាណិជ្ជកម្មទាំងជាមួយប្រទេសអភិវឌ្ឍន៍ និងប្រទេសកំពុងអភិវឌ្ឍន៍។ បន្ថែមពីនេះ រដ្ឋាភិបាលចិនក៏បានផ្តល់ជំនួយទៅដល់ប្រទេសមួយចំនួនតាមរយៈមធ្យោបាយទ្វេភាគីដើម្បីបង្កើនចំណងការទូតនិងទំនាក់ទំនងវិនិយោគផងដែរ។

### ២. ប្រសិទ្ធិភាពនៃការអនុវត្ត

តាមរយៈយុទ្ធសាស្ត្រក្នុងទាក់ទាញអោយការវិនិយោគ កាន់តែមានលក្ខណៈល្អប្រសើរនៅក្នុងប្រទេស ដែលបានដាក់ចេញតាមរយៈច្បាប់វិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ក៏ដូចជាច្បាប់វិនិយោគនៃសាធារណៈរដ្ឋប្រជាមានិតចិន យើងសង្កេតឃើញថាសម្រាប់ការអនុវត្តនូវយុទ្ធសាស្ត្រទាក់ទាញវិនិយោគនៅប្រទេសកម្ពុជា ហាក់បីដូចជាទទួលបានប្រសិទ្ធិខ្ពស់ ដោយសារតែក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ មានក្រុមហ៊ុនជាច្រើនបានមកវិនិយោគនៅក្នុងប្រទេសកម្ពុជា មិនថា

ក្រុមហ៊ុនវិនិយោគសញ្ជាតិខ្មែរ ឬសញ្ជាតិបរទេសនោះទេ ដែលក្រុមហ៊ុនទាំងនោះបានបណ្តាក់វិនិយោគទៅលើស្ទើរគ្រប់វិស័យសំខាន់នៅប្រទេសកម្ពុជា។ ជាក់ស្តែងតាមរបាយការណ៍របស់ក្រុមប្រឹក្សាអភិវឌ្ឍកម្ពុជា យើងសូមលើកបង្ហាញនូវក្រុមហ៊ុនបរទេសនៃប្រទេសមួយ ដែលជាប្រទេសនៃសមាជិកអាស៊ាននេះផងដែរ ព្រមទាំងជាប្រទេសដែលនៅជាប់ភូមិផងរបងជាមួយគ្នា ជាមួយនឹងប្រទេសកម្ពុជា ដែលមានក្រុមហ៊ុនវិនិយោគច្រើនបានមកធ្វើការវិនិយោគនៅប្រទេសកម្ពុជាដោយគិតចាប់រាប់ពីចន្លោះឆ្នាំពី ២០១០ ដល់ ២០១៥ នេះ គឺក្រុមហ៊ុនមានសញ្ជាតិវៀតណាម ដែលមានរហូតដល់៤០ក្រុមហ៊ុន ដែលបានមកធ្វើការវិនិយោគទៅលើគ្រប់វិស័យសំខាន់ៗ ដូចជាចំការកៅស៊ូ កសិកម្ម ឧស្សាហកម្ម។ល។ ប៉ុន្តែបើយើងរាប់បញ្ចូលជាសរុបនូវក្រុមហ៊ុនវិនិយោគដែលមកពីគ្រប់បណ្តាប្រទេសផ្សេងៗនោះវិញ យើងឃើញថាមានក្រុមហ៊ុនវិនិយោគប្រហែលជាង៣០០(បីរយ) ក្រុមហ៊ុន ដែលបានមកធ្វើការវិនិយោគនៅក្នុងប្រទេសកម្ពុជា ដែលភាគច្រើនក្រុមហ៊ុនទាំងនោះមកពីប្រទេសដូចជា៖ វៀតណាម ចិន ថៃ កូរ៉េ អាមេរិច ជប៉ុន សិង្ហបុរី។ល។ កំណើននូវក្រុមហ៊ុនវិនិយោគដ៏ច្រើននេះក៏ដោយសារតែប្រទេសកម្ពុជាមានកត្តាជាច្រើន ដែលអាចទាក់ទាញវិនិយោគិនអោយចង់មកបណ្តាក់ទុន ដែលក្នុងនោះកត្តាច្បាប់ ក៏ជាកត្តាមួយសំខាន់ក្នុងចំណោមកត្តាសំខាន់ៗផ្សេងទៀតផងដែរ។ ច្បាប់វិនិយោគប្រទេសកម្ពុជា បានផ្តល់ផលប្រយោជន៍ជាច្រើនសម្រាប់វិនិយោគិនដែលមានបំណងចងមកវិនិយោគនៅប្រទេសកម្ពុជា ដូចជាផ្តល់នូវការធានាលើការវិនិយោគ ការលើកទឹកចិត្តវិនិយោគ ដោយមិនយកពន្ធលើប្រាក់ចំណេញដែលវិនិយោគទទួលបាន លើកលែងពន្ធនាំចេញ-នាំចូលជាដើម។ ដោយសារតែសម្លឹងឃើញចំណុចទាំងអស់នេះហើយ ទើបជំរុញចិត្តវិនិយោគិន មកអោយមកធ្វើការវិនិយោគនៅក្នុងប្រទេសកម្ពុជាកាន់តែច្រើនឡើង។ ទន្ទឹមនឹងនោះសម្រាប់សាធារណៈប្រជាមានិតចិនវិញ បន្ទាប់ពីការដាក់ចេញនូវយុទ្ធសាស្ត្រសម្រាប់អនុវត្តក្នុងវិស័យវិនិយោគរួចមក វាហាក់បានកែប្រែមុខមាត់សាធារណៈរដ្ឋប្រជាមានិតចិនបានមួយកម្រិតទៀត ដោយសារតែភាពរីកចម្រើននូវសេដ្ឋកិច្ចទីផ្សាររបស់ចិនទាំងក្នុងប្រទេស និងក្រៅប្រទេស ហើយយុទ្ធសាស្ត្ររបស់រដ្ឋាភិបាល ក៏បានបង្កើតនូវលក្ខខណ្ឌសមរម្យសម្រាប់ការប្រកួតប្រជែងដោយស្មើភាពគ្នារវាងសហគ្រាសក្នុងស្រុក និងសហគ្រាសបរទេស។ តាមរយៈយុទ្ធសាស្ត្រនេះរដ្ឋាភិបាលប្រទេសចិន បានប្តេជ្ញាក្នុងការបន្តបើកចំហទីផ្សារទំនិញទៅកាន់បរទេស ស្របពេលដែលជំរុញការបើកអោយមាននូវសេវាកម្មនិងឧស្សាហកម្ម។ ចំណែកការកែប្រែបច្ចេកវិទ្យា និងយុទ្ធសាស្ត្រអភិវឌ្ឍបានផ្តល់នូវមូលដ្ឋានគ្រឹះដ៏រឹងមាំ សម្រាប់អភិវឌ្ឍបន្ថែមនូវឧស្សាហកម្មវិនិយោគបរទេស និងរចនាសម្ព័ន្ធឧស្សាហកម្មក្នុងតំបន់។ យុទ្ធសាស្ត្រនេះត្រូវបានបង្កើតឡើងដោយរដ្ឋា

ភិបាលចិនដើម្បីជាការលើកទឹកចិត្តវិនិយោគបរទេស បង្កើនការនាំចេញទៅក្រៅប្រទេស និងបង្កើនទំនាក់ទំនងការទូតជាមួយប្រទេសអភិវឌ្ឍន៍ និងប្រទេសកំពុងអភិវឌ្ឍន៍ ដើម្បីជាការបើកចំហានូវទីផ្សារសេដ្ឋកិច្ចអោយកាន់តែទូលាយសម្រាប់ជាប្រយោជន៍ដល់កំណើនសេដ្ឋកិច្ចជាតិ។ វាក៏បានផ្តល់នូវឱកាសទីផ្សារ និងស្ថេរភាពសម្រាប់ការវិនិយោគបរទេសនៅក្នុងប្រទេសចិនបានកាន់តែច្រើន និងក្នុងលក្ខណៈទ្រង់ទ្រាយធំសម្រាប់សហប្រតិបត្តិការពាណិជ្ជកម្ម ក៏ដូចជាធ្វើការដកស្រង់នូវឥទ្ធិពលវិជ្ជមានមួយចំនួនសម្រាប់ការស្វែងរក និងទាញយកធនធានបរទេស។

# សេចក្តីសន្និដ្ឋាន

ក្រោយការសិក្សាទៅលើប្រធានបទ "ក្របខណ្ឌគតិយុត្តវិនិយោគ រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណៈរដ្ឋប្រជាមានិតចិនរួចមក ការសិក្សាស្រាវជ្រាវមួយនេះពិតជាបានផ្តល់នូវផលប្រយោជន៍យ៉ាងច្រើនតាមរយៈការឆ្លុះបញ្ចាំងអោយឃើញពីភាពដូចគ្នា និងភាពខុសគ្នារវាងក្របខណ្ឌគតិយុត្តវិនិយោគរវាងប្រទេសទាំងពីរ។ ការសិក្សាស្រាវជ្រាវមួយនេះ បានរំលេចអោយឃើញពីអត្ថន័យនៃច្បាប់វិនិយោគរវាងប្រទេសទាំងពីរ។ ជាក់ស្តែង ទោះបីជាអត្ថន័យនៃក្របខណ្ឌគតិយុត្តវិនិយោគរបស់ប្រទេសទាំងពីរបានចែងខុសៗគ្នាក៏ដោយ តែគោលបំណងគឺមានភាពស្រដៀងគ្នាពោលធ្វើយ៉ាងណាអាចធានារាល់សកម្មភាពវិនិយោគនៅក្នុងប្រទេស និងជំរុញអោយមានការបើកចំហសកម្មភាពវិនិយោគ នៅក្នុងប្រទេសលើគ្រប់វិស័យដែលជាកម្លាំងចលករក្នុងការអភិវឌ្ឍនូវខឿនសេដ្ឋកិច្ចជាតិទាំងមូល។ យ៉ាងណាមិញ បទដ្ឋានគតិយុត្តមួយចំនួនត្រូវបានធ្វើវិសោធនកម្មដើម្បីអាចបំពេញបន្ថែមនូវកង្វះខាត និងអោយមានលក្ខណៈសមស្របតាមបរិបទសង្គម។ រដ្ឋាភិបាលនៃប្រទេសទាំងពីរក៏បានរៀបចំនូវប្រព័ន្ធគតិយុត្ត មួយចំនួនបន្ថែមទៀតតាមរយៈការកំណត់នូវបទបញ្ញត្តិពិសេសៗ ទាំងនៅព្រះរាជាណាចក្រកម្ពុជានិងសាធារណៈរដ្ឋប្រជាមានិតចិន ដូចជាការបង្កើតអោយមានតំបន់សេដ្ឋកិច្ចពិសេស ការកំណត់ពីអត្រាពន្ធជាដើម ដើម្បីអោយទិដ្ឋភាពនៃការវិនិយោគរឹតតែមានលក្ខណៈសមរម្យ និងបង្កើននូវបរិយាកាសវិនិយោគអោយកាន់តែមានភាពអំណោយផលដល់សេដ្ឋកិច្ចជាតិ។ តាមរយៈការបង្កើតនូវបទបញ្ញត្តិពិសេសទាំងនេះ ប្រទេសទាំងពីរបានទាក់ទាញ និងបានផ្តល់ទំនុកចិត្តដល់វិនិយោគិនជាតិ និងបរទេសដែលបានបណ្តាក់ទុននៅក្នុងប្រទេសរបស់ខ្លួន។ ការធានាមិនធ្វើជាតូបនីយកម្មនូវទ្រព្យសម្បត្តិឯកជន ការលើកលែងពន្ធលើប្រាក់ចំណេញ ការពង្រឹងនូវក្របខណ្ឌគតិយុត្តដែលទាក់ទងនឹងការវិនិយោគសុទ្ធសឹងតែជាបានបញ្ញត្តិយ៉ាងច្បាស់លាស់នៅក្នុងច្បាប់ ដែលជាការបើកចំហនូវទីផ្សារសេដ្ឋកិច្ចសម្រាប់អ្នកវិនិយោគ ។ ទោះជាយ៉ាងណា វិនិយោគិនទាំងអស់មិនថានៅប្រទេសកម្ពុជា ឬប្រទេសចិនសុទ្ធតែត្រូវឆ្លងកាត់ការដាក់ពាក្យស្នើសុំអាជ្ញាប័ណ្ណវិយោគ មុននឹងទទួលបានលក្ខណៈគ្រប់គ្រាន់ និងទទួលបាននូវការធានាសិទ្ធិវិនិយោគស្របច្បាប់។ នៅប្រទេសកម្ពុជា ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ឬអនុគណៈកម្មាធិការខេត្ត-ក្រុង ដែលជាអ្នកមានសមត្ថកិច្ចទទួលបន្ទុក និងជាសេនាធិការរបស់រាជរដ្ឋាភិបាលក្នុងការត្រួតពិនិត្យ និងសម្រេចការងារវិនិយោគ។ ចំណែកឯនៅប្រទេសចិនវិញគឺមានគណៈកម្មាធិការផែនការអភិវឌ្ឍន៍ ឬគណៈកម្មាធិការសេដ្ឋកិច្ច និងពាណិជ្ជកម្ម ដែលជាអ្នក

សម្រេចទៅលើគម្រោងណាមួយនោះ ដោយអាស្រ័យលើចំនួនទឹកប្រាក់នៃគម្រោងនីមួយៗ។ ដោយឡែកនៅក្នុងទំនាក់ទំនងវិនិយោគតែងតែជួបប្រទះនូវជម្លោះ ដែលទាមទារអោយមានការដោះស្រាយដ៏សមរម្យសម្រាប់ភាគី ទោះបីវិធីសាស្ត្រក្នុងការដោះស្រាយមានលក្ខណៈខុសគ្នាក៏ដោយ។ សម្រាប់ប្រទេសកម្ពុជា ការដោះស្រាយវិវាទវិនិយោគអាចធ្វើឡើងតាមរយៈការសម្របសម្រួលរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ការដោះស្រាយដោយមជ្ឈត្តកម្ម និងការដោះស្រាយតាមផ្លូវតុលាការ។ រីឯប្រទេសចិនវិញ ការដោះស្រាយវិវាទវិនិយោគក៏មានលក្ខណៈស្រដៀងគ្នានឹងការដោះស្រាយនៅប្រទេសកម្ពុជាដែរ គឺធ្វើឡើងតាមរយៈការចរចារ សន្ទាន មជ្ឈត្តកម្ម និងការដោះស្រាយតាមផ្លូវតុលាការ។ បន្ថែមពីនេះទៀតនោះ ការសិក្សាអំពីទម្រង់ក្រុមហ៊ុនវិនិយោគនៃប្រទេសនីមួយៗក៏ជាការចាំបាច់។ នៅប្រទេសកម្ពុជា ទម្រង់ក្រុមហ៊ុនវិនិយោគមានបីធំៗ គឺ ក្រុមហ៊ុនភាគទុន១០០% ជាខ្មែរ ឬបរទេស ក្រុមហ៊ុនចម្រុះ និងកិច្ចសន្យាសហប្រតិបត្តិការ។ ឯប្រទេសចិនវិញ គឺមានក្រុមហ៊ុនបណ្តាក់ទុនរួមគ្នា ក្រុមហ៊ុនសហប្រតិបត្តិការ ក្រុមហ៊ុនវិនិយោគបរទេសតែមួយគត់ ក្រុមហ៊ុនវិនិយោគទទួលខុសត្រូវមានកម្រិត ក្រុមហ៊ុនវិនិយោគទុនបរទេស និងកិច្ចសន្យាសាងសង់-អាជីវកម្ម-ផ្ទេរ-ល-។ ចំណែកឯដំណើរការនៃក្រុមហ៊ុននីមួយៗគឺមានកំណត់នៅក្នុងច្បាប់។ ការសិក្សាពីឱកាសដែលជំរុញអោយមានការវិនិយោគនៅប្រទេសកម្ពុជា និងនៅប្រទេសចិន ក៏ជាចំណុចសំខាន់ដែលត្រូវយកមកសិក្សាប្រៀបធៀបផងដែរ។ ជាក់ស្តែងព្រះរាជាណាចក្រកម្ពុជាបានដាក់ចេញនូវគោលនយោបាយ និងយុទ្ធសាស្ត្រសំខាន់ៗក្នុងការលើកស្ទួយវិស័យវិនិយោគនិងទាក់ទាញការវិនិយោគពីបរទេសអោយកាន់តែច្រើនផងដែរ។ អភិបាលកិច្ចល្អ ការគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេស និងការប្រើប្រាស់ដីធ្លី សុទ្ធតែជាគោលនយោបាយសំខាន់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា សម្រាប់ជាការទាក់ទាញដល់វិនិយោគិនបរទេសអោយមកវិនិយោគនៅកម្ពុជាអោយកាន់តែច្រើន។ ក៏មានការកំណត់ពីយុទ្ធសាស្ត្រមួយចំនួនទៀតផងដែរ ដូចជាការធានាសមភាព ការធានាកម្មសិទ្ធិឯកជន ការធានាសេរីភាពកំណត់តម្លៃ និងការធានាចរាចររូបិយប័ណ្ណ ក៏ដូចជាការលើកទឹកចិត្តតាមរយៈការលើកលែងពន្ធប្រាក់ចំណេញ ពន្ធគយនាំចេញជាដើម។ ទាំងនេះសុទ្ធសឹងតែជាចំណុចទាក់ទាញ និងផ្តល់ទំនុកចិត្តក្នុងការវិនិយោគ។ ស្រដៀងគ្នានឹងប្រទេសកម្ពុជាដែរ ប្រទេសចិនបានចេញនូវគោលនយោបាយមួយចំនួនដែលផ្តោតសំខាន់ទៅលើ "Going global" ដែលធ្វើយ៉ាងណាអាចទាក់ទាញវិនិយោគិនបរទេសមកវិនិយោគនៅក្នុងប្រទេសរបស់ខ្លួន និងអាចពង្រីកទីផ្សារសេដ្ឋកិច្ចទៅក្រៅប្រទេសផងដែរ។ រីឯយុទ្ធសាស្ត្រសម្រាប់ការអនុវត្តក្នុងវិស័យវិនិយោគនវិញ គឺធ្វើឡើងតាមរយៈគោលការណ៍មួយចំនួនដែលបង្កើតឡើងដោយរដ្ឋាភិបាល ដើម្បី

ជាឱកាសសម្រាប់ពង្រីកទីផ្សារវិនិយោគ និងសកលភាវូបនីយកម្ម ក៏ដូចជាសហប្រតិបត្តិការសេដ្ឋកិច្ចនិងបច្ចេកវិទ្យាអន្តរជាតិផងដែរ សម្រាប់ជាការទ្រទ្រង់ទៅដល់ការអភិវឌ្ឍប្រទេសជាតិទាំងមូល។ជាថ្មីម្តងទៀតការសិក្សាទៅលើប្រធានបទមួយនេះពិតជាផ្តល់សារៈសំខាន់និងអត្ថប្រយោជន៍សម្រាប់អភិវឌ្ឍដល់សេដ្ឋកិច្ច និងប្រទេសជាតិទាំងមូល ព្រោះការវិនិយោគគឺជាកម្លាំងចលករមួយដ៏សំខាន់ និងចាំបាច់សម្រាប់ទ្រទ្រង់ប្រទេសជាតិទាំងមូល។

# អនុសាសន៍

ការសិក្សាទៅលើប្រធានបទមួយនេះ ពិតជាបានផ្តល់អត្ថប្រយោជន៍យ៉ាងច្រើនទាក់ទិនទៅនឹងវិស័យវិនិយោគ។ យ៉ាងណាមិញ កង្វះខាតមួយចំនួនទាក់ទិននឹងវិស័យវិនិយោគនៅតែមានដែលតម្រូវអោយមានការយកចិត្តទុកដាក់ និងកែតម្រូវ។

ទោះបីជាក្របខណ្ឌគតិយុត្តវិនិយោគនៅប្រទេសកម្ពុជា មានចំនួនច្រើនក៏ពិតមែន តែការអនុវត្តជាក់ស្តែងនៅមានបញ្ហានៅឡើយ។ ទោះបីជាខ្លឹមសារគតិយុត្តមានលក្ខណៈល្អប្រសើរក៏ពិតមែន បើការអនុវត្តជាក់ស្តែងមានការធ្វេសប្រហែស ឬមិនបានអនុវត្តអោយបានខ្ជាប់ខ្ជួនទេនោះ វាអាចធ្វើអោយប៉ះពាល់ដល់សេដ្ឋកិច្ចជាតិយ៉ាងខ្លាំងដោយសារការបាត់បង់នូវប្រសិទ្ធិភាពច្បាប់ និងធ្វើអោយបាត់បង់ទំនុកចិត្តពីអ្នកវិនិយោគ។ ដូច្នេះរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ក៏ដូចជាស្ថាប័នដែលពាក់ព័ន្ធ គួរធ្វើការត្រួតពិនិត្យច្បាប់ និងការអនុវត្តអោយមានខ្ជាប់ខ្ជួនដើម្បីធានាអោយមានការអនុវត្តច្បាប់មានលក្ខណៈប្រសើរឡើង និងប្រកបដោយតម្លាភាព។ ស្ថាប័នដែលពាក់ព័ន្ធគួរតែចាត់វិធានការអោយបានតឹងរឹងផងដែរ ចំពោះសកម្មភាពណាមួយដែលប្រាសចាកនឹងច្បាប់។ ចំណែកឯរដ្ឋាភិបាល និងប្រជាពលរដ្ឋទាំងអស់គួររួមសហការគ្នាក្នុងកាអនុវត្តនូវច្បាប់វិនិយោគអោយបានខ្ជាប់ខ្ជួន និងធានានូវប្រសិទ្ធិភាពច្បាប់ ពីព្រោះការវិនិយោគគឺជាសក្តានុពលយ៉ាងចំបងសម្រាប់ការអភិវឌ្ឍជាតិ។

ចំណែកឯសាធារណៈរដ្ឋប្រជាមានិតចិនវិញ ក៏មានការផ្តោតលើវិស័យវិនិយោគខ្លាំងផងដែរ។ តែដើម្បីការវិនិយោគរឹតតែមានភាពប្រសើរឡើងទៀតនោះ រដ្ឋាភិបាលគួរត្រួតពិនិត្យមើលឡើងវិញនូវវិធានគតិយុត្តមួយចំនួន ហើយធ្វើការកែតម្រូវ ឬបង្កើតក្របខណ្ឌគតិយុត្តថ្មីបន្ថែមទៀតដើម្បីអោយការអនុវត្តរឹតតែស្របតាមបរិបទសង្គមបច្ចុប្បន្ន។ បន្ថែមជាងនេះទៀត សាធារណៈរដ្ឋប្រជាមានិតចិន គួរបង្កើនទំនាក់ទំនងក្រៅប្រទេសអោយបានកាន់តែច្រើន ដើម្បីជាការបង្ហាញពីគោលដៅវិនិយោគ និងជាការទាក់ទាញអ្នកវិនិយោគបរទេសនានាមកវិនិយោគអោយបានច្រើនដើម្បីជាការបំពេញតម្រូវការក្នុងស្រុក និងពន្លឿនការអភិវឌ្ឍសេដ្ឋកិច្ចជាតិ។

# ឧបសម្ព័ន្ធ

# ច្បាប់

# ស្ដីពី

# វិនិយោគ

# ១៩៩៤

Khmer Law's Association

# ច្បាប់

## ស្តីពី

# វិនិយោគ

# នៃព្រះរាជាណាចក្រកម្ពុជា

# ព្រះរាជក្រម

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

យោងតាមមាត្រាទី ១១ ជំពូកទី ២ ស្តីអំពី ព្រះមហាក្សត្រ នៃ រដ្ឋធម្មនុញ្ញព្រះរាជាណាចក្រ កម្ពុជា ដែលត្រូវបានសភាធម្មនុញ្ញអនុម័ត នៅ ថ្ងៃទី ២១ ខែកញ្ញា ឆ្នាំ១៩៩៣

## បង្គាប់

មាត្រា ១. ប្រកាសអោយប្រើជាផ្លូវការ នូវច្បាប់ស្តីពីវិនិយោគនៃ ព្រះរាជាណាចក្រកម្ពុជា ដែលរដ្ឋសភា បានអនុម័តនៅថ្ងៃទី ០៤ ខែសីហា ឆ្នាំ១៩៩៤ ។

មាត្រា ២. ព្រះរាជក្រមនេះចូលជាធរមានច្បាប់ ចាប់ពីពេលចុះ ហត្ថលេខានេះតទៅ ។

ធ្វើនៅព្រះរាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែសីហា ឆ្នាំ១៩៩៤

ក្នុងព្រះបរមនាម និង ដោយព្រះរាជបង្គាប់

ប្រមុខរដ្ឋស្តីទី

# ច្បាប់

## ស្តីពី

## វិនិយោគ

## នៃព្រះរាជាណាចក្រកម្ពុជា

### ជំពូកទី ១

### បទបញ្ញត្តិទូទៅ

មាត្រា ១.-

ច្បាប់នេះមានវិសាលភាពគ្របដណ្តប់លើការវិនិយោគនានា ដែលអនុវត្តនៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ដោយអ្នកវិនិយោគជាជនជាតិខ្មែរនិង / ឬ ជនបរទេស ។

មាត្រា ២.-

អ្នកវិនិយោគទាំងអស់ត្រូវស្ថិតនៅក្រោមច្បាប់នេះ ហើយអាចជារូបវន្តបុគ្គលឬជានីតិបុគ្គល ។

:

### ជំពូកទី ២

### ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

មាត្រា ៣.-

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ជាអង្គការមានសមត្ថកិច្ច និងជាច្រកចេញចូលតែមួយគត់ក្នុងការទទួលបន្ទុកការងារនីតិសម្បទា អភិវឌ្ឍន៍និងការវិនិយោគ ។ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ជាសេនាធិការរបស់រាជរដ្ឋាភិបាល ក្នុងការពិនិត្យនិងសំរេចការងារនីតិសម្បទានិងអភិវឌ្ឍន៍ និងការវិនិយោគនានា ។

មាត្រា ៤._

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា មានគណៈកម្មាធិការពីរសំរាប់ជំនួយការគឺ ៖

១_ គណៈកម្មាធិការនីតិសម្បទា និង អភិវឌ្ឍន៍

២_ គណៈកម្មាធិការវិនិយោគកម្ពុជា ។

មាត្រា ៥._

ការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ត្រូវកំណត់ដោយអនុក្រឹត្យ ។

## ជំពូកទី ៣
## នីតិវិធីនៃការវិនិយោគ

មាត្រា ៦._

អ្នកវិនិយោគត្រូវដាក់ពាក្យសុំទៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាដើម្បីពិនិត្យ និងសំរេច ។

មាត្រា ៧._

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ត្រូវឆ្លើយតបអំពីការសំរេចរបស់ខ្លួនទៅអ្នកវិនិយោគ ក្នុងរយៈពេល ៤៥ ថ្ងៃយ៉ាងយូរ គិតពីថ្ងៃទទួលពាក្យសុំដែលបានបំពេញបែបបទត្រឹមត្រូវនិងគ្រប់គ្រាន់ ។ បើគ្មានមូលហេតុត្រឹមត្រូវ មន្ត្រីរាជការណាដែលប្រកែកមិនព្រមទទួលពិនិត្យនិងឆ្លើយតបអំពីការសំរេចរបស់ខ្លួនទៅអ្នកវិនិយោគវិញ ហួសកាលកំណត់ខាងលើ ត្រូវផ្តន្ទាទោសតាមបញ្ញត្តិច្បាប់ ។

## ជំពូកទី ៤
## ការធានាលើការវិនិយោគ

មាត្រា ៨._

អ្នកវិនិយោគត្រូវបានទទួលស្គាល់និងចាត់ទុកដោយស្មើភាពគ្នាចំពោះមុខច្បាប់ គ្មានការរើសអើងអំពីសញ្ជាតិឬពូជសាសន៍ទេ លើកលែងតែចំពោះកម្មសិទ្ធិលើដីធ្លី ដូចដែលមានចែងក្នុងបទបញ្ញត្តិនៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ៩._

រាជរដ្ឋាភិបាលនឹងមិនធ្វើជាតូបនីយកម្ម ដែលនាំឱ្យប៉ះពាល់ដល់ទ្រព្យសម្បត្តិរបស់អ្នកវិនិយោគក្នុងព្រះរាជាណាចក្រកម្ពុជាឡើយ ។

មាត្រា ១០._

រាជរដ្ឋាភិបាលមិនត្រួតពិនិត្យលើថ្លៃផលិតផលឬថ្លៃសេវានានារបស់អ្នកវិនិយោគ ដែលបានទទួលការអនុញ្ញាតរួចហើយនោះឡើយ ។

មាត្រា ១១._

ដោយអនុលោមទៅតាមច្បាប់ទាំងឡាយដែលពាក់ព័ន្ធ ព្រមទាំងបទបញ្ញត្តិទាំងឡាយដែលបានកំណត់និងប្រកាសផ្សាយដោយធនាគារជាតិកម្ពុជា រាជរដ្ឋាភិបាលអនុញ្ញាតដល់អ្នកវិនិយោគ មានសិទ្ធិទិញរូបិយប័ណ្ណបរទេសតាមរយៈប្រព័ន្ធធនាគារ សំរាប់បង្វិលទៅបរទេសវិញ ដើម្បីទូទាត់កាតព្វកិច្ចខាងហិរញ្ញវត្ថុដែលពាក់ព័ន្ធនឹងការវិនិយោគរបស់ខ្លួន ។

ការទូទាត់ខាងលើនេះរួមមាន ៖

១._ ការទូទាត់លើការនាំចូល និងការបង្វិលទៅក្រៅប្រទេសទាំងដើមទាំងការប្រាក់ចងការ ។

២._ ការទូទាត់ចំណាយសួយសារ និង ថ្លៃសេវាគ្រប់គ្រង ។

៣._ ការផ្ទេរប្រាក់ចំណេញ ។

៤._ ការបង្វិលដើមទុនវិនិយោគទៅក្រៅប្រទេសវិញ ដូចមានចែងក្នុងជំពូកទី ៨ ។

## ជំពូកទី ៥
## ការលើកទឹកចិត្តវិនិយោគ

មាត្រា ១២._

រាជរដ្ឋាភិបាលលើកទឹកចិត្ត ដើម្បីជំរុញការវិនិយោគលើវិស័យសំខាន់ៗដូចតទៅ ៖

១._ ឧស្សាហកម្មនាំមុខ ឬ ឧស្សាហកម្មដែលមានបច្ចេកវិទ្យាខ្ពស់

២._ ការបង្កើតការងារ

៣_ ការបង្កើនការនាំចេញ

៤_ ឧស្សាហកម្មទេសចរណ៍

៥_ ការផលិតទំនិញកសិ_ឧស្សាហកម្ម និង ឧស្សាហកម្មកែច្នៃ

៦_ ការកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និង ការផលិតថាមពល

៧_ អភិវឌ្ឍន៍ខេត្ត និងជនបទ

៨_ ការការពារបរិស្ថាន

៩_ ការវិនិយោគក្នុងតំបន់អភិវឌ្ឍន៍ពិសេស ដែលនឹងត្រូវបង្កើតឡើងដោយច្បាប់ ។

មាត្រា ១៣._

ការលើកទឹកចិត្តមាន ការលើកលែងទាំងស្រុង ឬមួយផ្នែកនៃពន្ធគយនិងពន្ធអាករ ។

មាត្រា ១៤._

ការលើកទឹកចិត្តទាំងឡាយ រួមមានដូចខាងក្រោមនេះ ៖

១_ អត្រាពន្ធលើប្រាក់ចំណេញសុទ្ធ ៩% លើកលែងតែអត្រាពន្ធផ្សេងៗលើការរុករក និង អាជីវកម្មធនធានធម្មជាតិ ព្រៃឈើ ប្រេងកាត រ៉ែ មាស ត្បូងថ្មមានតម្លៃ ។ ល ។ ដែលត្រូវចែងក្នុងច្បាប់ដោយឡែក ។

២_ ពន្ធលើប្រាក់ចំណេញអាចលើកលែងបានរហូតដល់រយៈពេល ៨ ឆ្នាំ គឺអាស្រ័យលើលក្ខណៈសម្បត្តិរបស់ការវិនិយោគនីមួយៗនិងអាទិភាព ដែលរាជរដ្ឋាភិបាលនឹងកំណត់ដោយអនុក្រឹត្យ ។ ការលើកលែងពន្ធលើប្រាក់ចំណេញនឹងត្រូវអនុវត្តចាប់ពីឆ្នាំដែលបានទទួលប្រាក់ចំណេញលើកទីមួយ ។ ការខាតបង់រយៈពេល ៥ ឆ្នាំបន្តបន្ទាប់ ត្រូវបានអនុញ្ញាតឱ្យយកមកទូទាត់គិតប្រាក់ចំណេញ ។ ក្នុងករណីយកប្រាក់ចំណេញមកធ្វើវិនិយោគបន្ត ប្រាក់ចំណេញត្រូវបានអនុញ្ញាតឱ្យរួចពន្ធទាំងស្រុង ។

៣_ មិនយកអាករលើការបែងចែកប្រាក់ចំណេញនៃការវិនិយោគ ទោះជាប្រាក់ទាំងនោះត្រូវផ្ទេរទៅបរទេសក្តី ឬបែងចែកក្នុងប្រទេសក្តី ។

៤_ ការលើកលែងពន្ធគយ និងពន្ធអាករ ១០០% ក្នុងការនាំចូលសម្ភារៈសំណង់ មធ្យោបាយផលិតកម្ម គ្រឿងសម្ភារៈបរិក្ខារ ទំនិញពាក់កណ្តាលសំរេច វត្ថុធាតុដើម និងគ្រឿងបន្លាស់សំរាប់ប្រើប្រាស់ ត្រូវមានលក្ខខណ្ឌណាមួយដូចតទៅ ៖

ក_ ការវិនិយោគដែលមានទិសដៅសំរាប់បំរើឱ្យការនាំចេញ ក្នុងកំរិតអប្បបរមា ៨០% នៃផលិតផលសរុប ។

ខ_ មានទីតាំងនៅក្នុងតំបន់អភិវឌ្ឍន៍ពិសេស ដែលមានក្នុងបញ្ជីអាទិភាពសំរាប់អភិវឌ្ឍន៍ប្រកាសដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ។

គ_ ឧស្សាហកម្មទេសចរណ៍

ឃ_ ឧស្សាហកម្មប្រើប្រាស់កម្លាំងពលកម្មច្រើន ឧស្សាហកម្មកែច្នៃ កសិ_ឧស្សាហកម្ម ។

ង_ ការកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្តនិងការផលិតថាមពល ។

ការលើកលែងពន្ធគយ និងពន្ធអាករ ១០០% ខាងលើនេះ ត្រូវអនុវត្តជាបន្តបន្ទាប់ ហូតស្របតាមរយៈពេលដែលកំណត់ក្នុងកិច្ចសន្យា ឬ សៀវភៅបន្ទុក សំរាប់ការវិនិយោគដែលផលិតទំនិញនាំចេញក្នុងកំរិតអប្បបរមា ៨០% នៃផលិតកម្មសរុប ដូចមានចែងក្នុងចំណុច ( ៤ )ក ខាងលើ និងសំរាប់ការវិនិយោគដែលមានទីតាំងក្នុងតំបន់អភិវឌ្ឍន៍ពិសេស ដូចមានចែងក្នុងចំណុច ( ៤ )ខ ។

ក្រៅពីប្រភេទការវិនិយោគដែលមានចែងក្នុងចំណុច( ៤ )ក និងចំណុច ( ៤ )ខ ខាងលើនេះ ការលើកលែងពន្ធគយ និង ពន្ធអាករ ១០០% ត្រូវបានអនុញ្ញាតឱ្យសំរាប់តែក្នុងរយៈពេលនៃការរៀបចំកសាងសហគ្រាស រោងចក្រ អាគារនិងការចាប់ដំណើរការអាជីវកម្ម ផលិតកម្មនៅឆ្នាំដំបូងប៉ុណ្ណោះ ។

៥_ ការលើកលែងពន្ធគយ ១០០% ក្នុងការនាំចេញផលិតផលទៅក្រៅប្រទេស ។

៦_ ការអនុញ្ញាតឱ្យយកចូលមកក្នុងព្រះរាជាណាចក្រកម្ពុជានូវជនបរទេសណាដែលជា ៖

- បុគ្គលិក និង អ្នកជំនាញការខាងគ្រប់គ្រង
- បុគ្គលិកបច្ចេកទេស
- កម្មករជំនាញ
- សហព័ទ្ធនិងអ្នកក្នុងបន្ទុករបស់ខ្លួន ដែលអនុញ្ញាតដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ហើយស្របទៅតាមច្បាប់អន្តោប្រវេសន៍និងច្បាប់ការងារ ។

មាត្រា ១៥._

ការអនុញ្ញាតនិងការលើកទឹកចិត្តដែលបានផ្តល់ដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាមិនអាចផ្ទេរ ឬ លក់បានឡើយ ។

## ជំពូកទី ៦
## កម្មសិទ្ធិ និង ការប្រើប្រាស់ដីធ្លី

មាត្រា ១៦._

អនុលោមតាមរដ្ឋធម្មនុញ្ញ ច្បាប់និងបទបញ្ញត្តិទាំងឡាយ ដែលពាក់ព័ន្ធទៅនឹងកម្មសិទ្ធិ និងការប្រើប្រាស់ដីធ្លី ៖

១- កម្មសិទ្ធិដីធ្លីសំរាប់បំរើឱ្យគោលដៅនៃសកម្មភាពវិនិយោគ ត្រូវបាន ប្រគល់ជូនចំពោះអ្នកវិនិយោគដែលជារូបវន្តបុគ្គល ឬនីតិបុគ្គលដែលមានសញ្ជាតិជាខ្មែរ ។ នីតិបុគ្គលមាន សញ្ជាតិជាខ្មែរ គឺជានីតិបុគ្គលដែលភាគហ៊ុនចាប់តាំងពី ៥១% ឡើងទៅនៃដើមទុនសរុបជាកម្មសិទ្ធិនៃរូបវន្តបុគ្គល ឬ នីតិបុគ្គលដែលមានសញ្ជាតិជាខ្មែរ ។

២- អ្នកវិនិយោគអាចប្រើប្រាស់ដីធ្លីតាមរយៈការជួលសំរាប់រយៈពេលវែង រហូតដល់ ៧០ ឆ្នាំ ហើយអាចស្នើសុំជួលបន្ត ។ ការប្រើប្រាស់ដីធ្លីនេះ រាប់បញ្ចូលទាំងសិទ្ធិនៃកម្មសិទ្ធិទាំង ឡាយនៅលើផ្ទៃដីនោះ ត្រូវអនុវត្តស្របតាមច្បាប់ ។

## ជំពូកទី ៧
## ការប្រើប្រាស់កំលាំងពលកម្ម

មាត្រា ១៧.-

អ្នកវិនិយោគនៅព្រះរាជាណាចក្រកម្ពុជា មានសិទ្ធិធ្វើការជ្រើសរើស និងជួលនិយោ-ជិតខ្មែរ និង បរទេសបានដោយសេរី ផ្អែកលើមូលដ្ឋាននៃច្បាប់ការងារ និង ច្បាប់អន្តោប្រវេសន៍ ។

មាត្រា ១៨.-

អ្នកវិនិយោគត្រូវបានអនុញ្ញាតឱ្យជួលនិយោជិតបរទេស ដូចមានចែងក្នុងមាត្រា១៤ (៦) ក្នុងលក្ខខ័ណ្ឌដូចតទៅ ៖

១- គុណភាព សមត្ថភាព និងជំនាញមិនអាចរកបាននៅព្រះរាជាណា-ចក្រកម្ពុជាក្នុងចំណោមប្រជាពលរដ្ឋខ្មែរ ។ បើមានការជួលនិយោជិតប្រភេទនេះ ត្រូវភ្ជាប់មកជាមួយនូវសេចក្តី ចម្លងលិខិតឆ្លងដែន សញ្ញាប័ត្រ និងប្រវត្តិរូបសង្ខេបរបស់និយោជិតនោះ ។

២- អ្នកវិនិយោគមានកាតព្វកិច្ចធ្វើការបណ្តុះបណ្តាលជាប្រចាំ និងសម ស្របជូននិយោជិតខ្មែរ ។

៣- ការជំរុញលើកកំពស់ដល់និយោជិតខ្មែរ ដើម្បីអាចក្លាយទៅជាអ្នក មានឋានៈខ្ពស់ត្រូវធ្វើជាប្រចាំ ។

មាត្រា ១៩.-

និយោជិតបរទេស ត្រូវបានអនុញ្ញាតអោយផ្ទេរទៅក្រៅប្រទេសនូវប្រាក់បៀវត្ស ដែល ទទួលបាននៅក្នុងព្រះរាជាណាចក្រកម្ពុជា តាមរយៈប្រព័ន្ធធនាគារ ក្រោយពីបានបង់ពន្ធរួចហើយ ។

# ជំពូកទី ៨
## វិវាទ និង ការរំលាយ

មាត្រា ២០.-

វិវាទដែលទាក់ទងទៅនឹងកិច្ចការវិនិយោគនៅក្នុងព្រះរាជាណាចក្រកម្ពុជារបស់អ្នកវិនិយោគ ដែលពាក់ព័ន្ធទៅនឹងសិទ្ធិ និងភាតព្វកិច្ចដែលមានចែងក្នុងច្បាប់នេះអាច ៖

១- ដោះស្រាយដោយសម្រុះសម្រួលតាមរយៈការពិគ្រោះគ្នារវាងភាគីជំលោះទាំងឡាយ ។

២- ក្នុងអំឡុងពេលពីរខែ បើវិវាទមិនបានដោះស្រាយតាមការសម្រុះសម្រួលគ្នាទេ វិវាទនេះអាច ៖

- លើកយកមកដាក់ជូនក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាផ្តល់យោបល់
- ដោះស្រាយតាមផ្លូវតុលាការនៃព្រះរាជាណាចក្រកម្ពុជា
- ឬដោះស្រាយតាមនីតិវិធីអន្តរជាតិណាមួយ តាមការព្រមព្រៀងនៃភាគី ។

មាត្រា ២១.-

ក្នុងករណីអ្នកវិនិយោគមានបំណងចង់បញ្ចប់សកម្មភាពរបស់ខ្លួននៅក្នុងព្រះរាជាណាចក្រកម្ពុជា អ្នកវិនិយោគនោះ ត្រូវជូនពត៌មានទៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាតាមរយៈលិខិតអនុសិដ្ឋ ឬលិខិតប្រគល់ផ្ទាល់ដៃ ដោយមានបញ្ជាក់ថាបានទទួលត្រឹមត្រូវ ។ លិខិតខាងលើនេះ ត្រូវចុះហត្ថលេខាដោយអ្នកវិនិយោគ ឬអ្នកតំណាងពេញសិទ្ធិរបស់ក្រុមហ៊ុនហើយត្រូវបញ្ជាក់អំពីមូលហេតុនៃការបញ្ចប់សកម្មភាពនោះផង ។

មាត្រា ២២.-

ក្នុងករណីដែលមានការសុំរំលាយក្រៅផ្លូវតុលាការ អ្នកវិនិយោគត្រូវផ្តល់ជូនក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា នូវលិខិតបញ្ជាក់ពីម្ចាស់បំណុល ពីអ្នកប្តឹងរបស់ខ្លួន និងពីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ថាបញ្ហាទាំងឡាយត្រូវបានដោះស្រាយចប់ជាស្ថាពរហើយ ទើបអ្នកវិនិយោគនោះអាចត្រូវបានអនុញ្ញាតអោយរំលាយក្រុមហ៊ុន ឬ សហគ្រាសរបស់ខ្លួនជាផ្លូវការបាន តាមបែបបទនៃច្បាប់ពាណិជ្ជកម្ម ។

មាត្រា ២៣.-

ក្នុងករណីដែលអ្នកវិនិយោគត្រូវបានអនុញ្ញាតអោយរំលាយក្រុមហ៊ុន ឬសហគ្រាសរបស់ខ្លួនជាផ្លូវការ ទោះតាមផ្លូវតុលាការក្តី ឬក្រៅផ្លូវតុលាការក្តី អ្នកវិនិយោគអាចផ្ទេរនូវទ្រព្យសម្បត្តិដែលសេសសល់ទៅក្រៅប្រទេស ឬមួយប្រើប្រាស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។ ចំពោះគ្រឿងម៉ាស៊ីន និង

សម្ភារៈបរិក្ខារដែលបានការអនុញ្ញាតអោយនាំចូលដោយរួចពន្ធហើយបានប្រើប្រាស់ក្នុងអំឡុងពេលតិចជាងប្រាំឆ្នាំ ( ៥ឆ្នាំ)អ្នកវិនិយោគត្រូវបង់ពន្ធតាមច្បាប់ជាធរមាន ។

## ជំពូកទី ៩

## អវសានបញ្ញត្តិ

មាត្រា ២៤.-

ការវិនិយោគទាំងឡាយ ដែលបានទទួលការអនុញ្ញាត ក្រោមច្បាប់ស្តីពីការវិនិយោគនៅរដ្ឋកម្ពុជា និងអនុក្រឹត្យស្តីពីការវិនិយោគរបស់បរទេសនៅរដ្ឋកម្ពុជា ត្រូវបានទទួលផលប្រយោជន៍ និងកាតព្វកិច្ចដូចមានចែងក្នុងច្បាប់នេះដែរ ប៉ុន្តែច្បាប់នេះពុំមានអានុភាពប្រតិសកម្មទេ ។

មាត្រា ២៥.-

ក្នុងករណីដែលអ្នកវិនិយោគរំលោភ ឬមិនអនុវត្តតាមលក្ខខ័ណ្ឌទាំងឡាយដែលបានកំណត់ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាមានសិទ្ធិអំណាចដកហូតសិទ្ធិផ្សេងៗនិងផលប្រយោជន៍ទាំងអស់ ឬមួយផ្នែកដែលបានផ្តល់ជូនអ្នកវិនិយោគកន្លងមក ។

មាត្រា ២៦.-

ច្បាប់នេះត្រូវប្រកាសជាការប្រញាប់ ។

ច្បាប់នេះត្រូវបានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា
អនុម័តនៅថ្ងៃទី ០៤ ខែ សីហា ឆ្នាំ ១៩៩៤
នាសម័យប្រជុំវិសាមញ្ញនីតិកាលទី ១
ភ្នំពេញ,ថ្ងៃទី ០៤ ខែ សីហា ឆ្នាំ ១៩៩៤
ប្រធានរដ្ឋសភាស្តីទី

ឈួរ ស៊ីមហេង

# ច្បាប់
# ស្ដីពី
# វិសោធនកម្ម
# ច្បាប់ស្ដីពី
# វិនិយោគ
# ២០០៣

# ព្រះរាជក្រម

នស/រកម/០៣០៣/០០៩

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា និងរបស់ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីវិសោធនកម្ម នៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០០៣ នាសម័យប្រជុំពេញអង្គលើកទី ៩ នីតិកាល ទី ២ ហើយដែលព្រឹទ្ធសភាបានយល់ស្របតាមលើទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០០៣ នាសម័យប្រជុំពេញអង្គលើកទី ៩ នីតិកាលទី ១ ដែលមានសេចក្តីទាំងស្រុង ដូចតទៅ :

**មាត្រាតែមួយ ._**

ត្រូវបានកែប្រែមាត្រា ១, មាត្រា ២, មាត្រា ៦, មាត្រា ៧, មាត្រា ៨, មាត្រា ១០, មាត្រា ១២, មាត្រា ១៤, មាត្រា ១៥, មាត្រា ១៦, មាត្រា ១៨, មាត្រា ២០, មាត្រា ២១, មាត្រា ២២, មាត្រា ២៣ ជំពូកទី ៩ មាត្រា ២៤ និងជំពូកទី ១០ មាត្រា ២៥ មាត្រា ២៦ និងមាត្រា ២៧ នៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ០៣/នស/៩៤ ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៤ ដូចតទៅ :

**មាត្រា ១._ថ្មី**

ច្បាប់នេះមានវិសាលភាពចំពោះរាល់គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ និងកំណត់នីតិវិធីនៃការបង្កើតគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដែលធ្វើឡើងដោយបុគ្គលណាមួយ ។

មានតែគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ទេ ដែលមានសិទ្ធិទទួលបាននូវផលប្រយោជន៍ដែលស្ថិតក្នុងក្របខ័ណ្ឌនៃច្បាប់នេះ ។

**មាត្រា ២._ថ្មី**

ក្នុងន័យនៃច្បាប់នេះ វាក្យសព្ទដូចខាងក្រោម :

**គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់** ហៅកាត់ គ.ល.គ មានន័យថា គម្រោងវិនិយោគដែលទទួលបានវិញ្ញាបនប័ត្រចុះបញ្ជីជាស្ថាពរ

**គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់បម្រើឱ្យការនាំចេញ** មានន័យថា ជាគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដែលផលិតផលរបស់គម្រោងត្រូវបាននាំចេញ ដែលនឹងកំណត់ដោយអនុក្រឹត្យ

**គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដែលជាប្រភេទឧស្សាហកម្មគាំទ្រ** មានន័យថា គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដែលផលិតផលរបស់ខ្លួន ១០០% (មួយរយភាគរយ) ត្រូវផ្គត់ផ្គង់ដល់ឧស្សាហកម្មនាំចេញជិនូសវត្ថុធាតុដើម ឬសម្ភារៈបន្ទាប់បន្សំដែលតែងតែនាំចូល

**ថ្ងៃធ្វើការ** មានន័យថា ថ្ងៃប្រតិទិនដែលជាថ្ងៃធ្វើការជាផ្លូវការរបស់រាជរដ្ឋាភិបាលកម្ពុជា

**នីតិបុគ្គលសញ្ជាតិខ្មែរ** មានន័យថា ក្រុមហ៊ុនដែលមានទីកន្លែងធ្វើអាជីវកម្ម និងដែលបានធ្វើការចុះបញ្ជីនៅក្នុងព្រះរាជាណាចក្រកម្ពុជានិងភាគហ៊ុន ៥១% (ហាសិបមួយភាគរយ) ឬលើសក្នុងក្រុមហ៊ុន ត្រូវបានកាន់កាប់ដោយបុគ្គលមានសញ្ជាតិជាខ្មែរ

**បុគ្គល** មានន័យថា រូបវ័ន្តបុគ្គល ឬនីតិបុគ្គល

**វិញ្ញាបនប័ត្រចុះបញ្ជីមានលក្ខខណ្ឌ** មានន័យថា ឯកសារដែលចេញដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាដូចមានចែងក្នុងកថាខណ្ឌ ៣ មាត្រា ៧ ថ្មី នៃច្បាប់នេះ

**វិញ្ញាបនប័ត្រចុះបញ្ជីជាស្ថាពរ** មានន័យថា ឯកសារដែលចេញដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដូចមានចែងក្នុងកថាខណ្ឌ ៧ មាត្រា ៧ ថ្មី នៃច្បាប់នេះ

**សំណើវិនិយោគ** មានន័យថា សំណើដែលបានដាក់ជូនក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាដោយបុគ្គលណាមួយក្នុងគោលបំណងបង្កើតគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់

**អ្នកដាក់ពាក្យស្នើ** មានន័យថា បុគ្គលឬក្រុមបុគ្គលដែលដាក់សំណើវិនិយោគនៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

**អ្នកវិនិយោគ** មានន័យថា បុគ្គលដែលអនុវត្តគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ។

## មាត្រា ៦.–ថ្មី

រាល់បុគ្គលដែលមានបំណងបង្កើតគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ត្រូវដាក់សំណើវិនិយោគនៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាតាមទម្រង់និងតាមនីតិវិធីដែលមានចែងនៅក្នុងច្បាប់នេះនិងអនុក្រឹត្យ ។

## មាត្រា ៧.–ថ្មី

ក្នុងរយៈពេល ០៣ (បី) ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាទទួលបានសំណើវិនិយោគ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាត្រូវចេញវិញ្ញាបនប័ត្រចុះបញ្ជីមានលក្ខខណ្ឌឬលិខិតបដិសេធទៅឱ្យអ្នកស្នើសុំ ។

បសិនបើសំណើវិនិយោគផ្តល់ជូននូវពត៌មានទាំងអស់ដែលតម្រូវដោយអនុក្រឹត្យ និងប្រសិនបើសកម្មភាពដែលបានស្នើសុំពុំមានបញ្ជាក់នៅក្នុងបញ្ជីគម្រោងហាមឃាត់ដែលមានចែងនៅក្នុងអនុក្រឹត្យទេនោះ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាត្រូវចេញវិញ្ញាបនប័ត្រចុះបញ្ជីមានលក្ខខណ្ឌ ។ ផ្ទុយទៅវិញ បើសំណើវិនិយោគនោះពុំឆ្លើយតបតាមលក្ខខណ្ឌខាងលើនោះទេ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាត្រូវចេញលិខិតបដិសេធជូនទៅអ្នកស្នើសុំ ។

វិញ្ញាបនប័ត្រចុះបញ្ជីមានលក្ខខណ្ឌត្រូវបញ្ជាក់ឱ្យបានច្បាស់លាស់ពីការយល់ព្រម ការអនុញ្ញាត ការជំរះបញ្ជី អាជ្ញាប័ណ្ណ លិខិតអនុញ្ញាតឬបញ្ជិកានានា ដែលត្រូវជាតម្រូវការសម្រាប់ដំណើរការគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់រួមទាំងបញ្ជាក់ពីស្ថាប័នមានសមត្ថកិច្ចរបស់រាជរដ្ឋាភិបាលដែលទទួលបន្ទុកក្នុងការចេញលិខិតយល់ព្រមការជំរះបញ្ជី អាជ្ញាប័ណ្ណលិខិតអនុញ្ញាតឬបញ្ជិកាទាំងនោះផង ។ វិញ្ញាបនប័ត្រចុះបញ្ជីមានលក្ខខណ្ឌត្រូវបញ្ជាក់ផងដែរនូវការលើកទឹកចិត្តនានា ដែលគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់មានសិទ្ធិទទួល ដូចមានចែងក្នុងមាត្រា ១៤ ថ្មី នៃច្បាប់នេះ និងការទទួលស្គាល់លើលក្ខន្តិកៈនៃនីតិបុគ្គលដែលជាអ្នកអនុវត្តគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ។

ប្រសិនបើក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាខកខានពុំបានចេញវិញ្ញាបនប័ត្រចុះបញ្ជីមានលក្ខខណ្ឌឬលិខិតបដិសេធក្នុងរយៈពេល ៣ថ្ងៃ(បី) នៃថ្ងៃធ្វើការទេ វិញ្ញាបនប័ត្រចុះបញ្ជីមានលក្ខខណ្ឌត្រូវបានចាត់ទុកថា បានយល់ព្រមដោយស្វ័យប្រវត្តិ តាមទម្រង់ដូចមានកំណត់ដោយអនុក្រឹត្យ ។

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាត្រូវទទួលយកនូវអាជ្ញាប័ណ្ណទាំងអស់ពីក្រសួងស្ថាប័នពាក់ព័ន្ធ ដូចមានចែងក្នុងវិញ្ញាបនប័ត្រចុះបញ្ជីមានលក្ខខណ្ឌ ជំនួសមុខឱ្យអ្នកស្នើសុំ ។

រាល់ស្ថាប័នមានសមត្ថកិច្ចរបស់រដ្ឋាភិបាលដែលទទួលបន្ទុកចេញលិខិតអនុញ្ញាតការជំរះបញ្ជី រាជ្ជាប័ណ្ណ លេខិតយល់ព្រមឬបញ្ជិកាដែលមានរាយបញ្ជាក់នៅក្នុងវិញ្ញាបនប័ត្រចុះបញ្ជីមានលក្ខខណ្ឌ ត្រូវចេញឯកសារទាំងនេះ យ៉ាងយូរបំផុតអោយបានមុន ២៨ថ្ងៃ នៃថ្ងៃធ្វើការ គិតចាប់ពីកាលបរិច្ឆេទនៃវិញ្ញាបនប័ត្រចុះបញ្ជីមានលក្ខខណ្ឌ ។

មន្ត្រីរាជការណាមួយដែលខកខានពុំបានឆ្លើយតបទៅនឹងពាក្យស្នើសុំដោយគ្មានមូលហេតុត្រឹមត្រូវតាមកាលកំណត់ ត្រូវផ្តន្ទាទោសតាមច្បាប់ ។

ក្នុងរយៈពេល ២៨ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាចេញវិញ្ញាបនប័ត្រចុះបញ្ជីមានលក្ខខណ្ឌ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាត្រូវចេញវិញ្ញាបនប័ត្រចុះបញ្ជីជាស្ថាពរ ។ ការចេញវិញ្ញាបនប័ត្រចុះបញ្ជីជាស្ថាពរ មិនមែនជាការលើកលែងឱ្យគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់រួចផុតពីការទទួលនូវលិខិតអនុញ្ញាតនានាដែលក្រសួងស្ថាប័នមានសមត្ថកិច្ចបានកំណត់ឡើយ ។ ទោះបីផុតរយៈពេល ២៨ថ្ងៃ ដូចមានចែងក្នុងកថាខណ្ឌ ៦ ខាងលើក៏ដោយ រាល់ស្ថាប័នមានសមត្ថកិច្ចត្រូវតែចេញលិខិតអនុញ្ញាតតាមការកំណត់ដោយច្បាប់និងបទប្បញ្ញត្តិនានា ។ កាលបរិច្ឆេទនៃការចេញជូននូវវិញ្ញាបនប័ត្រចុះបញ្ជីជាស្ថាពរគឺជាកាលបរិច្ឆេទនៃការចាប់ផ្តើមគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ។

រាល់លិខិតបដិសេធត្រូវមានបញ្ជាក់មូលហេតុច្បាស់លាស់ពីការមិនអាចទទួលសំណើវិនិយោគរួមទាំងព័ត៌មានបន្ថែម ដើម្បីផ្តល់លទ្ធភាពឱ្យក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាអាចចេញវិញ្ញាបនប័ត្រចុះបញ្ជីមានលក្ខខណ្ឌបាន ។

**មាត្រា ៨.-ថ្មី**

អ្នកវិនិយោគបរទេសត្រូវបានទទួលស្គាល់និងមិនត្រូវជាកម្មវត្ថុនៃការរើសអើងដោយសារតែមូលហេតុសញ្ជាតិបរទេសទេ លើកលែងតែចំពោះដីធ្លី ដូចដែលមានចែងនៅក្នុងច្បាប់ភូមិបាល ។

**មាត្រា ១០.-ថ្មី**

រាជរដ្ឋាភិបាលមិនកំណត់ថ្លៃផលិតផលឬថ្លៃសេវានានានៃគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់នោះឡើយ ។

**មាត្រា ១២.-ថ្មី**

រាជរដ្ឋាភិបាលផ្តល់ការលើកទឹកចិត្តដែលមានចែងក្នុងជំពូកនេះ ដល់គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ។

**មាត្រា ១៤..ថ្មី**

ការលើកទឹកចិត្តដែលមានចែងក្នុងមាត្រា ១៣ រួមមានដូចខាងក្រោម :

១-គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់មានសិទ្ធិទទួលការលើកលែងពន្ធលើប្រាក់ចំណេញដែលមានកំណត់ក្នុងច្បាប់ស្តីពីសារពើពន្ធ ដោយទទួលបាននូវរយៈពេលលើកលែងពន្ធលើប្រាក់ចំណេញ ។ រយៈពេលលើកលែងពន្ធរួមមាន : រយៈពេលគន្លឹះបូករយៈពេល ៣(បី)ឆ្នាំបូករយៈពេលអាទិភាព ។ រយៈពេលអាទិភាពនឹងត្រូវកំណត់ក្នុងច្បាប់ស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុ ។ រយៈពេលគន្លឹះជាអតិបរមាគឺជាឆ្នាំទី ១ ដែលគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ទទួលបានប្រាក់ចំណេញ ឬរយៈពេល ៣(បី)ឆ្នាំ បន្ទាប់ពីគម្រោងវិនិយោគនោះបានទទួលប្រាក់ចំណូលដំបូងរបស់ខ្លួនដោយជ្រើសយកជម្រើសណាមួយដែលឆាប់ជាង ។

២-គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់មានសិទ្ធិទទួលបាននូវការលើកទឹកចិត្តផ្អែកតាមកថាខណ្ឌ ១ ខាងលើ លុះត្រាតែគម្រោងនោះទទួលបានពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជានូវវិញ្ញាបនប័ត្រប្រចាំឆ្នាំបញ្ជាក់ពីការបំពេញបាននូវកាតព្វកិច្ចចំពោះរដ្ឋដែលត្រូវកំណត់ដោយអនុក្រឹត្យ ។

៣-បន្ទាប់ពីផុតរយៈពេលលើកលែងពន្ធ គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ត្រូវជាប់ពន្ធលើប្រាក់ចំណេញ ។

៤-គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដែលប្រើប្រាស់សិទ្ធិទទួលបាននូវការលើកទឹកចិត្តផ្អែកតាមកថាខណ្ឌ ១ ខាងលើ ពុំមានសិទ្ធិធ្វើការទាមទារការរំលោះពិសេសណាមួយឡើយ ។

៥-គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដែលបម្រើទីផ្សារក្នុងស្រុក មានសិទ្ធិនាំចូលដោយរួចពន្ធគយនូវគ្រឿងសម្ភារៈបរិក្ខាផលិតកម្ម សម្ភារៈសាងសង់ បម្រើផលិតកម្ម ដែលត្រូវកំណត់ដោយអនុក្រឹត្យ ។

៦-ក្រៅពីគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់បម្រើឱ្យការនាំចេញដែលជ្រើសរើសឬបានជ្រើសរើសយកយន្តការ ភណ្ឌាគារផលិតកម្មក្រោមការគ្រប់គ្រងរបស់គយ គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់បម្រើឱ្យការនាំចេញដទៃទៀត មានសិទ្ធិនាំចូលដោយរួចពន្ធគយនូវគ្រឿងសម្ភារៈបរិក្ខាផលិតកម្ម សម្ភារៈសាង

សង់ វត្ថុធាតុដើម ផលិតផលពាក់កណ្តាលសម្រេចនិងសម្ភារៈបន្ទាប់បន្សំបម្រើផលិត-កម្ម ដែលត្រូវកំណត់ដោយអនុក្រឹត្យ ។

៧-គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដែលជាប្រភេទឧស្សាហកម្មគាំទ្រមានសិទ្ធិនាំចូល ដោយរួចពន្ធគយ នូវគ្រឿងសម្ភារៈបរិក្ខាផលិតកម្មសម្ភារៈសាងសង់ វត្ថុធាតុដើម ផលិតផលពាក់កណ្តាលសម្រេចនិងសម្ភារៈបន្ទាប់បន្សំបម្រើផលិតកម្មដែលត្រូវកំណត់ដោយអនុក្រឹត្យ ។

៨-បុគ្គលណាដែលបានទិញឬវិនិយោគដែលបានរំលាយបញ្ចូលគ្នាជាមួយអ្នកវិនិយោគណាមួយ អាចទទួលស្នងពីគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដោយផ្ញើសំណើទៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជានូវរាល់ការធានា សិទ្ធិ បុព្វសិទ្ធិ និងកាតព្វកិច្ចទាំងអស់ ដោយយោងទៅតាមនីតិវិធីនៃការទិញឬការរំលាយបញ្ចូលគ្នាដែលត្រូវកំណត់ដោយអនុក្រឹត្យ ។

៩-គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដែលមានទីតាំងនៅក្នុងតំបន់អភិវឌ្ឍន៍ពិសេសឬតំបន់ផលិតកែច្នៃនាំចេញដែលមានក្នុងបញ្ជីអាទិភាពសម្រាប់អភិវឌ្ឍន៍ ប្រកាសដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា មានសិទ្ធិទទួលបាននូវការលើកទឹកចិត្តនិងបុព្វសិទ្ធិដូចគ្នានឹងគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ផ្សេងៗទៀតដូចមានចែងនៅក្នុងច្បាប់នេះ ។

១០-គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់មានសិទ្ធិទទួលបាននូវការលើកលែងពន្ធនាំចេញ ១០០%(មួយរយភាគរយ) លើកលែងតែចំពោះសកម្មភាពទាំងឡាយ ដូចមានចែងនៅក្នុងច្បាប់ជាធរមាន ។

១១-គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ មានសិទ្ធិទទួលបាននូវទិដ្ឋាការនិងប័ណ្ណការងារ ដើម្បីធ្វើការនៅក្នុងព្រះរាជាណាចក្រកម្ពុជាសម្រាប់ជនបរទេសដែលធ្វើជាអ្នកគ្រប់គ្រង អ្នកបច្ចេកទេសនិងកម្មករជំនាញ រួមទាំងទិដ្ឋាការស្នាក់នៅសម្រាប់សហព័ទ្ធនិងអ្នកនៅក្នុងបន្ទុករបស់ជនបរទេសទាំងនោះ ដែលអនុញ្ញាតដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ស្របតាមច្បាប់ស្តីពីអន្តោប្រវេសន៍និងច្បាប់ស្តីពីការងារ ។

**មាត្រា ១៥._ថ្មី**

សិទ្ធិ បុព្វសិទ្ធិនិងសិទ្ធិដទៃទៀតដែលគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់បានទទួល មិនអាចផ្ទេរឬប្រគល់ជូនទៅតតិយជនណាមួយឡើយ លើកលែងតែក្នុងករណីទិញ ឬរំលាយបញ្ចូលគ្នា ដូចមានចែងនៅក្នុងកថាខណ្ឌ ៨ នៃមាត្រា ១៤ ថ្មី ។

**មាត្រា ១៦._ថ្មី**

កម្មសិទ្ធិដីធ្លីរបស់អ្នកវិនិយោគសម្រាប់មជ្រើឱ្យគោលដៅអនុវត្តគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ត្រូវបានអនុញ្ញាតចំពោះរូបវន្តបុគ្គល ឬនីតិបុគ្គលដែលមានសញ្ជាតិខ្មែរ ។

អ្នកវិនិយោគអាចប្រើប្រាស់ដីធ្លីតាមរយៈដីសម្បទានឬការជួលរយៈពេលមិនកំណត់ និងការជួលរយៈពេលមានកំណត់ដែលអាចបន្តជាថ្មីបាន ស្របតាមបទប្បញ្ញត្តិដូចមានចែងក្នុងច្បាប់ភូមិបាល ។

អ្នកវិនិយោគមានសិទ្ធិកាន់កាប់និងដាក់បញ្ចាំសម្រាប់ធានានិងផ្ទេរនូវចលនទ្រព្យនិងអចលនទ្រព្យដែលស្ថិតនៅលើដីនិងដីដែលគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ប្រើប្រាស់ តាមរយៈពេលមិនលើសពីរយៈពេលដែលមានកំណត់ក្នុងកិច្ចសន្យាសម្បទានដី ឬកិច្ចសន្យាជួល ដូចដែលបានអនុញ្ញាតដោយច្បាប់ ។

ចំពោះដីសម្បទានណាដែលពុំទាន់បានដំណើរការ អ្នកវិនិយោគមិនអាចផ្ទេរ ឬបញ្ចាំបន្តទៀតជាដាច់ខាត ។

**មាត្រា ១៨._ថ្មី**

អ្នកវិនិយោគត្រូវបានអនុញ្ញាតឱ្យជួលនិយោជិតបរទេសតាមលក្ខខណ្ឌដូចតទៅ :

- គុណភាព សមត្ថភាពនិងជំនាញមិនអាចរកបាននៅព្រះរាជាណាចក្រកម្ពុជាក្នុងចំណោមប្រជាពលរដ្ឋខ្មែរ ។ ក្នុងករណីមានការជួលនិយោជិតប្រភេទនេះ ត្រូវផ្ញើជូនមកក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជានូវឯកសាររួមមាន សេចក្ដីចម្លងលិខិតឆ្លងដែន សញ្ញាប័ត្រនិងប្រវត្តិរូបសង្ខេបរបស់និយោជិតនោះ

- ត្រូវមានលិខិតអះអាងពីតម្រូវការជួលនិយោជិតបរទេស ។ អ្នកវិនិយោគត្រូវមានការយល់ព្រម និងលិខិតអនុញ្ញាតពីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈនិងយុវនីតិសម្បទា

- មុននឹងចូលបម្រើការងារឱ្យអ្នកវិនិយោគ និយោជិតបរទេសត្រូវមានលិខិតអនុញ្ញាតឱ្យធ្វើការនៅព្រះរាជាណាចក្រកម្ពុជាពីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈនិងយុវនីតិសម្បទា ។

អ្នកវិនិយោគមានកាតព្វកិច្ចដូចតទៅ :

- ធ្វើការបណ្តុះបណ្តាលសមស្របជូននិយោជិតខ្មែរជាប្រចាំ

- ជំរុញលើកកំពស់ដល់និយោជិតខ្មែរដើម្បីអាចក្លាយទៅជាអ្នកមានតួនាទីដែលមានកម្រិតខ្ពស់ ត្រូវធ្វើជាប្រចាំ ។

## មាត្រា ២០-ថ្មី

វិវាទដែលទាក់ទងទៅនឹងគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ពាក់ព័ន្ធទៅនឹងសិទ្ធិនិងកាតព្វកិច្ចដែលមានចែងនៅក្នុងច្បាប់នេះ លើកលែងតែករណីទាក់ទងនឹងវិវាទដីធ្លី ត្រូវដោះស្រាយដោយសម្រុះសម្រួលតាមដែលអាចធ្វើទៅបាន តាមរយៈការពិគ្រោះគ្នារវាងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា អ្នកវិនិយោគ និងភាគីណាមួយផ្សេងទៀតដែលពាក់ព័ន្ធក្នុងវិវាទ ។

ក្នុងរយៈពេលពីរខែ បន្ទាប់ពីកាលបរិច្ឆេទនៃសំណើជាលាយលក្ខណ៍អក្សរដំបូងដែលស្នើសុំធ្វើការពិគ្រោះគ្នានេះ ប្រសិនបើភាគីមានវិវាទពុំអាចដោះស្រាយតាមការសម្រុះសម្រួលគ្នាទេ ភាគីណាមួយអាចលើកយកវិវាទនោះទៅ :

- សុំការផ្សះផ្សាសម្រុះសម្រួលនៅចំពោះមុខក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ឬ

- សុំធ្វើមជ្ឈត្តវិនិច្ឆ័យពីក្នុង ឬក្រៅប្រទេសកម្ពុជាតាមការព្រមព្រៀងរបស់គូភាគី ឬ

- សុំការជំនុំជំរះពីសាលាជំរះក្តីនៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ២១.-ថ្មី**

ក្នុងករណីអ្នកវិនិយោគមានបំណងចង់បញ្ឈប់សកម្មភាពរបស់ខ្លួននៅក្នុងព្រះរាជាណាចក្រកម្ពុជា អ្នកវិនិយោគនោះត្រូវជូនពត៌មានទៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា តាមរយៈលិខិតអនុសិដ្ឋឬលិខិតប្រគល់ផ្ទាល់ដៃ ដោយបញ្ជាក់អំពីមូលហេតុនៃការបញ្ឈប់សកម្មភាពនោះ និងចុះហត្ថលេខាដោយអ្នកវិនិយោគ ឬមេធាវីតំណាងផ្ទាល់របស់ខ្លួន ។

**មាត្រា ២២.-ថ្មី**

ប្រសិនបើអ្នកវិនិយោគមានបំណងចង់បញ្ឈប់សកម្មភាពនៃគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់របស់ខ្លួនក្រៅផ្លូវតុលាការ អ្នកវិនិយោគត្រូវផ្តល់ជូនក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជានូវភស្តុតាងបញ្ជាក់ថា គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់បានដោះស្រាយជំរះបំណុលរបស់ខ្លួនយ៉ាងត្រឹមត្រូវ រួមមានអ្នកប្តឹងឬការទាមទារណាមួយពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ទើបអ្នកវិនិយោគនោះត្រូវបានអនុញ្ញាតឱ្យបញ្ឈប់សកម្មភាពនៃគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ជាផ្លូវការឬរំលាយដោយយោងទៅតាមច្បាប់ជាធរមានពាក់ព័ន្ធនឹងវិស័យពាណិជ្ជកម្ម ។

**មាត្រា ២៣.-ថ្មី**

ក្នុងករណីដែលគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ត្រូវបានអនុញ្ញាតឱ្យបញ្ឈប់សកម្មភាពរបស់ខ្លួន ទោះតាមផ្លូវតុលាការក្តីឬក្រៅផ្លូវតុលាការក្តី អ្នកវិនិយោគអាចផ្ទេរនូវទ្រព្យសម្បត្តិដែលសេសសល់ទៅក្រៅប្រទេសឬមួយប្រើនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។ ប៉ុន្តែក្នុងករណីដែលគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់បានប្រើគ្រឿងម៉ាស៊ីននិងសម្ភារៈបរិក្ខាដែលបាននាំចូលដោយរួចពន្ធ ក្នុងអំឡុងពេលតិចជាង ៥(ប្រាំ)ឆ្នាំ គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់មានកាតព្វកិច្ចបង់ពន្ធលើគ្រឿងម៉ាស៊ីននិងសម្ភារៈបរិក្ខាទាំងនោះ យោងតាមការកំណត់របស់អនុក្រឹត្យ ។

## ជំពូកទី ៩ ថ្មី

## អន្តរប្បញ្ញត្តិ

**មាត្រា ២៤.–ថ្មី**

ការវិនិយោគទាំងឡាយដែលបានទទួលការអនុញ្ញាតដោយច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ០៣/នស/៩៤ ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៤ និងអនុក្រឹត្យនានា ត្រូវបានចាត់ទុកថាជាគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដូចមានចែងក្នុងច្បាប់នេះនិងអនុក្រឹត្យពាក់ព័ន្ធ ។

គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដែលមានសិទ្ធិទទួលបាននូវអត្រាពន្ធលើប្រាក់ចំណេញ ៩% (ប្រាំបួនភាគរយ) មុនពេលប្រកាសឱ្យប្រើនូវច្បាប់នេះ និងដែលបានចាប់ផ្តើមសកម្មភាពវិនិយោគដោយទទួលបានការយល់ព្រមអនុម័ត មានសិទ្ធិទទួលបានអត្រាពន្ធ ៩% (ប្រាំបួនភាគរយ)នេះ សម្រាប់រយៈពេល ៥(ប្រាំ)ឆ្នាំ ដោយចាប់ផ្តើមពីឆ្នាំសារពើពន្ធ បន្ទាប់ពីការប្រកាសឱ្យប្រើនូវច្បាប់នេះ លុះត្រាតែអ្នកវិនិយោគនោះបានដាក់ជាទៀងរាល់ឆ្នាំសារពើពន្ធនូវវិញ្ញាបនប័ត្រប្រចាំឆ្នាំ បញ្ជាក់ពីការបំពេញកាតព្វកិច្ចចំពោះរដ្ឋដែលត្រូវកំណត់ដោយអនុក្រឹត្យ ដូចមានចែងក្នុងកថាខណ្ឌ ២ មាត្រា ១៤ ថ្មីបន្ទាប់ពីការប្រកាសឱ្យប្រើច្បាប់នេះ ។

គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដែលមានសិទ្ធិត្រូវបានការលើកលែងពន្ធលើប្រាក់ចំណេញ តាមការយល់ព្រមជាលាយលក្ខណ៍អក្សររបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា មុនពេលប្រកាសឱ្យប្រើច្បាប់នេះ មានសិទ្ធិទទួលបន្តការលើកលែងពន្ធលើប្រាក់ចំណេញ លុះត្រាតែអ្នកវិនិយោគនោះ បានដាក់ជាទៀងរាល់ឆ្នាំសារពើពន្ធនូវវិញ្ញាបនប័ត្រប្រចាំឆ្នាំ បញ្ជាក់ពីការបំពេញកាតព្វកិច្ចចំពោះរដ្ឋដែលត្រូវកំណត់ដោយអនុក្រឹត្យ ដូចមានចែងក្នុងកថាខណ្ឌ ២ មាត្រា ១៤ ថ្មី បន្ទាប់ពីការប្រកាសឱ្យប្រើច្បាប់នេះ ។

## ជំពូកទី ១០ថ្មី
## អវសានប្បញ្ញត្តិ

**មាត្រា ២៥.–ថ្មី**

ក្នុងករណីដែលគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់រំលោភឬមិនអនុវត្តតាមលក្ខខណ្ឌទាំងឡាយដែលបានកំណត់ដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា នោះក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាមានសិទ្ធិអំណាចដកហូតសិទ្ធិផ្សេងៗនិងផលប្រយោជន៍ទាំងអស់ឬមួយផ្នែកដែលបានផ្តល់ជូនអ្នកវិនិយោគកន្លងមក ។

**មាត្រា ២៦.–ថ្មី**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះត្រូវទុកជានិរាករណ៍ ។

**មាត្រា ២៧.–ថ្មី**

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញ ថ្ងៃទី២៤ ខែមីនា ឆ្នាំ២០០៣
ក្នុងព្រះបរមនាមនិងតាមព្រះរាជត្រាស់បង្គាប់
ប្រមុខរដ្ឋស្តីទី

ពល.០៣.០៣.១៣៤

ហត្ថលេខា និង ត្រា

ជា ស៊ីម

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ
នាយករដ្ឋមន្ត្រី
ហត្ថលេខា

ហ៊ុន សែន

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី
ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ លេខ: ១០៧ ចល
ហត្ថលេខា

គាត ឈន់

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៤៨៦ អនក្រ.បក.

# អនុក្រឹត្យ

## ស្តីពី

## ការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែកក្កដា ឆ្នាំ២០០៤ ដែលប្រកាសអោយប្រើប្រាស់ច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៣/នស/៩៤ ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា និង ព្រះរាជក្រមលេខ នស/រកម/០៣០៣/០០៩ ចុះថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញសេចក្តីសម្រេចលេខ ២៨ សសរ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការកំណត់របៀបរបបការងារ និង ការបែងចែកភារកិច្ចរបស់ថ្នាក់ដឹកនាំរាជរដ្ឋាភិបាល
- យោងតាមសំណើរបស់ឧបនាយករដ្ឋមន្ត្រីប្រចាំការ អនុប្រធានទី១ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

### សម្រេច

### ជំពូកទី ១

### ការរៀបចំនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

**មាត្រា១ .-**

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាហៅកាត់ថា "ក.អ.ក" មានសមាសភាពដូចតទៅ÷

១- សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ប្រធាន

២- ឯកឧត្តម គាត ឈន់ ឧបនាយករដ្ឋមន្ត្រី ប្រចាំការ | អនុប្រធានទី១
៣- ឯកឧត្តម ស៊ុន ចាន់ថុល ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម | អនុប្រធាន
៤- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ឬតំណាង | សមាជិក
៥- រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ឬតំណាង | សមាជិក
៦- រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ឬតំណាង | សមាជិក
៧- រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឬតំណាង | សមាជិក
៨- រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឬតំណាង | សមាជិក
៩- រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ឬតំណាង | សមាជិក
១០-រដ្ឋមន្ត្រីក្រសួងផែនការ ឬតំណាង | សមាជិក
១១-រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ឬតំណាង | សមាជិក
១២- រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ឬតំណាង | សមាជិក
១៣- រដ្ឋមន្ត្រីក្រសួងបរិស្ថាន ឬតំណាង | សមាជិក
១៤- រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម ឬតំណាង | សមាជិក
១៥- រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ឬតំណាង | សមាជិក
១៦- រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន ឬតំណាង | សមាជិក
១៧- រដ្ឋមន្ត្រីក្រសួងទេសចរណ៍ ឬតំណាង | សមាជិក
១៨- រដ្ឋមន្ត្រីក្រសួងកិច្ចការនារី ឬតំណាង | សមាជិក
១៩- រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ឬតំណាង | សមាជិក
២០- អគ្គទេសាភិបាលធនាគារជាតិ នៃកម្ពុជា ឬតំណាង | សមាជិក
២១- ប្រធានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ ឬតំណាង | សមាជិក
២២- អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | លេខាធិការ

រដ្ឋមន្ត្រី ឬប្រធានស្ថាប័នឯទៀត នៃរាជរដ្ឋាភិបាល ត្រូវចូលរួមក្នុងការប្រជុំរបស់ "ក.អ.ក" តាមការអញ្ជើញរបស់ប្រធាន។ រដ្ឋមន្ត្រី ឬប្រធានស្ថាប័ន ដែលផ្តល់សិទ្ធិឱ្យតំណាងរបស់ខ្លួន ត្រូវផ្តល់សិទ្ធិសម្រេចពេញលេញសម្រាប់ការពិភាក្សា និងការសម្រេច។

**មាត្រា២ .-**

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា មានរចនាសម្ព័ន្ធដូចតទៅ ÷

១- គណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជា ហៅកាត់ "គ.ជ.នា" ដែលស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់របស់អគ្គលេខាធិការមួយរូប ។

២- គណៈកម្មាធិការវិនិយោគកម្ពុជា ហៅកាត់ "គ.វ.ក" ដែលស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់របស់អគ្គលេខាធិការមួយរូប ។

៣- គណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា ហៅកាត់ "គ.ស.ព" ដែលស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់របស់អគ្គលេខាធិការមួយរូប ។

៤- អគ្គលេខាធិការដ្ឋាននៃ "ក.អ.ក" ដែលស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់របស់អគ្គលេខាធិការ "ក.អ.ក" ។

**មាត្រា៣ .-**

អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា អគ្គលេខាធិការគណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជា អគ្គលេខាធិការគណៈកម្មាធិការវិនិយោគកម្ពុជា និងអគ្គលេខាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា មានអគ្គលេខាធិការរងមួយចំនួនរៀង១ខ្លួនសម្រាប់ជាជំនួយការក្នុងការងារ។ អគ្គលេខាធិការរងនីមួយ១ ត្រូវបំពេញកិច្ចការតាមភារកិច្ច ដែលអគ្គលេខាធិការប្រគល់ឱ្យក្រោយពីបានពិភាក្សាឯកភាពជាមួយគណៈកម្មាធិការប្រតិបត្តិនៃ "ក.អ.ក"។ អគ្គលេខាធិការមួយរូប១ត្រូវបំពេញការងារដោយផ្លាស់ប្តូរយោបល់ជាប្រចាំជាមួអគ្គលេខាធិការរងរបស់ខ្លួន ។

**មាត្រា៤ .-**

គណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជា មានរចនាសម្ព័ន្ធដូចតទៅ÷

១- ផ្នែកគោលនយោបាយ និង សម្របសម្រួលហិរញ្ញប្បទានសហប្រតិបត្តិការ

២- ផ្នែកឯកសារ និង គ្រប់គ្រងព័ត៌មាន

៣- ផ្នែកគ្រប់គ្រងហិរញ្ញប្បទានសហប្រតិបត្តិការទ្វេភាគី ជាមួយបណ្តាប្រទេសនៅទ្វីបអាស៊ី និងអូសេអានី

៤- ផ្នែកគ្រប់គ្រងហិរញ្ញប្បទានសហប្រតិបត្តិការទ្វេភាគី ជាមួយបណ្តាប្រទេសនៅទ្វីបអឺរ៉ុប និងសហគមន៍អឺរ៉ុប និងទ្វីបអាមេរិក

៥- ផ្នែកគ្រប់គ្រងហិរញ្ញប្បទានសហប្រតិបត្តិការនៃស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ (ធនាគារអភិវឌ្ឍន៍អាស៊ី ធនាគារពិភពលោក និង មូលនិធិរូបិយវត្ថុអន្តរជាតិ ។ល។)

៦- ផ្នែកគ្រប់គ្រងហិរញ្ញប្បទានសហប្រតិបត្តិការរបស់កម្មវិធីអភិវឌ្ឍន៍របស់សហប្រជាជាតិ និងបណ្តាស្ថាប័ននៃអង្គការរបស់សហប្រជាជាតិ

៧- ផ្នែកគ្រប់គ្រងសម្របសម្រួល និង ទំនាក់ទំនងជាមួយអង្គការមិនមែនរដ្ឋាភិបាល

៨- ផ្នែកវិភាគគម្រោងសហប្រតិបត្តិការ

៩- ផ្នែកភាពជាដៃគូ និងសុខដុមភាវូបនីយកម្មនៃកិច្ចសហប្រតិបត្តិការ

១០- ផ្នែករដ្ឋបាល ។

**មាត្រា៥ .-**

គណៈកម្មាធិការវិនិយោគកម្ពុជា មានរចនាសម្ព័ន្ធដូចតទៅ÷

១- ផ្នែកទំនាក់ទំនងសាធារណៈ និង ការជំរុញគម្រោងវិនិយោគឯកជន

២- ផ្នែកវិភាគគម្រោង និង ការលើកទឹកចិត្ត

៣- ផ្នែកវាយតំលៃខាងបរិស្ថាន

៤- ផ្នែកសម្របសម្រួលកិច្ចការអន្តរក្រសួង

៥- ផ្នែកវិភាគយុទ្ធសាស្ត្រនៃការវិនិយោគឯកជន

៦- ផ្នែកនីតិកម្ម និង ច្បាប់វិនិយោគ

៧- ផ្នែកត្រួតពិនិត្យ និងតាមដានគម្រោងវិនិយោគ

៨- ផ្នែករដ្ឋបាល

**មាត្រា៦ .-**

គណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា មានរចនាសម្ព័ន្ធដូចតទៅ÷

១- ផ្នែកគោលនយោបាយ និងផែនការ

២- ផ្នែកប្រតិបត្តិការ និងគ្រប់គ្រង

៣- ផ្នែកចុះបញ្ជី និងសិក្សាគម្រោង

៤- ផ្នែករដ្ឋបាល

**មាត្រា៧ .-**

អគ្គលេខាធិការដ្ឋាន នៃ "ក.អ.ក" រួមមាន "ផ្នែកគាំទ្រ" ចំនួន ៤ ÷

១- ផ្នែកនីតិកម្ម និង ដោះស្រាយវិវាទ

២- ផ្នែកផែនការនីយកម្មយុទ្ធសាស្ត្រ

៣- ផ្នែកគ្រប់គ្រងមន្ត្រី និង បុគ្គលិក

៤- ផ្នែកហិរញ្ញវត្ថុ និង រដ្ឋបាល ។

**មាត្រា៨ .-**

ផ្នែក និងផ្នែកគាំទ្រនីមួយៗ មានថ្នាក់ស្មើនឹងនាយកដ្ឋាន ហើយដឹកនាំដោយប្រធានមួយរូប ព្រមទាំងមានអនុប្រធានមួយរូប ឬ ច្រើនរូបជាជំនួយការ ។

**មាត្រា៩ .-**

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា មានគណៈកម្មាធិការប្រតិបត្តិសម្រាប់ដឹកនាំការងារប្រចាំថ្ងៃ ។

គណៈកម្មាធិការប្រតិបត្តិនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា មានសមាសភាពដូចតទៅ ÷

១- ប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

២- អនុប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

៣- អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

៤- អគ្គលេខាធិការគណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជា

៥- អគ្គលេខាធិការគណៈកម្មាធិការវិនិយោគកម្ពុជា

៦- អគ្គលេខាធិការគណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា ។

## ជំពូកទី ២
## សមត្ថកិច្ច និង ភារកិច្ចរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

**មាត្រា១០ .-**

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ជាស្ថាប័នប្រតិបត្តិរបស់រាជរដ្ឋាភិបាល ហើយមានភារកិច្ចដូចតទៅ ÷

១- ជាសេនាធិការ និង ជា "ច្រកចេញ-ចូលតែមួយ" របស់រាជរដ្ឋាភិបាល ក្នុងកិច្ចការនីតិសម្បទា និងអភិវឌ្ឍន៍ និងការវិនិយោគសាធារណៈ ការវិនិយោគឯកជន និងការបង្កើតនិងការគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេស ។

២- ទាក់ទងជាមួយដៃគូអភិវឌ្ឍន៍ និងអង្គការមិនមែនរដ្ឋាភិបាលទាំងអស់ ក្នុងគោលបំណងធ្វើអោយគេយល់ជ្រួតជ្រាបអំពីយុទ្ធសាស្ត្រ និងបណ្តាអាទិភាពរបស់រាជរដ្ឋាភិបាលក្នុងការអភិវឌ្ឍន៍ប្រទេស ដើម្បីសម្របសម្រួលការទទួល និងការប្រើប្រាស់ហិរញ្ញប្បទានសហប្រតិបត្តិការអោយមានប្រសិទ្ធភាព ស្របតាមសេចក្តីត្រូវការ និងអាទិភាពរបស់ប្រទេសជាតិ ដោយប្រកាន់តួនាទីជាម្ចាស់ សម្រាប់សម្រេចលទ្ធផលជូនប្រទេសជាតិ។

៣- សម្របសម្រួលការងាររវាងក្រសួង និងស្ថាប័ននានា ដែលមានការពាក់ព័ន្ធជាមួយនឹងដៃគូអភិវឌ្ឍន៍ និងអង្គការមិនមែនរដ្ឋាភិបាល ព្រមទាំងជាមួយអ្នកវិនិយោគ។

៤- តម្រង់ទិសក្នុងការបែងចែក និង ក្នុងការប្រើប្រាស់ធនធានសាធារណៈ និង ធនធានឯកជនក្នុងកិច្ចការអភិវឌ្ឍន៍កម្ពុជា ។

៥- បង្កលក្ខណៈងាយស្រួល និង សម្រួលកិច្ចការដល់ដៃគូអភិវឌ្ឍន៍ និងដល់អ្នកវិនិយោគ ។

៦- ពិនិត្យ និងសម្រេចរាល់កិច្ចការនីតិសម្បទានិងអភិវឌ្ឍន៍ និងគម្រោងវិនិយោគរបស់ដៃគូអភិវឌ្ឍន៍ គម្រោងវិនិយោគឯកជន និងការបង្កើត និងការគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេស។

**មាត្រា១១ .-**

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ត្រូវសុំយោបល់សម្រេចពីគណៈរដ្ឋមន្ត្រីលើគំរោងវិនិយោគទាំងឡាយដែលមានលក្ខណៈសម្បត្តិណាមួយដូចតទៅ÷

១- ទំហំទុនវិនិយោគសរុបចាប់ពី ៥០ លានដុល្លារអាមេរិក ឡើងទៅ

២- មានវិសាលភាពខាងនយោបាយ

៣- ការរុករក និងការធ្វើអាជីវកម្មរ៉ែ និងធនធានធម្មជាតិ

៤- អាចបង្កគ្រោះថ្នាក់ដល់បរិស្ថាន

៥- គម្រោងយុទ្ធសាស្ត្ររយៈពេលវែង

៦- គម្រោងសម្បទាននៃវិស័យហេដ្ឋារចនាសម្ព័ន្ធ

**មាត្រា១២ .-**

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ត្រូវទទួលខុសត្រូវចំពោះមុខគណៈរដ្ឋមន្ត្រី អំពីសកម្មភាពរបស់ខ្លួន ។

**មាត្រា១៣ .-**

ក្នុងកិច្ចការនីតិសម្បទា និងអភិវឌ្ឍន៍ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា មានភារកិច្ចដូចតទៅ ÷

១- ធ្វើជាចំណុចប្រមូលផ្ដុំ និងជា "ច្រកចេញ-ចូលតែមួយ" ក្នុងការទាក់ទងរវាងរាជរដ្ឋាភិបាលជាមួយនឹងដៃគូអភិវឌ្ឍន៍ និងអង្គការមិនមែនរដ្ឋាភិបាល ដែលផ្ដល់ហិរញ្ញប្បទានសហប្រតិបត្តិការឥតសំណងដល់កម្ពុជា និងធ្វើជាចំណុចប្រមូលផ្ដុំ និងជា "ច្រកចេញ-ចូលតែមួយ" ក្នុងការទាក់ទងរវាងស្ថាប័ននានានៃរាជរដ្ឋាភិបាល ដើម្បីសម្របសម្រួលការទទួល និង/ឬការគ្រប់គ្រងហិរញ្ញប្បទានសហប្រតិបត្តិការទាំងនេះ ។

២- រៀបចំ និងអនុវត្តយុទ្ធសាស្ត្រស្ដីពីការគ្រប់គ្រងកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ ដើម្បីពង្រឹងភាពជាម្ចាស់ និងភាពដឹកនាំរបស់រាជរដ្ឋាភិបាលក្នុងកិច្ចអភិវឌ្ឍន៍ ព្រមទាំងពង្រឹងភាពជាដៃគូជាមួយសហគមន៍ដៃគូអភិវឌ្ឍន៍ ។

៣- កៀរគរ និងវិភាជន៍ហិរញ្ញប្បទានសហប្រតិបត្តិការសម្រាប់អនុវត្តបណ្ដាគោលដៅអាទិភាពដែលមានចែងក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងផែនការអភិវឌ្ឍន៍តាមវិស័យ ។

៤- ដឹកនាំផ្ទាល់កិច្ចការសុខដុមនីយកម្មនៃការអនុវត្តរបស់ដៃគូអភិវឌ្ឍន៍ ដើម្បីបង្កើនប្រសិទ្ធភាព និងភាពសក្ដិសិទ្ធិនៃហិរញ្ញប្បទានសហប្រតិបត្តិការ ។

៥- ផ្ដល់ការគាំទ្រផ្នែកបច្ចេកទេស ដល់គណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ ដែលជាយន្តការសម្រាប់ពិភាក្សាកំរិតគោលនយោបាយ និងផ្ដល់ការគាំទ្រនានាសម្រាប់ពង្រឹងយន្តការរបស់ក្រុមការងារបច្ចេកទេសចម្រុះ ។

៦- ចូលរួមរៀបចំផែនការសេដ្ឋកិច្ច សង្គមកិច្ច និងផែនការតាមផ្នែកសម្រាប់អភិវឌ្ឍន៍កម្ពុជា ។

៧- ចូលរួមគ្រប់គ្រងកិច្ចការវិនិយោគសាធារណៈ ដោយសហការយ៉ាងជិតស្និទ្ធជាមួយនឹងក្រសួង និងស្ថាប័នទាំងឡាយដែលមានការពាក់ព័ន្ធ ។ ការងារនេះពាក់ព័ន្ធសំខាន់ទៅនឹងការសម្របសម្រួល និងការតំរង់ទិសក្នុងការបែងចែក និងការប្រើប្រាស់ធនធាននៅក្នុងប្រទេស និងធនធានដែលបានមកពីក្រៅប្រទេសដើម្បីកិច្ចការស្ដារ និងអភិវឌ្ឍន៍កម្ពុជា ។

៨- តាមការប្រគល់សិទ្ធិពីនាយករដ្ឋមន្ត្រី ចុះហត្ថលេខាតាងនាមរាជរដ្ឋាភិបាលជាមួយនឹងដៃគូអភិវឌ្ឍន៍ ដើម្បីទទួល និង/ឬបែងចែកហិរញ្ញប្បទានទាំងនោះ ។

៩- ដឹកនាំការងារក្នុងការរៀបចំឯកសារចាំបាច់នានាសម្រាប់កិច្ចប្រជុំកម្រិតគោលនយោបាយជាមួយដៃគូអភិវឌ្ឍន៍ ដូចជា "វេទិកាសម្រាប់កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា" ជាដើម ដោយសហការជាមួយបណ្ដាក្រសួង និងស្ថាប័នដែលមានការពាក់ព័ន្ធ ។

១០- ធ្វើរបាយការណ៍ប្រចាំឆមាស និងប្រចាំឆ្នាំជូនរាជរដ្ឋាភិបាល ដើម្បីរាជរដ្ឋាភិបាលពិនិត្យ និងលើកឡើងនូវវិធានការចាំបាច់សម្រាប់កែលំអ និងតម្រង់ទិសការងារនីតិសម្បទា និងអភិវឌ្ឍន៍ ។

## មាត្រា១៤ .-

ក្នុងការគ្រប់គ្រងកិច្ចការវិនិយោគសាធារណៈ ទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដែលមានការពាក់ព័ន្ធទៅនឹងបណ្ដាក្រសួង និងស្ថាប័ននានានៃរាជរដ្ឋាភិបាល ត្រូវកំណត់ដូចតទៅ÷

១- "ក.អ.ក" ជាអ្នកសម្របសម្រួលក្នុងការកំណត់លំដាប់អាទិភាពនៃកម្មវិធី និងគម្រោងវិនិយោគរបស់ដៃគូអភិវឌ្ឍន៍សម្រាប់រយៈពេលមធ្យម និងរយៈពេលមួយឆ្នាំ ។

២- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ជាបង្គួចការទូតផ្លូវការ ។

៣- ក្រសួងផែនការ សហការជាមួយក្រសួង និងស្ថាប័នពាក់ព័ន្ធ ជាអ្នកដឹកនាំក្នុងការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ៥ ឆ្នាំ និងកម្មវិធីវិនិយោគសាធារណៈ ។

៤- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាអ្នករៀបចំការប៉ាន់ប្រមាណស្ថានភាពម៉ាក្រូសេដ្ឋកិច្ចរយៈពេលមធ្យម ជាអ្នករៀបចំថវិកា សម្រាប់អនុវត្តកម្មវិធីវិនិយោគសាធារណៈប្រចាំឆ្នាំ និងជាអ្នកត្រួតពិនិត្យការប្រើប្រាស់ហិរញ្ញប្បទាន ។

៥- ក្រសួងជំនាញ ជាអ្នករៀបចំ ផែនការអភិវឌ្ឍន៍តាមវិស័យ និងគម្រោងវិនិយោគសាធារណៈ តាមផ្នែកដោយសហការយ៉ាងជិតស្និទ្ធជាមួយក្រសួងផែនការ និងជាមួយ "ក.អ.ក" ព្រមទាំងជាមួយអ្នកអនុវត្តកម្មវិធី និងគម្រោងវិនិយោគសាធារណៈតាមផ្នែកដែលមានការពាក់ព័ន្ធទៅនឹងសមត្ថកិច្ចរបស់ខ្លួន ។

## មាត្រា១៥ .-

ក្រសួង និងស្ថាប័ន ត្រូវធ្វើការងារ និងបំពេញភារកិច្ចរបស់ខ្លួន ខាងការវិនិយោគសាធារណៈដោយសម្របសម្រួលការងារជាមួយគ្នាតាមរយៈយន្តការ "ច្រកចេញ-ចូលតែមួយ" ។

## មាត្រា១៦ .-

ទីស្ដីការគណៈរដ្ឋមន្ត្រី ក្រសួង និងស្ថាប័ន ត្រូវតាមដានការអនុវត្តន៍កម្មវិធី និង/ឬ គម្រោងស្របតាមសមត្ថកិច្ចរៀងៗខ្លួន ដោយសម្របសម្រួលការងារជាមួយគ្នាតាមរយៈយន្តការ "ច្រកចេញ-ចូលតែមួយ" ។

**មាត្រា១៧ .-**

ក្នុងកិច្ចការវិនិយោគឯកជន ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា មានភារកិច្ចដូចតទៅ÷

១- បំពេញតួនាទីជាយន្តការ "ច្រកចេញ-ចូលតែមួយ" និងជាសេនាធិការរបស់រាជរដ្ឋាភិបាលក្នុងការពិនិត្យនិងសម្រេចលើការវិនិយោគនានាដូចបានកំណត់នៅក្នុងមាត្រា ៣ នៃច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ។

២- ធ្វើការវិភាគ "ការប្រណាំងប្រជែងដណ្តើមឈ្នះ" លើទីផ្សារអន្តរជាតិសម្រាប់ប្រទេសកម្ពុជា លើកឡើងនូវទស្សនៈអនាគតអំពីកិច្ចការវិនិយោគឯកជនសម្រាប់ប្រទេសកម្ពុជា និងសម្រេចអោយបាននូវទស្សនៈ នេះដោយធ្វើអោយប្រទេសកម្ពុជាក្លាយទៅជា "សាជីវកម្មកម្ពុជា" ។ សហការជាមួយក្រសួង និង ស្ថាប័នដែលមានការពាក់ព័ន្ធ ដើម្បីរៀបចំយុទ្ធសាស្ត្រនៃការវិនិយោគឯកជន និងដើម្បីលើកគម្រោងនានា សម្រាប់ការវិនិយោគឯកជន ។

៣- ផ្សព្វផ្សាយអំពីគម្រោងនានាសម្រាប់ការវិនិយោគឯកជន ដែលរាជរដ្ឋាភិបាលបានលើកឡើង និងផ្តល់គម្រោងទាំងនោះទៅអោយអ្នកវិនិយោគ តាមនីតិវិធី ដែលមានចែងនៅក្នុងបទបញ្ជាផ្ទៃក្នុងនៃ "ក.អ.ក" ។

៤- សម្របសម្រួលការគ្រប់គ្រងគម្រោងសម្បទាននៃវិស័យហេដ្ឋារចនាសម្ព័ន្ធ ។

៥- លើកគម្រោង និងផ្តល់យោបល់ជូនរាជរដ្ឋាភិបាលស្តីអំពីការរៀបចំ និងការកែលំអច្បាប់ បទប្បញ្ញត្តិ និងលិខិតបទដ្ឋានផ្សេងៗ ដែលទាក់ទិននឹងការវិនិយោគឯកជន ក្នុងគោលបំណងបង្កើតលក្ខខណ្ឌដែលអនុគ្រោះ និងដែលលើកទឹកចិត្តដល់អ្នកវិនិយោគ ដើម្បីបង្កើនប្រសិទ្ធភាពការងារក្នុងវិស័យវិនិយោគឯកជន ។

៦- រៀបចំចងក្រងឯកសារ និងលិខិតបទដ្ឋាននានា ដែលទាក់ទិនទៅនឹងកិច្ចការវិនិយោគឯកជនសម្រាប់ផ្សព្វផ្សាយនៅក្នុងប្រទេស និងក្រៅប្រទេស ។

៧- ធ្វើរបាយការណ៍ប្រចាំឆមាស និងប្រចាំឆ្នាំជូនរាជរដ្ឋាភិបាល ដើម្បីពិនិត្យ និងលើកឡើងនូវវិធានការចាំបាច់សម្រាប់កែលំអ និងតម្រង់ទិសការងារវិនិយោគឯកជន ។

**មាត្រា១៨ .-**

ទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្នុងការគ្រប់គ្រងកិច្ចការវិនិយោគឯកជន ដែលមានការពាក់ព័ន្ធទៅនឹងបណ្តាក្រសួង និងស្ថាប័ននានានៃរាជរដ្ឋាភិបាល ត្រូវកំណត់ដូចតទៅ÷

១- "ក.អ.ក" បំពេញតួនាទីជា "ច្រកចេញ-ចូលតែមួយ" របស់រាជរដ្ឋាភិបាល ក្នុងការត្រួតពិនិត្យ និងសម្រេចលើគម្រោងវិនិយោគឯកជននានា រាប់ទាំងសកម្មភាពរុករក-ស្រាវជ្រាវ-ការធ្វើអាជីវកម្មប្រេងកាត-ឧស្ម័ន និងធនធានធម្មជាតិផ្សេងៗ ទោះបីគម្រោងខ្លះ មិនត្រូវបានទទួលការលើកទឹកចិត្តក៏ដោយ ។

២- ក្រសួង និងស្ថាប័ននានា ដែលមានការពាក់ព័ន្ធចូលរួមផ្ដល់យោបល់ក្នុងការពិនិត្យ និងសម្រេចលើគម្រោងវិនិយោគឯកជននានា ក្នុងក្របខ័ណ្ឌនៃយន្តការ "ច្រកចេញ-ចូលតែមួយ"។

**មាត្រា១៩ .-**

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងក្រសួង-ស្ថាប័ននានា ដែលមានការពាក់ព័ន្ធ ធ្វើការងារ និងបំពេញកាតព្វកិច្ចរបស់ខ្លួនក្នុងការគ្រប់គ្រងការវិនិយោគឯកជនដោយសម្របសម្រួលការងារជាមួយគ្នាតាម រយៈយន្តការ "ច្រកចេញ-ចូលតែមួយ" ។

**មាត្រា២០ .-**

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា រួមជាមួយទីស្ដីការគណៈរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងផែនការ ក្រសួងពាណិជ្ជកម្ម និងក្រសួង ឬស្ថាប័ន ដែលមានការពាក់ព័ន្ធជាអ្នកតាមដានការអនុវត្តគម្រោងវិនិយោគឯកជនដែល "ក.អ.ក" បានផ្ដល់ការអនុញ្ញាតហើយ ដោយសម្របសម្រួលការងារជាមួយគ្នាតាមរយៈយន្តការ "ច្រកចេញ-ចូលតែមួយ" ។

**មាត្រា២១ .-**

ក្នុងកិច្ចការតំបន់សេដ្ឋកិច្ចពិសេស ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា មានភារកិច្ចដូចតទៅ÷

១- បំពេញតួនាទីជាយន្តការ "ច្រកចេញ-ចូលតែមួយ" និងជាសេនាធិការរបស់រាជរដ្ឋាភិបាលក្នុងការពិនិត្យនិងសម្រេចលើសំណើសុំបង្កើតតំបន់សេដ្ឋកិច្ចពិសេស ទាំងតាមរូបភាពរដ្ឋ ឯកជនចម្រុះរដ្ឋ និងឯកជននៅក្នុងព្រះរាជាណាចក្រកម្ពុជា។

២- ធ្វើការវិភាគ លើកផែនការយុទ្ធសាស្ត្រ ដើម្បីកំណត់ពីភូមិសាស្ត្រសំខាន់ៗ ដោយសហការជាមួយក្រសួង និងស្ថាប័នដែលមានការពាក់ព័ន្ធ ដើម្បីបង្កើតនូវតំបន់សេដ្ឋកិច្ចពិសេសនៅក្នុងប្រទេស និងលើកឡើងនូវទស្សនៈអនាគតអំពីកិច្ចការតំបន់សេដ្ឋកិច្ចពិសេសសម្រាប់ទាក់ទាញអ្នកអភិវឌ្ឍន៍តំបន់ និងអ្នកវិនិយោគក្នុងតំបន់ និងសម្រេចអោយបាននូវទស្សនៈនេះ ដោយធ្វើអោយប្រទេសកម្ពុជាក្លាយទៅជាតំបន់សាជីវកម្មទំនើបនាពេលអនាគត។

៣- ផ្សព្វផ្សាយអំពីគម្រោងនានាសម្រាប់ការវិនិយោគតំបន់សេដ្ឋកិច្ចពិសេស ដែលរាជរដ្ឋាភិបាលបានលើកឡើង និងផ្ដល់គម្រោងទាំងនោះទៅអោយអ្នកអភិវឌ្ឍន៍តំបន់តាមគ្រប់ប្រព័ន្ធឃោសនានានា ដែលមានប្រសិទ្ធភាព និងឆាប់រហ័ស។

៤- ផ្ដួចផ្ដើម និងសម្របសម្រួលការគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេសដែលជាអាទិភាពរបស់រាជរដ្ឋាភិបាល។

៥- លើកគម្រោង និងផ្ដល់យោបល់ជូនរាជរដ្ឋាភិបាលស្ដីពីការរៀបចំ និងការកែលំអច្បាប់ បទប្បញ្ញត្តិនានា និងដែលទាក់ទិននឹងការវិនិយោគតំបន់សេដ្ឋកិច្ចពិសេសក្នុងគោលបំណងបង្កើតល័ក្ខខ័ណ្ឌ ដែល

អនុគ្រោះ និងដែលលើកទឹកចិត្តដល់អ្នកអភិវឌ្ឍន៍តំបន់ ដើម្បីបង្កើនប្រសិទ្ធភាពការងារក្នុងវិស័យវិនិយោគ ។

៦- ចាត់តាំងការគ្រប់គ្រង ផ្តល់ការលើកទឹកចិត្ត និងការធានាលើការវិនិយោគ ការដោះស្រាយសំណូមពរនានា និង ការធ្វើអធិការកិច្ចចំពោះតំបន់សេដ្ឋកិច្ចពិសេស ។

៧- ចាត់បញ្ជូនមន្ត្រី ដើម្បីចូលរួមប្រចាំការអចិន្ត្រៃយ៍នៅតាមតំបន់តាមការចាំបាច់ និងតាមតម្រូវការ ។

៨- ធ្វើរបាយការណ៍បចាំឆមាស និងប្រចាំឆ្នាំជូនរាជរដ្ឋាភិបាល ដើម្បីពិនិត្យ និងលើកឡើងនូវវិធានការចាំបាច់សម្រាប់កែលំអបរិស្ថានវិនិយោគនៃតំបន់សេដ្ឋកិច្ចពិសេសនិងតម្រង់ទិសការងារវិនិយោគតំបន់ ។

**មាត្រា២២ .-**

ទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្នុងការគ្រប់គ្រងកិច្ចការតំបន់សេដ្ឋកិច្ចពិសេសដែលមានការពាក់ព័ន្ធទៅនឹងបណ្តាក្រសួង និងស្ថាប័ននានានៃរាជរដ្ឋាភិបាល ត្រូវកំណត់ដូចតទៅ÷

១- "ក.អ.ក " បំពេញតួនាទីជា "ច្រកចេញ-ចូលតែមួយ" របស់រាជរដ្ឋាភិបាល ក្នុងការត្រួតពិនិត្យ និងសម្រេចចុះបញ្ជីលើសំណើបង្កើតតំបន់សេដ្ឋកិច្ចពិសេស ។

២- ក្រសួង និងស្ថាប័ននានាដែលមានការពាក់ព័ន្ធចូលរួមផ្តល់យោបល់ក្នុងការពិនិត្យ និងសម្រេចលើគម្រោងបង្កើតតំបន់សេដ្ឋកិច្ចពិសេសក្នុងក្របខ័ណ្ឌនៃយន្តការ "ច្រកចេញ-ចូលតែមួយ" ។

៣- "ក.អ.ក" សហការជាមួយក្រសួង និងស្ថាប័នដែលមានការពាក់ព័ន្ធ ដើម្បីរៀបចំបង្កើតរដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេសប្រចាំតំបន់នីមួយៗ និងណែនាំការចេញលិខិតអនុញ្ញាតនានារបស់រដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេស ជូនដល់អ្នកវិនិយោគក្នុងតំបន់នៅនឹងកន្លែងនៃតំបន់នីមួយៗឱ្យបានឆាប់រហ័ស និងមានប្រសិទ្ធភាព ។

## ជំពូកទី ៣
## ការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

**មាត្រា២៣ .-**

ប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា មានតួនាទីដូចតទៅ:

១- ទទួលខុសត្រូវរួមលើការងាររបស់ "ក.អ.ក"

២- ធ្វើជាអធិបតីនៃអង្គប្រជុំរបស់គណៈកម្មាធិការប្រតិបត្តិនៃ "ក.អ.ក" និងនៃអង្គប្រជុំពេញអង្គរបស់ "ក.អ.ក" ។

៣- កោះប្រជុំវិសាមញ្ញរបស់គណៈកម្មាធិការប្រតិបត្តិនៃ "ក.អ.ក" និង ប្រជុំវិសាមញ្ញពេញអង្គរបស់ "ក.អ.ក" ។

៤- ទទួលខុសត្រូវក្នុងការគ្រប់គ្រងថវិការបស់ "ក.អ.ក" ។

**មាត្រា២៤ .-**

នាយករដ្ឋមន្ត្រីដឹកនាំផ្ទាល់លើការកំណត់គោលនយោបាយ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍តំបន់សេដ្ឋកិច្ច ពិសេស និងការអនុវត្ត និងតាមដានគោលនយោបាយ និងយុទ្ធសាស្ត្រនេះ ។

**មាត្រា២៥ .-**

អនុប្រធាននៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា មានតួនាទីដូចតទៅ:

**ក.** ឯកឧត្តម គាត ឈន់ អនុប្រធានទី១ ÷

១- ទទួលខុសត្រូវរួមលើការងាររបស់ "ក.អ.ក" ក្នុងករណីដែលប្រធាន "ក.អ.ក" អវត្តមាន ។

២- ទទួលខុសត្រូវក្នុងការដឹកនាំ និង គ្រប់គ្រងការងារប្រចាំថ្ងៃរបស់ "ក.អ.ក" ។

៣- ទទួលបន្ទុកលើក និងស្នើគោលនយោបាយយុទ្ធសាស្ត្រអភិវឌ្ឍន៍ជារួម ។

៤- ទទួលបន្ទុកការងារអភិវឌ្ឍន៍វិស័យឯកជន ។

៥- ទទួលបន្ទុកការងារភាពជាដៃគូក្នុងកិច្ចអភិវឌ្ឍន៍ជាមួយតួអង្គអភិវឌ្ឍន៍ដែលមានការពាក់ព័ន្ធ ។

៦-ទទួលបន្ទុកការងាររបស់គណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជា ដែលផ្តោតជាសំខាន់ទៅលើការសម្របសម្រួលលើកិច្ចការវិនិយោគសាធារណៈ និងកិច្ចការកៀរគរ និងសម្របសម្រួលហិរញ្ញប្បទានសហប្រតិបត្តិការ ។

៧-ដឹកនាំកិច្ចប្រជុំនៃយន្តការពិគ្រោះយោបល់ជាមួយដៃគូអភិវឌ្ឍន៍

៨- ទទួលបន្ទុកក្នុងការសម្របសម្រួលការងារអន្តរក្រសួងរវាង "ក.អ.ក" ជាមួយនឹងក្រសួង ស្ថាប័ននានានៃរាជរដ្ឋាភិបាល ។

៩- ទទួលសិទ្ធិពីនាយករដ្ឋមន្ត្រីក្នុងការពិនិត្យ និងសម្រេចលើការងាររបស់ "ច្រកចេញ-ចូលតែមួយ" នៃ "ក.អ.ក" លើកលែងតែការងារដែលមានវេទយិតភាពខ្ពស់ ។

១០- បំពេញការងារដទៃទៀត ដែលប្រធាន "ក.អ.ក" ប្រគល់សិទ្ធិ ។

**ខ.** ឯកឧត្តម ស៊ុន ចាន់ថុល អនុប្រធាន÷

១- ទទួលខុសត្រូវរួមលើការងាររបស់ "ក.អ.ក" ក្នុងករណីដែលប្រធាន និងអនុប្រធានទី១ នៃ "ក.អ.ក" អវត្តមាន ។

២- ទទួលបន្ទុកលើក និង ស្នើគោលនយោបាយ និង យុទ្ធសាស្ត្រពាណិជ្ជកម្ម ឧស្សាហកម្ម និង វិនិយោគឯកជន និងកិច្ចការដឹកនាំ អនុវត្តន៍ និងតាមដានការអនុវត្តគោលនយោបាយ និង យុទ្ធសាស្ត្រនេះ ។

៣- ទទួលបន្ទុកកិច្ចការវិនិយោគឯកជន និងការងាររបស់គណៈកម្មាធិការវិនិយោគកម្ពុជា ។

៤- ធ្វើជាអធិបតីនៃអង្គប្រជុំរបស់យន្តការ "ច្រកចេញ-ចូលតែមួយ" ដែលរៀបចំឡើងដោយ "គ.វ.ក" ដើម្បីពិនិត្យសម្រេចក្នុងយន្តការ "ច្រកចេញ-ចូលតែមួយ" លើការងារវិនិយោគឯកជន ។

៥- ទទួលបន្ទុកពិនិត្យ និងសម្រេចលើគម្រោងវិនិយោគឯកជនដែលមានលក្ខណៈសាមញ្ញ ដូចជា រោងចក្រកាត់ដេរ រោងចក្រស្បែកជើង និងឧស្សាហកម្មគាំទ្រជាដើម ព្រមទាំងបណ្ដាគម្រោងដែលមិនទាមទារការលើកទឹកចិត្តផងដែរ ។

៦- ទទួលបន្ទុកកិច្ចការវិនិយោគផ្សេងៗ នៅក្នុងក្របខ័ណ្ឌអាស៊ានដែលជាប្រការស្របគ្នាទៅនឹងការរៀបចំរបស់អាស៊ាន ។

៧- បំពេញការងារដទៃទៀត ដែលប្រធាន "ក.អ.ក" ប្រគល់សិទ្ធិ ។

**មាត្រា២៦ .-**

អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា មានតួនាទីដូចតទៅ ÷

១- គ្រប់គ្រងការងាររបស់អគ្គលេខាធិការដ្ឋាននៃ "ក.អ.ក" ។

២- ទទួលបន្ទុកសម្របសម្រួល និង តាមដានការងាររបស់គណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជា ការងាររបស់គណៈកម្មាធិការវិនិយោគកម្ពុជា និងការងាររបស់គណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា ។

៣- ធ្វើជាសេនាធិការបច្ចេកទេសអោយ "ក.អ.ក" ក្នុងការដឹកនាំ អនុវត្តន៍ និងតាមដានការអនុវត្តគោលនយោបាយ និងយុទ្ធសាស្ត្រពាណិជ្ជកម្ម ឧស្សាហកម្ម វិនិយោគឯកជន និងការអភិវឌ្ឍន៍តំបន់សេដ្ឋកិច្ចពិសេស ។

៤- រៀបចំកម្មវិធីការងាររបស់ "ក.អ.ក" និងរៀបចំរបៀបវារៈ និងសំណុំឯកសារផ្សេងៗ សម្រាប់អង្គប្រជុំរបស់គណៈកម្មាធិការប្រតិបត្តិនៃ "ក.អ.ក" និងអង្គប្រជុំពេញអង្គរបស់ "ក.អ.ក" ។

៥- សម្របសម្រួលការរៀបចំរបាយការណ៍ប្រចាំឆមាស និងប្រចាំឆ្នាំ អំពីការងារនីតិសម្បទា និងអភិវឌ្ឍន៍ ការងារវិនិយោគឯកជន និងការងារតំបន់សេដ្ឋកិច្ចពិសេស ដើម្បីដាក់ជូនគណៈកម្មាធិការប្រតិបត្តិនៃ "ក.អ.ក" ពិនិត្យ និងសម្រេច មុននឹងធ្វើជូនរាជរដ្ឋាភិបាល ។

៦- ចូលរួមក្នុងអង្គប្រជុំរបស់យន្តការ "ច្រកចេញ-ចូលតែមួយ" ដើម្បីពិនិត្យ និងសម្រេចលើកិច្ចការនីតិសម្បទា និងអភិវឌ្ឍន៍ ការវិនិយោគនានា និងការងារតំបន់សេដ្ឋកិច្ចពិសេស ។

៧- ទទួលបន្ទុកជាអគ្គលេខាធិការនៃ "វេទិការាជរដ្ឋាភិបាល និងផ្នែកឯកជន" ។

៨- បំពេញការងារដទៃទៀត ដែលប្រធាន "ក.អ.ក" ឬអនុប្រធាន "ក.អ.ក" ប្រគល់សិទ្ធិ ។

**មាត្រា២៧ .-**

អគ្គលេខាធិការគណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជា មានតួនាទីដូចតទៅ ÷

១- គ្រប់គ្រងការងាររបស់ "គ.ជ.នា" ។

២- រៀបចំរបៀបវារៈ និងឯកសារសម្រាប់អង្គប្រជុំនៃយន្តការ "ច្រកចេញ-ចូលតែមួយ" ដែលមានការទាក់ទងទៅនឹងកិច្ចការនីតិសម្បទា និងអភិវឌ្ឍន៍ និងចូលរួមក្នុងអង្គប្រជុំរបស់យន្តការនេះ ដើម្បីពិនិត្យ និងសម្រេចលើកិច្ចការនីតិសម្បទា និងអភិវឌ្ឍន៍ ។

៣- រៀបចំយុទ្ធសាស្ត្រសម្រាប់ពង្រឹងភាពជាដៃគូ និងសុខដុមភាវូបនីយកម្ម ហិរញ្ញប្បទានសហប្រតិបត្តិការ ដើម្បីធានាប្រសិទ្ធភាពនៃហិរញ្ញប្បទាននេះ ដោយឈរលើគោលការណ៍នៃភាពជាម្ចាស់ និងជាអ្នកដឹកនាំរបស់ព្រះរាជាណាចក្រកម្ពុជា ក្នុងការប្រើប្រាស់ហិរញ្ញប្បទានសហប្រតិបត្តិការ ។

៤- ទទួលបន្ទុកជាអគ្គលេខាធិការនៃ "វេទិកាសម្រាប់កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា" និងយន្តការពិគ្រោះយោបល់ដទៃទៀត ។

៥- ដឹកនាំកិច្ចពិគ្រោះយោបល់ទ្វេភាគីជាមួយដៃគូអភិវឌ្ឍន៍ ។

៦- ធ្វើការតាមដានលើការអនុវត្តកម្មវិធី និងគម្រោងវិនិយោគសាធារណៈផ្សេងៗ ដោយសហការជាមួយបណ្តាក្រសួង និងស្ថាប័នជំនាញដែលពាក់ព័ន្ធ ហើយធ្វើរបាយការណ៍បូកសរុប និងលើកយោបល់ជូនគណៈកម្មាធិការប្រតិបត្តិនៃ "ក.អ.ក" ដើម្បីពិនិត្យ និងចាត់វិធានការកែតម្រូវក្នុងករណីចាំបាច់ ។

៧- ជួយដល់អគ្គលេខាធិការ "ក.អ.ក" ក្នុងការរៀបចំសំណុំឯកសារចាំបាច់ ដែលមានការទាក់ទងទៅនឹងកិច្ចការនីតិសម្បទា និងអភិវឌ្ឍន៍ សម្រាប់អង្គប្រជុំរបស់គណៈកម្មាធិការប្រតិបត្តិនៃ "ក.អ.ក" និងសម្រាប់អង្គប្រជុំពេញអង្គរបស់ "ក.អ.ក" ។

៨- ជួយដល់អគ្គលេខាធិការ "ក.អ.ក" ក្នុងការរៀបចំរបាយការណ៍ប្រចាំឆមាស និងប្រចាំឆ្នាំលើផ្នែកការងារពាក់ព័ន្ធទៅនឹងកិច្ចការនីតិសម្បទា និងអភិវឌ្ឍន៍ ដើម្បីដាក់ជូនគណៈកម្មា-ធិការប្រតិបត្តិនៃ "ក.អ.ក" ពិនិត្យ និងសម្រេចមុននឹងធ្វើជូនរាជរដ្ឋាភិបាល ។

៩- បំពេញការងារដទៃទៀតដែលទាក់ទិនទៅនឹងកិច្ចការនីតិសម្បទា និងអភិវឌ្ឍន៍ ដែលប្រធាន ឬ អនុប្រធាន "ក.អ.ក" ប្រគល់សិទ្ធិ ។

**មាត្រា២៨ .-**

អគ្គលេខាធិការគណៈកម្មាធិការវិនិយោគកម្ពុជា មានតួនាទីដូចតទៅ ÷

១- គ្រប់គ្រងការងាររបស់ "គ.វ.ក" ។

២- រៀបចំរបៀបវារៈ និងឯកសារសម្រាប់អង្គប្រជុំយន្តការ "ច្រកចេញ-ចូលតែមួយ" ដែលមានការទាក់ទងទៅនឹងកិច្ចការវិនិយោគឯកជន និងចូលរួមក្នុងអង្គប្រជុំរបស់យន្តការនេះ ដើម្បីពិនិត្យ និងសម្រេចលើកិច្ចការវិនិយោគឯកជន ។

៣- ជួយដល់អគ្គលេខាធិការ "ក.អ.ក" ក្នុងការរៀបចំសំណុំឯកសារចាំបាច់ដែលមានការទាក់ទិនទៅនឹងកិច្ចការវិនិយោគឯកជន សម្រាប់អង្គប្រជុំរបស់គណៈកម្មាធិការប្រតិបត្តិនៃ "ក.អ.ក" និងសម្រាប់អង្គប្រជុំពេញអង្គរបស់ "ក.អ.ក" ។

៤- ធ្វើការតាមដានលើការអនុវត្តកម្មវិធី និងគម្រោងវិនិយោគឯកជនផ្សេងៗ ដោយសហការជាមួយបណ្តាក្រសួង និងស្ថាប័នជំនាញ ដែលមានការពាក់ព័ន្ធ ហើយធ្វើរបាយការណ៍បូកសរុប និងលើកយោបល់ជូនគណៈកម្មាធិការប្រតិបត្តិនៃ "ក.អ.ក" ដើម្បីពិនិត្យ និងចាត់វិធានការកែតម្រូវ ក្នុងករណីចាំបាច់ ។

៥- ជួយដល់អគ្គលេខាធិការ "ក.អ.ក" ក្នុងការរៀបចំរបាយការណ៍ប្រចាំឆមាស និងប្រចាំឆ្នាំលើផ្នែកការងារពាក់ព័ន្ធទៅនឹងកិច្ចការវិនិយោគឯកជន ដើម្បីដាក់ជូនគណៈកម្មាធិការប្រតិបត្តិ នៃ "ក.អ.ក" ពិនិត្យ និងសម្រេច មុននឹងផ្ញើជូនរាជរដ្ឋាភិបាល ។

៦- ទទួលការងារនៃតំបន់វិនិយោគអាស៊ាន (AIA) ដោយសម្របសម្រួលជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ ។

៧- បំពេញការងារដទៃទៀតដែលទាក់ទិនទៅនឹងកិច្ចការវិនិយោគឯកជន ដែលប្រធាន ឬអនុប្រធាន "ក.អ.ក" ប្រគល់សិទ្ធិ ។

**មាត្រា២៩ .-**

អគ្គលេខាធិការគណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា មានតួនាទីដូចតទៅ ÷

១- គ្រប់គ្រងការងាររបស់ "គ.ស.ព" ។

២- រៀបចំរបៀបវារៈ និងឯកសារសម្រាប់អង្គប្រជុំយន្តការ "ច្រកចេញ-ចូលតែមួយ" ដែលមានការទាក់ទងទៅនឹងកិច្ចការតំបន់សេដ្ឋកិច្ចពិសេស ។

៣- ធ្វើជាអធិបតីនៃអង្គប្រជុំរបស់យន្តការ "ច្រកចេញ-ចូលតែមួយ" ដែលរៀបចំឡើងដោយគណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា ដើម្បីពិនិត្យសម្រេចក្នុងយន្តការ "ច្រកចេញ-ចូលតែមួយ" ។

៤- ជួយដល់អគ្គលេខាធិការ "ក.អ.ក" ក្នុងការរៀបចំសំណុំឯកសារចាំបាច់ ដែលមានការទាក់ទិនទៅនឹងកិច្ចការតំបន់សេដ្ឋកិច្ចពិសេស សម្រាប់អង្គប្រជុំរបស់គណៈកម្មាធិការប្រតិបត្តិនៃ "ក.អ.ក" និងសម្រាប់អង្គប្រជុំពេញអង្គរបស់ "ក.អ.ក" ។

៥- ធ្វើការតាមដានលើការអនុវត្តកម្មវិធី និងការវិវឌ្ឍន៍នៃគម្រោងតំបន់សេដ្ឋកិច្ចពិសេសនានា ដោយសហការជាមួយបណ្ដាក្រសួង និងស្ថាប័នជំនាញ ដែលមានការពាក់ព័ន្ធ ហើយធ្វើរបាយការណ៍បូកសរុប និងលើកយោបល់ជូនគណៈកម្មាធិការប្រតិបត្តិនៃ "ក.អ.ក" ដើម្បីពិនិត្យ និងចាត់វិធានការកែតម្រូវក្នុងករណីចាំបាច់។

៦- ជួយដល់អគ្គលេខាធិការ "ក.អ.ក" ក្នុងការរៀបចំរបាយការណ៍ប្រចាំឆមាស និងប្រចាំឆ្នាំ លើផ្នែកការងារពាក់ព័ន្ធទៅនឹងកិច្ចការតំបន់សេដ្ឋកិច្ចពិសេស ដើម្បីដាក់ជូនគណៈកម្មាធិការប្រតិបត្តិនៃ "ក.អ.ក" ពិនិត្យ និងសម្រេច មុននឹងផ្ញើជូនរាជរដ្ឋាភិបាល។

៧-បំពេញការងារដទៃទៀតដែលទាក់ទិនទៅនឹងកិច្ចការតំបន់សេដ្ឋកិច្ចពិសេស ដែលប្រធាន "ក.អ.ក" ប្រគល់សិទ្ធិ ។

**មាត្រា៣០ .-**

សមាជិកនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា មានភារកិច្ចដូចតទៅ ៖

១- ចូលរួមក្នុងការកំណត់ទស្សនទាន និងគោលនយោបាយនៃកិច្ចការនីតិសម្បទា និងអភិវឌ្ឍន៍គម្រោងកិច្ចការវិនិយោគឯកជន និងគម្រោងតំបន់សេដ្ឋកិច្ចពិសេស ព្រមទាំងចូលរួមក្នុងការកំណត់លំដាប់អាទិភាពនៃកម្មវិធី គម្រោងវិនិយោគនានា និងគម្រោងបង្កើតតំបន់សេដ្ឋកិច្ចពិសេស ទាំងផ្នែកសាធារណៈ និងទាំងផ្នែកឯកជន។

២- ចូលរួមក្នុងការត្រួតពិនិត្យ ការអនុវត្តគោលនយោបាយកម្មវិធីគម្រោងវិនិយោគនានា និងគម្រោងតំបន់សេដ្ឋកិច្ចពិសេសដែលក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាបានអនុម័តទាំងខាងផ្នែកសាធារណៈ ទាំងខាងផ្នែកឯកជន និងទាំងខាងផ្នែកតំបន់សេដ្ឋកិច្ចពិសេស។

៣- ពិនិត្យ និងអនុម័តរបាយការណ៍ប្រចាំឆមាស និងប្រចាំឆ្នាំ អំពីកិច្ចការនីតិសម្បទា និងអភិវឌ្ឍន៍កិច្ចការវិនិយោគឯកជន កិច្ចការតំបន់សេដ្ឋកិច្ចពិសេស មុននឹងផ្ញើជូនរាជរដ្ឋាភិបាលពិនិត្យ និងសម្រេច។

**មាត្រា៣១ .-**

ក្នុងករណីចាំបាច់ប្រធាន "ក.អ.ក" អាចកោះប្រជុំវិសាមញ្ញរបស់គណៈកម្មាធិការប្រតិបត្តិនៃ "ក.អ.ក" ឬប្រជុំវិសាមញ្ញពេញអង្គរបស់ "ក.អ.ក"។

**មាត្រា៣២ .-**

ការប្រព្រឹត្តិទៅនៃអង្គប្រជុំរបស់គណៈកម្មាធិការប្រតិបត្តិនៃ "ក.អ.ក" និងអង្គប្រជុំពេញអង្គរបស់ "ក.អ.ក" ត្រូវកំណត់ក្នុងបទបញ្ជាផ្ទៃក្នុងនៃ "ក.អ.ក "។

មាត្រា៣៣ .-

ការអនុវត្តការងារនៃយន្តការ "ច្រកចេញ-ចូលតែមួយ" របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្នុងការពិនិត្យលើកិច្ចការនីតិសម្បទា និងអភិវឌ្ឍន៍ លើការវិនិយោគនានា និងកិច្ចការតំបន់សេដ្ឋកិច្ចពិសេស ត្រូវរៀបចំឡើងតាមរបៀបរបបជាគោលការណ៍ ដូចខាងក្រោម ÷

**ទី១**- សម្រាប់គណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជា ÷

ក- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ទីស្តីការគណៈរដ្ឋមន្ត្រី និងក្រសួងផែនការ ត្រូវចាត់មន្ត្រីរបស់ខ្លួន ថ្នាក់ប្រធាននាយកដ្ឋានមួយរូបអោយមកអមគណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជា។ មន្ត្រីរូបនោះត្រូវ ÷

- មានសមត្ថភាពការងារតាមមុខជំនាញរបស់ខ្លួន។
- ទទួលការប្រគល់សិទ្ធិពីប្រធានស្ថាប័នរបស់ខ្លួន ហើយស្ថិតរមូតក្នុងការទាក់ទងជាមួយប្រធានស្ថាប័នរបស់ខ្លួន ពិសេសធ្វើរបាយការណ៍ និងលើកមតិស្នើសុំយោបល់ពីប្រធានស្ថាប័នរបស់ខ្លួន។
- ស្ថិតរមូតក្នុងការងារក្នុងក្របខ័ណ្ឌគណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជា។
- ចេះភាសាបរទេសមួយ ឬពីរ ជាពិសេសភាសាអង់គ្លេស។

ខ- ក្រសួង និងស្ថាប័នដទៃទៀតនៃរាជរដ្ឋាភិបាល ក៏ត្រូវមានតំណាងចូលរួមក្នុងយន្តការ "ច្រកចេញ-ចូលតែមួយ" នេះដែរ តែត្រូវចូលរួមតាមលក្ខណៈ "អែដហុក" តាមការអញ្ជើញរបស់អគ្គលេខាធិការ "គ.ជ.នា" ចំពោះតែកិច្ចការវិនិយោគសាធារណៈណាដែលពាក់ព័ន្ធទៅនឹងសមត្ថកិច្ចនៃក្រសួង-ស្ថាប័នទាំងនោះ។

គ- អគ្គលេខាធិការ "គ.ជ.នា" មានភារកិច្ចផ្តល់សំណុំឯកសារសព្វគ្រប់ ដែលត្រូវរួមគ្នាពិនិត្យ និងឯកភាពក្នុងអង្គប្រជុំនៃយន្តការ "ច្រកចេញ-ចូលតែមួយ" ដល់តំណាងក្រសួង និងស្ថាប័នដែលមានការពាក់ព័ន្ធក្នុងរយៈពេលមួយសប្តាហ៍មុន ដើម្បីប្រធានស្ថាប័ន ដែលមានការពាក់ព័ន្ធអាចពិនិត្យ និងផ្តល់យោបល់ជាយថាហេតុតាមរយៈមន្ត្រីដែលជាតំណាងរបស់ខ្លួន។

ឃ- ក្រោយពីរៀបចំ និងប្រមូលផ្តុំនូវបណ្តាឯកសារចាំបាច់នានាបានចប់សព្វគ្រប់ តាមបែបបទជាធរមាន ហើយអគ្គលេខាធិការ "គ.ជ.នា " ត្រូវរៀបចំបញ្ចូលកម្មវិធី ឬ គម្រោងនោះទៅក្នុងអង្គប្រជុំនៃយន្តការ "ច្រកចេញ-ចូលតែមួយ " ដើម្បីពិនិត្យ និងសម្រេច។

ង- អគ្គលេខាធិការ "គ.ជ.នា" ត្រូវរៀបចំសំណុំឯកសារ និងពតិមានផ្សេងៗ ដែលជាលទ្ធផលនៃកិច្ចប្រជុំរបស់យន្តការ "ច្រកចេញ-ចូលតែមួយ" បញ្ជូនទៅអគ្គលេខាធិការ "ក.អ.ក" ដើម្បីរៀបចំដាក់ជូនអង្គប្រជុំគណៈកម្មាធិការប្រតិបត្តិនៃ "ក.អ.ក" ពិនិត្យ និងសម្រេច។

ទី២- សម្រាប់គណៈកម្មាធិការវិនិយោគកម្ពុជា ៖

ក- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងផែនការ ក្រសួងពាណិជ្ជកម្ម និងក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និងស្ថាប័នពាក់ព័ន្ធផ្សេងៗទៀត ត្រូវចាត់មន្ត្រីរបស់ខ្លួនថ្នាក់ប្រធាននាយកដ្ឋានមួយរូបឱ្យមកអមគណៈកម្មាធិការវិនិយោគកម្ពុជា ។

មន្ត្រីរូបនោះត្រូវ ៖

- មានសមត្ថភាពការងារតាមមុខជំនាញរបស់ខ្លួន ។
- ទទួលការប្រគល់សិទ្ធិពីប្រធានស្ថាប័នរបស់ខ្លួន ហើយស្ថិតរមូតក្នុងការទាក់ទងជាមួយប្រធានស្ថាប័នរបស់ខ្លួន ពិសេសធ្វើរបាយការណ៍និងលើកមតិស្នើសុំយោបល់ពីប្រធានស្ថាប័នរបស់ខ្លួន ។
- ស្ថិតរមូតក្នុងការងារ ក្នុងក្របខ័ណ្ឌគណៈកម្មាធិការវិនិយោគកម្ពុជា ។
- ចេះភាសាបរទេសមួយ ឬពីរ ជាពិសេសភាសាអង់គ្លេស ។

ខ- ក្រសួង និងស្ថាប័នដទៃទៀតនៃរាជរដ្ឋាភិបាល ក៏ត្រូវមានតំណាងចូលរួមក្នុងយន្តការ "ច្រកចេញ-ចូលតែមួយ" នេះដែរ តែត្រូវចូលរួមតាមលក្ខណៈ "អែដហុក" តាមការអញ្ជើញរបស់អគ្គលេខាធិការ "គ.វ.ក" ចំពោះតែកិច្ចការវិនិយោគឯកជនណា ដែលពាក់ព័ន្ធទៅនឹងសមត្ថកិច្ចនៃក្រសួង-ស្ថាប័នទាំងនោះ ។

គ- អគ្គលេខាធិការ "គ.វ.ក" មានភារកិច្ចផ្តល់សំណុំឯកសារសព្វគ្រប់ ដែលត្រូវរួមគ្នាពិនិត្យ និងសម្រេចក្នុងអង្គប្រជុំនៃយន្តការ "ច្រកចេញ-ចូលតែមួយ" ដល់តំណាងក្រសួង និងស្ថាប័នដែលមានការពាក់ព័ន្ធ ក្នុងរយៈពេលមួយសប្តាហ៍មុន ដើម្បីប្រធានស្ថាប័នដែលមានការពាក់ព័ន្ធអាចពិនិត្យ និងផ្តល់យោបល់ជាយថាហេតុ តាមរយៈមន្ត្រី ដែលជាតំណាងរបស់ខ្លួន ។

ឃ- ក្រោយពីរៀបចំ និងប្រមូលផ្តុំនូវបណ្តាឯកសារចាំបាច់នានាបានចប់សព្វគ្រប់ តាមបែបបទជាធរមាន ហើយអគ្គលេខាធិការ "គ.វ.ក." ត្រូវរៀបចំបញ្ចូលកម្មវិធី ឬគម្រោងនោះទៅក្នុងអង្គប្រជុំនៃយន្តការ "ច្រកចេញ-ចូលតែមួយ" ដើម្បីពិនិត្យ និងសម្រេច ។

ង- អគ្គលេខាធិការ "គ.វ.ក." ត្រូវរៀបចំសំណុំឯកសារ និងព័ត៌មានផ្សេងៗ ដែលជាលទ្ធផលនៃកិច្ចប្រជុំរបស់យន្តការ "ច្រកចេញ-ចូលតែមួយ" បញ្ជូនទៅអគ្គលេខាធិការ "ក.អ.ក" ដើម្បីរៀបចំដាក់ជូនអង្គប្រជុំគណៈកម្មាធិការប្រតិបត្តិនៃ "ក.អ.ក" ពិនិត្យ និងសម្រេច ។

ទី៣- សម្រាប់គណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា ៖

ក- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងផែនការ ក្រសួងពាណិជ្ជកម្ម និងក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងស្ថាប័នពាក់ព័ន្ធផ្សេងៗទៀតត្រូវចាត់មន្ត្រីរបស់ខ្លួនថ្នាក់ប្រធាននាយកដ្ឋានមួយរូបឱ្យមកអមគណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា ។ មន្ត្រីរូបនោះត្រូវ ៖

- មានសមត្ថភាពការងារតាមមុខជំនាញរបស់ខ្លួន ។

- ទទួលការប្រគល់សិទ្ធិពីប្រធានស្ថាប័នរបស់ខ្លួនហើយស្ថិតរមួតក្នុងការទាក់ទងជាមួយប្រធានស្ថាប័នរបស់ខ្លួន ពិសេសធ្វើរបាយការណ៍ និងលើកមតិស្នើសុំយោបល់ពីប្រធានស្ថាប័នរបស់ខ្លួន។
- ស្ថិតរមួតក្នុងការងារក្នុងក្របខ័ណ្ឌគណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា។
- ចេះភាសាបរទេសមួយ ឬពីរ ជាពិសេសភាសាអង់គ្លេស។

ខ- ក្រសួង និងស្ថាប័នដទៃទៀតនៃរាជរដ្ឋាភិបាល ក៏ត្រូវមានតំណាងចូលរួមក្នុងយន្តការ "ច្រកចេញ-ចូលតែមួយ" នេះដែរ តែត្រូវចូលរួមតាមលក្ខណៈ "អែដហុក" តាមការអញ្ជើញរបស់អគ្គលេខាធិការ "គ.ស.ព" ចំពោះតែកិច្ចការតំបន់សេដ្ឋកិច្ចពិសេសណា ដែលពាក់ព័ន្ធទៅនឹងសមត្ថកិច្ចនៃក្រសួង និងស្ថាប័នទាំងនោះ។

គ- អគ្គលេខាធិការ "គ.ស.ព" មានកាតព្វកិច្ចផ្តល់សំណុំឯកសារសព្វគ្រប់ ដែលត្រូវរួមគ្នាពិនិត្យ និងសម្រេចក្នុងអង្គប្រជុំនៃយន្តការ "ច្រកចេញ-ចូលតែមួយ" ដល់តំណាងក្រសួង និងស្ថាប័នដែលមានការពាក់ព័ន្ធ ក្នុងរយៈពេលមួយសប្តាហ៍មុន ដើម្បីប្រធានស្ថាប័នដែលមានការពាក់ព័ន្ធអាចពិនិត្យ និងផ្តល់យោបល់ជាយថាហេតុ តាមរយៈមន្ត្រី ដែលជាតំណាងរបស់ខ្លួន។

ឃ- ក្រោយពីរៀបចំ និងប្រមូលផ្តុំនូវបណ្តុំឯកសារចាំបាច់នានា បានចប់សព្វគ្រប់តាមបែបបទជាធរមាន ហើយអគ្គលេខាធិការ "គ.ស.ព" ត្រូវរៀបចំបញ្ចូលកម្មវិធី ឬគម្រោងនោះ ទៅក្នុងអង្គប្រជុំនៃយន្តការ "ច្រកចេញ-ចូលតែមួយ" ដើម្បីពិនិត្យ និងសម្រេច។

ង- អគ្គលេខាធិការ "គ.ស.ព" ត្រូវរៀបចំសំណុំឯកសារ និងព័ត៌មានផ្សេងៗ ដែលជាលទ្ធផលនៃកិច្ចប្រជុំរបស់យន្តការ "ច្រកចេញ-ចូលតែមួយ" បញ្ជូនទៅអគ្គលេខាធិការ "ក.អ.ក" ដើម្បីរៀបចំដាក់ជូនអង្គប្រជុំគណៈកម្មាធិការប្រតិបត្តិនៃ "ក.អ.ក" ពិនិត្យ និងសម្រេច។

**ទី៤**- ក្រោយពីទទួលបានគ្រប់គ្រាន់នូវឯកសារ និងព័ត៌មានផ្សេងៗពីអគ្គលេខាធិការ "គ.ជ.នា" អគ្គលេខាធិការ "គ.វ.ក" អគ្គលេខាធិការ "គ.ស.ព" មក អគ្គលេខាធិការ "ក.អ.ក" ត្រូវរៀបចំសំណុំឯកសារទាំងអស់នោះតាមលំដាប់ ហើយដាក់ចូលក្នុងរបៀបវារៈនៃអង្គប្រជុំរបស់គណៈកម្មាធិការប្រតិបត្តិនៃ "ក.អ.ក" ពិនិត្យ និងសម្រេច។

**មាត្រា៣៤ .-**

សេចក្តីលំអិតអំពីការរៀបចំ និងការប្រព្រឹត្តទៅនៃយន្តការ "ច្រកចេញ-ចូលតែមួយ" របស់ក្រុមប្រឹក្សា-អភិវឌ្ឍន៍កម្ពុជា ត្រូវកំណត់នៅក្នុងបទបញ្ជាផ្ទៃក្នុងនៃ "ក.អ.ក"។

**មាត្រា៣៥ .-**

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា មានក្របខ័ណ្ឌមន្ត្រីរាជការ និងមានខ្ទង់ចំណូល និងចំណាយថវិការបស់ខ្លួន។ ការគ្រប់គ្រងចំណូល និងចំណាយថវិកា នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាត្រូវស្ថិតនៅក្រោមច្បាប់ស្តីពីហិរញ្ញវត្ថុ។

## ជំពូកទី៤

## អវសានប្បញ្ញត្តិ

**មាត្រា៣៦ .-**

អនុក្រឹត្យនេះ ជំនួសអនុក្រឹត្យលេខ ១៤៩ អនក្រ.បក ចុះថ្ងៃទី ០៣ ខែ តុលា ឆ្នាំ ២០០៨។

**មាត្រា៣៧ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងផែនការ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័ន អភិបាលរាជធានី និងអភិបាលនៃគណៈអភិបាលគ្រប់ខេត្ត ពាក់ព័ន្ធទាំងអស់ និងសមាសភាពនានាដូចមាន ក្នុងមាត្រា ១ ត្រូវទទួលអនុវត្តន៍អនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១៣

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

*កន្លែងទទួល:*

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣៧
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**បានយកសេចក្តីគោរពជម្រាបជូន**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**នាយករដ្ឋមន្ត្រី សូមចុះហត្ថលេខា**

**គាត ឈន់**

**ឧបនាយករដ្ឋមន្ត្រី ប្រចាំការ**

**អនុប្រធានទី ១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា**

# អនុក្រឹត្យ

# ស្តីពីការអនុវត្តច្បាប់

# ស្តីពីវិសោធនកម្ម

# នៃច្បាប់ស្តីពី

# វិនិយោគ

# ២០០៥

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ១១១ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការអនុវត្តច្បាប់ស្តីពីវិសោធនកម្ម នៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា

*****

## រាជរដ្ឋាភិបាល

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៣/នស/៩៤ ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា និង ព្រះរាជក្រមលេខ នស/រកម/០៣០៣/០០៩ ចុះថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ និងព្រះរាជក្រមលេខ នស/រកម/០៣០៣/០១០ ចុះថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីសារពើពន្ធ
- បានឃើញអនុក្រឹត្យលេខ ៨៨ អនក្រ/បក ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីការអនុវត្តច្បាប់វិនិយោគនៃព្រះរាជាណាចក្រកម្ពុជា និង អនុក្រឹត្យវិសោធនកម្ម លេខ ៥៣ អនក្រ.បក ចុះថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ១៩៩៩ ស្តីពីការធ្វើវិសោធនកម្មលើអនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា និងលេខ១៣០ អនក្រ.បក ចុះថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ២០០១ ស្តីពីការធ្វើវិសោធនកម្ម លើអនុក្រឹត្យលេខ ៥៣ អនក្រ.បក ចុះថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ១៩៩៩

- បានឃើញអនុក្រឹត្យលេខ៧០អនក្រ/បកចុះថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និង អនុក្រឹត្យវិសោធនកម្មលេខ ១១២ អនក្រ. បក ចុះថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០០២ និងលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី ០៤ ខែ សីហា ឆ្នាំ ២០០៤ ស្តីពីការធ្វើវិសោធនកម្ម លើអនុក្រឹត្យលេខ ៧០ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០១
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ២០០៥

# សម្រេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

### មាត្រា ១: វិសាលភាពនៃអនុក្រឹត្យ

១.១ គោលដៅ: អនុក្រឹត្យនេះ បំពេញបន្ថែម និង ចាត់ចែង គ្រប់គ្រងការអនុវត្តច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា និង មានគោលដៅ ជំរុញការលើកទឹកចិត្ត និង ធ្វើនិយ័តកម្មលើការវិនិយោគទាំងឡាយរបស់នីតិបុគ្គលសញ្ជាតិខ្មែរ និង នីតិបុគ្គលសញ្ជាតិបរទេស នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

១.២ ការអនុវត្ត: អនុក្រឹត្យនេះ អនុវត្តទៅលើរាល់គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ "គ.ល.គ" ទាំងអស់ ដែលបានចុះបញ្ជីនៅក្រុមប្រឹក្សា និងនៅអនុគណៈកម្មាធិការវិនិយោគខេត្ត ក្រុង ។

### មាត្រា ២: វិស័យសម្រាប់វិនិយោគ

សកម្មភាពវិនិយោគ: អនុក្រឹត្យនេះអនុវត្តលើគ្រប់សកម្មភាពវិនិយោគ លើកលែងតែសកម្មភាពនោះបានកំណត់នៅក្នុងបញ្ជីអវិជ្ជមានដែលមានក្នុងឧបសម្ព័ន្ធទី១ ផ្នែកទី១ នៃអនុក្រឹត្យនេះ ដូចដែលមានចែងក្នុងមាត្រា ៧ ថ្មី នៃច្បាប់ស្តីពីវិនិយោគ ។

### មាត្រា ៣: ការវិនិយោគរបស់បុគ្គលសញ្ជាតិបរទេស និង បុគ្គលសញ្ជាតិខ្មែរ

៣.១ ការវិនិយោគរបស់បុគ្គលសញ្ជាតិបរទេស និង បុគ្គលសញ្ជាតិខ្មែរ: រាជរដ្ឋាភិបាលស្វាគមន៍ចំពោះការវិនិយោគពីសំណាក់បុគ្គលសញ្ជាតិបរទេស និងបុគ្គលសញ្ជាតិខ្មែរលើគ្រប់វិស័យសេដ្ឋកិច្ចទាំងអស់ លើកលែងតែសកម្មភាពដែលស្ថិតនៅក្រោមការដាក់កំហិតដូចមានចែងនៅក្នុងមាត្រា ២ នៃអនុក្រឹត្យនេះ។

៣.២ ការប្រើប្រាស់អ្នកតំណាង: គ្មានបុគ្គលសញ្ជាតិខ្មែរណា អាចធ្វើសកម្មភាព ឬ ធ្វើតំណាងដោយផ្ទាល់ ឬ ដោយប្រយោលឱ្យបុគ្គលសញ្ជាតិបរទេស ក្នុងគោលបំណងដើម្បីពង្វាងនូវការអនុវត្តបទប្បញ្ញត្តិណាមួយនៃអនុក្រឹត្យនេះ ដែលដាក់កំហិត ឬ ហាមឃាត់ ចំពោះសកម្មភាពរបស់បុគ្គលសញ្ជាតិបរទេសនោះបានឡើយ ។

**មាត្រា ៤: និយមន័យ**

ក្នុងន័យនៃអនុក្រឹត្យនេះ វាក្យស័ព្ទ:

ក្រុមប្រឹក្សា: សំដៅដល់ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដែលបានបង្កើតឡើងតាមមាត្រា ៧ នៃ ច្បាប់ស្តីពីវិនិយោគ ។

ការធានាលើការវិនិយោគ: សំដៅដល់ ការធានាដែលបានកំណត់នៅក្នុងជំពូក ៤ នៃច្បាប់ស្តីពីវិនិយោគ ហើយដែលមានចែងក្នុងអនុក្រឹត្យនេះ សម្រាប់ផ្តល់ជូនដល់អ្នកវិនិយោគណា ដែលបំពេញតាមលក្ខខណ្ឌទាំងឡាយនៃអនុក្រឹត្យនេះ ។

ការលើកទឹកចិត្តវិនិយោគ: សំដៅដល់ ការលើកទឹកចិត្តដែលមានកំណត់នៅក្នុងជំពូកទី៥ នៃច្បាប់ស្តីពីវិនិយោគហើយដែលមានចែងក្នុងអនុក្រឹត្យនេះ សម្រាប់ផ្តល់ជូនអ្នកវិនិយោគណា ដែលបំពេញតាមលក្ខខណ្ឌទាំងឡាយ នៃអនុក្រឹត្យនេះ ។

គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ : សំដៅដល់ គម្រោងវិនិយោគដែលទទួលបានវិញ្ញាបនប័ត្រចុះបញ្ជីជាស្ថាពរ ។

គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ មានទិសដៅបម្រើតម្រូវការក្នុងស្រុក: សំដៅដល់គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដែលមិនបម្រើឱ្យការនាំចេញ ។

គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់បម្រើឱ្យការនាំចេញ: សំដៅដល់ គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដែលបានលក់ ឬបានផ្ទេរសមាមាត្រណាមួយនៃផលិតផលរបស់ខ្លួន ទៅឱ្យអ្នកទិញ ឬអ្នកទទួលនៅក្រៅព្រះរាជាណាចក្រកម្ពុជា ។

គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដែលជាប្រភេទឧស្សាហកម្មគាំទ្រ: សំដៅដល់ គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដែលផលិតផលរបស់ខ្លួន ១០០ (មួយរយ) ភាគរយ ត្រូវផ្គត់ផ្គង់ដល់ឧស្សាហកម្មនាំចេញ ជំនួសវត្ថុធាតុដើម ឬ សម្ភារៈបន្ទាប់បន្សំដែលតែងតែនាំចូល ។

ច្បាប់ស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុ: សំដៅដល់ ច្បាប់ស្តីពីហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ ។

ច្បាប់ស្តីពីវិនិយោគ: សំដៅដល់ ច្បាប់ស្តីពីវិនិយោគដែលបានប្រកាសឱ្យប្រើដោយព្រះរាជក្រម លេខ ០៣/នស៩៤ ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៤ និង ដែលបានធ្វើវិសោធនកម្មដោយច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ដែលបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៣០៣/០០៩ ចុះថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០០៣ ។

ច្បាប់ស្តីពីសារពើពន្ធ: សំដៅដល់ ច្បាប់ដែលបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ១៩៩៧ និង ដែលបានធ្វើវិសោធនកម្មដោយច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីសារពើពន្ធ ដែលបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៣០៣/០១០ ចុះថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០០៣ ។

ថ្ងៃធ្វើការ: សំដៅដល់ ថ្ងៃប្រតិទិន ដែលជាថ្ងៃធ្វើការជាផ្លូវការរបស់រាជរដ្ឋាភិបាលកម្ពុជា ។

ទុនវិនិយោគ: សំដៅដល់ តម្លៃវិនិយោគដែលបង្ហាញជា រូបិយប័ណ្ណ ដុល្លារអាមេរិក ដោយមិនរាប់បញ្ចូល តម្លៃដីធ្លី និង ទុនបង្វិលទេ ។

ធាតុចូលផលិតកម្ម: សំដៅដល់ ទំនិញ **រួម**បញ្ចូលទាំងវត្ថុធាតុដើម ផលិតផលពាក់កណ្ដាលសម្រេច និង សម្ភារៈបន្ទាប់បន្សំបម្រើផលិតកម្មដែលត្រូវបានបំប្លែង ឬ ត្រូវបានប្រើប្រាស់យ៉ាងពេញលេញនៅក្នុងកិច្ចដំណើរការផលិតកម្មរបស់គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់មិនអោយហួសពីរយៈពេល ២(ពីរ)ឆ្នាំ បន្ទាប់ពីបាននាំចូល។

និយមន័យនេះ មិនគិតបញ្ចូលផងទេ នូវសម្ភារៈ និង គ្រឿងសង្ហារឹមសម្រាប់ប្រើប្រាស់ក្នុងការិយាល័យ ផលិតផលតេលសិលា យានយន្ត និង គ្រឿងបន្លាស់យានយន្ត។

ធាតុចេញផលិតកម្ម: សំដៅដល់ ទំនិញ ដែលបានផលិតចេញពីធាតុចូលផលិតកម្ម ដែលត្រូវបានបំប្លែង។

នីតិបុគ្គលសញ្ជាតិខ្មែរ: សំដៅដល់ ក្រុមហ៊ុនដែលមានទីកន្លែងធ្វើអាជីវកម្ម និង ដែលបានធ្វើការចុះបញ្ជីនៅក្នុងព្រះរាជាណាចក្រកម្ពុជា និងភាគហ៊ុន ៥១ (ហាសិបមួយ) ភាគរយ ឬ លើសក្នុងក្រុមហ៊ុន ត្រូវបានកាន់កាប់ដោយបុគ្គលមានសញ្ជាតិជាខ្មែរ។

នីតិបុគ្គលសញ្ជាតិបរទេស: សំដៅដល់ នីតិបុគ្គលដែលមិនមែនសញ្ជាតិខ្មែរ ឬ ដែលមិនបានបង្កើតឡើងតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។

បុគ្គល: សំដៅដល់ រូបវន្តបុគ្គល ឬនីតិបុគ្គល ។

បញ្ជីអវិជ្ជមាន: សំដៅដល់ បញ្ជីគម្រោងវិនិយោគ ដែលកំណត់នៅក្នុងឧបសម្ព័ន្ធទី ១ នៃអនុក្រឹត្យនេះ និង ដែលតាមមាត្រា ៧ ថ្មី នៃច្បាប់ស្ដីពីវិនិយោគ ជាបញ្ជីនៃសកម្មភាពវិនិយោគ ដែលមិនអាចចាត់ទុកថាជាគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់។

បំណែកនៃម៉ាស៊ីន: សំដៅដល់ បំណែកនៃសម្ភារៈបរិក្ខារផលិតកម្ម ដែលមានរយៈពេលប្រើប្រាស់តិចជាង ២ (ពីរ)ឆ្នាំ ដោយរួមបញ្ចូលទាំងគ្រឿងបន្លាស់នៃបំណែកសម្ភារៈទាំងនោះផង។

ពន្ធគយ: សំដៅដល់ពន្ធលើពាណិជ្ជកម្មក្រៅប្រទេស ដែលបានដាក់ឱ្យប្រើប្រាស់នៅក្នុងតារាងពន្ធគយ ចំពោះទំនិញដែលត្រូវបង់នាពេលនាំចូលដែនគយ ឬ នាំចេញពីដែនគយ។

វិញ្ញាបនប័ត្រចុះបញ្ជីមានលក្ខខណ្ឌ: សំដៅដល់ ឯកសារដែលចេញដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ឬអនុគណៈកម្មាធិការវិនិយោគខេត្ត ក្រុង ដូចមានចែងក្នុងកថាខណ្ឌ ៣ មាត្រា ៧ថ្មី នៃច្បាប់ស្ដីពីវិនិយោគ និងមាត្រា ៦ ចំណុច ៦.៣ នៃអនុក្រឹត្យនេះ។

វិញ្ញាបនប័ត្រចុះបញ្ជីជាស្ថាពរ: សំដៅដល់ ឯកសារដែលចេញដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ឬអនុគណៈកម្មាធិការវិនិយោគខេត្ត ក្រុង ដូចមានចែងក្នុងកថាខណ្ឌ ៧ មាត្រា៧ថ្មី នៃច្បាប់ស្ដីពីវិនិយោគ និងមាត្រា ៧ ចំណុច ៧.៣ នៃអនុក្រឹត្យនេះ។

វិញ្ញាបនប័ត្របញ្ជាក់ពីការបំពេញបាននូវកាតព្វកិច្ចចំពោះរដ្ឋ: សំដៅដល់ វិញ្ញាបនប័ត្របញ្ជាក់ពីការបំពេញបាននូវកាតព្វកិច្ចដែលតម្រូវឱ្យបំពេញតាមមាត្រា ១៤ ថ្មី ចំណុច ២ ឬ មាត្រា ២៤ ថ្មី នៃច្បាប់ស្ដីពីវិនិយោគ ហើយចេញជូន តាមមាត្រា ១៨ ចំណុច ១៨.២ នៃអនុក្រឹត្យនេះ។

សំណើវិនិយោគ: សំដៅដល់ សំណើដែលបានដាក់ជូនក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ឬអនុគណៈកម្មាធិការវិនិយោគខេត្ត ក្រុង ដោយបុគ្គលណាមួយ ក្នុងគោលបំណង បង្កើតគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់។

សម្ភារៈសាងសង់: សំដៅដល់ សម្ភារៈសំណង់ រួមទាំងឧបករណ៍ បរិក្ខារ បំពាក់ឱ្យសំណង់ ដែលបានបំប្លែង ឬ បានប្រើប្រាស់ទាំងស្រុង នៅក្នុងការសាងសង់សំណង់នានា សម្រាប់គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ប្រើប្រាស់ ដើម្បីដំណើរការសកម្មភាពវិនិយោគរបស់ខ្លួន នៅក្នុងដំណាក់កាលសាងសង់ដំបូង ឬ ពង្រីក។

សកម្មភាពវិនិយោគ: សំដៅដល់ សកម្មភាពអាជីវកម្មដែលដំណើរការនៅក្នុងប្រទេសកម្ពុជា ក្រោមរូបភាពជាគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់។

សម្ភារៈបរិក្ខារផលិតកម្ម: សំដៅដល់ គ្រឿងម៉ាស៊ីន ឧបករណ៍ ដែលបានប្រើប្រាស់ជាមូលដ្ឋានសំខាន់ក្នុងការបំប្លែងធាតុចូលផលិតកម្ម ហើយដែលវត្ថុទាំងនោះ មិនអាចបំប្លែងដោយខ្លួនឯង ឬ មិនត្រូវបានប្រើប្រាស់អស់ក្នុងរយៈពេល ២ (ពីរ)ឆ្នាំបន្ទាប់ពីបាននាំចូល ។ គ្រឿងម៉ាស៊ីន និង ឧបករណ៍ទាំងនោះ មិនត្រូវគិតបញ្ចូលផងទេនូវឧបករណ៍ផ្នែកព័ត៌មានវិទ្យា ឬ យានយន្ត ដែលប្រើប្រាស់សម្រាប់គោលបំណងផ្សេង ក្រៅពីកិច្ចដំណើរការផលិតកម្មរបស់គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់។

សេវាកម្មវិជ្ជាជីវៈ: សំដៅដល់ សេវាទាំងឡាយ ដែលមានជាអាទិ៍ សេវាកម្មច្បាប់ ហិរញ្ញវត្ថុ គណនេយ្យ សវនកម្ម ទីប្រឹក្សាសារពើពន្ធ ស្ថាបត្យកម្ម វិស្វកម្ម សេវាកម្មបច្ចេកវិទ្យាព័ត៌មាន ផ្សព្វផ្សាយពាណិជ្ជកម្ម សេវាកម្មគ្រប់គ្រង។

អនុគណៈកម្មាធិការវិនិយោគខេត្ត ក្រុង: សំដៅដល់ អនុគណៈកម្មាធិការវិនិយោគរបស់ខេត្ត ក្រុង ដែលបានបង្កើតឡើងដោយអនុក្រឹត្យ ដើម្បីពិនិត្យសម្រេចចុះបញ្ជីវិនិយោគតាមខេត្ត ក្រុង ដែលមានទុនវិនិយោគចាប់ពី ២.០០០.០០០ (ពីរលាន) ដុល្លារអាមេរិក ចុះក្រោម។

អ្នកដាក់ពាក្យសុំ: សំដៅដល់ បុគ្គល ឬ ក្រុមបុគ្គលដែលដាក់សំណើវិនិយោគនៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ឬ អនុគណៈកម្មាធិការវិនិយោគខេត្ត ក្រុង។

អ្នកវិនិយោគ: សំដៅដល់ បុគ្គលដែលអនុវត្តគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ។

អ្នកវិនិយោគសញ្ជាតិខ្មែរ: សំដៅដល់ អ្នកវិនិយោគសញ្ជាតិខ្មែរ ឬ នីតិបុគ្គលសញ្ជាតិខ្មែរ។

អនុក្រឹត្យរបស់ក្រុមប្រឹក្សា: សំដៅដល់ អនុក្រឹត្យលេខ ៧០ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០១ ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និង អនុក្រឹត្យវិសោធនកម្ម លេខ ១១២ អនក្រ.បក ចុះថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០០២ និង លេខ ៣៥ អនក្រ.បក ចុះថ្ងៃទី ០៤ ខែ សីហា ឆ្នាំ ២០០៤ ស្ដីពីការធ្វើវិសោធនកម្មលើអនុក្រឹត្យលេខ ៧០ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០១។

## ជំពូកទី ២

## សំណើវិនិយោគ និង វិញ្ញាបនបត្រចុះបញ្ជីវិនិយោគ

### មាត្រា ៥: ការស្នើសុំវិញ្ញាបនបត្រចុះបញ្ជីមានលក្ខខណ្ឌ

៥.១ ពាក្យសុំ និង ថ្ងៃចុះបញ្ជី: បុគ្គលណាមួយដែលមានបំណងស្នើសុំការលើកទឹកចិត្ត និង ការធានាលើការវិនិយោគ ឬ តែការធានាលើការវិនិយោគ ត្រូវដាក់ជូនក្រុមប្រឹក្សា ឬ អនុគណៈកម្មាធិការវិនិយោគខេត្ត ក្រុង

នូវសំណើវិនិយោគ តាមទម្រង់បែបបទនៃការដាក់ពាក្យសុំ ដែលបានបំពេញសព្វគ្រប់ ហើយចុះហត្ថលេខាត្រឹមត្រូវដោយម្ចាស់គម្រោងដែលមានសិទ្ធិ ឬអ្នកតំណាងឱ្យអ្នកដាក់ពាក្យសុំដែលមានការប្រគល់សិទ្ធិត្រឹមត្រូវ និងត្រូវបង់ថ្លៃចុះបញ្ជី ចំនួន ៧.០០០.០០០ (ប្រាំពីរលាន) រៀល នៅក្រុមប្រឹក្សា ឬនៅអនុគណៈកម្មាធិការវិនិយោគខេត្ត ក្រុង ដែលជាថ្ងៃសេវារដ្ឋបាលដើម្បីទទួលបាននូវ រាល់ការយល់ព្រម ការអនុញ្ញាត អាជ្ញាប័ណ្ណ ឬ បញ្ជីការនានាពីគ្រប់ក្រសួង ស្ថាប័ន មន្ទីរមានសមត្ថកិច្ចពាក់ព័ន្ធទាំងអស់រួមទាំងពន្ធប្រថាប់ត្រាផងដែរ។

៥.២ ទម្រង់បែបបទនៃពាក្យសុំ: ទម្រង់បែបបទសម្រាប់សំណើវិនិយោគ មានកំណត់នៅក្នុងឧបសម្ព័ន្ធទី ២ នៃអនុក្រឹត្យនេះ។

៥.៣ ភស្តុតាងស្តីពីសិទ្ធិអំណាចក្នុងការចុះហត្ថលេខា: ប្រសិនបើសំណើវិនិយោគនោះ ចុះហត្ថលេខាដោយតំណាងរបស់អ្នកដាក់ពាក្យសុំ ឯកសារភស្តុតាងស្តីពីការទទួលសិទ្ធិអោយចុះហត្ថលេខានេះ ត្រូវដាក់ជូនទៅក្រុមប្រឹក្សា ឬអនុគណៈកម្មាធិការវិនិយោគខេត្ត ក្រុង ដោយភ្ជាប់ជាមួយនឹងសំណើវិនិយោគ។

៥.៤ គម្រោងពហុសកម្មភាព: ប្រសិនបើបុគ្គលមានបំណងធ្វើការវិនិយោគ និង ដំណើរការលើសពីសកម្មភាពវិនិយោគមួយឡើងទៅ ហើយប្រសិនបើគម្រោងត្រូវបានចុះបញ្ជី ដើម្បីដំណើរការជាគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ បុគ្គលនោះត្រូវដាក់សំណើវិនិយោគដាច់ដោយឡែកពីគ្នាសម្រាប់សកម្មភាពវិនិយោគនីមួយៗ។

៥.៥ ការជ្រើសរើសការលើកលែងពន្ធលើប្រាក់ចំណេញ: អ្នកដាក់ពាក្យសុំ ដែលចង់ទទួលបានការលើកលែងពន្ធលើប្រាក់ចំណេញតាមមាត្រា ១៤ ចំណុច ១៤.១ នៃច្បាប់ស្តីពីវិនិយោគ ដោយអនុលោមទៅតាមមាត្រា ១៥ នៃអនុក្រឹត្យនេះនៅពេលទទួលវិញ្ញាបនប័ត្រចុះបញ្ជីជាស្ថាពរ ត្រូវធ្វើការជ្រើសរើសជាលាយលក្ខណ៍អក្សរនូវការលើកទឹកចិត្តដែលខ្លួនចង់បាននៅក្នុងសំណើវិនិយោគ។

៥.៦ ការជ្រើសរើសដោយបដិសេធនូវរំលោះពិសេសផ្នែកសារពើពន្ធផ្សេងៗ: ក្នុងការជ្រើសរើសតាមកថាខ័ណ្ឌ ៥.៥ អ្នកដាក់ពាក្យសុំទទួលស្គាល់ថា ការជ្រើសរើសដើម្បីប្រើប្រាស់រយៈពេលលើកលែងពន្ធលើប្រាក់ចំណេញ ដែលមានចែងនៅក្នុងមាត្រា ១៤ ចំណុច ១៤.១ នៃច្បាប់ស្តីពីវិនិយោគ នឹងធ្វើឱ្យអ្នកវិនិយោគគ្មានសិទ្ធិក្នុងការទាមទាររំលោះពិសេសផ្នែកវិនិយោគ ដែលអនុវត្តសម្រាប់អ្នកវិនិយោគតាមច្បាប់ស្តីពីសារពើពន្ធទាក់ទងទៅនឹងគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់នោះឡើយ។

៥.៧ ការជ្រើសរើសយកតែការធានាលើការវិនិយោគ: អ្នកដាក់ពាក្យសុំ ដែលមានបំណងចង់ទទួលបាននូវផលប្រយោជន៍តែការធានាលើការវិនិយោគ អាចធ្វើការជ្រើសរើសជាលាយលក្ខណ៍អក្សរនៅក្នុងទម្រង់បែបបទនៃពាក្យស្នើសុំ ដោយអ្នកដាក់ពាក្យសុំនោះមិនមែនជាគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ទេ តែស្ថិតនៅក្រោមការធានាលើការវិនិយោគនៃច្បាប់ស្តីពីវិនិយោគ។ ក្រុមប្រឹក្សា ឬ អនុគណៈកម្មាធិការវិនិយោគខេត្ត ក្រុង ត្រូវចេញនូវអាជ្ញាប័ណ្ណមួយដោយឡែក ដើម្បីបញ្ជាក់ជូនអ្នកដាក់ពាក្យសុំសម្រាប់ករណីនេះ។

## មាត្រា ៦: ការចុះបញ្ជី ឬ ការបដិសេធពាក្យសុំ

៦.១ កិច្ចដំណើរការចុះបញ្ជីពាក្យសុំ: ក្នុងរយៈពេល ៣ (បី) ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីទទួលបាននូវសំណើវិនិយោគ

តាមមាត្រា ៥ ចំណុច ៥.១ ក្រុមប្រឹក្សា ឬ អនុគណៈកម្មាធិការវិនិយោគ ខេត្ត ក្រុងត្រូវ ÷

(ក) ចុះបញ្ជីសំណើវិនិយោគ និង ជូនដំណឹងទៅអ្នកដាក់ពាក្យសុំ អនុលោមទៅតាមកថាខ័ណ្ឌ ៦.៣ ប្រសិនបើមិនស្ថិតក្នុងកថាខ័ណ្ឌ (ខ) ឬ (គ) ទេ ឬ

(ខ) បដិសេធសំណើវិនិយោគនោះ ហើយជូនដំណឹងទៅអ្នកដាក់ពាក្យសុំវិញ អនុលោមទៅតាមកថាខ័ណ្ឌ ៦.៦ ប្រសិនបើសំណើវិនិយោគ ដែលលើកឡើងនោះ ពាក់ព័ន្ធទៅនឹងសកម្មភាពវិនិយោគ

(១) ដែលមាននៅក្នុងបញ្ជីអវិជ្ជមាន ឬ

(២) ដែលពីមុនបាន ឬ បច្ចុប្បន្នកំពុងដំណើរការដោយអ្នកវិនិយោគ ឬបុគ្គលផ្សេង ហើយដែលបានទទួលរួចហើយនូវការលើកទឹកចិត្តតាមច្បាប់ស្តីពីវិនិយោគ

(គ) បដិសេធសំណើវិនិយោគ ហើយជូនដំណឹងទៅអ្នកដាក់ពាក្យសុំវិញ ដោយអនុលោមទៅតាមកថាខ័ណ្ឌ ៦.៦ ប្រសិនបើសំណើវិនិយោគ មិនបានផ្តល់ជូននូវព័ត៌មានគ្រប់គ្រាន់ ដែលតម្រូវដោយកថាខ័ណ្ឌ ៥.១ ទេនោះ ។

(ឃ) ក្រុមប្រឹក្សា ឬ អនុគណៈកម្មាធិការវិនិយោគខេត្ត ក្រុង មានសិទ្ធិក្នុងការពន្យាពេលចុះបញ្ជីសំណើវិនិយោគទាំងឡាយដែលមានលក្ខណៈពិសេស ពាក់ព័ន្ធដល់ផលប្រយោជន៍ជាតិ និងផលប៉ះពាល់ដល់បរិស្ថាន ដែលតម្រូវដាក់គម្រោងឆ្លងយន្តការច្រកចេញចូលតែមួយនៃក្រុមប្រឹក្សា ឬ អនុគណៈកម្មាធិការវិនិយោគខេត្ត ក្រុង ដោយត្រូវផ្តល់នូវហេតុផលច្បាស់លាស់ដល់អ្នកដាក់ពាក្យសុំឱ្យបានដឹង ក្នុងរយៈពេល ០៣ (បី) ថ្ងៃ នៃថ្ងៃធ្វើការ ក្រោយថ្ងៃទទួលបានសំណើវិនិយោគ ។

៦.២ ការកែតម្រូវសំណើវិនិយោគៈ ប្រសិនបើសំណើវិនិយោគដែលបានដាក់ជូនក្រុមប្រឹក្សា ឬ អនុគណៈកម្មាធិការវិនិយោគខេត្ត ក្រុង មិនស្របទៅតាមមាត្រា៥នៃអនុក្រឹត្យនេះទេ ក្នុងរយៈពេល ០៣ (បី) ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីថ្ងៃទទួលសំណើនោះ ក្រុមប្រឹក្សា ឬ អនុគណៈកម្មាធិការវិនិយោគខេត្ត ក្រុង ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅអ្នកដាក់ពាក្យសុំ ដោយស្នើសុំឱ្យកែតម្រូវសំណើវិនិយោគ ហើយដាក់សំណើនោះជាថ្មីជូនក្រុមប្រឹក្សា ឬអនុគណៈកម្មាធិការវិនិយោគខេត្ត ក្រុង ។

៦.៣ ការចេញវិញ្ញាបនប័ត្រចុះបញ្ជីមានលក្ខខណ្ឌ ៈ ប្រសិនបើក្រុមប្រឹក្សា ឬ អនុគណៈកម្មាធិការវិនិយោគខេត្ត ក្រុង យល់ព្រមចុះបញ្ជីសំណើវិនិយោគតាមកថាខ័ណ្ឌ ៦.១ (ក) ក្រុមប្រឹក្សា ឬ អនុគណៈកម្មាធិការវិនិយោគខេត្ត ក្រុង ត្រូវចេញវិញ្ញាបនប័ត្រចុះបញ្ជីមានលក្ខខណ្ឌ តាមគំរូដូចមានកំណត់នៅក្នុងឧបសម្ព័ន្ធទី ៣ នៅក្នុងរយៈពេល ០៣ (បី) ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីបានទទួលសំណើវិនិយោគ ហើយវិញ្ញាបនប័ត្រចុះបញ្ជីមានលក្ខខណ្ឌនោះ ត្រូវធ្វើការបញ្ជាក់លើចំណុចដូចខាងក្រោម ÷

(ក) បញ្ជីស្តីពីរាល់ការយល់ព្រម ការអនុញ្ញាត អាជ្ញាប័ណ្ណ លិខិតអនុញ្ញាត ឬ បញ្ជីការសំខាន់នានាដែលជាតម្រូវការស្របច្បាប់សម្រាប់ដំណើរការរបស់គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ រួមទាំងការបញ្ជាក់ពីក្រសួង នាយកដ្ឋាន អាជ្ញាធរ មន្ទីរនានាចំណុះខេត្ត ក្រុង ឬភ្នាក់ងាររបស់រាជរដ្ឋាភិបាលដែលទទួលបន្ទុកការងារទាំងនេះ នៅពេលដែលអ្នកដាក់ពាក្យសុំមានលក្ខណៈវិនិច្ឆ័យសមស្របនឹងទទួលបានលិខិតទាំងនោះ ។

(ខ) ការជ្រើសរើសដោយអ្នកដាក់ពាក្យសុំ អនុលោមតាមកថាខ័ណ្ឌ ៥.៥ ឬ ៥.៦ ឬ ៥.៧ ។

(គ) ការលើកទឹកចិត្តវិនិយោគ និង ការធានាលើការវិនិយោគ ដែលគម្រោងវិនិយោគមានសិទ្ធិទទួលបាន ប្រសិនបើវិញ្ញាបនប័ត្រចុះបញ្ជីជាស្ថាពរនឹងត្រូវចេញជូន ដោយរាប់បញ្ចូលទាំងរយៈពេលលើកលែងពន្ធលើប្រាក់ចំណេញ តាមមាត្រា ១៤ ចំណុច ១៤.១ នៃច្បាប់ស្តីពីវិនិយោគ ។

(ឃ) ការជ្រើសរើសដោយអ្នកដាក់ពាក្យសុំតាមមាត្រា ៥ ចំណុច ៥.៧ នៃអនុក្រឹត្យនេះ ប្រសិនបើមាន និង ផលបច្ច័យនៃភាពគ្មានសិទ្ធិ លើការទទួលបាននូវការលើកទឹកចិត្តវិនិយោគ ។

(ង) ការទទួលស្គាល់លើលក្ខខ័ណ្ឌនៃនីតិបុគ្គល ដែលជាអ្នកអនុវត្តគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ។

៦.៤ ការខកខានមិនបានចេញវិញ្ញាបនប័ត្រចុះបញ្ជីមានលក្ខខណ្ឌៈ ប្រសិនបើក្រុមប្រឹក្សា ឬ អនុគណៈកម្មាធិការវិនិយោគខេត្ត ក្រុង ខកខានពុំបានចេញវិញ្ញាបនប័ត្រចុះបញ្ជីមានលក្ខខណ្ឌ តាមកថាខ័ណ្ឌ ៦.៣ ឬ ខកខានមិនបានចេញលិខិតបដិសេធ អនុលោមតាម កថាខ័ណ្ឌ ៦.៦ ក្នុងរយៈ ពេល ០៣ (បី) ថ្ងៃ នៃថ្ងៃធ្វើការទេ សំណើវិនិយោគត្រូវបានចាត់ទុកថាបានចុះបញ្ជី ហើយក្រុមប្រឹក្សា ឬ អនុគណៈកម្មាធិការវិនិយោគខេត្ត ក្រុង ត្រូវចេញវិញ្ញាបនប័ត្រចុះបញ្ជីមានលក្ខខណ្ឌ ជូនអ្នកដាក់ពាក្យសុំជាបន្ទាន់ ។

៦.៥ ព័ត៌មានដែលអមជាមួយវិញ្ញាបនប័ត្រចុះបញ្ជីមានលក្ខខណ្ឌៈ ក្នុងវិញ្ញាបនប័ត្រចុះបញ្ជីមានលក្ខខណ្ឌ ក្រុមប្រឹក្សា ឬ អនុគណៈកម្មាធិការវិនិយោគខេត្ត ក្រុង ត្រូវចេញផងដែរនូវគោលការណ៍ណែនាំវិនិយោគ និង លក្ខណៈវិនិច្ឆ័យសម្រាប់វាយតម្លៃលើការទទួលបាននូវ ការយល់ព្រម ការអនុញ្ញាត អាជ្ញាប័ណ្ណ លិខិតអនុញ្ញាត ឬ បញ្ជីការ ដូចមានយោងនៅក្នុងកថាខ័ណ្ឌ ៦.៣ (ក) ។

៦.៦ លិខិតបដិសេធៈ ប្រសិនបើក្រុមប្រឹក្សា ឬ អនុគណៈកម្មាធិការវិនិយោគខេត្ត ក្រុង បដិសេធចំពោះសំណើវិនិយោគណាមួយតាមកថាខ័ណ្ឌ ៦.១ (ខ) ក្រុមប្រឹក្សា ឬ អនុគណៈកម្មាធិការវិនិយោគខេត្ត ក្រុង ត្រូវចេញលិខិតបដិសេធជូនទៅអ្នកដាក់ពាក្យសុំ ដោយលិខិតនោះត្រូវបញ្ជាក់÷

(ក) មូលហេតុស្តីពីការមិនអាចទទួលសំណើវិនិយោគនោះបាន ។

(ខ) ព័ត៌មានបន្ថែម ដើម្បីផ្តល់លទ្ធភាពឱ្យក្រុមប្រឹក្សា ឬ អនុគណៈកម្មាធិការវិនិយោគខេត្ត ក្រុង អាចចុះបញ្ជីសំណើវិនិយោគ ដែលបានកែតម្រូវនោះ ។

**មាត្រា ៧ៈ *ការចេញជូនអ្នកវិនិយោគនូវវិញ្ញាបនប័ត្រចុះបញ្ជីជាស្ថាពរ***

៧.១ ក្រុមប្រឹក្សា ឬ អនុគណៈកម្មាធិការវិនិយោគខេត្ត ក្រុង ត្រូវជួយសុំការយល់ព្រម ការអនុញ្ញាតផ្សេងៗ នៅពេលដែលក្រុមប្រឹក្សា ឬ អនុគណៈកម្មាធិការវិនិយោគខេត្ត ក្រុង ចេញវិញ្ញាបនប័ត្រចុះបញ្ជីមានលក្ខខណ្ឌ ដោយអនុលោមទៅតាមកថាខ័ណ្ឌ ៦.៣ រួចហើយ ក្រុមប្រឹក្សា ឬ អនុគណៈកម្មាធិការវិនិយោគខេត្ត ក្រុង ត្រូវទទួលយកជំនួសមុខឱ្យ អ្នកដាក់ពាក្យសុំ នូវការយល់ព្រម ការអនុញ្ញាត អាជ្ញាប័ណ្ណ លិខិតអនុញ្ញាត ឬ បញ្ជីការនានា ដែលមានចែងនៅក្នុងកថាខ័ណ្ឌ ៦.៣ (ក) ពីក្រសួង នាយកដ្ឋាន អាជ្ញាធរ មន្ទីរនានាចំណុះខេត្ត ក្រុង ឬ ភ្នាក់ងារ ដែលមានការពាក់ព័ន្ធផ្សេងៗ របស់រាជរដ្ឋាភិបាល ។

៧.២ ការបង់ប្រាក់កក់: អ្នកវិនិយោគ មិនត្រូវបានកំណត់ឱ្យបង់ប្រាក់កក់សម្រាប់ធានាការវិនិយោគឡើយ លើកលែងតែករណីសម្បទានលើវិស័យហេដ្ឋារចនាសម្ព័ន្ធ ដែលកិច្ចសន្យាសម្បទាននោះបានតម្រូវឱ្យបង់ ។

៧.៣ ការចេញវិញ្ញាបនប័ត្រចុះបញ្ជីជាស្ថាពរ: ប្រសិនបើអ្នកមានវិញ្ញាបនប័ត្រចុះបញ្ជីមានលក្ខខណ្ឌ ទទួលបាននូវរាល់ការយល់ព្រម ការអនុញ្ញាត អាជ្ញាប័ណ្ណ លិខិតអនុញ្ញាត ឬ បញ្ជីការនានា ដែលមានចែងក្នុងកថាខ័ណ្ឌ ៦.៣ (ក) រួចហើយនោះ ក្រុមប្រឹក្សា ឬ អនុគណៈកម្មាធិការវិនិយោគ ខេត្ត ក្រុង ត្រូវចេញវិញ្ញាបនប័ត្រចុះបញ្ជីជាស្ថាពរ ។

៧.៤ រយៈពេលចេញវិញ្ញាបនប័ត្រចុះបញ្ជីជាស្ថាពរ: ប្រសិនបើអ្នកមានវិញ្ញាបនប័ត្រចុះបញ្ជីមានលក្ខខណ្ឌ មិនបានទទួលនូវរាល់ ការយល់ព្រម ការអនុញ្ញាត អាជ្ញាប័ណ្ណ លិខិតអនុញ្ញាត ឬ បញ្ជីការនានា ដែលមានចែងនៅក្នុងកថាខ័ណ្ឌ ៦.៣ (ក) នៅក្នុងរយៈពេល ២៨ (ម្ភៃប្រាំបី) ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីចេញវិញ្ញាបនប័ត្រចុះបញ្ជីមានលក្ខខណ្ឌមកទេនោះ ក្រុមប្រឹក្សា ឬ អនុគណៈកម្មាធិការវិនិយោគខេត្ត ក្រុង ត្រូវចេញវិញ្ញាបនប័ត្រចុះបញ្ជីជាស្ថាពរ ។

៧.៥ ការសុំការយល់ព្រមនានាពីស្ថាប័នពាក់ព័ន្ធ: ការចេញវិញ្ញាបនប័ត្រចុះបញ្ជីជាស្ថាពរដោយក្រុមប្រឹក្សា ឬ អនុគណៈកម្មាធិការវិនិយោគខេត្ត ក្រុង អនុលោមទៅតាមកថាខ័ណ្ឌ ៧.៤ មិនមែនជាការលើកលែងឱ្យអ្នកដាក់ពាក្យសុំរួចផុតពីកាតព្វកិច្ច ដែលត្រូវទទួលបាននូវរាល់ ការយល់ព្រម ការអនុញ្ញាត អាជ្ញាប័ណ្ណ លិខិតអនុញ្ញាត ឬបញ្ជីការនានា ដើម្បីគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដំណើរការដោយស្របច្បាប់នោះទេ ។

៧.៦ ការចាប់ផ្តើមគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់: គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ចាប់ផ្តើមនៅថ្ងៃចេញវិញ្ញាបនប័ត្រចុះបញ្ជីជាស្ថាពរសម្រាប់គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់នោះ ហើយចាប់ផ្តើមរយៈពេលគន្លឹះសម្រាប់ការគណនារយៈពេលលើកលែងពន្ធលើប្រាក់ចំណេញតាមមាត្រា ១៤ ចំណុច ១៤.១ នៃច្បាប់ស្តីពីវិនិយោគ និង កថាខ័ណ្ឌ ១៥.១ នៃអនុក្រឹត្យនេះតែម្តង ។

៧.៧ កាតព្វកិច្ចស្នើសុំការយល់ព្រមផ្សេងៗ: គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ត្រូវដាក់ពាក្យស្នើសុំការសម្រេចជាលាយលក្ខណ៍អក្សរជូន ក្រុមប្រឹក្សា ឬ អនុគណៈកម្មាធិការវិនិយោគខេត្ត ក្រុង តាមនីតិវិធីដើម្បីទទួលបាននូវការយល់ព្រម លើរាល់ការប្តូរ អាសយដ្ឋាន ទីស្នាក់ការ ការប្តូរទីតាំងអាជីវកម្ម ការប្តូរនាមករណ៍ ការប្តូរភាគហ៊ុន ឬការផ្លាស់ប្តូរលម្អិតផ្សេងៗទៀត ដែលមាននៅក្នុងសំណើវិនិយោគ និងនៅក្នុងលក្ខន្តិកៈរបស់អ្នកវិនិយោគ ក្នុងរយៈពេលមុនធ្វើការប្តូរ ១០ (ដប់) ថ្ងៃ នៃថ្ងៃធ្វើការ ដើម្បីក្រុមប្រឹក្សា ឬអនុគណៈកម្មាធិការវិនិយោគខេត្ត ក្រុង សម្រេចជូនយ៉ាងយូរក្នុងរយៈពេល ១០ (ដប់) ថ្ងៃ នៃថ្ងៃធ្វើការ ។

## មាត្រា ៨: ការដកហូត ឬ លុបចោលវិញ្ញាបនប័ត្រចុះបញ្ជីជាស្ថាពរ

៨.១ ការដកហូតវិញ្ញាបនប័ត្រចុះបញ្ជីជាស្ថាពរ: វិញ្ញាបនប័ត្រចុះបញ្ជីជាស្ថាពរត្រូវបានដកហូតវិញ ចាប់ពីថ្ងៃចេញផ្តល់ជូនដោយក្រុមប្រឹក្សា ឬ អនុគណៈកម្មាធិការវិនិយោគខេត្ត ក្រុង ប្រសិនបើអ្នកវិនិយោគ ÷

(ក) ទទួលបាននូវវិញ្ញាបនប័ត្រចុះបញ្ជីជាស្ថាពរ ឬ វិញ្ញាបនប័ត្របញ្ជាក់ពីការបំពេញបាននូវកាតព្វកិច្ចចំពោះរដ្ឋ តាមរយៈឯកសារក្លែងបន្លំ ឬ មិនត្រឹមត្រូវ ឬ

(ខ) មិនបានចាប់ផ្តើមធ្វើសកម្មភាពក្នុងរយៈពេល ០៦ (ប្រាំមួយ) ខែ ក្រោយពេលទទួលបាននូវឯកសារទាំងអស់ដោយយោងទៅ តាមកថាខ័ណ្ឌ ៧.៣ លើកលែងករណីកិច្ចសន្យាសម្បទាន ដែលរយៈពេលនឹងកំណត់ជាក់ស្តែង តាមការព្រមព្រៀងគ្នាក្នុងកិច្ចសន្យា ។

៨.២ ការលុបចោលវិញ្ញាបនប័ត្រចុះបញ្ជីជាស្ថាពរៈ ប្រសិនបើអ្នកវិនិយោគស្នើសុំអោយក្រុមប្រឹក្សា ឬអនុគណៈកម្មាធិការវិនិយោគខេត្ត ក្រុង លុបចោលវិញ្ញាបនប័ត្រចុះបញ្ជីជាស្ថាពរ អនុលោមតាមមាត្រា ២១ថ្មី នៃច្បាប់ស្តីពីវិនិយោគ ក្រុមប្រឹក្សា ឬ អនុគណៈកម្មាធិការវិនិយោគខេត្ត ក្រុង ត្រូវលុបចោលវិញ្ញាបនប័ត្រចុះបញ្ជីជាស្ថាពរនោះតែនៅពេលដែលអ្នកវិនិយោគបានអនុវត្ត ស្របទៅតាមមាត្រា ២២ថ្មី និងមាត្រា ២៣ថ្មី នៃច្បាប់ស្តីពីវិនិយោគប៉ុណ្ណោះ ។

៨.៣ ការជូនដំណឹងអំពីការដកហូតវិញ្ញាបនប័ត្រចុះបញ្ជីជាស្ថាពរៈ ប្រសិនបើក្រុមប្រឹក្សា ឬ អនុគណៈកម្មាធិការវិនិយោគខេត្ត ក្រុង ដកហូតវិញ្ញាបនប័ត្រចុះបញ្ជីជាស្ថាពរ ដោយអនុលោមទៅតាមមាត្រានេះ ក្រុមប្រឹក្សា ឬអនុគណៈកម្មាធិការវិនិយោគខេត្ត ក្រុង ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរ ស្តីពីការដកហូតនោះ ជូនទៅអ្នកវិនិយោគ។

៨.៤ ការតវ៉ាៈ អ្នកវិនិយោគដែលវិញ្ញាបនប័ត្រចុះបញ្ជីជាស្ថាពររបស់ខ្លួន ត្រូវបានដកហូតដោយក្រុមប្រឹក្សា ឬ អនុគណៈកម្មាធិការវិនិយោគខេត្ត ក្រុង តាមមាត្រានេះ អាចតវ៉ាជាលាយលក្ខណ៍អក្សរទៅសហប្រធានក្រុមប្រឹក្សាក្នុងរយៈពេល ២០ (ម្ភៃ) ថ្ងៃ នៃថ្ងៃធ្វើការ ចាប់ពីថ្ងៃទទួលបានការជូនដំណឹងជាលាយលក្ខណ៍អក្សរពីក្រុមប្រឹក្សា ឬ ពីអនុគណៈកម្មាធិការវិនិយោគខេត្ត ក្រុងតាមកថាខ័ណ្ឌ ៨.៣ ។

៨.៥ ការបាត់បង់ការលើកទឹកចិត្តវិនិយោគ ៖ គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដែលវិញ្ញាបនប័ត្រចុះបញ្ជីជាស្ថាពររបស់ខ្លួន ត្រូវបានដកហូត ឬលុបចោល មិនមានសិទ្ធិទាមទារការលើកទឹកចិត្តវិនិយោគណាមួយ ដែលមានចែងនៅក្នុងវិញ្ញាបនប័ត្រចុះបញ្ជីជាស្ថាពរទេ គិតចាប់ពីកាលបរិច្ឆេទដកហូត ឬលុបចោលនោះមក ។

## ជំពូកទី ៣

## ការទិញ និង ការរំលាយបញ្ចូលគ្នានៃគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់

### មាត្រា ៩ៈ ការរំលាយបញ្ចូលគ្នានៃគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់

៩.១ ប្រសិនបើ អ្នកវិនិយោគ ពីរ ឬ ច្រើន ឬអ្នកវិនិយោគ និង ជនណាមួយ ព្រមព្រៀងរំលាយបញ្ចូលគ្នា បង្កើតជានីតិបុគ្គលថ្មី ហើយនីតិបុគ្គលថ្មីនោះមានបំណងអនុវត្តគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់របស់អ្នកវិនិយោគ និងមានសិទ្ធិទទួលបាននូវការលើកទឹកចិត្ត និងការធានាលើការវិនិយោគដែលមានចែងនៅក្នុងវិញ្ញាបនប័ត្រចុះបញ្ជីជាស្ថាពរនៃគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ នីតិបុគ្គលថ្មីនោះ ត្រូវស្នើសុំការ

សម្រេចជាលាយលក្ខណ៍អក្សរទៅក្រុមប្រឹក្សា ឬ អនុគណៈកម្មាធិការវិនិយោគខេត្ត ក្រុង តាមនីតិវិធី ដើម្បីចុះបញ្ជីជាអ្នកវិនិយោគ និង ស្នើសុំផ្ទេរវិញ្ញាបនប័ត្រចុះបញ្ជីជាស្ថាពរនៃគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់មកអោយនីតិបុគ្គលថ្មីក្នុងរយៈពេល ១០ (ដប់) ថ្ងៃ នៃថ្ងៃធ្វើការ មុនធ្វើការរំលាយបញ្ចូលគ្នា និងមុនការផ្ទេរវិញ្ញាបនប័ត្រចុះបញ្ជីជាស្ថាពរ ។

៩.២ ក្រុមប្រឹក្សា ឬ អនុគណៈកម្មាធិការវិនិយោគខេត្ត ក្រុង ត្រូវពិនិត្យពាក្យស្នើសុំដែលមានចែងនៅក្នុងកថាខ័ណ្ឌ ៩.១ មាត្រា ៩ នៃអនុក្រឹត្យនេះ ហើយត្រូវផ្តល់ទៅនីតិបុគ្គលថ្មីជាលាយលក្ខណ៍អក្សរនូវការយល់ព្រម ឬមិនយល់ព្រមនៃការចុះបញ្ជី និងការផ្ទេរវិញ្ញាបនប័ត្រចុះបញ្ជីជាស្ថាពរ ក្នុងរយៈពេល ១០ (ដប់) ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីថ្ងៃទទួលបានពាក្យស្នើសុំនោះ ។

**មាត្រា ១០៖ ការទិញយកគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដោយបុគ្គលដែលមិនបានចុះបញ្ជី**

១០.១ ប្រសិនបើបុគ្គលដែលមិនបានចុះបញ្ជី ទិញយកគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ហើយចង់ដំណើរការអនុវត្តគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់នៃអ្នកវិនិយោគ និង ទទួលបាននូវសិទ្ធិលើការលើកទឹកចិត្ត និង ការធានាលើការវិនិយោគ ដែលមានបញ្ជាក់នៅក្នុងវិញ្ញាបនប័ត្រចុះបញ្ជីជាស្ថាពរ បុគ្គលដែលទិញត្រូវស្នើសុំការសម្រេចជាលាយលក្ខណ៍អក្សរទៅក្រុមប្រឹក្សា ឬ អនុគណៈកម្មាធិការវិនិយោគខេត្ត ក្រុង តាមនីតិវិធីដើម្បីចុះបញ្ជីជាអ្នកវិនិយោគ និងស្នើសុំផ្ទេរវិញ្ញាបនប័ត្រចុះបញ្ជីជាស្ថាពរនៃគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ មកឱ្យនីតិបុគ្គលថ្មី ក្នុងរយៈពេល ១០ (ដប់ ) ថ្ងៃ នៃថ្ងៃធ្វើការ មុនការផ្ទេរវិញ្ញាបនប័ត្រចុះបញ្ជីជាស្ថាពរ ។

១០.២ ក្រុមប្រឹក្សា ឬ អនុគណៈកម្មាធិការវិនិយោគខេត្ត ក្រុង ត្រូវពិនិត្យពាក្យស្នើសុំ ដែលមានចែងនៅក្នុងកថាខ័ណ្ឌ ១០.១ មាត្រា ១០ នៃអនុក្រឹត្យនេះ ហើយត្រូវផ្តល់ជូនទៅនីតិបុគ្គលអ្នកទិញជាលាយលក្ខណ៍អក្សរនូវការយល់ព្រម ឬមិនយល់ព្រមនៃការចុះបញ្ជី និងការផ្ទេរវិញ្ញាបនប័ត្រចុះបញ្ជីជាស្ថាពរ ក្នុងរយៈពេល ១០ (ដប់) ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីថ្ងៃទទួលបានពាក្យស្នើសុំនោះ ។

១០.៣ ប្រសិនបើការផ្ទេរភាគហ៊ុនរបស់អ្នកវិនិយោគបណ្តាលអោយការ "គ្រប់គ្រង" ត្រូវបានទទួលដោយអ្នកត្រូវទទួលការផ្ទេរ អ្នកវិនិយោគត្រូវស្នើសុំទៅក្រុមប្រឹក្សា ឬ អនុគណៈកម្មាធិការវិនិយោគខេត្ត ក្រុង តាមនីតិវិធីនូវការផ្ទេរឈ្មោះ និងអាស័យដ្ឋាននៃអ្នកត្រូវទទួលការផ្ទេរ ក្នុងរយៈពេល ១០ (ដប់) ថ្ងៃ នៃថ្ងៃធ្វើការ មុនធ្វើការផ្ទេរភាគហ៊ុននោះ ដើម្បីក្រុមប្រឹក្សា ឬអនុគណៈកម្មាធិការវិនិយោគខេត្ត ក្រុង សម្រេចជូនយ៉ាងយូរក្នុងរយៈពេល ១០ (ដប់) ថ្ងៃ នៃថ្ងៃធ្វើការ។

១០.៤ ចំពោះកថាខ័ណ្ឌ ១០.៣ មាត្រា ១០ នៃអនុក្រឹត្យនេះ ពាក្យថា "គ្រប់គ្រង" សំដៅដល់ អ្នកកាន់កាប់ភាគហ៊ុនយ៉ាងតិច ២០ (ម្ភៃ) ភាគរយ នៃភាគហ៊ុនរបស់អ្នកវិនិយោគ ។

### មាត្រា ១១: ការទិញយកគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដោយអ្នកវិនិយោគផ្សេងទៀត

១១.១ ប្រសិនបើអ្នកវិនិយោគដែលបានចុះបញ្ជីមួយមានបំណង ទិញយកភាពជាម្ចាស់គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ របស់អ្នកវិនិយោគផ្សេងទៀត ហើយចង់ទទួលបាននូវការលើកទឹកចិត្តវិនិយោគ និងការធានាលើការវិនិយោគនៃគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដែលដំណើរការដោយអ្នកវិនិយោគនោះ អ្នកវិនិយោគដែលជាអ្នកទិញ ត្រូវស្នើសុំការសម្រេចជាលាយលក្ខណ៍អក្សរទៅក្រុមប្រឹក្សា ឬអនុគណៈកម្មាធិការវិនិយោគខេត្ត ក្រុង តាមនីតិវិធី នូវការទិញយក ក្នុងរយៈពេល ១០ (ដប់ ) ថ្ងៃ នៃថ្ងៃធ្វើការ មុនការទិញយកនោះ ដើម្បីទទួលបាននូវសិទ្ធិទាំងនោះ ។

១១.២ ក្រុមប្រឹក្សា ឬអនុគណៈកម្មាធិការវិនិយោគខេត្ត ក្រុង ត្រូវពិនិត្យពាក្យស្នើសុំដែលមានចែងនៅក្នុងកថាខ័ណ្ឌ ១១.១ មាត្រា ១១ នៃអនុក្រឹត្យនេះ ហើយត្រូវផ្តល់ជូនទៅអ្នកវិនិយោគជាអ្នកទិញនោះ ជាលាយលក្ខណ៍អក្សរនូវការយល់ព្រម ឬមិនយល់ព្រមនៃការចុះបញ្ជី និងការផ្ទេរវិញ្ញាបនប័ត្រចុះបញ្ជីជាស្ថាពរ ក្នុងរយៈពេល ១០ (ដប់) ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីថ្ងៃទទួលបានពាក្យស្នើសុំនោះ ។

### មាត្រា ១២: ការខកខានមិនបានចុះបញ្ជី ឬ សុំការសម្រេច

ប្រសិនបើ បុគ្គលថ្មី ឬអ្នកវិនិយោគដែលជាអ្នកទិញ ខកខានមិនបានស្នើសុំមកក្រុមប្រឹក្សា ឬ អនុគណៈកម្មាធិការវិនិយោគខេត្ត ក្រុង ដើម្បីចុះបញ្ជីវិនិយោគ អនុលោមទៅតាមមាត្រា ៩ ឬមាត្រា ១០ នៃអនុក្រឹត្យនេះ ឬអ្នកវិនិយោគដែលជាអ្នកទិញ ខកខានមិនបានសុំការសម្រេចទៅក្រុមប្រឹក្សា ឬអនុគណៈកម្មាធិការវិនិយោគខេត្ត ក្រុង អនុលោមទៅតាមមាត្រា ១១ នៃអនុក្រឹត្យនេះ បុគ្គលថ្មី ឬអ្នកវិនិយោគដែលជាអ្នកទិញនោះ មិនមានសិទ្ធិទទួលបាននូវការលើកទឹកចិត្ត និងការធានាលើការវិនិយោគណាមួយរបស់គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ឡើយ ។

## ជំពូកទី ៤

## សម្ព័ន្ធអាជីវកម្ម

### មាត្រា ១៣: សម្ព័ន្ធអាជីវកម្ម

គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ អាចមានទ្រង់ទ្រាយជាសម្ព័ន្ធអាជីវកម្ម។ សម្ព័ន្ធអាជីវកម្មអាចបង្កើតឡើងរវាងនីតិបុគ្គលសញ្ជាតិខ្មែរនឹងនីតិបុគ្គលសញ្ជាតិខ្មែរ នីតិបុគ្គលសញ្ជាតិខ្មែរជាមួយនឹងនីតិបុគ្គលសញ្ជាតិបរទេស និង នីតិបុគ្គលសញ្ជាតិបរទេសជាមួយនឹងនីតិបុគ្គលសញ្ជាតិបរទេស រួមបញ្ចូលផងដែរជាសម្ព័ន្ធអាជីវកម្ម ជាមួយស្ថាប័ននានានៃរាជរដ្ឋាភិបាល។ មិនមានការដាក់កម្រិតកំណត់ដោយផ្អែកលើសញ្ជាតិ ឬសមាមាត្រនៃការដាក់ភាគហ៊ុនរបស់ ម្ចាស់ភាគហ៊ុននីមួយៗឡើយ លើកលែងតែសម្ព័ន្ធអាជីវកម្មនោះ ជាកម្មសិទ្ធិករ ឬ មានបំណងធ្វើជាកម្មសិទ្ធិករលើដីធ្លី ឬដើម្បីផលប្រយោជន៍លើដីធ្លីនៅក្នុងព្រះរាជាណាចក្រ

ចក្រកម្ពុជា។ ក្នុងករណីនេះ ការចូលរួមភាគហ៊ុន អតិបរមានៃបុគ្គលទាំងអស់ ដែលមិនមែនជានីតិបុគ្គលសញ្ជាតិខ្មែរនោះ មិនត្រូវអោយលើសពី ៤៩ (សែសិបប្រាំបួន) ភាគរយឡើយ ។

## ជំពូកទី ៥

## សារពើពន្ធ

### មាត្រា ១៤: គោលការណ៍ទូទៅ

១៤.១ ការទទួលខុសត្រូវចំពោះពន្ធអាករ: អ្នកវិនិយោគត្រូវមានកាតព្វកិច្ចចំពោះពន្ធ និង ត្រូវប្រតិបត្តិតាមបទប្បញ្ញត្តិទាំងឡាយនៃច្បាប់ស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុ ច្បាប់ស្តីពីសារពើពន្ធ ច្បាប់ស្តីពីវិនិយោគ និងបទប្បញ្ញត្តិពាក់ព័ន្ធ ។

១៤.២ ធនធានធម្មជាតិ: អត្រាពន្ធលើប្រាក់ចំណេញ អនុវត្តចំពោះប្រាក់ចំណេញដែលសម្រេចបានក្រោមកិច្ចសន្យាបែងចែកផលិតផលប្រេងកាត និងឧស្ម័នធម្មជាតិ ឬសម្រេចបានពីការធ្វើអាជីវកម្មលើធនធានធម្មជាតិ មានជាអាទិ៍ ព្រៃឈើ រ៉ែ មាស ឬត្បូងថ្មមានតម្លៃនានា ត្រូវកំណត់តាមកថាខ័ណ្ឌ ២ មាត្រា ២០ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីសារពើពន្ធ ។

១៤.៣ ការដាក់កម្រិត: ការលើកលែងទាំងស្រុង ឬ មួយផ្នែកនៃពន្ធអាករ និង ពន្ធគយ ត្រូវអនុវត្តចំពោះតែពន្ធលើប្រាក់ចំណេញ និងពន្ធគយ ដូចមានចែងនៅក្នុងអនុក្រឹត្យនេះតែប៉ុណ្ណោះ។ ការលើកលែងនេះ ពុំរាប់បញ្ចូលនូវពន្ធអាករដូចខាងក្រោមនេះទេ ÷

ក- ពន្ធលើប្រាក់បៀវត្ស ពន្ធកាត់ទុក ដូចបានកំណត់ក្នុងមាត្រា ២៥ និង ២៦ ថ្មីនៃច្បាប់ស្តីពីសារពើពន្ធ និង ពន្ធ លើប្រាក់ចំណេញបន្ថែមលើការបែងចែកភាគលាភ និង

ខ- អាករលើតម្លៃបន្ថែម អាករពិសេសលើទំនិញ និងសេវាមួយចំនួន អាករដែលត្រូវបង់នៅពេលនាំចូល និងពន្ធអាករដទៃទៀត ដូចមានចែងក្នុងច្បាប់មានសុពលភាពជាធរមាន ។

### មាត្រា ១៥: ពន្ធលើប្រាក់ចំណេញ

១៥.១ រយៈពេលលើកលែងពន្ធលើប្រាក់ចំណេញ : យោងតាមមាត្រា ១៤ ចំណុច ១៤.១ នៃច្បាប់ស្តីពីវិនិយោគ រយៈពេលលើកលែងពន្ធលើប្រាក់ចំណេញ ដែលរួមមាន រយៈពេលគន្លឹះ បូក រយៈពេល ០៣ (បី) ឆ្នាំ បូករយៈពេលអាទិភាព គឺត្រូវបានកំណត់ដូចមានចែងក្នុងមាត្រានេះ ។

១៥.២ រយៈពេលគន្លឹះ: សម្រាប់មាត្រា ១៤ ចំណុច ១៤.១ នៃច្បាប់ស្តីពីវិនិយោគ រយៈពេលគន្លឹះនៃរយៈពេលលើកលែងពន្ធលើប្រាក់ចំណេញ គឺជារយៈពេលចាប់ផ្តើមពីថ្ងៃចេញវិញ្ញាបនប័ត្រចុះបញ្ជីជាស្ថាពរ និង បញ្ចប់នៅថ្ងៃចុងក្រោយនៃឆ្នាំសារពើពន្ធណាមួយដែលឆាប់ជាង ÷

ក- ប្រសិនបើ គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ មានប្រាក់ចំណេញ គឺជាឆ្នាំសារពើពន្ធមុនឆ្នាំដែលគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ មានប្រាក់ចំណេញដំបូង និង

ខ- ប្រសិនបើ គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ មានប្រាក់ចំណូលពីសកម្មភាពវិនិយោគចំពោះការលក់ទំនិញឬសេវា គឺជាឆ្នាំសារពើពន្ធទី៣ បន្ទាប់ពីគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ទទួលបានប្រាក់ចំណូលដំបូង ។

សម្រាប់គោលដៅនៃកថាខ័ណ្ឌនេះ និងមាត្រា១៤ ចំណុច ១៤.១ នៃច្បាប់ស្តីពីវិនិយោគ ប្រាក់ចំណេញគឺសំដៅដល់ប្រាក់ចំណេញជាប់ពន្ធ ដែលគណនាទៅតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីសារពើពន្ធដោយពុំគិតពីបទប្បញ្ញត្តិនៃការយោងការខាត ដូចមានចែងក្នុងមាត្រា ១៧ នៃច្បាប់ស្តីពីសារពើពន្ធ ។

១៥.៣ រយៈពេល ០៣ (បី) ឆ្នាំៈ គឺចាប់ផ្តើមគិតភ្លាមពីឆ្នាំសារពើពន្ធ បន្ទាប់ពីរយៈពេលគន្លឹះ និង ០២ (ពីរ) ឆ្នាំបន្តបន្ទាប់មកទៀត ។

១៥.៤ រយៈពេលអាទិភាពៈ រយៈពេលអាទិភាព ត្រូវបានកំណត់នៅក្នុងច្បាប់ស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុដោយចាប់ផ្តើមគិតភ្លាមបន្ទាប់ពីឆ្នាំសារពើពន្ធទី៣ នៃរយៈពេល ០៣ (បី) ឆ្នាំ ដូចមានចែងនៅក្នុងកថាខ័ណ្ឌ ១៥.៣ ខាងលើ ។

១៥.៥ ប្រាក់រំដោះពន្ធលើប្រាក់ចំណេញ សម្រាប់គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដែលបានចុះបញ្ជីក្រោយថ្ងៃប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីវិនិយោគៈ ប្រាក់រំដោះពន្ធលើប្រាក់ចំណេញមិនត្រូវអនុវត្តចំពោះគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដែលទទួលបានការលើកលែងពន្ធលើប្រាក់ចំណេញ ដូចមានចែងក្នុងមាត្រា១៤ ចំណុច ១៤.១ នៃច្បាប់ស្តីពីវិនិយោគទេ ។

១៥.៦ ប្រាក់រំដោះពន្ធលើប្រាក់ចំណេញសម្រាប់គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដែលបានទទួលការអនុញ្ញាតមុនពេលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគៈ គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ណាដែលត្រូវអនុវត្តតាមកថាខ័ណ្ឌទី២ នៃមាត្រា ២៤ ថ្មីនៃច្បាប់ស្តីពីវិនិយោគ ត្រូវមានកាតព្វកិច្ចបង់ប្រាក់រំដោះប្រចាំខែ សម្រាប់ពន្ធលើប្រាក់ចំណេញតាមអត្រា ០១ (មួយ) ភាគរយនៃផលរបរគិតរួមបញ្ចូលទាំងពន្ធអាករទាំងអស់ លើកលែងតែអាករលើតម្លៃបន្ថែម ដែលបានសម្រេចក្នុងខែមុន ដូចមានចែងនៅក្នុងមាត្រា ២៨ ថ្មីនៃច្បាប់ស្តីពីសារពើពន្ធ។ ផលរបររបស់គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ក្នុងរយៈពេលលើកលែងពន្ធ ដែលកំណត់ដោយច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ត្រូវលើកលែងពីការបង់ប្រាក់រំដោះនេះ ។

១៥.៧ ដោយអនុលោមតាមមាត្រា ២៤ថ្មី នៃច្បាប់ស្តីពីសារពើពន្ធ គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់មិនត្រូវជាប់ពន្ធអប្បបរមាទេ ។

## មាត្រា ១៦: ការលើកលែងពន្ធគយលើសម្ភារៈបរិក្ខារផលិតកម្ម សម្ភារៈសាងសង់ និង ធាតុចូលផលិតកម្ម

១៦.១ ការលើកលែងពន្ធគយ លើសម្ភារៈបរិក្ខារផលិតកម្ម និងសម្ភារៈសាងសង់របស់គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដែលបម្រើទីផ្សារក្នុងស្រុក : អនុលោមទៅតាមមាត្រា ១៤ ចំណុច ១៤.៥ នៃច្បាប់ស្តីពី

វិនិយោគ គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដែលបម្រើទីផ្សារក្នុងស្រុក ត្រូវបានលើកលែងពន្ធគយ លើការនាំចូលសម្ភារៈបរិក្ខារផលិតកម្ម និងសម្ភារៈសាងសង់តែប៉ុណ្ណោះ ក្នុងករណីដែលគម្រោងប្រភេទនេះ មានលទ្ធភាពនាំចេញនូវផ្នែកណាមួយនៃផលិតផលដែលផលិតបានដោយផ្ទាល់ ឬ បានផ្គត់ផ្គង់ដល់ឧស្សាហកម្មនាំចេញ បរិមាណធាតុចូលផលិតកម្មដែលបានបង់ពន្ធនាំចូលរួយកទៅផលិតបម្រើការនាំចេញដោយផ្ទាល់ ឬដោយប្រយោលនោះ ត្រូវបានទទួលការលើកលែងពន្ធគយក្រោយពីការត្រួតពិនិត្យរបាយការណ៍ប្រចាំត្រីមាស ។

១៦.២ ការលើកលែងពន្ធគយ លើសម្ភារៈបរិក្ខារផលិតកម្ម សម្ភារៈសាងសង់ និងធាតុចូលផលិតកម្មរបស់គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់បំរើឱ្យការនាំចេញ : អនុលោមតាមមាត្រា ១៤ ចំណុច ១៤.៦ នៃច្បាប់ស្តីពីវិនិយោគ គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដែលបម្រើឱ្យការនាំចេញត្រូវបានលើកលែងពន្ធគយលើការនាំចូល សម្ភារៈបរិក្ខារផលិតកម្ម សម្ភារៈសាងសង់ និងធាតុចូលផលិតកម្ម ។ ដោយឡែកគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់បម្រើឱ្យការនាំចេញ ដែលស្ថិតនៅក្រោមយន្តការភណ្ឌាគារផលិតកម្ម ក្រោមការគ្រប់គ្រងរបស់គយ ការលើកលែងពន្ធគយត្រូវអនុវត្តទៅតាមច្បាប់ និង បទប្បញ្ញត្តិគយជាធរមានរបស់យន្តការនេះ។ ធាតុចូលផលិតកម្មដែលកែច្នៃហើយមិនបាននាំចេញ ត្រូវបង់ពន្ធគយ និង អាករឡើងវិញលើធាតុចូលផលិតកម្មនាពេលនាំចូល ក្រោយពីការត្រួតពិនិត្យរបាយការណ៍ប្រចាំត្រីមាស ។

១៦.៣ ការលើកលែងពន្ធគយ លើសម្ភារៈបរិក្ខារផលិតកម្ម សម្ភារៈសាងសង់ និង ធាតុចូលផលិតកម្ម របស់គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដែលជាប្រភេទឧស្សាហកម្មគាំទ្រ អនុលោមតាមមាត្រា ១៤ ចំណុច ១៤.៧ នៃច្បាប់ស្តីពីវិនិយោគ គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដែលជាឧស្សាហកម្មគាំទ្រ ត្រូវបានលើកលែងពន្ធគយ លើការនាំចូលសម្ភារៈបរិក្ខារផលិតកម្ម សម្ភារៈសាងសង់ និង ធាតុចូលផលិតកម្ម។ ប៉ុន្តែក្នុងករណី ដែលគម្រោងទាំងនោះមិនបានធ្វើការផ្គត់ផ្គង់ ១០០ (មួយរយ) ភាគរយ នៃផលិតផលដែលផលិតបានទៅដល់ឧស្សាហកម្មនាំចេញ ឬនាំចេញដោយផ្ទាល់ទេនោះ គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ទាំងនោះ ត្រូវបង់ពន្ធគយនិងអាករឡើងវិញលើធាតុចូលផលិតកម្មនាពេលនាំចូលនូវបរិមាណដែលមិនបានផ្គត់ផ្គង់ឱ្យឧស្សាហកម្មនាំចេញ ឬ នាំចេញដោយផ្ទាល់ ក្រោយពីការត្រួតពិនិត្យរបាយការណ៍ប្រចាំត្រីមាស។

១៦.៤ នីតិវិធីលើកលែងពន្ធគយៈ ក្រុមប្រឹក្សាត្រូវរៀបចំ ÷

ក-បង្កើតយន្តការអន្តរស្ថាប័ន ដែលមានសមាសភាពមកពីក្រុមប្រឹក្សា ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុសម្រាប់ពិនិត្យផ្ទាល់ការលើកទឹកចិត្ត លើការនាំចូល និង ការប្រើប្រាស់នូវសម្ភារៈបរិក្ខារផលិតកម្ម សម្ភារៈសាងសង់ និងធាតុចូលផលិតកម្មរបស់គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ តាមវិញ្ញាបនបត្រចុះបញ្ជីវិនិយោគនីមួយៗ។

ខ-សេចក្តីណែនាំលម្អិតស្តីពីនីតិវិធីសម្រាប់គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដែលត្រូវបានទទួលការលើកលែងពន្ធគយ ។

១៦.៥ ការផ្ទេរ ការលក់ សម្ភារៈបរិក្ខារផលិតកម្ម សម្ភារៈសាងសង់ ធាតុចូលផលិតកម្មៈ ប្រសិនបើ សម្ភារៈបរិក្ខារផលិតកម្ម សម្ភារៈសាងសង់ ធាតុចូលផលិតកម្ម ដែលបាននាំចូលក្រោមការលើកលែងពន្ធគយ អាករ ត្រូវបានលក់ ឬ ប្រើប្រាស់មិនចំគោលដៅតាមរូបភាពណាមួយ អ្នកវិនិយោគត្រូវ ÷

ក- ធ្វើការបង់ពន្ធគយ អាករ ក្នុងរយៈពេល ២៨ (ម្ភៃប្រាំបី) ថ្ងៃ នៃថ្ងៃធ្វើការ ទៅតាមចំនួនទឹកប្រាក់ដែលគណនាផ្អែកតាមច្បាប់ និង បទប្បញ្ញត្តិគយ ជាធរមាន ក្នុងករណីដែលការផ្ទេរ ឬការលក់ បានទទួលការអនុញ្ញាតជាមុនពីក្រុមប្រឹក្សា។

ខ- ធ្វើការបង់ពន្ធគយ អាករ និង ពិន័យ ក្នុងរយៈពេល ២៨ (ម្ភៃប្រាំបី) ថ្ងៃ នៃថ្ងៃធ្វើការ ទៅតាមចំនួនទឹកប្រាក់ដែលគណនាផ្អែកតាមច្បាប់ និងបទប្បញ្ញត្តិគយ ជាធរមាន ក្នុងករណីដែលការផ្ទេរ ឬការលក់នោះ មិនបានទទួលការអនុញ្ញាតជាមុន ពីក្រុមប្រឹក្សា។

គ- ទទួលរងការដាក់ជាបណ្តោះអាសន្ននូវ ការអនុញ្ញាតឱ្យនាំចូល ការពិនិត្យលើសំណើសុំលើកលែងពន្ធគយ ដែលបានផ្តល់ឱ្យ នៅក្រោមច្បាប់ស្តីពីវិនិយោគ រួមទាំងការពិន័យផ្អែកគយផ្សេងៗទៀត ក្នុងករណីមានការខកខាន ការយឺតយូរ ក្នុងការបង់ពន្ធគយ អាករ និងការពិន័យ ដូចមានចែងក្នុងកថាខ័ណ្ឌ ក និង ខ នៃកថាខ័ណ្ឌ ១៦.៥ មាត្រា ១៦ នៃអនុក្រឹត្យនេះ។

១៦.៦ ការផ្ទេរ ការលក់ សម្ភារៈបរិក្ខារផលិតកម្ម សម្ភារៈសាងសង់ ធាតុចូលផលិតកម្ម ទៅឱ្យអ្នកវិនិយោគផ្សេងទៀត : អ្នកវិនិយោគ ឬ តំណាងរបស់អ្នកវិនិយោគ អាចដាក់សំណើជាលាយលក្ខណ៍អក្សរទៅក្រុមប្រឹក្សាដើម្បីសុំការសម្រេច លើការផ្ទេរ ការលក់ ដោយគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ នូវសម្ភារៈបរិក្ខារផលិតកម្ម សម្ភារៈសាងសង់ ធាតុចូលផលិតកម្ម ដែលបាននាំចូលដោយលើកលែងពន្ធគយទៅឱ្យអ្នកវិនិយោគផ្សេងទៀត សម្រាប់ប្រើប្រាស់ក្នុងគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់។

## ជំពូកទី ៦

## កាតព្វកិច្ចរាយការណ៍ និង វិញ្ញាបនបត្របញ្ជាក់ពីការបំពេញបាននូវកាតព្វកិច្ចចំពោះរដ្ឋ

### មាត្រា ១៧: កាតព្វកិច្ចរាយការណ៍

១៧.១ កាតព្វកិច្ចរាយការណ៍ស្តីពីសារពើពន្ធៈ ដូចបានកំណត់ក្នុងមាត្រា ១០៤ ថ្មី នៃច្បាប់ស្តីពីសារពើពន្ធ ចាប់ពីថ្ងៃចេញវិញ្ញាបនប័ត្រចុះបញ្ជីជាស្ថាពរ គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ទាំងអស់ត្រូវដាក់លិខិតប្រកាសសារពើពន្ធប្រចាំខែសម្រាប់ខែនីមួយៗ និងលិខិតប្រកាសសារពើពន្ធប្រចាំឆ្នាំសម្រាប់ឆ្នាំសារពើពន្ធនោះ និងបង់ពន្ធអាករទាំងអស់តាមបទប្បញ្ញត្តិនៃពន្ធនីមួយៗ ជូននាយកដ្ឋានពន្ធដារ ដោយត្រូវដាក់ភ្ជាប់នូវវិញ្ញាបនប័ត្របញ្ជាក់ពីការបំពេញបាននូវកាតព្វកិច្ចចំពោះរដ្ឋសម្រាប់ឆ្នាំសារពើពន្ធ ។

១៧.២ កាតព្វកិច្ចរាយការណ៍ពីការលើកលែងពន្ធគយៈ រាល់សម្ភារៈបរិក្ខារផលិតកម្ម និងសម្ភារៈសាងសង់នាំចូលដោយគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ត្រូវតែមានការបំពេញបែបបទគយឱ្យបានសព្វគ្រប់ត្រឹមត្រូវ ។ ក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ នៃថ្ងៃធ្វើការ ក្រោយការនាំចូល គម្រោងវិនិយោគមានលក្ខណៈ

សម្បត្តិគ្រប់គ្រាន់ ត្រូវដាក់ជូនក្រុមប្រឹក្សា និង នាយកដ្ឋានពន្ធដារ នូវច្បាប់ចម្លង ដែលមានការបញ្ជាក់ត្រឹមត្រូវលើឯកសារបំពេញបែបបទគយ ក្នុងនោះមានទាំងឯកសារបញ្ជាក់តម្លៃទំនិញពីភ្នាក់ងារដែលរដ្ឋាភិបាលបានជ្រើសតាំងឱ្យទទួលភារកិច្ចផង ។

## មាត្រា ១៨: វិញ្ញាបនប័ត្របញ្ជាក់ពីការបំពេញបាននូវកាតព្វកិច្ចចំពោះរដ្ឋ

១៨.១ វិញ្ញាបនប័ត្របញ្ជាក់ពីការបំពេញបាននូវកាតព្វកិច្ចចំពោះរដ្ឋ: រៀងរាល់ឆ្នាំសារពើពន្ធនីមួយៗគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ មិនអាចទាមទារ និងមិនមានសិទ្ធិទទួលបាននូវការលើកទឹកចិត្តវិនិយោគណាមួយទេ ល្គឹកណា គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ មិនទទួលបាននូវវិញ្ញាបនប័ត្របញ្ជាក់ពីការបំពេញបាននូវកាតព្វកិច្ចចំពោះរដ្ឋ ។

១៨.២ ការចេញជាស្វ័យប្រវត្តិ: យោលទៅតាមការដកហូតដោយក្រុមប្រឹក្សាតាមកថាខ័ណ្ឌ ១៨.៤ និង ១៨.៥ ក្រុមប្រឹក្សា ត្រូវចេញវិញ្ញាបនបត្រ័បញ្ជាក់ពីការបំពេញបាននូវកាតព្វកិច្ចចំពោះរដ្ឋជូន គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ក្នុងរយៈពេល ៩០ (កៅសិប )ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីដំណាច់ឆ្នាំសារពើពន្ធនីមួយៗ ។

១៨.៣ ការខកខានមិនបានចេញ: ប្រសិនបើក្រុមប្រឹក្សា ខកខានមិនបានចេញវិញ្ញាបនបត្រ័បញ្ជាក់ពីការបំពេញបាននូវកាតព្វកិច្ចចំពោះរដ្ឋ ដូចបានតម្រូវក្នុងកថាខ័ណ្ឌ ១៨.២ ទេនោះ វិញ្ញាបនបត្រ័បញ្ជាក់ពីការបំពេញបាននូវកាតព្វកិច្ចចំពោះរដ្ឋនឹងត្រូវចាត់ទុកថា បានចេញជូនគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ប៉ុន្តែអាចនឹងត្រូវបានដកហូតវិញតាម កថាខ័ណ្ឌ ១៨.៤ និង ១៨.៥។

១៨.៤ សិទ្ធិពិនិត្យឡើងវិញ: ក្រុមប្រឹក្សាមានសិទ្ធិពិនិត្យឡើងវិញដើម្បីកំណត់ច្បាស់ថា គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដែលកាន់កាប់វិញ្ញាបនប័ត្របញ្ជាក់ពីការបំពេញបាននូវកាតព្វកិច្ចចំពោះរដ្ឋនោះ បានផ្តល់រាល់ព័ត៌មានដែលតម្រូវ ស្របតាមកថាខ័ណ្ឌ ១៨.៦ ។

១៨.៥ ការបាត់បង់ការលើកទឹកចិត្តវិនិយោគ: ក្រុមប្រឹក្សាអាចដកហូតវិញ្ញាបនប័ត្របញ្ជាក់ពីការបំពេញបាននូវកាតព្វកិច្ចចំពោះរដ្ឋរបស់គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ប្រសិនបើក្រុមប្រឹក្សាយល់ថា គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ មិនបានផ្តល់នូវព័ត៌មានដែលតម្រូវដោយមាត្រានេះ បន្ទាប់ពីការពិនិត្យសមហេតុផលឡើងវិញ តាមកថាខ័ណ្ឌ ១៨.៤ ហើយគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់នោះនឹងបាត់បង់នូវសិទ្ធិនៃការទទួលរាល់ការលើកទឹកចិត្តវិនិយោគ ចាប់ពីថ្ងៃដកហូតវិញ្ញាបនប័ត្រនេះតទៅ ។

១៨.៦ ព័ត៌មានដែលត្រូវប្រគល់ជូន: គ្រប់អ្នកវិនិយោគទាំងអស់ ត្រូវដាក់ជូនទៅក្រុមប្រឹក្សានូវ ÷

(ក) របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ រួមមាន តារាងតុល្យការ របាយការណ៍លទ្ធផល តារាងចលនា សាច់ប្រាក់ និង កំណត់សម្គាល់ ដោយមិនឱ្យហួសពីថ្ងៃទី ៣១ ខែ មីនា នៃឆ្នាំបន្ទាប់ ។

(ខ) លិខិតបញ្ជាក់ពីការបំពេញកាតព្វកិច្ចសារពើពន្ធពីនាយកដ្ឋានពន្ធដារ ដែលបញ្ជាក់ថាអ្នកវិនិយោគបាន :

(១) បំពេញត្រឹមត្រូវ និងដាក់លិខិតប្រកាសសារពើពន្ធប្រចាំខែគ្រប់គ្រាន់ទាន់ពេលវេលា [illegible] តែលិខិតប្រកាសប្រចាំឆ្នាំនោះ ដែលតម្រូវដោយច្បាប់ស្តីពីសារពើពន្ធ ។

(ខ) បង់ពន្ធទាំងអស់ ប្រាក់ពន្ធ ការប្រាក់ និងប្រាក់ពន្ធបន្ថែម ដែលបានកំណត់សម្រាប់រយៈពេលជាប់ពន្ធ ដែលបានធ្វើសវនកម្មរួចដោយនាយកដ្ឋានពន្ធដារ ។

(គ) របាយការណ៍ប្រចាំត្រីមាសស្តីពីការនាំចូលជាក់ស្តែងនូវ សម្ភារៈបរិក្ខារផលិតកម្ម និងធាតុចូលផលិតកម្ម ដែលបម្រើឱ្យផលិតកម្ម និងរបាយការណ៍ប្រចាំត្រីមាសស្តីពីការនាំចេញជាក់ស្តែងនូវផលិតផលសម្រេច របស់គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ព្រមទាំងតារាងអចលនៈទ្រព្យប្រចាំឆ្នាំ ។

(ឃ) បញ្ជីអង្កេតព័ត៌មានវិនិយោគទម្រង់ CIB 01S ។

## ជំពូកទី ៧
## កម្មសិទ្ធិ និង ការប្រើប្រាស់ដីធ្លី

### មាត្រា ១៩: កម្មសិទ្ធិ

១៩.១ កម្មសិទ្ធិ: កម្មសិទ្ធិដីធ្លី សម្រាប់បម្រើឱ្យគោលដៅនៃសកម្មភាពវិនិយោគ ដែលត្រូវផ្តល់ជូនរូបវន្តបុគ្គល ឬ នីតិបុគ្គលសញ្ជាតិខ្មែរ ត្រូវអនុលោមទៅតាមច្បាប់ជាធរមាន ។

១៩.២ ការចុះបញ្ជីកម្មសិទ្ធិ: ក្នុងការចុះបញ្ជីកម្មសិទ្ធិដីធ្លី អ្នកវិនិយោគត្រូវទៅបំពេញរាល់ទម្រង់បែបបទចុះបញ្ជីនៅរដ្ឋបាលសុរិយោដី ក្នុងមូលដ្ឋានដែលអចលនវត្ថុនោះតាំងនៅ ។

១៩.៣ ការកំណត់សិទ្ធិលើកម្មសិទ្ធិ: អនុលោមតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា រូបវន្តបុគ្គល ឬ នីតិបុគ្គលសញ្ជាតិបរទេស មិនអាចធ្វើជាកម្មសិទ្ធិករនៃដីធ្លីក្នុងព្រះរាជាណាចក្រកម្ពុជាបានឡើយ ។

### មាត្រា ២០ : ការប្រើប្រាស់ដីធ្លី

២០.១ នីតិបុគ្គលសញ្ជាតិខ្មែរ: ក្រៅពីសិទ្ធិកម្មសិទ្ធិ អ្នកវិនិយោគសញ្ជាតិខ្មែរមានសិទ្ធិប្រើប្រាស់ដីធ្លីតាមរូបភាពផ្សេងៗ ដែលមានជាធរមានដូចជា:សម្បទាន ការជួល ការផ្ទេរ ការដាក់ប្រាតិភោគជាដើម ។

២០.២ នីតិបុគ្គលសញ្ជាតិបរទេស: នីតិបុគ្គលសញ្ជាតិបរទេសអាចប្រើប្រាស់ដីធ្លីតាមរូបភាពផ្សេងៗដូចជា សម្បទាន ការជួលរយៈពេលវែង ១៥ (ដប់ប្រាំ) ឆ្នាំឡើង ឬ លើស និងការជួលរយៈពេលខ្លី ហើយអាចបន្តជាថ្មីបាន ។ ការប្រើប្រាស់ដីធ្លីនេះរាប់បញ្ចូលទាំងសិទ្ធិលើសំណង់ ការរៀបចំឬ ការកែលំអទាំងឡាយ ដែលបានធ្វើដោយអ្នកជួលក្នុងរយៈពេលកំណត់នៃកិច្ចសន្យា តែត្រូវអនុវត្តតាមច្បាប់ជាធរមាន ។

២០.៣ ការជួលដីរបស់រដ្ឋ: រូបវន្តបុគ្គលឬ នីតិបុគ្គល ដែលបានជួលដីពីរដ្ឋ ត្រូវអនុវត្តទៅតាមបទប្បញ្ញត្តិ ស្តីពីការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ។

២០.៤ ការជួលបន្ត: រូបវន្តបុគ្គល ឬនីតិបុគ្គលដែលបានទទួលការអនុញ្ញាតអោយជួលដីធ្លីពីរដ្ឋ អាចធ្វើការជួលបន្តទៅអោយតតីយជនបាន លុះត្រាតែមានការយល់ព្រមដោយជាក់លាក់ ឬ ការអនុញ្ញាតពីស្ថាប័នមានសមត្ថកិច្ចជាមុនសិន ។

# ជំពូកទី ៨

## កម្លាំងពលកម្ម

### មាត្រា ២១ : ការប្រើប្រាស់កម្លាំងពលកម្ម

ក្រុមប្រឹក្សា មានភារកិច្ចណែនាំ និង សម្រួលដល់អ្នកវិនិយោគ ដើម្បីនាំមកជាមួយនូវសហព័ទ្ធ ជាជនបរទេស ដើម្បីទទួលបាននូវទិដ្ឋាការ សិទ្ធិស្នាក់នៅ និង លិខិតធ្វើដំណើរនានាត្រឹមត្រូវ ស្របទៅតាមច្បាប់ និង បទប្បញ្ញត្តិស្តីពីអន្តោប្រវេសន៍ ។

រាល់ការនាំមកនូវ បុគ្គលិក និង អ្នកជំនាញការខាងការគ្រប់គ្រង បុគ្គលិកបច្ចេកទេស កម្មករជំនាញ ដែលជាជនបរទេសរបស់អ្នកវិនិយោគដែលមិនអាចរកបាននៅក្នុងចំណោមប្រជាជនកម្ពុជា ក្រុមប្រឹក្សាត្រូវបង្កការងាយស្រួលជូនដល់អ្នកវិនិយោគ ដើម្បីអាចមានសិទ្ធិនាំនិយោជិតបរទេសទាំងនោះមកបំពេញការងារតាមតម្រូវការ ស្របតាមច្បាប់ស្តីពីការងារ ច្បាប់ស្តីពីអន្តោប្រវេសន៍ និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន ។

# ជំពូកទី ៩

## ទោសប្បញ្ញត្តិ

### មាត្រា ២២: ទោសប្បញ្ញត្តិ

ប្រសិនបើអ្នកវិនិយោគ មិនអនុវត្តតាមកាតព្វកិច្ចណាមួយដែលបានកំណត់ឱ្យខ្លួន តាមអនុក្រឹត្យនេះ ឬតាមច្បាប់ស្តីពីវិនិយោគ អ្នកវិនិយោគត្រូវទទួលរងនូវទោសប្បញ្ញត្តិ ដែលបានកំណត់ដោយមាត្រា ៨ ចំណុច ៨.១ មាត្រា ១២ មាត្រា ១៨ ចំណុច ១៨.៥ នៃអនុក្រឹត្យនេះ ឬ ច្បាប់ដទៃទៀត ស្តីពីការមិនបំពេញនូវកាតព្វកិច្ច ។

# ជំពូកទី ១០

## អន្តរប្បញ្ញត្តិ

### មាត្រា ២៣: ការទទួលស្គាល់ជាគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ នៃគម្រោងវិនិយោគដែលទទួលបានការអនុញ្ញាតមុនច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគ

២៣.១ គម្រោងវិនិយោគទាំងឡាយ ដែលបានទទួលការអនុញ្ញាតដោយច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ០៣/នស/៩៤ ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៤ និងដែលកំពុងធ្វើសកម្មភាពបច្ចុប្បន្ន មុនថ្ងៃចូលជាធរមាននៃអនុក្រឹត្យនេះ និងត្រូវបានទទួលស្គាល់ជាគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ក្រោយពេលដែលអ្នកវិនិយោគនោះ បានដាក់សំណើជាលាយលក្ខណ៍អក្សរជូនមកក្រុមប្រឹក្សា ដើម្បីកំណត់ជាជាគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ហើយទទួលអនុវត្តនូវកាតព្វកិច្ចទាំងឡាយដូចមានចែងក្នុងច្បាប់ស្តីពីវិនិយោគ និង អនុក្រឹត្យនេះ ។

ក្រុមប្រឹក្សា ត្រូវចេញលិខិតទទួលស្គាល់គម្រោងវិនិយោគខាងលើនោះ ថាជាគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ក្នុងរយៈពេលយ៉ាងយូរ ០៣ (បី)ថ្ងៃ នៃថ្ងៃធ្វើការ ជូនទៅអ្នកវិនិយោគវិញ។ ចំពោះគម្រោងវិនិយោគ ដែលពីមុនបានទទួលគោលការណ៍ឱ្យវិនិយោគកន្លងមក តែមិនបានធ្វើសកម្មភាពអ្វីឡើយ ឬបានធ្វើមួយរយៈ តែបានផ្អាកសកម្មភាពទៅវិញ ហើយមិនបានជូនដំណឹងពីការបញ្ឈប់ ឬផ្អាកសកម្មភាពនោះមកក្រុមប្រឹក្សា គម្រោងវិនិយោគនោះ ត្រូវធ្វើនិយ័តកម្មឯកសារបន្ថែមដើម្បីអាចទទួលបានសិទ្ធិជាគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ មុននឹងចាប់ផ្តើមអនុវត្តគម្រោងជាបន្តទៅទៀត។

២៣.២ ការលើកទឹកចិត្តនានា របស់គម្រោងវិនិយោគ ដែលទទួលការអនុញ្ញាតមុនច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគៈ គម្រោងវិនិយោគ ដែលទទួលការអនុញ្ញាតមុនច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគ ហើយបានទទួលស្គាល់ជាគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដែលមានសិទ្ធិទទួលបាននូវអត្រាពន្ធលើប្រាក់ចំណេញ ០៩ (ប្រាំបួន) ភាគរយ មុនពេលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា មានសិទ្ធិទទួលបានអត្រាពន្ធ ០៩ (ប្រាំបួន) ភាគរយនេះ សម្រាប់រយៈពេលអន្តរកាលមិនលើសពី ០៥ (ប្រាំ) ឆ្នាំ ដោយចាប់ផ្តើមពីឆ្នាំសារពើពន្ធបន្ទាប់ពីការប្រកាសចូលជាធរមាននូវច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា និងអនុក្រឹត្យនេះ លុះត្រាតែអ្នកវិនិយោគនោះ បានបំពេញត្រឹមត្រូវនូវ កាតព្វកិច្ចទាំងឡាយ ដូចមានចែងក្នុងជំពូកទី ៦ នៃអនុក្រឹត្យនេះ។
គម្រោងវិនិយោគដែលទទួលការអនុញ្ញាតមុនច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគ ហើយបានទទួលស្គាល់ជាគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ និង ដែលទទួលបាននូវការលើកទឹកចិត្តជាលាយលក្ខណ៍អក្សរពីក្រុមប្រឹក្សា អាចបន្តទទួលការលើកទឹកចិត្តលើកលែងពន្ធលើប្រាក់ចំណេញ ពន្ធគយលើការនាំចូលសម្ភារៈបរិក្ខារផលិតកម្ម សម្ភារៈសាងសង់ និងធាតុចូលផលិតកម្មបានទៀត លុះត្រាតែអ្នកវិនិយោគនោះ បានបំពេញត្រឹមត្រូវនូវកាតព្វកិច្ចទាំងឡាយ ដូចមានចែងក្នុង ជំពូកទី ៦ នៃអនុក្រឹត្យនេះ។

## ជំពូកទី ១១

## អវសានប្បញ្ញត្តិ

### មាត្រា ២៤: និរាករណ៍

អនុក្រឹត្យលេខ ៨៨ អនក្រ/បក ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីការអនុវត្តច្បាប់វិនិយោគនៃព្រះរាជាណាចក្រកម្ពុជា អនុក្រឹត្យវិសោធនកម្ម លេខ ៥៣ អនក្រ.បក ចុះថ្ងៃទី ១១ ខែមិថុនា ឆ្នាំ ១៩៩៩ ស្តីពីការធ្វើវិសោធនកម្មលើអនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា អនុក្រឹត្យលេខ ១៣០ អនក្រ.បក ចុះថ្ងៃ ទី ២៦ ខែ ធ្នូ ឆ្នាំ ២០០១ ស្តីពីការធ្វើវិសោធនកម្មលើអនុក្រឹត្យលេខ ៥៣ អនក្រ.បក ចុះថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ១៩៩៩ និង បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ២៥:**

រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា រដ្ឋមន្ត្រីគ្រប់ក្រសួង និង ប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធទាំងអស់ អភិបាលគ្រប់ខេត្ត ក្រុង ត្រូវទទួលអនុវត្ត អនុក្រឹត្យនេះតាមភារកិច្ចរៀង១ខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ ២០០៥

នាយករដ្ឋមន្ត្រី

*កន្លែងទទួល:*

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ដូចមាត្រា ២៥
- ឯកសារ-កាលប្បវត្តិ

## ឧបសម្ព័ន្ធទី ១

នៃអនុក្រឹត្យលេខ.១១១.អនក្រ.បក.ចុះថ្ងៃទី.២៧..ខែ.កញ្ញា.ឆ្នាំ ២០០៥ ស្តីពីការអនុវត្តច្បាប់ស្តីពីវិសោធនកម្ម
នៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា

### បញ្ជីអវិជ្ជមាន (មាត្រា ៦.១)

**ផ្នែកទី ១ : *សកម្មភាពវិនិយោគដែលហាមឃាត់ ដោយច្បាប់ និង អនុក្រឹត្យពាក់ព័ន្ធ***

១- ផលិតកម្ម កែច្នៃសារធាតុប្រព័ន្ធសរសៃប្រសាទ (Psychotropic Substances) និង សារធាតុ (Narcotic) ។

២- ផលិតកម្មគ្រឿងគីមីពុល ថ្នាំពុលកសិកម្ម និង ទំនិញផ្សេងទៀត តាមរយៈការប្រើប្រាស់ សារធាតុគីមី ដែលហាមឃាត់ ដោយបទប្បញ្ញត្តិអន្តរជាតិនានា ឬ អង្គការសុខភាពពិភពលោក ដែលធ្វើឱ្យប៉ះពាល់ដល់សុខភាពសាធារណៈ និង បរិស្ថាន ។

៣- ការកែច្នៃ ការផលិតអគ្គិសនី ដោយប្រើប្រាស់ កាកសំណល់គ្រប់ប្រភេទ ដែលនាំចូលពីបរទេស ។

៤- ការធ្វើអាជីវកម្ម ព្រៃឈើ ដែលច្បាប់ស្តីពីព្រៃឈើហាមឃាត់ ។

៥- សកម្មភាពវិនិយោគផ្សេងៗទៀត ដែលច្បាប់ហាមឃាត់ ។

**ផ្នែកទី ២ : *សកម្មភាពវិនិយោគដែលមិនទទួលបាននូវការលើកទឹកចិត្ត***

១- សកម្មភាពពាណិជ្ជកម្ម អាហារីណ នីហារីណ លក់ដុំ លក់រាយ គ្រប់ប្រភេទ រួមទាំងហាងលក់ទំនិញរួចពន្ធ ។

២- សេវាកម្មដឹកជញ្ជូនគ្រប់ប្រភេទ ទាំងផ្លូវទឹក ផ្លូវគោក និងផ្លូវអាកាស លើកលែងតែការវិនិយោគផ្នែករថភ្លើង ។

៣- ភោជនីយដ្ឋាន ការ៉ាអូខេ រង្គសាល បារីយដ្ឋាន កន្លែងធ្វើសរសៃ កន្លែងហាត់កីឡា ដែលស្ថិតនៅក្រៅបរិវេណសណ្ឋាគារ ខ្នាតអន្តរជាតិ ។ ប៉ុន្តែ ទោះបីស្ថិតនៅក្នុងបរិវេណសណ្ឋាគារខ្នាតអន្តរជាតិក៏ដោយ ប្រសិនបើអ្នកវិនិយោគបានយកទីតាំងខាងលើនោះ ជួលបន្តឱ្យតតិយជនធ្វើអាជីវកម្ម អ្នកជួលដែលមិនមែនជាគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់នឹងមិនទទួលបាននូវការលើកលែងពន្ធលើប្រាក់ចំណេញ ដែលសម្រាប់ផ្តល់ដល់អ្នកវិនិយោគ ស្របតាមច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីវិនិយោគនោះឡើយ ។

៤- សេវាកម្ម ការិទេសចរណ៍ ភ្នាក់ងារទេសចរណ៍ ព័ត៌មាន និង ផ្សព្វផ្សាយទេសចរណ៍ ។

៥- អាជីវកម្ម សេវាកម្ម និង អាជីវកម្ម កាស៊ីណូ និង ល្បែងស៊ីសង គ្រប់ប្រភេទ ។

៦- សេវាកម្ម និង អាជីវកម្ម រូបិយវត្ថុ និង ហិរញ្ញវត្ថុ រួមមាន ធនាគារ ស្ថាប័នហិរញ្ញវត្ថុ ក្រុមហ៊ុនធានារ៉ាប់រង និង ប្រតិបត្តិការ ហិរញ្ញវត្ថុអន្តរការីយកម្ម គ្រប់ប្រភេទ ។

៧- សកម្មភាពដែលទាក់ទងទៅនឹង សារព័ត៌មាន និងប្រព័ន្ធឃោសនា មានជាអាទិ៍ វិទ្យុ ទូរទស្សន៍ កាសែត ទស្សនាវដ្តី ភាពយន្ត ផលិត ឬថតចម្លងវីដេអូ ល្ខោន ស្ទូឌីយោថត និង សកម្មភាពពាក់ព័ន្ធ ។

៨- សេវាកម្មវិជ្ជាជីវៈ ។

៩- សារពាង្គកាយកែច្នៃរស់ (LMOs) ដែលបង្កឱ្យមានគ្រោះថ្នាក់ដល់ជីវចំរុះ សុខភាពមនុស្ស និង បរិស្ថាន ។

១០- ការផលិត ឬការកែច្នៃផលិតផលឈើ ដែលប្រើប្រាស់ឈើមូលពីព្រៃឈើធម្មជាតិមានប្រភពផ្គត់ផ្គង់ស្របច្បាប់ក្នុងស្រុកជាវត្ថុធាតុដើម។

១១- ការផលិត ផលិតផលពីថ្នាំជក់គ្រប់ប្រភេទ។

១២- ការផលិត ផលិតផលម្ហូបអាហារ និង ភេសជ្ជៈ ដែលមានទុនវិនិយោគសមមូលទាបជាង ៥០០.០០០ (ប្រាំរយពាន់) ដុល្លារអាមេរិក។

១៣- ការផលិត ផលិតផលសម្រាប់រោងចក្រវាយនភ័ណ្ឌ ដែលមានទុនវិនិយោគសមមូលទាបជាង ៥០០.០០០ (ប្រាំរយពាន់) ដុល្លារអាមេរិក។

១៤- ការផលិត សំលៀកបំពាក់ វាយនភ័ណ្ឌ ស្បែកជើង មួក ដែលមានទុនវិនិយោគសមមូលទាបជាង ៥០០.០០០ (ប្រាំរយពាន់) ដុល្លារអាមេរិក។

១៥- ការផលិត គ្រឿងសង្ហារឹម និង គ្រឿងតាំងភ្ជាប់ មិនប្រើប្រាស់ឈើធម្មជាតិ ដែលមានទុនវិនិយោគសមមូលទាបជាង ៥០០.០០០ (ប្រាំរយពាន់) ដុល្លារអាមេរិក។

១៦- ការផលិត ក្រដាស និងផលិតផលធ្វើពីក្រដាស ដែលមានទុនវិនិយោគសមមូលទាបជាង ៥០០.០០០ (ប្រាំរយពាន់) ដុល្លារអាមេរិក។

១៧- ការផលិត ធាតុគីមី ស៊ីម៉ងត៍ ជីកសិកម្ម គីមីកែច្នៃពីប្រេងកាត ដែលមានទុនវិនិយោគសមមូលទាបជាង ១.០០០.០០០ (មួយលាន) ដុល្លារអាមេរិក។

១៨- ការផលិត ផលិតផលពីកៅស៊ូ និង ផលិតផលធ្វើពីជ័រប្លាស្ទិក ដែលមានទុនវិនិយោគសមមូលទាបជាង ៥០០.០០០ (ប្រាំរយពាន់) ដុល្លារអាមេរិក។

១៩- ការផលិត ផលិតផលស្បែក និង ផលិតផលពាក់ព័ន្ធផ្សេងៗទៀត ដែលមានទុនវិនិយោគសមមូលទាបជាង ៣០០.០០០ (បីរយពាន់) ដុល្លារអាមេរិក។

២០- ការផលិត ផលិតផលធ្វើពីលោហៈគ្រប់ប្រភេទ ដែលមានទុនវិនិយោគសមមូលទាបជាង ៣០០.០០០ (បីរយពាន់) ដុល្លារអាមេរិក។

២១- ការផលិត សម្ភារៈបរិក្ខារអគ្គិសនី និង អេឡិចត្រូនិច និងសម្ភារៈការិយាល័យ ដែលមានទុនវិនិយោគសមមូលទាបជាង ៣០០.០០០ (បីរយពាន់) ដុល្លារអាមេរិក។

២២- ការផលិត ប្រដាប់ក្មេងលេង និង សម្ភារៈកីឡា ដែលមានទុនវិនិយោគសមមូលទាបជាង ៣០០.០០០ (បីរយពាន់) ដុល្លារអាមេរិក។

២៣- ការផលិត បំណែកយានយន្ត និង គ្រឿងបន្លាស់យានយន្ត ដែលមានទុនវិនិយោគសមមូលទាបជាង ៣០០.០០០ (បីរយពាន់) ដុល្លារអាមេរិក។

២៤- ការផ្គត់ផ្គង់ទឹកស្អាត ដែលមានទុនវិនិយោគសមមូលទាបជាង ៥០០.០០០ (ប្រាំរយពាន់) ដុល្លារអាមេរិក។

២៥- ឧស្សាហកម្មគាំទ្រដែលផលិតផល ១០០ (មួយរយ) ភាគរយ ផ្គត់ផ្គង់ឱ្យឧស្សាហកម្មនាំចេញ ដែលមានទុនវិនិយោគសមមូលទាបជាង ១០០.០០០ (មួយរយពាន់) ដុល្លារអាមេរិក។

២៦- មជ្ឈមណ្ឌលតាំងពិពណ៌ពាណិជ្ជកម្មអន្តរជាតិ និងសាលសន្និសីទ ដែលមានទុនវិនិយោគសមមូលទាបជាង ៨.០០០.០០០ (ប្រាំបីលាន) ដុល្លារអាមេរិក។

២៧- ការសាងសង់ផ្សារទំនើប ឬ មជ្ឈមណ្ឌលពាណិជ្ជកម្ម ដែលមានទុនវិនិយោគសមមូលទាបជាង ២.០០០.០០០ (ពីរលាន) ដុល្លារអាមេរិក មានទំហំតិចជាង ១០.០០០ (ដប់ពាន់) ម៉ែត្រក្រឡា និងមិនមានកន្លែងចតរថយន្តគ្រប់គ្រាន់។

២៨- ការផលិត ចំណីសត្វ ដែលមានទុនវិនិយោគសមមូលទាបជាង ២០០.០០០ (ពីររយពាន់) ដុល្លារអាមេរិក។

២៩- ការផលិត សម្ភារៈធ្វើពីកុលាលភាជន៍ ដែលមានទុនវិនិយោគសមមូលទាបជាង ៣០០.០០០ (បីរយពាន់) ដុល្លារអាមេរិក។

៣០- វិទ្យាស្ថានបង្ហាត់បង្រៀន និងអប់រំ ដែលធ្វើការបំពាក់បំប៉នលើមុខជំនាញ បច្ចេកវិទ្យា ឬ ពហុបច្ចេកទេស បំរើឱ្យវិស័យឧស្សាហកម្ម កសិកម្ម ទេសចរណ៍ ហេដ្ឋារចនាសម្ព័ន្ធ បរិស្ថាន វិស្វកម្ម វិទ្យាសាស្ត្រ និង សេវាកម្មផ្សេងទៀត ដែលមានទុនវិនិយោគសមមូលទាបជាង ៤.០០០.០០០ (បួនលាន) ដុល្លារអាមេរិក។

៣១- សណ្ឋាគារក្រោមកម្រិតផ្កាយ ៣ (បី)។

៣២- មជ្ឈមណ្ឌលទេសចរណ៍ ដែលមានសណ្ឋាគារមានបន្ទប់តិចជាង ១០០ (មួយរយ) បន្ទប់ ឬ មានសណ្ឋាគារបែបលំនៅដ្ឋាន តិចជាង ៣០ (សាមសិប) លំនៅដ្ឋាន និងមានរមណីយដ្ឋានដែលមានសេវាកម្មចម្រុះ ដែលមានទំហំតិចជាង ១០ (ដប់) ហិកតា។

៣៣- ទេសចរណ៍ធម្មជាតិ និង ការបង្កើតតំបន់ទេសចរណ៍ធម្មជាតិ ដែលមានផ្ទៃដីតិចជាង ១.០០០ (មួយពាន់) ហិកតា និងមានទុនវិនិយោគសមមូលទាបជាង ១.០០០.០០០ (មួយលាន) ដុល្លារអាមេរិក។

៣៤- រមណីយដ្ឋានដែលមានសេវាកម្មចម្រុះ រួមមាន សណ្ឋាគារ សួនកំសាន្ត កន្លែងហាត់កីឡា សួនសត្វ ដែលមានទំហំតិចជាង ៥០ (ហាសិប) ហិកតា។

៣៥- ចំណតរថយន្ត។

៣៦- មណ្ឌលឃ្លាំងទំនិញ។

៣៧- មន្ទីរពហុព្យាបាលជម្ងឺ ដែលមានគ្រែតិចជាង ៥០ (ហាសិប)គ្រែ មិនមានការបំពាក់នូវឧបករណ៍ទំនើប បន្ទប់ពិសោធន៍ បន្ទប់វះកាត់ បន្ទប់កាំរស្មីអ៊ិច បន្ទប់សង្គ្រោះបន្ទាន់ ឱសថស្ថាន ជណ្តើរយន្ត (ក្នុងករណីមានអាគារលើសពី ៣ (បី) ជាន់) រថយន្តសង្គ្រោះបន្ទាន់ សាលដាក់ដំកល់សព និងដែលមានទុនវិនិយោគសមមូលទាបជាង ១.០០០.០០០ (មួយលាន) ដុល្លារអាមេរិក។

៣៨- ផលិតកម្មឱសថសម័យ ដែលមានទុនវិនិយោគសមមូលទាបជាង ១.០០០.០០០ (មួយលាន) ដុល្លារអាមេរិក។

៣៩- ផលិតកម្មឱសថបូរាណ ដែលមានទុនវិនិយោគសមមូលទាបជាង ៥០០.០០០ (ប្រាំរយពាន់) ដុល្លារអាមេរិក។

៤០- ផលិតកម្មកសិកម្ម

| | | |
|---|---|---|
| ៤០.១ | ដំណាំស្រូវ | តិចជាង ១.០០០ (មួយពាន់) ហិកតា។ |
| ៤០.២ | ដំណាំរូបីយវត្ថុគ្រប់ប្រភេទ | តិចជាង ៥០០ (ប្រាំរយ) ហិកតា។ |
| ៤០.៣ | បន្លែ | តិចជាង ៥០ (ហាសិប) ហិកតា។ |

៤១- ផលិតកម្មបសុសត្វ

| | | |
|---|---|---|
| ៤១.១ | ការចិញ្ចឹមសត្វចតុបាត | តិចជាង ១.០០០ (មួយពាន់) ក្បាល។ |

៤១.២ កសិដ្ឋានចិញ្ចឹមគោយកទឹកដោះ តិចជាង ១០០ (មួយរយ) ក្បាល ។

៤១.៣ កសិដ្ឋានចិញ្ចឹម បសុបក្សីយកសាច់ និង ស៊ុត តិចជាង ១០.០០០ (ដប់ពាន់) ក្បាល ។

៤២- ផលិតកម្មជលផល

៤២.១ កសិដ្ឋានវារីវប្បកម្ម ទឹកសាប តិចជាង ៥ (ប្រាំ) ហិកតា ។

៤២.២ កសិដ្ឋានវារីវប្បកម្ម សមុទ្រ តិចជាង ១០ (ដប់) ហិកតា ។

៤៣- ការដាំឈើ រុក្ខជាតិ និង ការចិញ្ចឹមសត្វព្រៃផ្សេងៗ ÷

៤៣.១ ការដាំដើមឈើ តិចជាង ១.០០០ (មួយពាន់) ហិកតា ។

៤៣.២ ការដាំរុក្ខជាតិផ្សេងៗ តិចជាង ២០០ (ពីររយ) ហិកតា ។

៤៣.៣ ការចិញ្ចឹមថនិកសត្វព្រៃ តិចជាង ១០០ (មួយរយ) ក្បាល ។

៤៣.៤ ការចិញ្ចឹមបក្សីព្រៃ តិចជាង ៥០០ (ប្រាំរយ) ក្បាល ។

៤៣.៥ ការចិញ្ចឹមឧរង្គសត្វព្រៃ តិចជាង ១.០០០ (មួយពាន់) ក្បាល ។

និយមន័យនៃចំណុច ៤៣ ខាងលើ នឹងកំណត់ដោយប្រកាសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ។

៤៤- ការបង្កក និង ការកែច្នៃនាំចេញ នូវជលផល និង កសិផល ÷

៤៤.១ ការកែច្នៃ និង បង្កកផលិតផលជលផល សំរាប់នាំចេញ ដែលមានទុនវិនិយោគសមមូលទាបជាង ៥០០.០០០ (ប្រាំរយពាន់) ដុល្លារអាមេរិក ។

៤៤.២ ការកែច្នៃកសិផលគ្រប់ប្រភេទ ដើម្បីនាំចេញ ដែលមានទុនវិនិយោគសមមូលទាបជាង ៥០០.០០០ (ប្រាំរយពាន់) ដុល្លារអាមេរិក ។

៤៥- ការផ្គត់ផ្គង់សេវាតម្លៃបន្ថែម នៃវិស័យសេវាទូរគមនាគមន៍គ្រប់ប្រភេទ ។

៤៦-ការអភិវឌ្ឍន៍ផ្នែកអចលនវត្ថុ។

<u>ផ្នែកទី ៣ : *សកម្មភាពវិនិយោគដែលមានលក្ខណៈពិសេស ហើយដែលត្រូវទទួលការលើកទឹកចិត្តផ្នែកពន្ធគយលើការនាំចូល តែមិនទទួលបានការលើកទឹកចិត្តផ្នែកពន្ធលើប្រាក់ចំណេញ :*</u>

១- សេវាទូរគមនាគមន៍មូលដ្ឋាន។

២- សិក្សាស្រាវជ្រាវ ឧស្ម័ន ប្រេងកាត និងរ៉ែគ្រប់ប្រភេទ រួមទាំងមូលដ្ឋានផ្គត់ផ្គង់សំរាប់ឧស្ម័ន និងប្រេងកាត។

## ឧបសម្ព័ន្ធទី ២

នៃអនុក្រឹត្យលេខ១១១ អនក.បក ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ ២០០៥ ស្តីពីការអនុវត្តច្បាប់ស្តីពីវិសោធនកម្ម

នៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា

## ពាក្យស្នើវិនិយោគនៅព្រះរាជាណាចក្រកម្ពុជា (មាត្រា ៥.២)

I- **ចេនាសម្ព័ន្ធក្រុមហ៊ុន** :

*ក.ព័ត៌មានទូទៅ*

- ឈ្មោះ បុគ្គល មានរូបវ័ន្ត ឬ នីតិបុគ្គល) :..........................................................................

- អាស័យដ្ឋាន: -ទីស្នាក់ការបុគ្គល :..........................................................Tel:....................

Fax:......................................E-mail:......................................................

-ឈ្មោះបុគ្គលមេ :..........................................អាស័យដ្ឋាន..........................................

.....................................................Tel:..................................Fax:.....................

Website:..........................................E-mail:..........................................................

- ទ្រង់ទ្រាយក្រុមហ៊ុន : (*សូមគូស ✓ ក្នុងប្រអប់*☐ )

☐ ក្រុមហ៊ុនមូលធន (Corporation) ☐ ក្រុមហ៊ុនសហកម្មសិទ្ធិ (Partnership)

☐ ក្រុមហ៊ុនពាណិជ្ជកម្មបរទេស (Foreign Company)

*កំណត់សម្គាល់* : ក្រុមហ៊ុនមូលធនរួមមាន : ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត និងក្រុមហ៊ុនឯកបុគ្គលទទួលខុសត្រូវមានកម្រិត (Single Member Private Limited Company)

- ទុនចុះបញ្ជី..........................................................បរទេស...........% ក្នុងស្រុក................%

- លិខិតបញ្ជាក់ប្រាក់តម្កល់នៅធនាគារ ២៥%លេខ.........................................

*ខ.សមាសភាពក្រុមហ៊ុន*

ម្ចាស់ភាគហ៊ុន

| នាមត្រកូល និងនាមខ្លួន | សញ្ជាតិ | លេខ និងកាលបរិច្ឆេទអត្តសញ្ញាណប័ណ្ណ ឬ លិខិតឆ្លងដែន | អាស័យដ្ឋាន | អត្រាភាគហ៊ុន% |
|---|---|---|---|---|
| ១........................<br>២........................<br>៣........................<br>៤........................ | | | | |

សមាសភាពក្រុមប្រឹក្សាភិបាល (រួមទាំងគតិយជន)

| នាមត្រកូល និងនាមខ្លួន | សញ្ជាតិ | លេខ និងកាលបរិច្ឆេទ អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន | អាស័យដ្ឋាន | តួនាទីក្នុងក្រុមហ៊ុន | អ្នកដែលមានសិទ្ធិចុះហត្ថលេខា សម្រាប់កិច្ចការ |
|---|---|---|---|---|---|
| ១........................<br>២........................<br>៣........................ | | | | | |

## II- ពាក្យស្នើសុំវិនិយោគ :

### ក. ព័ត៌មានទូទៅ

- សកម្មភាពវិនិយោគ : ..................................................................................................................................

- វិស័យវិនិយោគ : ( *សូមគូស ✓ ក្នុងប្រអប់* ☐ )

☐ កសិកម្ម-កសិ-ឧស្សាហកម្ម ☐សំណង់ស៊ីវិល ☐ ថាមពល ☐ ហិរញ្ញវត្ថុ ☐ ឧស្សាហកម្ម ☐ ធនធានរ៉ែ
☐ ទេសចរណ៍ ☐ ដឹកជញ្ជូន ☐ទូរគមនាគមន៍ ☐ ទឹកស្អាត ☐ តំបន់ឧស្សាហកម្ម ☐ផ្សេងៗ

- អ្នកដាក់ពាក្យសុំ :
  - ឈ្មោះ.........................................អាស័យដ្ឋាន :........................................................................
  - តួនាទីក្នុងក្រុមហ៊ុន : ...........................................Tel :.................................Fax : .......................
  - លិខិតប្រគល់សិទ្ធិ ( *បើសិនមិនមានតួនាទីក្នុងក្រុមហ៊ុន* ): លេខ ............... ចុះថ្ងៃទី.........ខែ.........ឆ្នាំ............

- ទុនវិនិយោគសរុប : ...............................................ក្នុងនោះទុនលើ :
  - សំណង់អាគារ/រៀបចំការដ្ឋាន .......................ម$^{២}$ តម្លៃ:...........................USD អាគារមានស្រាប់ ☐ អាគារថ្មី ☐
  - សម្ភារៈបរិក្ខាផលិតកម្ម ( គ្រឿងចក្រ-គ្រឿងម៉ាស៊ីនផលិតកម្ម-សម្ភារៈបរិក្ខាផ្សេងៗ) តម្លៃ(USD) :...........................
    ( មានបញ្ជីជូនភ្ជាប់ តាមទម្រង់ដូចមានចែងក្នុងឧបសម្ព័ន្ធ )
  - សម្ភារៈការិយាល័យតម្លៃ (USD) :..................................................................................................
  - ផ្សេងៗតម្លៃ (USD) : ...................................................................................................................

- ដីធ្លី ( ទំហំ ម$^{២}$ ) : ...............................................................តម្លៃ ...............................USD

- ប្រភពទុនវិនិយោគ : ទុនផ្ទាល់:.................................ឥណទានធនាគាររយៈពេលវែង :............................
ឥណទានធនាគាររយៈពេលខ្លី :............................................

- ទីតាំងវិនិយោគ : ដីឡូត៍លេខ..................ផ្លូវលេខ.......................ភូមិ :.......................ឃុំ សង្កាត់ :............................
ស្រុក/ខណ្ឌ :...............................ខេត្ត ក្រុង :..............................ទំហំ :................................ម$^{២}$

- កម្មវិធីអនុវត្តគម្រោង :
  - ចាប់ផ្តើមសាងសង់ : .................................. ព្យាករណ៍បញ្ចប់ការសាងសង់.......................................
  - ពេលបំពាក់គ្រឿងម៉ាស៊ីន :............................. ចាប់ផ្តើមដំណើរការផលិតកម្ម.......................................

- ព័ត៌មានស្តីពីផលិតផល :

| ប្រភេទផលិតផល | ឯកតា | សមត្ថភាពផលិតប្រចាំឆ្នាំ | | | | ទីផ្សារ | |
|---|---|---|---|---|---|---|---|
| | | ឆ្នាំដំបូង | | ពេញផលិតកម្ម | | ក្នុងស្រុក គិតជា % | នាំចេញ គិតជា % |
| | | បរិមាណ | តម្លៃ | បរិមាណ | តម្លៃ | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |

-តម្រូវការពលកម្ម

| ប្រភេទពលកម្ម | ពេលចាប់ផ្តើម | | ពេលពេញសមត្ថភាព | |
|---|---|---|---|---|
| | ក្នុងស្រុក | បរទេស | ក្នុងស្រុក | បរទេស |
| - អ្នកគ្រប់គ្រង | | | | |
| - វិស្វករ | | | | |
| - អ្នកបច្ចេកទេស | | | | |
| - ទីប្រឹក្សា | | | | |
| - បុគ្គលិកការិយាល័យ | | | | |
| - កម្មករជំនាញ | | | | |
| - កម្មករគ្មានជំនាញ | | | | |
| សរុប | | | | |

- តម្រូវការធាតុចូលផលិតកម្ម (វត្ថុធាតុដើម) ប្រចាំឆ្នាំ : *បំពេញតាមទម្រង់ដូចមានចែងក្នុងឧបសម្ព័ន្ធភ្ជាប់មកជាមួយ*

- តម្រូវការថាមពល និង ទឹក :

- ធ្យូងថ្ម ឬអុសប្រចាំឆ្នាំ :.................................ម$^{៣}$/ឆ្នាំ, ឧស្ម័ន:.................................តោន/ឆ្នាំ
- ប្រេងឥន្ធនៈ :.................................................តោន ឬលីត្រ/ឆ្នាំ
- អគ្គិសនី (អនុភាពតម្លើង) :...........................MW តម្រូវការប្រចាំឆ្នាំ :..............................KWH
- ប្រើប្រាស់ទឹក :..............................................ម$^{៣}$/ឆ្នាំ

*ខ.__ការជ្រើសរើសរបាង__*: □ ការលើកលែងពន្ធលើប្រាក់ចំណេញ និងការធានាលើការវិនិយោគ

□ ការរំលោះពិសេស និង ការធានាលើការវិនិយោគ

□ ការធានាលើការវិនិយោគ (មិនទាមទារការលើកទឹកចិត្ត)

*(ក្នុងចំណោមជម្រើសទាំងបីនេះ អ្នកវិនិយោគមានសិទ្ធិទទួលបានតែមួយប៉ុណ្ណោះ)*

*គ.__ព័ត៌មានស្តីពីបរិស្ថាន__*:

- រូបភាពនៃការដឹកជញ្ជូនវត្ថុធាតុដើម និងផលិតផលសម្រេចចេញ-ចូល ទីតាំងវិនិយោគ :

........................................................................................................................................

........................................................................................................................................

........................................................................................................................................

.........................................................................................ប៉ាន់ស្មានបរិមាណ :

សំណល់រាវ :............................ ម$^{៣}$/ខែ សំណល់រឹង :......................ម$^{៣}$ ឬ តោន/ ខែ

ឧស្ម័នដែលត្រូវបញ្ចេញ : ............................................................/ ថ្ងៃ

- តារាងប៉ាន់ស្មាននៃកំហាប់ក្នុង :

*ដំណើរការបញ្ចេញទឹកស្អុយ*

- pH:........................................................................ - អាម៉ូញាក់ Ammonia ($NH_3$)..............................................
- នីត្រាតអាសូត Nitrate Nitrogen.............................. - លោហៈធ្ងន់ Heavy Metal..............................................
- ផេណុល Phenol ($C_6H_5OH$)................................ - ប្រេង និងខ្លាញ់ Oil and Grease..............................................
- ភាពល្អក់ Turbidity................................................ - ភាពចម្លងអគ្គិសនី Conductivity..............................................
- ចំនួនសរុបនៃសារធាតុរឹងដែលរលាយក្នុងទឹក ..............................................................................................
- ចំនួនសរុបនៃសារធាតុរឹងដែលរងកករចុះទៅក្នុងទឹក..............................................................................................

*ការបំភាយភាគល្អិតតូចៗនៃឧស្ម័នក្នុងខ្យល់*

- កាបូនម៉ូណូអុកស៊ីត Carbon mono-oxide.................................. - អាសូតឌីអុកស៊ីត Nitrogen dioxide.......................
- អុកស៊ីតស៊ុលហ្វួរិច Sulfur Oxide.................................................. - អូហ្សូន Ozone..............................................
- សំណរ Lead..............................................................................

- ទីតាំងដែលប្រើសម្រាប់បោះបង់សំណល់រឹង បង្ហូរសំណល់រាវ និងការបញ្ចេញឧស្ម័ន

......................................................................................................................................................
......................................................................................................................................................
......................................................................................................................................................
..................................................................................

- ប្រភពដែលមានសម្លេង និងភាពរំញ័រខ្ពស់កើនឡើង

......................................................................................................................................................
......................................................................................................................................................
......................................................................................................................................................
..................................................................................

- ទំហំផ្ទៃដីដែលនឹងគ្របដណ្តប់ សម្លេងករណីចាក់ដីបំពេញ-ការឈូសឆាយ និងការរានដីថ្មី

......................................................................................................................................................
......................................................................................................................................................
......................................................................................................................................................
..................................................................................

- ស្ថានភាពស្នាក់នៅរបស់បុគ្គលិក-កម្មករ

- ផ្គត់ផ្គង់ទឹកស្អាត :..............................................................................................
- សុខភាព-សុវត្ថិភាព :..............................................................................................
- អនាម័យ :..............................................................................................
- ការគ្រប់គ្រងសំណល់រឹង :..............................................................................................



*ឃ.ព័ត៌មានស្តីពីពន្ធដារ*

បំពេញតាមទម្រង់បែបបទ ( Form ) ដូចមានឧបសម្ព័ន្ធជូនភ្ជាប់។

*ង.ព័ត៌មានស្តីពីលក្ខន្តិកៈ*

ជូនភ្ជាប់មកជាមួយនូវលក្ខន្តិកៈរបស់ក្រុមហ៊ុន រូបថត លិខិតថតចម្លងលិខិតឆ្លងដែន ឬ អត្តសញ្ញាណប័ណ្ណ របស់ម្ចាស់ភាគហ៊ុននិមួយ១។

III- ការធានា : ក្នុងនាមម្ចាស់គម្រោងសូមធានាអះអាងថា

- គម្រោងនេះមិនស្ថិតក្នុងបញ្ជីអវិជ្ជមាន ដូចមានចែងក្នុងឧបសម្ព័ន្ធទី ១ ផ្នែកទី១ នៃអនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជាទេ។
- ព័ត៌មានខាងលើនេះ គឺពិតជាត្រឹមត្រូវ ដោយមិនមានចេតនាក្លែងបន្លំឡើយ ។

ធ្វើនៅ............ថ្ងៃទី.........ខែ ...............ឆ្នាំ...............

ហត្ថលេខា

## ឧបសម្ព័ន្ធទី ២-១

នៃអនុក្រឹត្យលេខ ១១១ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ កញ្ញា ....ឆ្នាំ ២០០៥

ស្ដីពីការអនុវត្តច្បាប់ស្ដីពីវិសោធនកម្មនៃច្បាប់ស្ដីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា

### តារាងតម្រូវការសម្ភារៈបរិក្ខារផលិតកម្ម

សម្រាប់គម្រោងវិនិយោគ.......................................................................................

| ល.រ | រាយមុខទំនិញ | ឯកតា | បរិមាណ | តម្លៃឯកត្តា (USD) | តម្លៃសរុប (USD) | ប្រភព | |
|---|---|---|---|---|---|---|---|
| | | | | | | ក្នុងស្រុក | នាំចូល |
| | 1 | 2 | 3 | 4 | 5 | 6 | 7 |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | សរុប | | | | | | |

**ឧបសម្ព័ន្ធទី ២-២**

នៃអនុក្រឹត្យលេខ១១១.អនក្រ.បក.ចុះថ្ងៃទី២៧ ខែកញ្ញា....ឆ្នាំ ២០០៥

ស្តីពីការអនុវត្តច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា

## តារាងតម្រូវការធាតុចូលផលិតកម្ម

សម្រាប់គម្រោងវិនិយោគ.............................................................................

| ល.រ | រាយមុខទំនិញ | ឯកតា | តម្លៃឯកតា (USD) | តម្រូវការប្រចាំឆ្នាំ | | | | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|
| | | | | ក្នុងស្រុក | | នាំចូល | | |
| | | | | បរិមាណ | តម្លៃសរុប (USD) | បរិមាណ | តម្លៃសរុប (USD) | |
| | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | សរុប | | | | | | | |

## ឧបសម្ព័ន្ធទី ៣

នៃអនុក្រឹត្យលេខ១១១.អនក្រ.បក.ចុះថ្ងៃទី២៧.ខែកញ្ញា....ឆ្នាំ ២០០៥ ស្តីពីការអនុវត្តច្បាប់ស្តីពីវិសោធនកម្ម
នៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា

(មាត្រា ៦.៣)

បញ្ជីមានលក្ខខណ្ឌ នៃគម្រោងវិនិយោគ អនុលោមទៅតាមច្បាប់ស្តីពីវិនិយោគ និង អនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា

ឈ្មោះ អ្នកវិនិយោគ :..........................................................................................

អាស័យដ្ឋាន នៃអ្នកវិនិយោគ :..........................................................................................

ការរាយលម្អិតអំពីគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់

..........................................................................................

..........................................................................................

ឈ្មោះ អាស័យដ្ឋាន និង លេខទំនាក់ទំនងលម្អិត របស់បុគ្គលតំណាងអ្នកវិនិយោគនៅកម្ពុជា..........................................

..........................................................................................

លិខិតយល់ព្រម ការអនុញ្ញាត អាជ្ញាប័ណ្ណ លិខិតអនុញ្ញាត ឬ ការចុះបញ្ជីដែលជាតម្រូវការ សម្រាប់ឱ្យគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ មានលក្ខណៈស្របច្បាប់ក្នុងការអនុវត្តន៍ និងក្រសួង នាយកដ្ឋាន អាជ្ញាធរ ឬភ្នាក់ងាររាជរដ្ឋាភិបាល ដែលទទួលបន្ទុកចេញលិខិតទាំងនេះ នៅពេលអ្នកដាក់ពាក្យសុំបានបំពេញស្របតាមលក្ខណៈវិនិច្ឆ័យនៃសមត្ថកិច្ចពាក់ព័ន្ធ។

ការអនុម័ត....... ក្រសួង លក្ខណៈវិនិច្ឆ័យ

ជម្រើសរបស់អ្នកវិនិយោគផ្អែកតាមមាត្រា ៩.៥ នៃអនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ..........................................................................................

ជម្រើសរបស់អ្នកវិនិយោគផ្អែកតាមមាត្រា ៩.៧ នៃអនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ..........................................................................................

ការលើកទឹកចិត្ត និងការធានាលើការវិនិយោគ ដែលអ្នកវិនិយោគមានសិទ្ធិទទួល ប្រសិនបើវិញ្ញាបនប័ត្រចុះបញ្ជីជាស្ថាពរត្រូវបានចេញជូន រួមទាំងរយៈពេលលើកលែងពន្ធលើប្រាក់ចំណេញ តាមមាត្រា ១៤.១ នៃច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ..........................................................................................

..........................................................................................

..........................................................................................

លក្ខន្តិកៈរបស់អ្នកវិនិយោគដែលនឹងដំណើរការគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់..........................

..........................................................................................




iisd International Institute for Sustainable Development
Institut international du développement durable

IIER Institute for International Economic Research


# Chinese Outward Investment: An emerging policy framework

*Editors: Nathalie Bernasconi-Osterwalder, Lise Johnson, and Jianping Zhang*

**A COMPILATION OF PRIMARY SOURCES**



5. *Five Measures Announced by the Chinese Government on the UN High-Level Meeting on Financing for Development* (September 2005)

1. China has decided to accord zero tariff treatment to some products from all the 39 least-developed countries (LDCs) having diplomatic relations with China, which covers most of the China-bound exports from these countries.
2. China will further expand its aid programs to the heavily-indebted poor countries (HIPCs) and LDCs, and through bilateral channels, write off or forgive in other ways, within the next two years, all the overdue parts as of the end of 2004 of the interest-free or low-interest governmental loans owed by all the HIPCs having diplomatic relations with China.
3. Within the next three years, China will provide US$10 billion in concessional loans and preferential export buyer's credit to other developing countries to improve their infrastructure and cooperation between enterprises on both sides.
4. China will, in the next three years, increase its assistance to other developing countries, African countries in particular, by providing them with anti-malaria drugs and other medicines, helping them set up and improve medical facilities and training medical staff. Specific programs will be implemented through such mechanisms as the Forum on China–Africa Cooperation as well as bilateral channels.
5. China will train 30,000 personnel of various professions from other developing countries within the next three years so as to help them speed up their human resources development.

7 *Nine Principles on Encouraging and Standardizing Outward Investment* (State Council,October 2006)

In order to seize economic globalization and regional cooperation opportunities, and encourage qualified enterprises to actively and steadily participate in international economic and technological cooperation, and to further enhance the level of opening up, the meeting stressed:

1. Insistence on mutual respect, equality, and mutual benefit, complementarity and win–win cooperation.
2. Strengthening of policy guidance, coordinating and standardizing orderly and rational distribution, preventing disorderly competition, and safeguarding national interests.

3. Improving the policy-making mechanism, the implementation of overseas investment enterprises, the autonomy of scientific studies and careful decision making, and prevention of investment and operational risks.

4. Strengthening supervision of state-owned assets overseas, and supervision of sound evaluation and examination systems, establishment of security risk assessment and project cost accounting systems, and preserving and increasing the value of assets.

5. Complying with local laws and regulations, and adhering to fair, transparent public works project contracts, making a commitment to and fulfilling the necessary social responsibility to protect the legitimate rights and interests of local employees, paying attention to environmental resource protection, caring for and supporting the local community and people's livelihood.

6. Increasing the level of offshore project building contracts, improving product quality and efficiency, and constantly enhancing overall competitiveness.

7. Strengthening safety training, improving safe production responsibility systems, increasing protection of foreign-funded enterprises, institutions and property safety.

8. Accelerating personnel training, paying attention to the cultivation of operating in the international talents, and enhance their transnational operations management capabilities.

9. Creating a friendly environment for public opinion, walking the road of peaceful development policy, and preserving our good image and a good corporate reputation.

## 10. *Twelfth Five-Year Plan, 2011–2015* (Chapters 52 & 53) (National People's Congress, March2011)

**Chapter 52: Coordinate "Bring in" and "Going Out"**

China will continue the combination of the strategies "bringing in" and "going out" and [will] pay equal attention to both foreign investment in China and Chinese investments abroad in order to increase safe and effective use of the two markets and their resources.

**Section One: Increasing the level of foreign capital usage**

China will optimize the structure of foreign capital, guide foreign investment to the sectors of modern agriculture, high-end technology, advanced manufacturing, energy conservation, new energy, modern service industry etc. and encourage foreign capital to be invested in the middle and western parts of

China. China will encourage foreign capital to use different means to take part in merger and acquisitions of domestic enterprises, such as buying shares, joint ventures etc. China will bring in senior talent and advanced technology from overseas, encourage foreign enterprises to set up R&D centres in China, learn advanced international management concepts and systems, actively integrate into the global innovation system, optimize the soft environment of investments and protect the legal rights of investors. China will conduct the National Security Review of foreign mergers and acquisitions in a [proper] manner. Favourable foreign lending and international commercial lending will be used effectively to optimize the management of foreign debt.

**Section Two: Speeding up the implementation of the [“Going Global”] strategy**

China will follow the strategy of market orientation and self-willingness of enterprises to guide enterprises with different ownership to develop overseas investment cooperation in an orderly manner. China will deepen the development of international energy resources and mutually beneficial processing cooperation. China will support the carrying out of technology R&D investment cooperation abroad and encourage leading enterprises in the manufacturing industry to conduct outward investment to create internationalized marketing and sales channels and famous brands. China will enlarge international cooperation in the agricultural sector and develop overseas project contracts, labour cooperation and cooperation projects that can improve living standards in local areas. China will gradually develop its own large cross-country corporations and cross country financial institutions to increase China’s level of international operations. China will conduct research for overseas investment environments and enhance scientific evaluation of investment projects. China will increase its ability of comprehensive all-around consideration, optimize the cross-agency coordination system, and enhance the guidance and services to enforce the [“Going Global”] strategy. The formulation of laws and regulations concerning overseas investments will be speeded up and optimised. China will actively discuss and sign mutual agreements on investment protection and agreements to avoid double taxation as well as other multilateral or bilateral agreements. China’s overseas investment promotional system will be improved to increase the level of investment facilitation for enterprises to invest overseas and to protect the overseas rights of China and to avoid different kinds of risks. The enterprises that are “going out” and their overseas cooperation projects should bear corporate social responsibility in mind in order to bring benefits to the local people.

**Chapter 53: Actively participate in global economic governance and regional cooperation**

China is to expand exchange and cooperation with developed countries to obtain an increase of mutual trust and a higher level of cooperation. In order to maintain peace and stability and to promote prosperity and development in the region, friendly relationships and pragmatic cooperation with neighbouring countries will be deepened. China will strengthen unity and cooperation with developing countries, deepen traditional friendships, and maintain common interest. Multilateral cooperation will be [actively] developed. China will push for a reform of the international economic system and [encourage] the international economic order to develop in a more fair and reasonable direction. China will [actively] participate in the G20’s global economic governance mechanism in order to promote and build a balanced, commonly beneficial “win–win” situation of the multilateral trade system. China will work against all kinds of protectionism. Furthermore, China will actively promote a reform of the international financial system and [rationalization of] the international currency system. Coordination with the major economic bodies’ macroeconomic policies will be strengthened. Finally, China will actively take part in the drafting and amending of the international regulations and standards to increase its influence in international economic and financial organizations. China will speed up the formulation of Free Trade Zones, further enhance the economic relations between China and its major trading partners, and deepen the pragmatic cooperation with both emerging market countries and developing countries. China should use APEC, as well as other international or sub-regional cooperation mechanisms, and enhance regional cooperation with other countries and regions. South–South cooperation should be enhanced. China will optimize the foreign aid structure, innovate the manner of providing foreign aid, increase economic and technology aid in the areas such as people’s livelihood and welfare projects in developing countries, social public facility, and self-development capacity building. The organic unity of adherence to leadership by the Party, ensuring that the people are masters of the country and governing the country according to law must be upheld, while developing socialist democracy, accelerating the building of a socialist country under the rule of law.

# ឯកសារយោង

# ឯកសារយោង


រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣។

ច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ៥ ខែសីហា ឆ្នាំ ១៩៩៤។

ច្បាប់ស្តីពីវិសោធនកម្មច្បាប់វិនិយោគនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៣០៣/០០៩ ចុះថ្ងៃទី២៤ ខែមិនា ឆ្នាំ ២០០៣។

ច្បាប់ភូមិបាលឆ្នាំ២០០១។

ច្បាប់ស្តីពីសារពើពន្ធឆ្នាំ២០០៣។

ច្បាប់ស្តីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ឆ្នាំ២០០៦។

អនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីវិសោធនកម្ម នៃច្បាប់វិនិយោគនៃព្រះរាជាណាចក្រកម្ពុជា, លេខ១១១ អនក្រ.បក ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០០៥។

អនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា, លេខ ៣៤ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០០៧ ។

អនុក្រឹត្យស្តីពីការបង្កើត និងការគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេស, លេខ ១៤៨ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ២០០៥។

អនុក្រឹត្យស្តីពីការបង្កើតអនុគណៈកម្មាធិការវិនិយោគខេត្ត-ក្រុង,លេខ ៣៣ អនក្រ.បក ។

លោក មេធាវី អ៊ីវ ប៉ូលី, នីតិក្រុមហ៊ុន,២០០៨។

http://www.lehmanlaw.com/resource-centre/laws-and-regulations/tax/law-on-income-tax-of-foreign-investment-enterprises-and-foreign-enterprises.html

http://www.eaglelink.com/law-review/w99/wang5.htm

http://www.investopedia.com/terms/j/jointventure.asp

http://www.skooolnigeria.com/ec_forms_of_business_co-op.aspx

http://english.mofcom.gov.cn/aarticle/lawsdata/chineselaw/200301/20030100062858.html

http://www.china.org.cn/business/laws_regulations/2007-06/22/content_1214773.htm

http://english.mofcom.gov.cn/article/policyrelease/Businessregulations/201303/20130300045747.shtml

http://www.iisd.org/pdf/2012/chinese_outward_investment.pdf

http://china.org.cn/living_in_china/abc/2009-07/15/content_18141137.htm

http://www.mac.doc.gov/China/Docs/DisputeAvoidanceandResolution.pdf

http://www2.deloitte.com/content/dam/Deloitte/global/Documents/Tax/dttl-tax-chinaguide-2014.pdf

http://www.jonesday.com/china_supreme_peoples_court_issues_rules/